# ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី នៅក្នុងប្រទេសកម្ពុជា

## តម្លៃនៃផលប៉ះពាល់ជាអវិជ្ជមានចំពោះមនុស្ស ឥទ្ធិពល និងដំណោះស្រាយ




ការសិក្សាអំពីករណីនៃការតាំងទីលំនៅថ្មី នៃ
តំបន់ក្រីក្រតាមទីប្រជុំជនមួយចំនួន

សហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំកម្ពុជា - ភ្នំពេញ



ច្រកផ្លូវនៅកន្លែងតាំងទីលំនៅថ្មី អភិវឌ្ឍន៍មានជ័យ

ថ្លែងអំណរគុណចំពោះការថតរូបដោយ: R McCormack/ OHCHR

# មាតិកា


អក្សរកាត់ និង ពាក្យបំព្រួញ ........ IV

បញ្ជីឈ្មោះប្រអប់ និង តារាង ........ V

សេចក្តីសង្ខេប ........ ១

ជំពូកទី១: សេចក្តីផ្តើម និងបរិបទ ........ ១៦

ជំពូកទី២: វិធីសាស្រ្ត ........ ២៤

ជំពូកទី៣: ក្របខ័ណ្ឌគតិយុត្តិ ........ ៣០

ជំពូកទី៤: ដំណើរការមុនការបណ្តេញចេញ និងសកម្មភាពក្នុងពេលបណ្តេញចេញ ........ ៣៦

៤.១. ហេតុផលសំអាងសំរាប់ការបណ្តេញចេញ ........ ៣៧

៤.២. សកម្មភាពក្នុងអំឡុងពេលនៃការបណ្តេញចេញ ........ ៣៧

៤.៣. ការទទួលបានការដោះស្រាយដោយប្រសិទ្ធិភាព និងការទទួលបានសំណង ........ ៤១

៤.៤. ការបំភិតបំភ័យ និងការចោទប្រកាន់សហាគមន៍ពីបទព្រហ្មទណ្ឌ ........ ៤៦

៤.៥. ការចូលរួម និងការរួបរួមគ្នារបស់សហាគមន៍ ........ ៤៨

ជំពូកទី៥: ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី ........ ៥១

៥.១. លំនៅដ្ឋានសមរម្យ ........ ៥២

៥.២. ទឹកស្អាត និងអនាម័យ ........ ៥៩

៥.៣. សុវត្ថិភាពខាងការកាន់កាប់ដីធ្លី ........ ៦៤

៥.៤. ជីវភាពរស់នៅ និង ឱកាសការងារ ........ ៧៣

៥.៥. សន្តិសុខស្បៀង ........ ៧៨

៥.៦. សុខភាព ........ ៨១

៥.៧. ការអប់រំ ........ ៨៨

៥.៨. បញ្ហាផ្នែកស៊ីវិល និងរដ្ឋបាល ........ ៩៣

៥.៩. ការចូលរួម និងសមាហរណកម្មទៅក្នុងសង្គមរបស់សហាគមន៍ ........ ៩៥

ជំពូកទី៦: សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ........ ១០៣

ឧបសម្ព័ន្ធ: ........ ១១៣

ឧបសម្ព័ន្ធទី១: សេចក្តីសង្ខេបនៃករណីទាំងឡាយដែលបានសិក្សាទៅតាមទីកន្លែងនៃការតាំងទីលំនៅថ្មី ........ ១១៤

ឧបសម្ព័ន្ធទី២: ឯកសារចេញផ្តល់ឲ្យអ្នកតាំងទីលំនៅថ្មីដើម្បីទទួលស្គាល់កម្មសិទ្ធិ ........ ១២២

ឧបសម្ព័ន្ធទី៣: ឯកសារយោង ........ ១២៦

**សេចក្តីថ្លែងអំណរគុណ:**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា

សូមថ្លែងអំណរគុណ ចំពោះមន្ត្រីរាជរដ្ឋាភិបាល បុគ្គលិកអង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងបុគ្គលមួយចំនួនទៀត ដែលបានផ្តល់ព័ត៌មាន គំនិតសំខាន់ៗ និងសំណូមពរដល់យើងខ្ញុំ។ ជាពិសេស សូមថ្លែងអំណរគុណចំពោះសហគមន៍ដែលទទួលរងផលប៉ះពាល់ និងសមាជិកសហគមន៍ ដែលបានយល់ព្រមផ្តល់បទសម្ភាសន៍សម្រាប់របាយការណ៍នេះ។

រូបគម្របសៀវភៅ:  ប្រជាពលរដ្ឋនៅបូរីកីឡារៀបចំទ្រព្យសម្បត្តិពួកគេមុនពេលបណ្តេញចេញ

ថ្លែងអំណរគុណចំពោះការថតរូបដោយ:  ភីតធើ ហារី

**រក្សាសិទ្ធិគ្រប់យ៉ាង @  ឆ្នាំ ២០១២**

ការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស
ប្រចាំប្រទេសកម្ពុជា
ផ្ទះលេខ ១០ ផ្លូវ៣០២
បឹងកេងកង១ ខណ្ឌចំការមន
ប្រអប់សំបុត្រ១០៨
ភ្នំពេញ កម្ពុជា

# ការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅក្នុងប្រទេសកម្ពុជា

## តម្លៃនៃផលប៉ះពាល់ជាអវិជ្ជមានចំពោះមនុស្ស ឥទ្ធិពល និងដំណោះស្រាយ

ការសិក្សាអំពីករណីនៃការតាំងទីលំនៅថ្មី នៃតំបន់ក្រីក្រតាមទីប្រជុំជនមួយចំនួន

ដោយ ការិយាល័យឧត្តមស្នងការ នៃអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស

ប្រចាំប្រទេសកម្ពុជា

# អក្សរកាត់និងពាក្យបំព្រួញ

| | |
|---|---|
| ARV | ថ្នាំពន្យាអាយុជីវិត (អ្នកជំងឺអេដស៍) |
| ACHR | សម្ព័ន្ធសិទ្ធិលំនៅដ្ឋានអាស៊ី |
| BABSEA | អង្គការស្ពានឆ្ពោះទៅកាន់សន្តិភាពអាស៊ីអាគ្នេយ៍ |
| CCAMH | មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារនិងមនុស្សពេញវ័យ |
| CESCR | គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| HIV | មេរោគអេដស៍ |
| AIDS | ជំងឺអេដស៍ |
| COMFREL | គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា |
| DPC | អង្គការអភិវឌ្ឍន៍ប្រជាជនកម្ពុជា |
| EDC | អគ្គិសនីកម្ពុជា |
| FAO | អង្គការស្បៀងអាហារនិងកសិកម្ម នៃអង្គការសហប្រជាជាតិ |
| Licadho | អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស |
| MCC | គណៈកម្មការសុរិយោដីរាជធានីភ្នំពេញ |
| MDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MOI | ក្រសួងមហាផ្ទៃ |
| MPP | សាលារាជធានីភ្នំពេញ |
| NCC | គណៈកម្មការសុរិយោដីថ្នាក់ជាតិ |
| NCHADS-MOH | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| OHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស |
| PLHIV | អ្នកផ្ទុកមេរោគអេដស៍ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SLC | សម្បទានដីសង្គមកិច្ច |
| STD | ជំងឺកាមរោគ |
| STT | សមាគមន៍ធាងត្នោត |
| SUPF | សហព័ន្ធសាមគ្គីភាព សហគមន៍អ្នកក្រីក្រក្នុងទីក្រុង |
| UN | អង្គការសហប្រជាជាតិ |
| UNAIDS | កម្មវិធីរួមគ្នារបស់អង្គការសហប្រជាជាតិប្រយុទ្ធនឹង មេរោគអេដស៍ និងជំងឺអេដស៍ |
| UNCHS | មជ្ឈមណ្ឌលសហប្រជាជាតិដើម្បីលំនៅដ្ឋាន |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UN Habitat | អង្គការសហប្រជាជាតិលំនៅដ្ឋានមនុស្សជាតិនិងទីក្រុង |
| UNHCR | ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន |
| UNICEF | មូលនិធិសម្រាប់កុមារអង្គការសហប្រជាជាតិ |
| UNTAC | អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា |
| UPDF | មូលនិធិអភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្រក្នុងទីក្រុង |
| WSA | រដ្ឋាករទឹកស្វ័យយ័ត |

# បញ្ជីឈ្មោះប្រអប់ និងតារាង


ប្រអប់លេខ១: កំណត់សំគាល់អំពីពាក្យបច្ចេកទេស និងការបកប្រែ ........ ៣២

ប្រអប់លេខ ២: ការបណ្តេញចេញនៅស្ពានឆេះ ខេត្តព្រះសីហនុ ........ ៤០

ប្រអប់លេខ ៣: ការបណ្តេញចេញនៅដីក្រហម ភ្នំពេញ ........ ៤២

ប្រអប់លេខ ៤: កិច្ចខិតខំប្រឹងប្រែងរបស់ក្រុម៧៨ ដើម្បីទទួលបានដំណោះស្រាយ........ ៤៤

ប្រអប់លេខ ៥: ការចោទប្រកាន់សមាជិកសហគមន៍ស្ពានឆេះពីបទព្រហ្មទណ្ឌ ........ ៤៧

ប្រអប់លេខ ៦: ផែនការអភិវឌ្ឍន៍នៅនឹងកន្លែងរបស់សហគមន៍ក្រុម៧៨........ ៤៩

ប្រអប់លេខ ៧: សហគមន៍អភិវឌ្ឍន៍មានជ័យ ........ ៥៣

ប្រអប់លេខ ៨: សមាធាតុនៃសិទ្ធិមានលំនៅដ្ឋានសមរម្យ........ ៥៤

ប្រអប់លេខ ៩: គំរោងសាងសង់លំនៅដ្ឋាននៅអណ្តូង........៥៦

ប្រអប់លេខ ១០: ការវាយតំលៃគុណភាពទឹកនៅអណ្តូង........ ៦០

ប្រអប់លេខ ១១: អណ្តូង: ទ្វេរគ្រោះនៃចំនួនប្រជាពលរដ្ឋ និង ដីឡូត៍ដែលមានការទទួលស្គាល់ និង មិនទាន់មានការទទួលស្គាល់........ ៦៥

ប្រអប់លេខ ១២: ជំរើសមុខរបរចិញ្ចឹមជីវិតនៅតំបន់ពាក់កណ្តាលជនបទ ពាក់កណ្តាលទីក្រុង ខេត្ត ព្រះសីហនុ ........ ៧៤

ប្រអប់លេខ ១៣: សុខភាពអ្នកជំងឺអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍........ ៨៤

ប្រអប់លេខ ១៤: កិច្ចឧបត្ថម្ភគាំទ្ររបស់អង្គការ ការីតាស់ ចំពោះសហគមន៍ទួលសំបូរ ឆ្ពោះទៅរកសមាហរណកម្មសហគមន៍ និងការពឹងផ្អែកលើខ្លួនឯង ........ ៩៨

ប្រអប់លេខ ១៥: ដំណើររឿងរបស់មករា រស់នៅបុរីសន្តិភាព២ ដំណាក់ត្រយឹង........ ១០០

តារាងលេខ១: ព័ត៌មានសង្ខេបអំពីសហគមន៍ដែលបានតាំងទីលំនៅថ្មី និងដែលបានជ្រើសរើស សំរាប់ការសិក្សានេះ ........ ២៦


6
7

E

# សេចក្តីសង្ខេប

**រូបថតទំព័រមុខ**

ស្ត្រីដែលបានផ្លាស់ទីលំនៅពីសហគមន៍ដីក្រហម ស្ថិតនៅក្នុងផ្ទះថ្មី របស់គាត់ នៅដំណាក់ត្រយឹង

ថ្លែងអំណរគុណចំពោះការថតរូបដោយ: R McCormack/ OHCHR






# សេចក្តីសង្ខេប

## សេចក្តីផ្តើម

ការបណ្តេញចេញ និង ការតាំងទីលំនៅថ្មី ជាទូទៅគឺជាទិដ្ឋភាពរួមមួយនៃការអភិវឌ្ឍន៍ទីប្រជុំជនបែបទំនើប ហើយជាអ្វីដែលកើតមានឡើងនៅប្រទេសកម្ពុជាផងដែរ។ ទោះបីជាមិនមានទិន្នន័យផ្លូវការក្តី ការប៉ាន់ស្មានបង្ហាញថា មានប្រជាពលរដ្ឋច្រើនជាង ១២០០០០នាក់ នៅរាជធានីភ្នំពេញ ត្រូវបានគេបណ្តេញចេញចាប់តាំងពីឆ្នាំ ១៩៩០ មក ហើយប្រជាពលរដ្ឋរាប់ម៉ឺននាក់ទៀត ប្រឈមមុខនឹងហានិភ័យនៃការបណ្តេញចេញដោយបំពាន នាពេលខាងមុខ។

ចក្ខុវិស័យចំពោះ គោលនយោបាយដីធ្លីរបស់ព្រះរាជាណាចក្រកម្ពុជា គឺក្នុងគោលបំណងសំរេច "ទិសដៅជាតិកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយសមធម៌ និង អភិបាលកិច្ចល្អ ក្នុងសង្គមប្រជាធិបតេយ្យ និងសេដ្ឋកិច្ចទីផ្សារសេរី"។[១] គោលនយោបាយគ្រប់គ្រងដីធ្លីនៃព្រះរាជាណាចក្រកម្ពុជា សំដៅ "កំណត់ និងចុះបញ្ជីកម្មសិទ្ធិ និង សិទ្ធិដទៃទៀត [...] ដើម្បីពង្រឹងសុវត្ថិភាពកាន់កាប់ដីធ្លី បង្កើនប្រសិទ្ធិភាព និងភាពអាចទុកចិត្តបាននៃទីផ្សារដីធ្លី និងការពារភាពសុខដុមនៃសង្គម ដោយការបង្ការ ឬ ការដោះស្រាយជំលោះដីធ្លី"។[២] រដ្ឋាភិបាល ជាពិសេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ បានបង្កើត ក្របខ័ណ្ឌច្បាប់ គោលនយោបាយនិងស្ថាប័នដ៏លំអិតមួយ ដើម្បីអនុវត្តច្បាប់ភូមិបាលឆ្នាំ២០០១។ ក្របខ័ណ្ឌនេះទទួលស្គាល់ និង ផ្តល់ភាពសំខាន់ដល់ការធានាការពារ សិទ្ធិកាន់កាប់ដីធ្លី ក៏ដូចជា សិទ្ធិភោគៈ និងសិទ្ធិកម្មសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជា រួមទាំងការពារពួកគាត់ពីការបណ្តេញចេញដោយបង្ខំ។ ក្រោមគោលនយោបាយទាំងនេះការបណ្តេញចេញដោយបង្ខំគឺខុសច្បាប់ ហើយការតាំងទីលំនៅថ្មី អាចប្រព្រឹត្តទៅបានលុះត្រាតែជាជម្រើសចុងក្រោយតែប៉ុណ្ណោះ[៣] ក្នុងករណីលើកលែងមួយចំនួនដែលការបណ្តេញចេញស្របច្បាប់អាចប្រព្រឹត្តទៅបាននោះ ត្រូវមានការពិគ្រោះយោបល់គ្រប់គ្រាន់ ជាមួយសហគមន៍ដែលរងផលប៉ះពាល់ និងមានការផ្តល់សំណងសមស្រប ។

នៅពេលដែលការការពារស្របតាមច្បាប់មិនត្រូវបានអនុវត្តទេនោះ ការបណ្តេញចេញកើតឡើងដោយផ្តល់អោយមាននូវផលវិបាកធ្ងន់ធ្ងរដល់ជីវភាពរស់នៅ និងសុខមាលភាពរបស់ប្រជាពលរដ្ឋ

សេចក្តីសង្ខេប

ដែលត្រូវបានបណ្តេញចេញនោះ។ ការអនុវត្តន៍បែបនេះ ផ្ទុយទៅនឹងគោលគំនិតជាមូលដ្ឋាននៃសិទ្ធិមនុស្ស ការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងយុត្តិធម៌សង្គម។ ការអនុវត្តន៍បែបនេះ ធ្វើឲ្យអន្តរាយដល់កិច្ចខិតខំប្រឹងប្រែងដើម្បីអភិបាលកិច្ចល្អ និងនីតិរដ្ឋ ហើយធ្វើឲ្យកាន់មានភាពក្រីក្រថែមទៀត ។

## គោលដៅ និង វិសាលភាពនៃការសិក្សា

ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា (OHCHR) បានធ្វើការសិក្សានេះឡើង ដើម្បីវាស់ស្ទង់ពីតំលៃប៉ះពាល់លើមនុស្ស និងសេដ្ឋកិច្ចសង្គម និងផលប៉ះពាល់នៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅកម្ពុជា និងបង្ហាញនូវដំណោះស្រាយមួយចំនួនផ្អែកតាមច្បាប់ក្នុងស្រុក និងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងការប្តេជ្ញាចិត្តក្រោមសន្និសញ្ញាសិទ្ធិមនុស្សរបស់កម្ពុជា។ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស គិតថា ការសិក្សានេះគឺជាឧបករណ៏ សម្រាប់ផ្សព្វផ្សាយអោយមានការយល់ដឹង និងពិគ្រោះយោបល់គ្នា ដើម្បីរួមចំណែកដល់ការពិភាក្សាអោយមានការផ្លាស់ប្តូរមួយដោយជៀសវាងបានការប្រឈមមុខដាក់គ្នា ហើយឈានទៅរកការពិភាក្សាបែបស្ថាបនាក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីស្វែងរកដំណោះស្រាយរយៈពេលវែងប្រកបដោយសមធម៌ និងនិរន្តរភាពមួយ ចំពោះបញ្ហាដ៏ស្មុគ្រស្មាញនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មី។ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស សង្ឃឹមថា ការសិក្សានេះនឹងរួមចំណែកដល់ កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍន៏ក្របខ័ណ្ឌគោលនយោបាយដែលផ្អែកលើសិទ្ធិមនុស្ស ដើម្បីត្រួសត្រាយការអនុវត្តទាក់ទងនឹងការតាំងទីលំនៅថ្មី។

ការសិក្សានេះ ផ្អែកលើក្របខ័ណ្ឌសិទ្ធិមនុស្សអន្តរជាតិ ជាពិសេសបទដ្ឋានទាំងឡាយទាក់ទងនឹងសិទ្ធិមានលំនៅដ្ឋានសមរម្យ និងការការពារមិនឲ្យមានការបណ្តេញចេញ និងការតាំងទីលំនៅថ្មីដោយខុសច្បាប់។ កាតព្វកិច្ចសិទ្ធិមនុស្សទាំងនេះ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាទទួលយកដោយស្ម័គ្រចិត្ត តាមរយៈការផ្តល់សច្ចាប័នលើឧបករណ៏សិទ្ធិមនុស្សអន្តរជាតិនានា ជាពិសេសកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ការសិក្សានេះ យោងបទប្បញ្ញត្តពាក់ព័ន្ធនានាក្នុងច្បាប់ជាតិផងដែរ ។

ការសិក្សានេះ ផ្តោតលើដំណើរការនៃការបណ្តេញចេញនិងការតាំងទីលំនៅថ្មី និងទីតាំងមួយចំនួននៅទីប្រជុំជន ដែលដំណើរការនេះកើតឡើងជាចម្បងដោយសារការអភិវឌ្ឍន៍ទីក្រុង។ ការសិក្សានេះ មិនពិភាក្សាអំពីការបណ្តេញចេញនៅតំបន់ជនបទ ឬការតាំងទីលំនៅថ្មីដែលពាក់ព័ន្ធនឹងគំរោងសាធារណៈការធំៗឡើយ។ ដោយសារសកម្មភាពនៃការបណ្តេញចេញនៅកម្ពុជា ត្រូវបានគេសរសេរចងក្រងជាឯកសារនិងរបាយការណ៏យ៉ាងច្រើន គឺមានច្រើនជាងការសរសេរចងក្រងអំពីស្ថានភាពនៅកន្លែងតាំងទីលំនៅថ្មី ដូច្នេះការសិក្សានេះផ្តោតជាសំខាន់លើ ស្ថានភាពនៃគ្រួសារដែលបានតាំងទីលំនៅថ្មី ប៉ុន្តែក៏បានបញ្ចូលការវាយតំលៃលើដំណើរការនៃការបណ្តេញចេញផងដែរ។

[១] ឯកសារបណ្តោះអាសន្ន ស្តីពីយុទ្ធសាស្ត្រក្របខ័ណ្ឌគោលនយោបាយដីធ្លី ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ឆ្នាំ២០០២ ទំព័រ ១១

[២] មើលឯកសារវិភាគ។

[៣] គោលការណ៍នេះ ត្រូវបានបញ្ជាក់ជាថ្មីដោយ ឯកឧត្តម អ៊ឹម ឈុន លឹម ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ នៅពេលដែល ឯកឧត្តម បានទទួលជួបពិភាក្សាជាមួយលោកស្រី ឃ្យុង ហ្វា កាំង ឧត្តមស្នងការរង អង្គការសហប្រជាជាតិទទួល បន្ទុកសិទ្ធិមនុស្ស នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១០ ។

# សេចក្តីសង្ខេប

## វិធីសាស្ត្រ

ការសិក្សានេះ ផ្អែកលើប្រភពព័ត៌មានផ្សេងៗ ជាពិសេស ផ្អែកលើសក្ខីកម្ម និងព័ត៌មានផ្ទាល់ដែលបុគ្គលិកការិយាល័យ OHCHR ប្រមូលបានពីបុគ្គល និងពីសហគមន៍នានានៅកន្លែងតាំងទីលំនៅថ្មី ដែលបានជ្រើសសម្រាំងសំរាប់ការសិក្សានេះ នៅក្នុងចុងឆ្នាំ២០០៩ ដល់ដើមឆ្នាំ២០១០ និងដោយមានការធ្វើទស្សនកិច្ចទៅកាន់ទីតាំងទាំងអស់នោះកាលពីចុងឆ្នាំ២០១១ និងដើមឆ្នាំ២០១២ ដើម្បីតាមដានមើលការវិវឌ្ឍន៍រីកចម្រើននានា។ការសិក្សានេះក៏ផ្អែកផងដែរលើការសម្ភាសន៍ជាមួយ មន្ត្រីរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកផ្តល់សេវាផ្សេងៗ និងទិន្នន័យដែលការិយាល័យ OHCHR ប្រមូលបានតាមរយៈការធ្វើការងារលើករណីនៃការបណ្តេញចេញ (ជាពិសេសលើករណីនៃសហគមន៍ "ក្រុម៧៨" ក្នុងខណ្ឌចំការមន) និងការពិនិត្យឡើងវិញលើឯកសារផ្លូវការ និងមិនផ្លូវការនានា ។

ការសិក្សានេះ ផ្តោតលើទីតាំងចំនួនប្រាំពីរ ដែលប្រជាពលរដ្ឋបានតាំងទីលំនៅថ្មី ដែលទីតាំងទាំងអស់នេះ ត្រូវបានជ្រើសរើសយកមកធ្វើការសិក្សា ក្នុងគោលដៅផ្តល់រូបភាពមានតុល្យភាពមួយចំពោះលំនាំនៃការតាំងទីលំនៅថ្មីនាពេលបច្ចុប្បន្ននេះ ហើយជាទីតាំងដែលមានលក្ខណៈជាតំណាងបំផុតនៃលំនាំនៃការតាំងទីលំនៅថ្មី។ ការសម្ភាសន៍ និងការវាយតំលៃបានធ្វើឡើងនៅទីតាំងទាំងនេះ៖ នៅភ្នំពេញមាន **អភិវឌ្ឍន៍មានជ័យ** (ឬផ្លូវវែងស្រែង) ក្នុងខណ្ឌមានជ័យ (អតីតអ្នកភូមិរស់នៅលើផ្លូវជិតស្ពានទូតចិន) **អណ្តូង** ខណ្ឌដង្កោរ (អតីតអ្នកភូមិសំបុកចាប) **ដំណាក់ត្រយឹង** ក្នុងខណ្ឌដង្កោរ (អតីតអ្នកភូមិដីក្រហម) **ទួលសំបូរ** ក្នុងខណ្ឌដង្កោរ (អតីតអ្នកភូមិបូរីកីឡា) **ត្រពាំងអញ្ចាញ** ខណ្ឌដង្កោរ (អតីតអ្នកភូមិសំបុកចាប) និងនៅខេត្តព្រះសីហនុមាន **អូរកម្ពុជា** ក្នុងខណ្ឌព្រៃនប់ (អតីតអ្នករស់នៅតំបន់ក្បាលហុង) និង **ស្ពានឆេះ** ក្នុងខណ្ឌមិត្តភាព (អតីតអ្នកភូមិស្ពានឆេះ) ។ ការសិក្សានេះបានបូកបន្ថែម តំបន់ទីប្រាំបី បន្ទាប់ពីប្រជាពលរដ្ឋរស់នៅតាមផ្លូវក្នុងភូមិដំណាក់ត្រយឹង ត្រូវបានគេឲ្យរុះរើទៅរស់នៅភូមិ **ស្រះពោធិ** ក្នុងខេត្តកណ្តាល នៅចុងឆ្នាំ ២០០៩ ។

## ដំណើរការមុនការបណ្តេញចេញ និង សកម្មភាពអំឡុងពេលនៃការបណ្តេញចេញ

ហេតុផលដែលអាជ្ញាធរ តែងតែបានលើកសំអាងជារឿយៗ សំរាប់ការបណ្តេញចេញ គឺសហគមន៍ បានរស់នៅលើដីសាធារណៈរបស់រដ្ឋ ឬនៅលើដីដែលជាកម្មសិទ្ធិរបស់ឯកជន។ ក្នុងករណីជាច្រើន ដីដែលសហគមន៍កំពុងរស់នៅ មានស្ថានភាពផ្លូវច្បាប់មិនទាន់ច្បាស់លាស់នៅឡើយ ប៉ុន្តែអាជ្ញាធរពាក់ព័ន្ធ បានបណ្តេញសហគមន៍ទាំងនោះចេញ នៅមុនពេលមានការសំរេចអំពីស្ថានភាពផ្លូវច្បាប់របស់សហគមន៍លើដីនោះ និងការកំណត់ស្ថាពរលើការអះអាងអំពីសិទ្ធិលើដីរបស់ពួកគេ ។

ដើម្បីកាត់បន្ថយជាអប្បរមានូវផលប៉ះពាល់អវិជ្ជមានលើជីវិតរបស់ប្រជាពលរដ្ឋ (រាប់ទាំងអំពីហឹង្សាផង) ប្រការសំខាន់នោះគឺ ការការពារផ្អែកនីតិវិធីដែលស្របតាមបទដ្ឋានសិទ្ធិមនុស្ស ត្រូវតែគោរព

សេចក្តីសង្ខេប

រាប់ទាំងការផ្តល់ឱកាសពិគ្រោះយោបល់ពិតប្រាកដ ការជៀសវាងការប្រើប្រាស់កំលាំងមិនសមាមាត្រ ការជូនដំណឹងមានរយៈពេលគ្រប់គ្រាន់ និងសមហេតុផល និងធានាឲ្យមានច្រកទៅរកដំណោះស្រាយតាមច្បាប់។ ករណីមួយចំនួនដែលបានពិនិត្យក្នុងការសិក្សានេះ បង្ហាញអោយឃើញពីការអនុវត្តន៍ដែលមិនគោរពចំពោះការការពារទាំងអស់នេះ ។

ទន្ទឹមគ្នានឹងគ្រួសារប្រជាពលរដ្ឋ ដែលត្រូវបានតាំងទីលំនៅថ្មីនៅ ទួលសំបូរ និងអភិវឌ្ឍន៍មានជ័យ បានប្រព្រឹត្តទៅដោយសន្តិវិធី (ដែលករណីអភិវឌ្ឍន៍មានជ័យ ការតាំងទីលំនៅថ្មីត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្តលើគ្រប់ទិដ្ឋភាព) ការបណ្តេញចេញផ្សេងទៀត ដែលបានពិនិត្យនៅក្នុងការសិក្សានេះ មានទៅដោយកំរិតផ្សេងៗនៃ ការបង្ខិតបង្ខំ ការរំលោភបំពាន និងការបំភិតបំភ័យ ។ ចំពោះករណីសហគមន៍ដីក្រហម ស្ពានឆេះ និងសំបុកចាប គឺអាជ្ញាធរមិនបានជូនដំណឹងគ្រប់គ្រាន់ទៅដល់ ប្រជាពលរដ្ឋ នៅមុនការបណ្តេញចេញទេ អាជ្ញាធរ បានបណ្តេញប្រជាពលរដ្ឋចេញនៅពេលយប់ ឬនៅព្រឹកព្រលឹម មានការបំផ្លិចបំផ្លាញផ្ទះសំបែង និងទ្រព្យសម្បត្តិឯកជន ហើយក្នុងករណីសហគមន៍ដីក្រហម និងស្ពានឆេះ អាជ្ញាធរបានប្រើប្រាស់កំលាំងដែលមិនចាំបាច់ និងមិនសមាមាត្រទៅលើប្រជាពលរដ្ឋ។

ក្នុងករណីភាគច្រើន ដែលបានពិនិត្យ អាជ្ញាធរមិនបានផ្តល់ឲ្យសហគមន៍នូវជំរើសផ្សេងពីការបណ្តេញចេញ ឬឱកាសសំរាប់ការពិគ្រោះយោបល់ពិតប្រាកដឡើយ។ សំណើររបស់សហគមន៍សុំឲ្យមានជំរើសផ្សេងៗ មិនត្រូវបានគេគិតគូរអើពើឡើយ។ ផ្ទុយទៅវិញ នៅពេលដែលសហគមន៍ទាំងបានរៀបចំ និងបានស្នើសុំចូលរួមចរចាប្រកបដោយអត្ថន័យនោះ ពួកគាត់ត្រូវបានគេគាបសង្កត់គំរាមកំហែង និងបំភិតបំភ័យ ។

## ច្រកទៅរកការទទួលបានដំណោះស្រាយ និងសំណង

ក្នុងករណីដែលបានពិនិត្យឡើងវិញ ឃើញថា ទាំងគណៈកម្មការសុរិយោដី ទាំងតុលាការ មិនផ្តល់មធ្យោបាយដោះស្រាយការទាមទារលើដី ឬការពារបុគ្គលពីការបណ្តេញចេញឡើយ មានឧទាហរណ៍ដូចជា ករណីសហគមន៍ដីក្រហម និងក្រុម៧៨ ដែលត្រូវបានបណ្តេញចេញនៅមុនពេលមានការសំរេចស្តាពរអំពីស្ថានភាពគតិយុត្តនៃដីធ្លី ឬលើការទាមទារសិទ្ធិលើដីរបស់សហគមន៍។ ម្យ៉ាងវិញទៀត ក្នុងករណីនៃសហគមន៍ដីក្រហម និងស្ពានឆេះ មិនត្រឹមតែការទាមទាររបស់សហគមន៍ប៉ុណ្ណោះទេ ដែលត្រូវគេមិនគិតគូ ប៉ុន្តែតំណាងសហគមន៍ ក៏ត្រូវបានគេចោទប្រកាន់ពីបទព្រហ្មទណ្ឌ ហើយអ្នកទាំងនោះភាគច្រើនត្រូវបានតុលាការជំនុំជម្រះ និងកាត់ទោសឲ្យជាប់ពន្ធនាគារទៀតផង ។

នៅពេលដែលមានការស្នើផ្តល់ជាសំណងឲ្យដល់សហគមន៍ដែលត្រូវបណ្តេញចេញ សំណងដែលស្នើឡើងនោះមានត្រឹមតែជាសំណងជាលុយដែលមានកំរិតទាបជាងតំលៃទីផ្សារ ឬតំលៃជំនួស ឬមានត្រឹមតែជាដីឡូត៍ដែលមិនសូវមានតំលៃ។ ក្នុងចំណោមករណីសិក្សាទាំងអស់ គ្មានករណីណាមួយ

(លើកលែងតែសហាគមន៍អភិវឌ្ឍន៍មានជ័យ) ដែលគ្រួសារប្រជាពលរដ្ឋ បានទទួលសំណងដែលគិតរាប់បញ្ចូលទាំងការបាត់បង់ផ្ទះសម្បែង ការខូចខាត ឬការបាត់បង់ទ្រព្យសម្បត្តិ ឬការបាត់បង់ប្រាក់ចំណូលផ្សេងៗទៀតដូចជា ការបាត់បង់មុខរបរចិញ្ចឹមជីវិតនោះឡើយ ។ អ្នកភូមិនៅស្ពានឆេះ និងអាជីវករ និងអ្នកជួលផ្ទះនៅដីក្រហមមិនបានទទួលសំណងទាល់តែសោះ ។

## ការចាប់ផ្តើមកសាងជីវិតឡើងវិញ នៅកន្លែងតាំងទីលំនៅថ្មី

ការសិក្សានេះពិនិត្យស៊ីជម្រៅលើលក្ខខ័ណ្ឌរស់នៅរបស់គ្រួសារដែលបានតាំងទីលំនៅថ្មី រាប់ទាំង ផ្ទះសម្បែងសមរម្យ ទឹក និងអនាម័យ សុវត្ថិភាពខាងការកាន់កាប់ដី ការចិញ្ចឹមជីវិត និងការងារ/មុខរបរ សន្តិសុខស្បៀងអាហារ សុខភាព ការអប់រំ បញ្ហាពលរដ្ឋ និងរដ្ឋបាល និងការរាប់បញ្ចូលពួកគេទៅក្នុងសង្គមផងដែរ។ **ទស្សនកិច្ចតាមដានមើលការវិវឌ្ឍន៍រីកចម្រើន នៅកន្លែងតាំងទីលំនៅថ្មីទាំងនេះ ដែលបានធ្វើឡើងនៅចុងឆ្នាំ២០១១ និងដើមឆ្នាំ ២០១២ រកឃើញថា អ្វីដែលបានរកឃើញនៅក្នុងការសិក្សានេះ ជាទូទៅស្ថិតនៅក្នុងស្ថានភាពដដែល ដោយមានករណីរីកចម្រើនតិចតួច។**

សក្ខីកម្មបង្ហាញថា គ្រួសារដែលតាំងទីលំនៅថ្មី បានជួបប្រទះការលំបាកស្រដៀងៗគ្នា ទាំងនៅពេលភ្លាមៗបន្ទាប់ពីការបណ្តេញចេញ និងប៉ុន្មានឆ្នាំបន្តបន្ទាប់មកទៀត។ លើកលែងតែគ្រួសារនៅសហាគមន៍អភិឌ្ឍន៍មានជ័យ និងគ្រួសារដែលផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ដែលបានតាំងទីលំនៅថ្មីនៅទួលសំបូរ ស្ថានភាពរស់នៅរបស់គ្រួសារដែលបានតាំងទីលំនៅថ្មី ត្រូវបានរកឃើញថាមានសភាពអាក្រក់ជាងស្ថានភាពនៅមុនពេលនៃការបណ្តេញចេញ ជាពិសេសលើការចិញ្ចឹមជីវិត សន្តិសុខស្បៀង និងលំនៅដ្ឋាន។ ក្នុងករណីភាគច្រើន ការជួយឧបត្ថម្ភគាំទ្រពីអាជ្ញាធរ មានកំរិតតិចតួចស្តួចស្តើងណាស់ ហើយគ្រួសាររងផលប៉ះពាល់ទាំងឡាយបន្តពឹងអាស្រ័យលើជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាលនានា រាប់ទាំងអង្គការខាងសាសនា ។

ជាទូទៅ កន្លែងតាំងទីលំនៅថ្មីនៅខ្វះលំនៅដ្ឋានសមរម្យ ៖ តាមពិតទៅ ទីតាំងភាគច្រើន ពីដំបូងគឺមិនរាប់បញ្ចូលលំនៅដ្ឋាន ឬជម្រកទេ នៅពេលធ្វើការតាំងទីលំនៅថ្មី ។ សហាគមន៍ស្ពានឆេះ អូរកម្ពុជា អណ្តូង ត្រពាំងអញ្ចាញ និងអាជីវករ និងអ្នកជួលផ្ទះនៅដំណាក់ត្រយឹងត្រូវបានគេឲ្យរស់នៅលើដីរហោដ្ឋាន ខណៈដែរ សំណង់ផ្ទះសម្បែងនៅដំណាក់ត្រយឹង និងនៅទួលសំបូរ មិនគ្រប់គ្រាន់សមស្របតាមបទដ្ឋានអន្តរជាតិទេ។ ក្នុងករណីនៃសហាគមន៍ស្ពានឆេះ និងអាជីវករ និងអ្នកជួលផ្ទះនៅដំណាក់ត្រយឹង គេមិនបានផ្តល់ឲ្យដីនៅកន្លែងផ្សេងទេ នៅពេលបណ្តេញចេញ ដូច្នេះហើយបានធ្វើឲ្យពួកគាត់គ្មានដីធ្លីសំរាប់រស់នៅ ។ ចាប់តាំងពីពេលនោះមក ពួកគាត់បានរស់នៅដោយមានការភ័យខ្លាចជានិច្ច អំពីការបណ្តេញចេញជាថ្មី ។ ស្ថានភាពរបស់អាជីវករ និងអ្នកជួលផ្ទះនៅដំណាក់ត្រយឹង មានការរីកចំរើនតិចតួចនៅក្នុងខែធ្នូ ឆ្នាំ២០០៩ នៅពេលដែលពួក

សេចក្តីសង្ខេប

គាត់ត្រូវគេឲ្យទៅ តាំងទីលំនៅថ្មីនៅភូមិស្រះពោធិ ខេត្តកណ្តាល។

កន្លែងតាំងទីលំនៅថ្មីទាំងនោះ ខ្វះហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ជាពិសេស ទឹកស្អាតសំរាប់ប្រើប្រាស់ និង អនាម័យ ក៏ដូចជា រាល់សេវាដែលសំខាន់ចាំបាច់។ ស្ថានភាពរិតតែអាក្រក់ថែមទៀតនៅរដូវភ្លៀង ដោយសារ នៅទីតាំងទាំងនោះ បង្គន់ ប្រព័ន្ធលូទឹកសំអុយ ឬផ្ទះសម្បែង ត្រូវទឹកលិច ដូចជា នៅអណ្តូង ត្រពាំងអញ្ចាញ និងគ្រួសារដែលរស់នៅតាមចិញ្ចើមថ្នល់ក្នុងភូមិដំណាក់ត្រយឹង និងនៅស្ពានឆេះ ។ នៅអំឡុងទស្សនកិច្ចតាមដានការវិវឌ្ឍន៍រីកចំរើនទៅកាន់ទីកន្លែងតាំងទីលំនៅថ្មីនានា គ្រួសារប្រជាពលរដ្ឋក្នុងសហគមន៍មួយចំនួនដែលបានចុះបញ្ជី នៅភូមិស្រះពោធិ អណ្តូង និងត្រពាំងអញ្ចាញ បានរាយការណ៍អំពីការទៅប្រើប្រាស់បានកាន់តែច្រើនឡើងនូវសេវាមួយចំនួន ប៉ុន្តែដោយសារតែភាពខ្វះខាតនូវឱកាសរកប្រាក់ចំណូល ធ្វើអោយគ្រួសារប្រជាពលរដ្ឋភាគច្រើននៅតែមិនមានលទ្ធភាពទៅប្រើសេវាដែលមានទាំងនោះបាន។

សុវត្ថិភាពខាងការកាន់កាប់ដីធ្លី នៅកន្លែងតាំងទីលំនៅថ្មីភាគច្រើន បន្តមានបញ្ហានេះ សូម្បីតែនៅរយៈពេលជាច្រើនឆ្នាំបន្ទាប់ពីការតាំងទីលំនៅថ្មីមកហើយក្តី សហគមន៍ដែលតាំងទីលំនៅថ្មីទាំងនោះ បានបន្ត លើកឡើង អំពីបញ្ហានេះដដែលៗ ថាជាកង្វល់ដ៏ធំមួយរបស់ពួកគាត់។ នេះគឺជាបញ្ហា ជាពិសេសនៅពេលដែលមានចំណាប់អារម្មណ៍ណាមួយលើការអភិវឌ្ឍន៍ជាបន្តលើដីពាក់ព័ន្ធនោះ ដូចជាករណីអូរកម្ពុជាជាដើម។ ដោយសារខ្វះភាពប្រាកដប្រជា អំពីសុវត្ថិភាពខាងការកាន់កាប់ដីធ្លីដែលពួកគាត់កំពុងរស់នៅ នាពេលបច្ចុប្បន្ននេះ សហគមន៍តាំងទីលំនៅថ្មី មានការរារែកចិត្តក្នុងការរៀបចំខ្លួននៅលើទីតាំងថ្មីនេះ ឧទាហរណ៍ដូចជាការដាក់ទុនក្នុងមុខរបរផ្សេងៗ ឬ ក្នុងការរៀបចំផ្ទះសម្បែងឲ្យបានល្អ ជាដើម ។ បញ្ហានេះ រិតតែធ្ងន់ធ្ងរខ្លាំងថែមទៀត ចំពោះករណីនៃសហគមន៍ដែលមិនបានទទួលដីជាផ្លូវការបន្ទាប់ពីការបណ្តេញចេញ ដូចជា សហគមន៍ស្ពានឆេះ ក៏ដូចជាគ្រួសារប្រជាពលរដ្ឋដែលកំពុងតែរង់ចាំការទទួលស្គាល់ជាផ្លូវការនៅអណ្តូង ។

វិធានការដែលបានចាត់ឡើង ដើម្បីធានាសុវត្ថិភាពកាន់កាប់ដីធ្លី សំរាប់គ្រួសារដែលបានតាំងទីលំនៅថ្មី មានភាពខុសប្លែកគ្នាច្រើនពីទីតាំងមួយទៅទីតាំងមួយ។ មិនមានប្រព័ន្ធណាមួយដែលមានស្រាប់ ដើម្បីធានាសុវត្ថិភាពកាន់កាប់ដីធ្លីដល់គ្រួសារប្រជាពលរដ្ឋ បន្ទាប់ពីការឲ្យតាំងទីលំនៅថ្មីឡើយ ។ ទោះជាដូច្នេះក្តី នៅកន្លែងតាំងទីលំនៅថ្មីភាគច្រើន អាជ្ញាធរបានសន្យាថានឹងចេញប័ណ្ណកម្មសិទ្ធិដីធ្លីដល់គ្រួសារដែលបានកាន់កាប់ និងប្រើប្រាស់ដីធ្លីនោះ ផុតរយៈពេល ០៥ ឆ្នាំ (ឬរយៈពេល ១០ឆ្នាំ ក្នុងករណីខ្លះ) ដែលការកំណត់បែបនេះ មិនមានមូលដ្ឋានគតិយុត្តច្បាស់លាស់ទេ។ យ៉ាងហោចណាស់ក៏មានឯកសារផ្សេងៗគ្នាចំនួន ១២ ប្រភេទដែរ ដែលចេញអោយគ្រួសារប្រជាពលរដ្ឋទាំងនោះ ដើម្បីទទួលស្គាល់ពួកគេលើការទទួលបានដីឡូតិ៍ ឬជាការសន្យាចេញប័ណ្ណកម្មសិទ្ធិ ដីធ្លីអោយក្នុងពេលអនាគត ឬធានាចំពោះសុវត្ថិភាពកាន់កាប់ ដែលវា

# សេចក្តីសង្ខេប

បានបង្កឲ្យមានការភ័ន្តច្រឡំជាច្រើន ។ មិនមានការបញ្ជាក់ណាមួយពីអាជ្ញាធរ ថាតើការចេញប័ណ្ណកម្មសិទ្ធិដីធ្លីនេះប្រព្រឹត្តទៅដូចម្តេច ក្នុងក្របខ័ណ្ឌពេលវេលាដែលបានសន្យាឡើយ ។

គ្រួសារដែលបានតាំងទីលំនៅថ្មី មានការលំបាកក្នុងការរកប្រភពសំរាប់ចិញ្ចឹមជីវិត ជំរើសការងារ និងមុខរបរ។ ហើយនៅចុងឆ្នាំ២០១១ និងដើមឆ្នាំ២០១២ បញ្ហានេះនៅតែជាកង្វល់ដ៏ធំ ដែលត្រូវបានរាយការណ៍មកកាន់ OHCHR។ កន្លែងតាំងទីលំនៅថ្មី ជាធម្មតាស្ថិតនៅឆ្ងាយក្រុងដែលជាទូទៅវាផ្តល់ឱកាសតិចតួចសំរាប់ការងារ និងមុខរបរ។ មានការលំបាកផងដែរសំរាប់គ្រួសារក្នុងការបន្ត ឬស្វែងរកការងារធ្វើនៅកណ្តាលទីក្រុង ដោយសារតែការចំណាយសំរាប់ការធ្វើដំណើរនិងឧបសគ្គផ្សេងៗទៀត។ ករណីនេះបានបណ្តាលឲ្យមេគ្រួសារ ឬគ្រួសារទាំងមូលត្រូវវិលត្រឡប់មកកាន់ កណ្តាលទីក្រុងវិញ ដើម្បីស្វែងរកការងារធ្វើ ហើយជួនកាលពួកគាត់បានលក់ដីឡូត៍របស់ខ្លួននៅកន្លែងទីតាំងថ្មីក្នុងដំណើរការនេះ។ ផលវិបាកខាងសេដ្ឋកិច្ច និងសង្គម ដែលកើតចេញពីដំណើរការនេះទៅលើគ្រួសារប្រជាពលរដ្ឋមានទំហំធំធេង ដែលវាជាការបណ្តាលអោយមានការបែកបាក់គ្រួសារផងដែរ ។

**អសន្តិសុខស្បៀង** គឺជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធទៅនឹងការលំបាករបស់គ្រួសារក្នុងការចិញ្ចឹមជីវិត និងឱកាសមានការងារគត់មុត។ គ្រួសារដែលបានតាំងទីលំនៅថ្មីទទួលស្បៀងអាហារបានដោយភាពមិនទៀងទាត់ ហើយពួកគេបានកាត់បន្ថយរបបអាហាររបស់ពួកគេយ៉ាងច្រើន។ សហគមន៍ទួលសំបូរ គឺជាសហគមន៍តែមួយគត់ដែលបានទទួលរបបអាហារឧបត្ថម្ភប្រចាំខែ បន្ទាប់ពីការតាំងទីលំនៅថ្មី ចំណែកឯនៅទីតាំងផ្សេងទៀតគ្រួសារខ្លះទទួលជំនួយឧបត្ថម្ភពីអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែមិនមានលក្ខណៈទូលំទូលាយនោះទេ ហើយការចែកចាយម្ហូបអាហារដែលមានលក្ខណៈបណ្តោះអាសន្ន និងតាមការស្ម័គ្រចិត្តបែបនេះ គឺមិនមាននិរន្តរភាពទេ។

**សុខភាព** គឺជាបញ្ហាមួយផងដែរ ។ទោះបីជាមានមណ្ឌលសុខភាព នៅជិតទីតាំងថ្មីនោះក្តី ក៏គ្រួសារភាគច្រើន ពឹងអាស្រ័យលើអង្គការមិនមែនរដ្ឋាភិបាល ដោយសារអង្គការទាំងនេះ បានផ្តល់សេវាដោយមិនយកកំរៃ អាចជឿទុកចិត្តបាន និងមានលក្ខណៈទូលំទូលាយជាង។ ការសម្ភាសន៍ជាមួយគ្រួសារដែលតាំងទីលំនៅថ្មី បានបង្ហាញឲ្យឃើញអំពីបញ្ហាចិត្តសាស្រ្តសង្គម ដែលបញ្ហានេះតម្រូវនូវការសិក្សាស្រាវជ្រាវបន្ថែមអំពី ផលប៉ះពាល់ភ្លាមៗ និងផលប៉ះពាល់រយៈពេលយូរអង្វែងលើសុខភាពផ្លូវចិត្ត ទាក់ទងនឹងការបណ្តេញចេញ និងការតាំងទីនៅថ្មី ។

ស្ថានភាព**អ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍** គឺជាកង្វល់ដោយឡែកមួយទៀត។ អាជ្ញាធរ និងអ្នកផ្តល់សេវាសុខភាព មិនបានទៅធ្វើការពិនិត្យតាមដានសុខភាពជាប្រព័ន្ធដល់គ្រួសារអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ដែលចេញពីទីតាំងដើមមករស់នៅកន្លែងតាំងទីលំនៅថ្មីទេ ដែលជាការទុកគ្រួសារទាំងនេះចោលដោយគ្មានការជួយឧបត្ថម្ភ

គាំពារឡើយ។ មិនមានការវាយតំលៃអំពីភាពងាយរងគ្រោះនៃគ្រួសារទាំងនេះ នៅមុនការតាំងទីលំនៅថ្មីទាក់ទងនឹងកិច្ចគាំពារសុខភាព ផ្ទះសម្បែង និងភាពមិនរើសអើង។ ក្នុងករណីអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ នៅទួលសំបូរ ការវាយតំលៃត្រូវគេធ្វើឡើងនៅក្រោយការតាំងទីលំនៅថ្មី ដែលបានឈានដល់ការចាត់វិធានការកែតម្រូវជាដុំកំភួន រាប់ទាំងការបន្តការពិនិត្យព្យាបាលជាទៀងទាត់ កិច្ចគាំពារ និងការជួយឧបត្ថម្ភគាំទ្រ ។

ការតាំងទីលំនៅថ្មីនេះ ក៏មានផលប៉ះពាល់អវិជ្ជមានផងដែរទៅលើការសិក្សាអប់រំរបស់កុមារ ។ ក្រោយពីការតាំងទីលំនៅថ្មី កុមារជាច្រើនបានបោះបង់ចោលការសិក្សា ឬគ្រួសារខ្លះត្រូវរស់នៅបែកគ្នា ដោយទុកកូនឲ្យរស់នៅឯទីក្រុងដើម្បីសិក្សាបញ្ចប់ឆ្នាំ ។ គ្រួសារខ្លះ ត្រូវចំណាយលុយកាក់ក្រៅផ្លូវការផងដែរ ដើម្បីផ្ទេរកូនពីសាលារៀនមួយ ទៅសាលារៀនមួយទៀត ហើយការបង់ប្រាក់ក្រៅផ្លូវការប្រចាំថ្ងៃតាមការស្នើរបស់គ្រូបង្រៀន បានដាក់បន្ទុកមួយធ្ងន់ធ្ងរថែមទៀត ទៅលើប្រាក់ចំណូលដ៏មានកំរិតរបស់គ្រួសារ ។

គ្រួសារជាច្រើនបានជួបប្រទះផងដែរ នូវការលំបាកផ្នែកស៊ីវិល និង រដ្ឋបាលនៅទីតាំងថ្មី រាប់ទាំង ការលំបាកក្នុងការទទួលបានសៀវភៅស្នាក់នៅ និងអត្តសញ្ញាណប័ណ្ណ ការកែព័ត៌មានក្នុងសៀវភៅគ្រួសារ និងការផ្ទេរឈ្មោះរបស់ខ្លួនលើបញ្ជីឈ្មោះអ្នកបោះឆ្នោត។ អាជ្ញាធរមិនបានផ្តល់ការជួយឧបត្ថម្ភទេ ជារឿយៗពួកគាត់ត្រូវចំណាយលុយកាក់ច្រើន និងពេលវេលាយ៉ាងយូរដ៏គួរឲ្យធុញទ្រាន់ក្នុងដំណើរការនេះ។ លើសពីនេះទៀត ពួកគាត់ត្រូវទៅរកជួបអាជ្ញាធរទាំងនៅទីតាំងដើម និងនៅទីតាំងថ្មី ដើម្បីផ្ទេរ ឬរៀបចំសំណុំឯកសារថ្មី ហើយដែលជារឿយៗ អាជ្ញាធរនៅឯទីតាំងទាំងនេះតែងតែតម្រូវឲ្យបង់ប្រាក់ក្រៅផ្លូវការ ។ ចំពោះហេតុផលនេះ និងហេតុផលផ្សេងទៀត បុគ្គលខ្លះឈប់អើរពើនឹងការទៅរកអជ្ញាធរ ដើម្បីធ្វើសំណុំឯកសារ ហើយការខ្វះសំណុំឯកសារទាំងនេះ ក្លាយទៅជាឧបសគ្គសំរាប់ធានាការងារផ្លូវការ និងការចុះបញ្ជីអ្នកបោះឆ្នោត។

នៅទីបញ្ចប់ ការសិក្សាបង្ហាញពីភាពទន់ខ្សោយជាទូទៅនៃ ការចូលរួម និងការរួបរួមគ្នារបស់សហគមន៍ នៅតាមទីតាំងថ្មី ។ អាជ្ញាធរបានធ្វើការងារតិចតួចដើម្បីពិគ្រោះយោបល់ និងជំរុញទឹកចិត្តដល់គ្រួសារដែលតាំងទីលំនៅថ្មី ឲ្យចូលរួមក្នុងគំរោង និងការសំរេចចិត្តនានា ដើម្បីធ្វើឲ្យស្ថានភាពនៅទីតាំងថ្មីនោះបានប្រសើរឡើង ។ ម្យ៉ាងវិញទៀត ការធ្វើសមាហរណកម្មទៅក្នុងសង្គម ជាមួយសហគមន៍ជិតខាងផ្សេងៗទៀត កម្រនឹងត្រូវបានគេគិតគូរពិចារណានៅក្នុងគំរោងផែនការតាំងទីលំនៅថ្មីណាស់។ សហគមន៍ទួលសំបូរ គឺជាករណីដែលត្រូវបានពិភាក្សាក្នុងការសិក្សានេះថា ជាគំរូមួយនៃការបញ្ចូលក្នុងសង្គមនិងការអភិវឌ្ឍន៍សហគមន៍ ដោយសារតែសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលការីតាស់ ដែលអនុវត្តគំរោងមួយចំនួន ដែលមានប្រយោជន៍មិនត្រឹមតែសំរាប់គ្រួសារដែលផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានប្រយោជន៍សំរាប់ប្រជាពលរដ្ឋទូទៅ នៅភូមិទួលសំបូរទាំងមូលផងដែរ ។

# សេចក្ដីសង្ខេប

## គំរូ ល្អ ៗ

ការតាំងទីលំនៅថ្មី ក្នុងឆ្នាំ ១៩៩៧ - ១៩៩៩ នៃសហាគមន៍អភិវឌ្ឍន៍មានជ័យ ផ្ដល់មកនូវគំរូល្អនៃដំណើរការតាំងទីលំនៅថ្មី ដែលប្រកបដោយការចូលរួម ការគោរពជម្រើសរបស់សហាគមន៍ និងមានការទុកពេលវេលាគ្រប់គ្រាន់សំរាប់ធ្វើផែនការ និងការរៀបចំ។ សាលារាជធានីភ្នំពេញបានចូលរួមដោយពិតប្រាកដជាមួយសហាគមន៍ និងអង្គការជាដៃគូ ដើម្បីធ្វើផែនការរៀបចំការតាំងទីលំនៅថ្មីរបស់សហាគមន៍នៅលើទីតាំងមួយ ដែលនៅជិតទីតាំងដើមរបស់ខ្លួន ស្របតាមបំណងប្រាថ្នារបស់សហាគមន៍ ។ ហេត្ថារចនាសម្ព័ន្ធ និងផ្ទះសម្បែងសមរម្យត្រូវបានគេសាងសង់រួចជាមុន មុនការផ្លាស់ទីលំនៅថ្មីនៃគ្រួសារទាំងនេះ។ ដប់ឆ្នាំក្រោយពីការតាំងទីលំនៅថ្មីនេះ ជីវភាពរបស់សហាគមន៍នេះ មានលំនឹង មានការរីកចំរើន និងមាននិរន្តរភាព ។

ឧទាហរណ៍មួយទៀត គឺករណីនៃ គ្រួសារដែលផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ដែលបានផ្លាស់ប្ដូរទីតាំងក្នុងឆ្នាំ២០០៩ទៅទួលសំបូរ ។ ករណីនេះបង្ហាញអំពីរបៀបដែល ផលប៉ះពាល់អវិជ្ជមាននៃការតាំងទីលំនៅថ្មី អាចត្រូវដោះស្រាយបានសូម្បីតែនៅបន្ទាប់ពីការតាំងទីលំនៅថ្មីរួចហើយក្ដី។ ពីដំបូងដោយសារតែមិនមានការយកចិត្តទុកដាក់ចំពោះសេចក្ដីត្រូវការរបស់គ្រួសារទាំងនោះទាក់ទងនឹងស្ថានភាពផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍របស់ពួកគេបានធ្វើឲ្យសុខភាព និងជីវភាពរបស់ពួកគាត់ធ្លាក់ដុនដាប និងត្រូវគេធ្វើអោយអសោចកេរ្ដិ៍ឈ្មោះ (Stigmatization) នៅទីតាំងថ្មី ។ មិនមានការរៀបចំផែនការច្បាស់លាស់ ដើម្បីធានាកំរិតជីវភាពរស់នៅជាអប្បបរមាទាក់ទងនឹងផ្ទះសម្បែង ទឹក ស្បៀងអាហារ អនាម័យ ឬសុខភាព ។ កិច្ចសហការនៅពេលបន្តបន្ទាប់មកក្នុងចំណោមអាជ្ញាធរជាតិ និងអាជ្ញាធរក្រុង អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារសហប្រជាជាតិ បាននាំមកនូវភាពរីកចំរើនជាចម្បងនៅក្នុងតំបន់នេះ ។

## សេចក្ដីសន្និដ្ឋាន

ដំណើរការនៃការបណ្ដេញចេញ និងការតាំងទីលំនៅថ្មី ជាញឹកញាប់អាចនាំមកនូវភាពក្រីក្រដុនដាប និងការលំបាកជាខ្លាំង សំរាប់សហាគមន៍ដែលរងផលប៉ះពាល់។ បទពិសោធន៍នៅកម្ពុជា មិនមានអ្វីខុសប្លែកគ្នានោះទេ ។ កាលបើមានការត្រៀមរៀបចំតិចតួចសំរាប់ការបណ្ដេញចេញ និងការតាំងទីលំនៅថ្មី កាលបើសហាគមន៍មិនមានឱកាសចូលរួមក្នុងការធ្វើសេចក្ដីសំរេចចិត្ត កាលបើមិនអនុវត្តការការពារតាមផ្លូវច្បាប់ទេ ហើយការបណ្ដេញចេញត្រូវបានធ្វើឡើងដោយបង្ខំ និងដោយអំពើហឹង្សា កាលបើសេវាហេដ្ឋារចនាសម្ព័ន្ធ និងជំរើសសំរាប់ការចិញ្ចឹមជីវិតនៅកន្លែងតាំងទីលំនៅថ្មីមិនមានគ្រប់គ្រាន់ ជាធម្មតាគ្រួសារទាំងនោះប្រឈមនឹងភាពក្រីក្រយ៉ាងធ្ងន់ធ្ងរបំផុត ។

ច្រើនឆ្នាំបន្ទាប់ពីការតាំងទីលំនៅថ្មី គ្រួសារប្រជាពលរដ្ឋភាគច្រើននៅកន្លែងតាំងទីលំនៅថ្មីនៅតែបន្តខិតខំយ៉ាងលំបាកក្នុងការចិញ្ចឹមជីវិត។ ផ្ទុយ

ទៅវិញ បើសិនជាអាជ្ញាធរ សហាគមន៍ អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ធ្វើការរួមគ្នាដើម្បីរៀបចំផែនការតាំងទីលំនៅថ្មី ដោយមានការចូលរួមពីសហាគមន៍ និងដោយមានការគិតគូរយ៉ាងពេញលេញអំពីសេចក្ដីត្រូវការរបស់ពួកគាត់ នោះវាមិនត្រឹមតែកាត់បន្ថយបាននូវផលប៉ះពាល់អវិជ្ជមាននៃការតាំងទីលំនៅថ្មីនោះប៉ុណ្ណោះទេ ប៉ុន្តែដំណើរការនេះ អាចជួយធ្វើឲ្យស្ថានភាពរស់នៅរបស់គ្រួសារប្រជាពលរដ្ឋបានល្អប្រសើរ និងមាននិរន្តរភាពដូចដែលបានបង្ហាញក្នុងករណីសហគមន៍អភិវឌ្ឍន៍មានជ័យ ។

ពេលខ្លះការបណ្ដេញចេញ និងការតាំងទីលំនៅថ្មី ត្រូវបានគេសំអាងលើហេតុផល តំរូវការខាងការអភិវឌ្ឍន៍ទីក្រុង ឬការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក៏ប៉ុន្តែហេតុផលនេះមិនពិតប្រាកដូចជាការអះអាងក្នុងករណីទាំងអស់នោះទេ។ ប៉ុន្តែ មានមតិផ្ទុយថា ការអនុវត្តន៍បែបនេះ វាអាចមិនត្រឹមតែរំលោភច្បាប់ជាតិ ការប្ដេជ្ញាចិត្តក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងអាចធ្វើឲ្យខូចដល់ការរីកចំរើនផ្នែកសេដ្ឋកិច្ចរយៈពេលវែង និងទិសដៅកាត់បន្ថយភាពក្រក្រីរបស់កម្ពុជាផងដែរ។ សិទ្ធិមនុស្ស មានសារៈសំខាន់ទាំងអត្ថន័យ និងខ្លឹមសារ ហើយមិនចាំបាច់ត្រូវធ្វើការពន្យល់ដោះសារបន្ថែមទៀតទេ ។ ទន្ទឹមនេះក៏មានការកើនឡើងនៃភស្តុតាងបទពិសោធន៍ដែលបង្ហាញអំពីសារៈសំខាន់នៃសុវត្ថិភាពខាងការកាន់កាប់ដីធ្លី និងសិទ្ធិមនុស្ស ដែលទាក់ទងនឹង ទឹកអនាម័យ សុខភាព និងកត្តាដទៃទៀត សំរាប់ការអភិវឌ្ឍន៍ និងការរីកចំរើនផ្នែកសេដ្ឋកិច្ច ។

នៅចំពោះមុខស្ថានការបែបនេះ វាគឺជាការសំខាន់ដែលគេត្រូវចំណាយធនធានចាំបាច់ ដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមាន នៃការតាំងទីលំនៅថ្មី ហើយដាក់បញ្ចូលដំណើរការនៃការតាំងទីលំនៅថ្មី ជាចំនុចសំខាន់ទៅក្នុងរបៀបវារៈនៃការអភិវឌ្ឍន៍និងការកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា។

ទន្ទឹមនឹង នគរូបនីយកម្មមានសន្ទុះខ្លាំង សេចក្ដីត្រូវការឲ្យមានគំរូសំរាប់ការតាំងទីលំនៅថ្មី ប្រកបដោយសមធម៌ និងមានប្រសិទ្ធភាព គឺជាបញ្ហាបន្ទាន់ថែមទៀត។ គេសង្ឃឹមថារាជរដ្ឋាភិបាលកម្ពុជា រួមជាមួយដៃគូនានានឹងកសាងពីលើអ្វីដែលជាការអនុវត្តន៍ល្អៗក្នុងស្រុក និងជាអន្តរជាតិ ដើម្បីធ្វើអោយគំរូសំរាប់ការតាំងទីលំនៅថ្មីកាន់តែបានល្អប្រសើរឡើងថែមទៀត ដែលវាមិនមែនត្រឹមតែគិតលើការគណនាសំណងបែបចង្អៀត និងសំរាប់តែរយៈពេលខ្លី និងការកាត់បន្ថយលើចំណាយប៉ុណ្ណោះទេ ប៉ុន្តែជាគំរូប្រកបដោយចក្ខុវិស័យទូលំទូលាយគិតដល់ការស្តារឡើងវិញ និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដែលនេះ គឺជាគោលការណ៍ "ឈ្នះ ឈ្នះ" សំរាប់អាជ្ញាធរ និង សហាគមន៍យ៉ាងពិតប្រាកដ ។

## អនុសាសន៍

របាយការណ៍នេះ ដាក់ស្នើជាអនុសាសន៍មួយចំនួន សំរាប់ដំណោះស្រាយ។ អនុសាសន៍នេះដាក់ស្នើជាបឋមទៅរាជរដ្ឋាភិបាល ជាពិសេស ទៅ

# សេចក្ដីសង្ខេប

ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល (ជាពិសេស អាជ្ញាធរប្រយុទ្ធនឹងមេរោគអេដស៍/ជម្ងឺអេដស៍) ក៏ដូចជា អាជ្ញាធររាជធានី និង អាជ្ញាធរមូលដ្ឋាន ។ ការិយាល័យ OHCHR សង្ឃឹមថា អនុសាសន៍ទាំងនេះ អាចជួយជំរុញ និង លើកទឹកចិត្តឲ្យមានការពិភាក្សាតាមការចាំបាច់ ដើម្បីបង្កើតគោលនយោបាយមួយ ស្ដីពីការតាំងទីលំនៅថ្មី ដែលជាចក្ខុវិស័យក្នុងឯកសារបណ្ដោះអាសន្នឆ្នាំ២០០២ ស្ដីពីយុទ្ធសាស្ត្រក្របខ័ណ្ឌគោលនយោបាយដីធ្លី។ សង្ឃឹមថាអនុសាសន៍ទាំងនេះភាគច្រើន នឹងជាប្រយោជន៍ ដល់អ្នកពាក់ព័ន្ធផ្ដល់ជំនួយ តួអង្គ អភិវឌ្ឍន៍ និង អ្នកពាក់ព័ន្ធដទៃទៀត ដែលនឹងពាក់ព័ន្ធ ក្នុងកិច្ចគាំទ្រដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងអនុសាសន៍លំអិតមួយចំនួន មានរាយនៅក្នុងជំពូកទី៦ នៃការសិក្សានេះក្ដី ចំណុចអនុសាសន៍សំខាន់ៗមួយចំនួនត្រូវបានរៀបរាប់សង្ខេបដូចខាងក្រោមនេះ៖

## ១. ដំណើរការមួយចំនួន មុនការបណ្ដេញចេញ និង កំឡុងពេលនៃការតាំងទីលំនៅថ្មី ៖

- ការបណ្ដេញចេញ គួរអនុវត្តជាមធ្យោបាយចុងក្រោយបំផុតតែប៉ុណ្ណោះ ។ គួរស្វែងរកជំរើសគ្រប់យ៉ាងផ្សេងទៀតជាមុនសិន ។
- អនុម័តផែនការដែលមានលក្ខណៈទូលំទូលាយច្បាស់លាស់ និងមានតម្លាភាព សំរាប់ការតាំងទីលំនៅថ្មីជាមុន មុននឹងធ្វើការបណ្ដេញចេញ។
- ធានាការចូលរួមនៃសហគមន៍ដែលរងផលប៉ះពាល់នៅក្នុងដំណើរការធ្វើផែនការ នៅមុននិងក្រោយការតាំងទីលំនៅថ្មី ។
- ទទួលស្គាល់សិទ្ធិទទួលព័ត៌មានរបស់ប្រជាពលរដ្ឋ និងបង្កើតយន្តការផ្សព្វផ្សាយព័ត៌មានឲ្យបានគ្រប់គ្រាន់ដល់គ្រួសារដែលរងផលប៉ះពាល់ ។
- គិតគូអំពីសេចក្ដីត្រូវការចំពោះមុខ និងភាពងាយរងគ្រោះរបស់បុគ្គល ឬក្រុមមនុស្សមួយចំនួនដូចជាជនពិការ ឬអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ជាដើម ។

## ២. សកម្មភាពនៅក្នុងអំឡុងពេលនៃការបណ្ដេញចេញ និងការទទួលបានដំណោះស្រាយ ៖

- ការអនុវត្តន៍ការបណ្ដេញចេញ ត្រូវគោរពទាំងស្រុង ចំពោះសេចក្ដីតម្រូវខាងនីតិវិធីត្រឹមត្រូវដូចមាន ចែងក្នុងបទដ្ឋានសិទ្ធិមនុស្ស ស្របតាមគោលការណ៍ទូទៅស្ដីពីភាពចាំបាច់ និងសមាមាត្រ ។
- ធានាការគោរពយ៉ាងម៉ឺងម៉ាត់តាម នីតិវិធីច្បាប់ពាក់ព័ន្ធនិងនិតិវិធីព្រហ្មទណ្ឌ ក្នុងករណីនៃការចោទប្រកាន់សមាជិកសហគមន៍ ។
- ការផ្ដល់សំណង គឺមិនត្រឹមតែសំរាប់ការបាត់បង់ដីធ្លី និងអាគារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសំរាប់ការបាត់បង់មុខរបរចិញ្ចឹមជីវិត និងការបាត់បង់ដែលមិនមែនជាសេដ្ឋកិច្ចទាំងឡាយ ។

## ៣. លក្ខខ័ណ្ឌ និងបទដ្ឋាននៅកន្លែងតាំងទីលំនៅថ្មី ៖

- ធានាថា សហគមន៍ដែលតាំងទីលំនៅថ្មី ទទួលបានយ៉ាងហោចណាស់នូវកំរិតជីវភាពរស់នៅស្រដៀងគ្នា បន្ទាប់ពីការបណ្តេញចេញ ។

- ធានាថា ដីឡូត៍ និងផ្ទះសម្បែងដែលបានផ្តល់ឲ្យមានទំហំ និងគុណភាពសមស្រប ។ ធានាបទដ្ឋានអប្បបរមានៃភាពគ្រប់គ្រាន់ និងទំហំសមល្មមសំរាប់គ្រួសារទាំងអស់ ដោយមិនគិតពីប្រភេទផ្ទះសម្បែងដែលពួកគាត់មានពីមុនមកនោះឡើយ ។ ប៉ុន្តែត្រូវធានានូវលក្ខខ័ណ្ឌ ដែលមានពីមុនបើក្នុងករណីដែលផ្ទះសម្បែងរបស់ពួកគាត់មានលក្ខណៈប្រសើរលើសពីបទដ្ឋានអប្បបរមា នៅមុនការតាំងទីលំនៅថ្មី ។

- វាយតំលៃអំពីឱកាសមានមុខរបរចិញ្ចឹមជីវិតនៅកន្លែងតាំងទីលំនៅថ្មី និងដោះស្រាយបញ្ហាទាក់ទងនឹង ការបាត់បង់ប្រាក់ចំណូល ។

- ធានាថា សេវា និង ហេដ្ឋារចនាសម្ព័ន្ធអប្បបរមាផ្សេងៗ ត្រូវបានបង្កើតឲ្យមាននៅមុនការតាំងទីលំនៅថ្មី រាប់ទាំងការទទួលបានទឹកស្អាត អនាម័យគ្រប់គ្រាន់ និងប្រព័ន្ធលូទឹកសំអ៊ុយ ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងផ្ទះសម្បែង និង ការទទួលកិច្ចគាំពារសុខភាព និង ការអប់រំ ។

- ពង្រឹងកិច្ចសម្របសម្រួលរវាង និងក្នុងស្ថាប័នរដ្ឋ និង ក្រសួង/មន្ទីរនានា ដើម្បីធានាការទទួលបានសេវាផ្សេងៗ។

## ៤. សុវត្ថិភាពខាងការកាន់កាប់ដី និងការចុះបញ្ជីដី ៖

- នៅមុនការបណ្តេញចេញ គួរធ្វើការវាស់វែងដី និង ចុះបញ្ជីដីដែលសហគមន៍រងផលប៉ះពាល់រស់នៅ ហើយពិនិត្យបណ្តឹងទាមទារតាមផ្លូវច្បាប់លើដីរបស់គ្រួសារប្រជាពលរដ្ឋអោយស្របតាមច្បាប់ ។

- ការពារភោគីនិងម្ចាស់ដីមិនឲ្យមានការបណ្តេញចេញដោយខុសច្បាប់និងផ្តល់ឲ្យពួកគាត់នូវសំណងត្រឹមត្រូវនិងយុត្តិធម៌ ក្នុងករណីមានការដកហូតដីនោះមកប្រើប្រាស់ជាប្រយោជន៍សាធារណៈតាមការកំណត់ក្នុងច្បាប់អស្សាមិករណ៍ ។

- សំរួលនីតិវិធី និង ឯកសារដែលធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ជូនដល់គ្រួសារដែលគ្មានសិទ្ធិលើអចលនៈទ្រព្យភ្លាមៗ បន្ទាប់ពីការតាំងទីលំនៅថ្មី និងរហូតដល់ប្រជាពលរដ្ឋទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី ។ គំរូពីអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ចនិងពីគំរោងបែងចែកដីសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច (LASED) អាចត្រូវបានយកមកប្រើប្រាស់ ។

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ជាមួយនឹងអាជ្ញាធរឯទៀតដែលពាក់ព័ន្ធគួរបង្កើត នីតិវីធី ដើម្បីចុះបញ្ជីជាប្រព័ន្ធ និង ធ្វើប្លង់ដី សំរាប់គ្រួសារដែលតាំងទីលំនៅថ្មី ក្នុងក្របខ័ណ្ឌពេលវេលាមួយសមស្រប និងប្រាកដប្រជាគិតចាប់ពីថ្ងៃតាំងទីលំនៅលើទីកន្លែងតាំងទីលំនៅថ្មី ។

## ៥. ក្របខ័ណ្ឌច្បាប់ និង គោលយោបាយ ៖

- អភិវឌ្ឍបន្ថែមនូវគោលការណ៍ណែនាំទូលំទូលាយ

មួយ ដើម្បីណែនាំអំពីដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មី ដូចជា គោលនយោបាយ ឬបទបញ្ញាស្តីពីការតាំងទីលំនៅថ្មី ដែលមានបញ្ចូលបទដ្ឋានអន្តរជាតិ និង វិធីអនុវត្តន៍ល្អៗ ។

- ធ្វើការស្រាវជ្រាវជាបន្ថែមអំពីផលប៉ះពាល់នៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មីទៅលើសុខភាពផ្លូវចិត្ត ឧប្បត្តិហេតុ និងការកើតមានអំពើហឹង្សាក្នុងគ្រួសារ និងស្ថានភាពសេដ្ឋកិច្ចសង្គមនៃគ្រួសារទាំងឡាយ ដែលសំរេចចិត្តជ្រើសយកសំណងជាលុយកាក់ជំនួសឲ្យការទៅតាំងទីលំនៅថ្មី ។

- ធានា ឬ ធ្វើឲ្យប្រសើរឡើងនូវ ផ្ទះសម្បែង ការទទួលបានទឹកស្អាត និងអនាម័យនៅ ភូមិអណ្តូងត្រពាំងអញ្ចាញ (រាជធានីភ្នំពេញ) ភូមិស្រះពោធិ (ខេត្តកណ្តាល) និង អូរកម្ពុជា (ខេត្តព្រះសីហនុ) និងនៅទីតាំងផ្សេងៗទៀតដែលមានសេចក្តីត្រូវការខ្លាំងបំផុត ។

- ធ្វើជំរឿនប្រជាជននៅភូមិអណ្តូង ដើម្បីឲ្យដឹងចំនួនអ្នករស់នៅទីនោះពិតប្រាកដ មុននឹងបន្តអនុវត្តគំរោងលំនៅដ្ឋាន ។

- អាជ្ញាធរ ខេត្តព្រះសីហនុ គួរផ្តល់ដីធ្លីគ្រប់គ្រាន់ និងផ្ទះសម្បែងដល់គ្រួសារប្រជាពលរដ្ឋនៅសហគមន៍ស្ពានឆេះ ។

- វាយតំលៃអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់គ្រួសារប្រជាពលរដ្ឋនៅកន្លែងតាំងទីលំនៅថ្មីទាំងអស់ ដើម្បីកំណត់អំពីកំរិតត្រូវការខាងស្បៀងអាហារ និងខាងការជួយឧបត្ថម្ភការចិញ្ចឹមជីវិតនៃគ្រួសារទាំងនោះ ។

- អាជ្ញាធរពាក់ព័ន្ធ និងដៃគូសហការ គួរធ្វើការវាយតំលៃអំពីសេចក្តីត្រូវការ និង ភាពងាយរងគ្រោះនៃគ្រួសារ ដែលផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ នៅតាមកន្លែងតាំងទីលំនៅថ្មីនានា នៅរាជធានីភ្នំពេញ ដើម្បីធានាឲ្យមានការពិនិត្យព្យាបាល កិច្ចគាំពារសុខភាព និង វិធានការកាត់បន្ថយផលប៉ះពាល់ឲ្យបានសមស្រប។

### ៨. ការសាកល្បងបង្កើតជាគំរូមួយនៃការតាំងទីលំនៅថ្មីនៅកម្ពុជា ៖

- គំរោងសាកល្បងមួយអាចត្រូវបានបង្កើតឡើង និងអនុវត្តរួមគ្នាដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ដោយប្រើប្រាស់អនុសាសន៍នៃការសិក្សា




គ្រួសារមួយប្រមូលទឹកនៅត្រពាំងអញ្ចាញក្នុងតំបន់តាំងទីលំនៅថ្មី
ថ្លែងអំណរគុណចំពោះការថតរូបដោយ: B. Keat/ OHCHR

១

# សេចក្តីផ្តើម និង បរិបទ

ជំពូកនេះសង្ខេបអំពីទម្រង់នៃការបណ្តេញចេញ នៅក្នុងប្រទេសកម្ពុជា រយៈពេលប៉ុន្មានទសវត្សរ៍កន្លងទៅថ្មីៗរហូតមកដល់សព្វថ្ងៃនេះ និងបង្ហាញអំពីកត្តាផ្សេងៗដែលប្រហែលជាកត្តារួមចំណែកបណ្តាលឱ្យមាននិន្នាការបច្ចុប្បន្ននៃការបណ្តេញចេញទាំងនោះ។ ជំពូកនេះ មានផ្តល់ស្ថិតិមួយចំនួនផងដែរអំពីវិសាលភាពនៃការបណ្តេញចេញនៅក្នុងរាជធានីភ្នំពេញ និងជាទូទៅនៅប្រទេសកម្ពុជា។ បន្ទាប់មកទៀត ជំពូកនេះនឹងពិភាក្សាអំពីហេតុផល និង គោលបំណងនៃការសិក្សានេះ។ ចុងបញ្ចប់នឹងមានពន្យល់អំពីទម្រង់នៃរបាយការណ៍។






# ជំពូកទី១
# សេចក្តីផ្តើម និង បរិបទ

ការបណ្តេញចេញ និង ការតាំងទីលំនៅថ្មី គឺជាទិដ្ឋភាពទូទៅមួយនៃការអភិវឌ្ឍន៍ទីប្រជុំជនបែបទំនើប ហើយជាពិសេស ចំពោះសង្គមទាំងឡាយដែលការអភិវឌ្ឍន៍សេដ្ឋកិច្ចធ្វើឡើងដោយសេរី និង ជាធម្មតាហើយ "ទំនើបភាវូបនីយកម្ម" នៅកម្ពុជាក៏ដូច្នោះដែរ។ បើទោះជាមិនមានទិន្នន័យផ្លូវការក្តី ការប៉ាន់ ស្មានបង្ហាញថាមានប្រជាពលរដ្ឋច្រើនជាង ១២០០០០ នាក់ នៅរាជធានីភ្នំពេញ ត្រូវបានគេបណ្តេញចេញ ចាប់ពីឆ្នាំ១៩៩០ មកហើយប្រជាពលរដ្ឋរាប់មឺននាក់ទៀត ត្រូវប្រឈមនឹងហានិភ័យនៃការបណ្តេញចេញដោយបំពានចេញពីលំនៅដ្ឋាន របស់ខ្លួននៅទសវត្សរ៍ខាងមុខ។

ការបណ្តេញចេញ និង ការតាំងទីលំនៅថ្មីនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានកើត មានក្នុងទសវត្សរ៍កន្លងមកនេះ ទាំងនៅទីប្រជុំជន ទាំងនៅតាមតំបន់ជនបទក្នុងបរិបទនៃទំនាស់ដីធ្លី។ សង្គ្រាមស៊ីវិល (១៩៧០ - ១៩៧៥) របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩) និងសង្គ្រាមអូសបន្លាយបន្ទាប់ពីរបបនេះ បានផ្តួលរលំដោយកងទ័ពវៀតណាម (១៩៧៩ - ១៩៩១) បានធ្វើឲ្យប្រជាពលរដ្ឋធ្វើចំណាកស្រុកនៅទូទាំងប្រទេស និង ឆ្លងដែន និង បណ្តាលអោយមានការខូចខាតទាំងស្រុងនៃប្រព័ន្ធចុះបញ្ជីដីធ្លី និងកម្មសិទ្ធិ។ ក្នុងទសវត្សរ៍ ឆ្នាំ១៩៨០ ប្រជាពលរដ្ឋបានតាំង ឬ តាំងទីលំនៅថ្មីនៅទូទាំងប្រទេស។ ទោះជាក្នុងឆ្នាំ១៩៧៩ ដីធ្លីមានលក្ខណៈជាសមូហ ភាពក្តីក៏សិទ្ធិកាន់កាប់ និងកម្មសិទ្ធិឯកជនត្រូវបានទទួលស្គាល់ក្នុងឆ្នាំ១៩៨៩ និងត្រូវបានធានាការពារក្នុងច្បាប់ ភូមិបាល ឆ្នាំ១៩៩២ ហើយក្រោយមកទៀត ក្នុងច្បាប់ភូមិបាល ឆ្នាំ២០០១។ ក្នុងសម័យអន្តរកាល (១៩៩១ - ១៩៩៣) ដែលការគ្រប់គ្រង រដ្ឋបាល ស្ថិតក្រោមកិច្ចឧបត្ថម្ភពីអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ នៅកម្ពុជា (អ៊ុនតាក់)ប្រជាពលរដ្ឋប្រមាណជិតកន្លះលាននាក់ ដែល ជាប់ក្នុងជំរំជនភៀសខ្លួន នៅតាមបណ្តាយព្រំដែនកម្ពុជាថៃអស់ពេលមួយទសវត្សរ៍មកនោះ ត្រូវបានអនុញ្ញាតឲ្យធ្វើមាតុភូមិនិវត្តន៍ ។

ហេតុការណ៍ដ៏ភ័យរន្ធត់ទាំងនេះ បានជិត

ជាមជ៏ជ្រៅក្នុងសតិអារម្មណ៍របស់ប្រជាពលរដ្ឋ ជាពិសេស នៅពេលដែលមានការបណ្តេញចេញដោយបំពាន ពួកគេតែងនឹកឃើញពីហេតុការណ៍ទាំងនេះ។ លំនៅដ្ឋាន គួរតែជាទីកន្លែងដែលមនុស្សគ្រប់រូបមានអារម្មណ៍ថាជាកន្លែងមួយមានសុវត្ថិភាព។ ការបាត់បង់លំនៅដ្ឋាន ពេលឃើញផ្ទះសម្បែងរបស់ខ្លួនត្រូវម៉ាស៊ីនឈូសបំផ្លាញ និង ការក្លាយជនអានាថា ឬ ត្រូវបានគេឲ្យទៅ តាំងទីលំនៅថ្មីនៅ កន្លែងមួយដែលហេត្ថរចនាសម្ព័ន្ធ និង ឱកាសមានតិចតួច សំរាប់កសាងជីវិត និងជីវភាពរស់នៅសារជាថ្មី ដែលអាចជាការមិនផ្តល់អំណាចយ៉ាងវិសមញ្ញ។

ចាប់ពីចុងទសវត្សរ៍ ឆ្នាំ១៩៩០ មក ខណៈពេលដែលនយោបាយមានស្ថិរភាព អាជ្ញាធរក្រុង និង អាជ្ញាធរមូលដ្ឋាន (យ៉ាងហោចណាស់ក៏នៅរាជធានីភ្នំពេញដែរ) ត្រូវបានអង្គការមិនមែនរដ្ឋាភិបាល និង ទីភ្នាក់ងារ អភិវឌ្ឍន៍នានាជំរុញលើកទឹកចិត្តឲ្យស្វែងរកការដោះស្រាយការបណ្តេញចេញ តាមបែបមនុស្សធម៌។ ឧទាហរណ៍ ជោគជ័យមួយនៅពេលកន្លងមក គឺករណីសហគមន៍មួយឈ្មោះ អភិវឌ្ឍន៍មានជ័យ ត្រូវបានពិភាក្សាលំអិតនៅ ក្នុងការសិក្សានេះ។[៤] ទន្ទឹមនេះ ក៏មានគំនិតផ្តួចផ្តើមមួយចំនួនឲ្យពង្រឹង ស្ថានភាពប្រជាពលរដ្ឋ ក្រីក្រនៅទីប្រជុំជន ហើយនៅក្នុងឆ្នាំ២០០៣ លោកនាយករដ្ឋមន្ត្រីបានប្រកាសថា កន្លែងតាំងទីលំនៅមិនរៀបរយចំនួន ១០០ កន្លែង នឹងត្រូវធ្វើការអភិវឌ្ឍន៍នៅនឹងកន្លែង។[៥] សេចក្តីប្រកាសនេះ ត្រូវបានសារទរថាជាជំហានដ៏សំខាន់មួយ ឆ្ពោះទៅគ្រប់គ្រងប្រជាពលរដ្ឋក្រីក្រនៅទីប្រជុំជន ។

ការអនុវត្តន៍ចាប់ពីពេលនោះមក មានការប្រែប្រួលច្រើន ប៉ុន្តែ ការបណ្តេញចេញដោយបំពាននៅតែកើតមានជារឿយៗ។ ការបណ្តេញចេញទ្រង់ទ្រាយធំ (ជាញឹកញយពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ទីប្រជុំជន ឬ វិស័យពាណិជ្ជកម្ម) ជារៀងរាល់ពេលតែងស្ថិតក្នុងរូបភាពជាការមិនគោរពច្បាប់សំរាប់ការពារ ហើយសកម្មភាពអាចជាការយាយី ការបំភិតបំភ័យ អំពើហឹង្សា ហើយជួនកាលមាន ការចាប់ខ្លួន ឬ ការគំរាមចាត់វិធានការផ្លូវច្បាប់ និង ការមិនគោរពកិច្ចធានាការពារផ្លូវច្បាប់ដែលមានស្រាប់ ទន្ទឹមនេះ ការបណ្តេញចេញ ឬ ការឲ្យទៅតាំងទីលំនៅថ្មីក្នុងទ្រង់ទ្រាយតូច (ជារឿយៗចំពោះសហគមន៍ ដែលតាំងទីលំនៅនៅលើដីសាធារណៈរបស់រដ្ឋ) ផ្ទុយទៅវិញជាទូទៅច្រើនមានការស្ម័គ្រចិត្ត និងដោយសន្តិវិធី ច្រើនជាង។[៦]

ការបណ្តេញចេញក្នុងរយៈកាល ១០ ឆ្នាំចុងក្រោយនេះ គួរតែបានធ្វើការវាយតំលៃផ្អែកលើនៃការរីក ចំរើនផ្នែកសេដ្ឋកិច្ច និងការពង្រីកទីក្រុងដ៏ឆាប់រហ័សនៅរាជធានីភ្នំពេញ និងផ្អែកលើវិសាលភាពជាក់លាក់ជាងនេះ នៅតំបន់ទីប្រជុំជនតូចៗ និង តំបន់ទេសចរណ៍មួយចំនួន មានជាអាទិ៍ ក្រុងព្រះសីហនុ និងខេត្តសៀមរាប ជាដើម។ ដីធ្លី និង អចលទ្រព្យ បានក្លាយជាវិស័យសំខាន់សំរាប់ការវិនិយោគទុន ដែលទុនវិនិយោគបានកើនឡើងយ៉ាង

---

[៤] សូមមើលប្រអប់លេខ ៧

[៥] យូ ភី ឌី អេហ្វ *ព័ត៌មានសហគមន៍* អត្ថបទចុះផ្សាយ ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៣។

[៦] ផ្អែកលើករណីដែល OHCHR បានធ្វើការនៅក្នុងទសវត្សរ៍កន្លងទៅនេះ។

[៧] ទិន្នន័យទទួលបានពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅឆ្នាំ២០០៤ គម្រោងសងសង់ចំនួន ២៨០០ កន្លែងត្រូវបានអនុញ្ញាត ដែលគម្រោងនេះ មានតម្លៃស្មើរ ៨២៣ លាន ដុល្លារ គឺកើនឡើង ១៥២ភាគរយ ពីឆ្នាំ២០០០ ដែលនៅឆ្នាំនោះ គម្រោង ១៩៤៨ កន្លែង ដែលមានតម្លៃ ៣២៦ លាន ដុល្លារប៉ុណ្ណោះត្រូវបាន អនុម័ត។ នៅឆ្នាំ២០០៨ គម្រោងសាងសង់ចំនួន ១១៥៦ កន្លែង ដែលមានតម្លៃ ៣,១៩២ កោដិដុល្លារ ត្រូវបានអនុម័ត។ តម្លៃនៃការវិនិយោគក្នុងឆ្នាំ២០០៨ បង្ហាញឱ្យឃើញកំណើន ៨៧៨%ពីចំនួនវិនិយោគសរុប នៅក្នុងឆ្នាំ២០០០។ ដោយសារតែវិបត្តិសេដ្ឋកិច្ច ពិភពលោក គម្រោងសាងសង់ចំនួន ២២៣០ ត្រូវបានអនុម័តនៅឆ្នាំ២០០៩ ដែលមានតម្លៃ ១៩៨៩ កោដិដុល្លារ ដែលតិចជាងឆ្នាំ២០០៨ ចំនួន៣៨%។ សូមមើលផងដែរ អត្ថបទ របស់កាសែតភ្នំពេញប៉ុស្តិ៍ ចុះផ្សាយថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១០ ក្រោមចំណងជើងថា “ការអនុវត្តន៍គម្រោង ធ្លាក់ចុះ ៨៣% ។

ខ្លាំងចាប់ពីឆ្នាំ២០០៩[៧] ស្របពេលដែលមានការជួញដូរដីធ្លី បង្កការលំបាកជាច្រើនដល់ការគ្រប់គ្រងវិស័យលំនៅដ្ឋាន និងវិស័យដីធ្លីក្នុងលក្ខណ: សមធម៌។ ការខ្វះកំណត់ត្រាសុរិយោដី ការអនុវត្តន៍មិនស្មើភាព គ្នានៃច្បាប់ភូមិបាល ឆ្នាំ២០០១ និងនីតិវិធីពាក់ព័ន្ធ និងការកំណត់ព្រំប្រទល់ដីរដ្ឋ និងដីឯកជនមិនច្បាស់លាស់ បានរួមចំណែក និងធ្វើឲ្យកាន់ធ្ងន់ធ្ងរថែមទៀតដល់និន្នាការបច្ចុប្បន្ននៃការបណ្តេញចេញ។ ម្យ៉ាងវិញទៀត ទន្ទឹមនឹងរដ្ឋាភិបាលបង្កើតជាបណ្តើរនូវគោលនយោបាយរឹងមាំមួយនៃនីតិ និងក្របខ័ណ្ឌគតិយុត្តនានា សំរាប់គ្រប់គ្រងដីធ្លីនៅតំបន់ទីប្រជុំជន រាប់ទាំងការចុះបញ្ជីដីធ្លី ដែលបានចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ លើដីប្រមាណជា ៣ លានឡូត៍ នៅតំបន់ជនបទនានា ការអនុវត្តន៍គំរោងនេះនៅមិនទាន់ធានាសុវត្ថិភាពកាន់សមរម្យដល់ប្រជាពលរដ្ឋក្រីក្រនៅទីប្រជុំជន ដែលប្រឈមនឹងការគំរាមបណ្តេញចេញ។[៨]

ចក្ខុវិស័យនៃគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាលកម្ពុជា មានគោលដៅសំរេច "ទិសដៅជាតិកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយសមធម៌ និងអភិបាលកិច្ចល្អក្នុងសង្គមប្រជាធិប តេយ្យសេដ្ឋកិច្ចទីផ្សារសេរី" ។[៩] គោលនយោបាយគ្រប់គ្រងដីធ្លីនៃព្រះរាជាណាចក្រកម្ពុជា សំដៅ "កំណត់ និង ចុះបញ្ជីកម្មសិទ្ធិ និង សិទ្ធិដទៃទៀត [...] ដើម្បីពង្រឹងសុវត្ថិភាពកាន់កាប់ដីធ្លី បង្កើនប្រសិទ្ធិភាព និងភាពអាចទុកចិត្តបាននៃទីផ្សារដីធ្លី និងការពារភាពសុខដុមនៃសង្គម ដោយការបង្ការ ឬការដោះស្រាយជំលោះដីធ្លី"។[១០] រដ្ឋាភិបាល ជាពិសេស ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ បានបង្កើតគោលនយោបាយលំអិតមួយ ក្របខ័ណ្ឌច្បាប់ គោលការណ៍ និងស្ថាប័ន ដើម្បីអនុវត្តច្បាប់ភូមិបាល ឆ្នាំ២០០១។ ក្របខ័ណ្ឌនេះទទួលស្គាល់ និង ផ្តល់ភាពសំខាន់ដល់ការធានាការពារ សិទ្ធិកាន់កាប់ដីធ្លី ក៏ដូចជាសិទ្ធិភោគ: និង សិទ្ធិកម្មសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជា រួមទាំងការពារពួកគាត់ពីការបណ្តេញចេញដោយបំពាន។ ក្រោមគោលនយោបាយទាំងនេះ ការបណ្តេញចេញដោយបង្ខំគឺខុសច្បាប់ ហើយការតាំងទីលំនៅថ្មី អាចប្រព្រឹត្តទៅបានតែក្នុងមធ្យោបាយចុងក្រោយតែប៉ុណ្ណោះ[១១] នៅពេលករណីលើកលែងមួយចំនួនការបណ្តេញចេញ អាចកើតមានដោយស្របច្បាប់ ដោយមានការពិគ្រោះយោបលជាមុនជាមួយសហគមន៍ដែលទទួលរងគ្រោះ និង មានការផ្តល់សំណងសមស្របរួចរាល់ ។

## ទិន្នន័យ និង ស្ថិតិ

មានការលំបាក ដើម្បីដឹងឱ្យបានច្បាស់លាស់ អំពីវិសាលភាពនៃការបណ្តេញចេញនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ ការប្រឈមមួយក្នុងចំណោមការប្រឈមជាច្រើន ក្នុងន័យនេះគឺកង្វះខាតទិន្នន័យផ្លូវការជាសាធារណ: អំពីចំនួន

[៨] សូមមើល ការវិភាគអំពីប្រព័ន្ធគ្រប់គ្រងដីធ្លី ៖ អង្គការស្ពានទៅកាន់សន្តិភាពអាស៊ីអាគ្នេយ៍ (BABSEA), មជ្ឈមណ្ឌលស្តីពីសិទ្ធិលំនៅដ្ឋាន និង ការបណ្តេញចេញ (COHRE), អង្គការ Jesuit Refugee Service (JRS), *មិនទទួលបានកម្មសិទ្ធ: អសុវត្ថិភាពខាងការកាន់កាប់ដីធ្លី និងអសមភាពក្នុងវិស័យដីធ្លីនៅកម្ពុជា* (ខែតុលា ឆ្នាំ២០០៩) (ពីពេលនេះទៅ :*មិនទទួលបានកម្មសិទ្ធិ*)។

[៩] ឯកសារបណ្តោះអាសន្នស្តីពីក្របខណ្ឌ័គោលនយោបាយដីធ្លី ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ឆ្នាំ២០១១ ទំព័រ១១

[១០] ឯកសារបណ្តោះអាសន្នទំព័រ១៣

[១១] គោលការណ៍នេះ ត្រូវបានបញ្ជាក់ជាថ្មីដោយ ឯកឧត្តម អ៊ឹម ឈុន លឹម ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ នៅពេលដែល ឯកឧត្តម បានទទួលជួបពិភាក្សាជាមួយលោកស្រី យ៉ុង ហ្វា កាំង ឧត្តមស្នងការរង អង្គការសហប្រជាជាតិទទួល បន្ទុកសិទ្ធិមនុស្ស នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១០ ។

# ជំពូកទី១ ៖ សេចក្តីផ្តើម និង បរិបទ

ទាំងនៅក្នុងរាជធានីភ្នំពេញ ឬនៅទូទាំងប្រទេស ។ ទិន្នន័យភាគច្រើនដែលមានស្រាប់ មានប្រភពមកពីអង្គការនានា ដែលធ្វើការយ៉ាងសកម្មផ្នែកលំនៅដ្ឋាន។ ទិន្នន័យថ្មីបំផុត មានប្រភពមកពីអង្គការលើកលែងទោសអន្តរជាតិ (Amnesty International) ដែលបានបញ្ជាក់ថា ក្នុងឆ្នាំ២០០៩ យ៉ាងហោចណាស់ មានការបណ្តេញចេញ ២៦ ករណី ដែលបានធ្វើឱ្យប្រជាពលរដ្ឋប្រមាណជា២៧,០០០នាក់ គ្មានទីជម្រក។ [១២] អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកគឺ សមាគមន៍ធាងត្នោត បានធ្វើការប៉ាន់ស្មាននៅក្នុងខែមេសា ឆ្នាំ២០០៩ ថាប្រជាពលរដ្ឋកម្ពុជាជាង ១២០,០០០នាក់ នៅក្នុងរាជធានីភ្នំពេញ បានត្រូវគេបណ្តេញចេញ តាំងពីឆ្នាំ១៩៩០[១៣] ដែលការប៉ាន់ស្មាននេះ បានទទួលការគាំទ្រយ៉ាងខ្លាំង ពីសហគមន៍អង្គការមិនមែនរដ្ឋាភិបាល។[១៤] ប្រភពមួយទៀត បានធ្វើការប៉ាន់ស្មានក្នុងឆ្នាំ២០០៨ ថា មានប្រជាពលរដ្ឋជាង ១៥,០០០ គ្រួសារ ត្រូវបានផ្លាស់ប្តូរទីលំនៅចេញពីភ្នំពេញ ក្នុងរយៈពេល ១០ ឆ្នាំ កន្លងមកនេះ ហើយពីរភាគបីនៃប្រជាពលរដ្ឋទាំងនេះ បានត្រឡប់មករាជធានីភ្នំពេញវិញ។[១៥] នៅទីបំផុត យោងតាមអង្គការ Amnesty International បានឱ្យដឹងថា ក្នុងឆ្នាំ២០០៨យ៉ាងហោចណាស់ មានប្រជាពលរដ្ឋប្រហែលជា ១៥០,០០០ នាក់ នៅទូទាំងប្រទេស ប្រឈមមុខនឹងការផ្លាស់ប្តូរទីលំនៅដោយបង្ខំ។[១៦] ចំណែកឯកន្លែងតាំងទីលំនៅថ្មីនៅភ្នំពេញវិញ មានប្រភពជាច្រើនបានបញ្ជាក់ថា មានកន្លែងតាំងទីលំនៅថ្មីចំនួន ៤១កន្លែង នៅក្នុងឆ្នាំ២០០៦[១៧] និងជាង ៥០ កន្លែង គិតមកដល់ឆ្នាំ ២០០៩។ [១៨]

យោងតាមតួលេខ របស់អាជ្ញាធររាជធានី បានឱ្យដឹងថា មានសហគមន៍ដែលបានកំណត់ នៅឆ្នាំ២០០៣ ថាជាសហគមន៍ក្រីក្រ ចំនួនជាង ៣០០ សហគមន៍ ក្នុងចំណោម ៥៦៩ សហគមន៍ នៅរាជធានីភ្នំពេញត្រូវបាន “ដោះស្រាយ” រួចហើយ។[១៩] គេដឹងមិនដឹងច្បាស់ថា តើក្នុងចំណោម ៣០០ សហគមន៍នេះ មានសហគមន៍ចំនួនប៉ុន្មាន ដែលពិតជាទទួលបានប្រយោជន៍ ពីការអភិវឌ្ឍន៍នៅនឹងកន្លែង ឬពីការផ្លាស់ប្តូរទីតាំងថ្មី ដោយភាពសមស្របនោះទេ។ តាមការប៉ាន់ស្មាន ក្រៅផ្លូវការថ្មីៗនេះមួយទៀត បានបង្ហាញថា ចំនួនសហគមន៍ក្រីក្រ តាមទីប្រជុំជន នៅរាជធានីភ្នំពេញ មានដល់ទៅ ៤១០

[១២] របាយការណ៍របស់អង្គការ អង្គការលើកលែងទោសអន្តរជាតិ ឆ្នាំ ២០១០ នៅកម្ពុជា ទំព័រទី៩៣។

[១៣] សមាគមធាងត្នោត, ព្រឹត្តិន័យ និងតួលេខ *(Facts & Figures)*, លេខ១១( ចេញខែមេសា ឆ្នាំ២០០៩)

[១៤] សូមមើលឧទាហរណ៍ដូចជា របាយការណ៍ស្រប របស់ក្រុមការងារសិទ្ធិដីធ្លី និងលំនៅដ្ឋាន *សិទ្ធិដីធ្លី និងលំនៅដ្ឋាន នៅកម្ពុជា* ដាក់ជូន គណកម្មការសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ របស់អង្គការសហប្រជាជាតិ (ខែមេសា ឆ្នាំ២០០៩)។ ក្នុងពេល សរសេររបាយការណ៍នេះ សមាគមន៍ធាងត្នោត បានប៉ាន់ស្មាន ថា ប្រជាពលរដ្ឋ ប្រហែលជា ១៣៣,០០០ ត្រូវបានបណ្តេញចេញក្នុងឆ្នាំ ២០០៩ (ដូចត្រូវបានបង្ហាញក្នុងរបាយការណ៍ស្របនេះ( ប៉ុន្តែតួលេខនេះ ត្រូវកែប្រែទៅជា ១២០,០០០នាក់វិញ )។

[១៥] ព្រឹត្តិប័ត្រ អង្គការ UPDF (ខែមេសា ឆ្នាំ ២០០៨)។

[១៦] អង្គការលើកលែងទោសអន្តរជាតិ *សិទ្ធិត្រូវបានគេដកហូត: ការបណ្តេញចេញដោយបង្ខំនៅកម្ពុជា (ឆ្នាំ២០០៨)*។

[១៧] ការអង្កេត ដោយសមាគមធាងត្នោត ខែសីហា ឆ្នាំ២០០៧ បានឱ្យដឹងថា ពីខែតុលា ឆ្នាំ២០០០ ដល់ខែមិថុនា ឆ្នាំ២០០៦ នៅតាមកន្លែងតាំងទីលំនៅថ្មីនៅក្នុង និងនៅក្បែរៗរាជធានី ភ្នំពេញ មានកន្លែងតាំងទីលំនៅថ្មី ៤១ កន្លែងត្រូវបានបង្កើតឡើង ដោយមានប្រជាពលរដ្ឋ ១៥,៨៣១ គ្រួសារបានផ្លាស់ទៅរស់នៅទីនោះ។

[១៨] សមាគមន៍ធាងត្នោត៖ *ការអង្កេតលើខ័ណ្ឌទាំង៨: ការតាំងទីលំនៅនៃអ្នកក្រីក្រក្នុងទីក្រុងភ្នំពេញ* (ខែធ្នូ ឆ្នាំ២០០៩) [ពីពេលនេះតទៅហៅ ៖ ការអង្កេតលើខណ្ឌទាំង៨] ។

[១៩] បទអន្តរា គមន៍ ដោយ ឯកឧត្តម អ៊ឹម ឈន់ លឹម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងដែនដី នគរូបនីយកម្ម និង សំណង់ នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលដៃគូអភិវឌ្ឍន៍របស់រដ្ឋាភិបាល លើកទី១៥ (ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០០៩) ។ ក្នុងឆ្នាំ២០០៣ សហព័ន្ធសាមគ្គីភាព សហគម ន៍អ្នកក្រីក្រក្នុងទីក្រុង បានប៉ាន់ស្មានថា សហគមន៍ក្រីក្រក្នុងទីក្រុងចំនួន ៥៦៩ សហគមន៍ ដែលស្មើនឹង ប្រជាពលរដ្ឋ ៣៧៤,៨៣៦ នាក់ បានកំពុង រស់នៅក្នុងរាជធានីភ្នំពេញ ដែលតំណាងអោយ ៣៥ ភាគរយនៃចំនួនប្រជាជនសរុប ។

សហគមន៍។[២០]

គួរកត់សំគាល់ថា ទន្ទឹមនឹងការផ្តោតការយកចិត្តទុកដាក់ ច្រើនទៅលើស្ថានភាពនៅតំបន់ទីប្រជុំជននោះ ការបណ្តេញចេញនៅតំបន់ជនបទដោយសារការផ្តល់សម្បទានដីសេដ្ឋកិច្ច ឬ ជំនួញដីធ្លីផ្សេងៗទៀត ក៏កើតមានដែរ។ ខណៈនៃការខ្វះទិន្នន័យរឹងមាំ និងដែលអាចពឹងពាក់បាន នៅក្នុងឆ្នាំ២០០៩ និងនៅដើមឆ្នាំ២០១០ នេះ មានការបណ្តេញចេញយ៉ាងហោចណាស់ចំនួន ៦ ករណីដែរ ដែលបានកើតឡើង ហើយដែលពាក់ព័ន្ធប្រជាពលរដ្ឋប្រមាណ ជា ២,៥០០ គ្រួសារ។[២១]

## គោលបំណងនៃការសិក្សានេះ

យោលទៅលើនិន្នាការនៃការបណ្តេញចេញ និងដោយផ្អែកលើបទពិសោធន៍ និងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរ និងដៃគូដទៃទៀត ដើម្បីរកដំណោះស្រាយតាមផ្លូវច្បាប់ និងប្រកបដោយមនុស្សធម៌ ចំពោះករណីនៃការបណ្តេញចេញ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅ កម្ពុជា (OHCHR) បានសម្រេចចិត្ត ធ្វើការសិក្សាអំពីការបណ្តេញចេញ និង ការតាំងទីលំនៅថ្មីនេះ។ ការសិក្សានេះ មានគោលបំណងបង្ហាញពីការវាស់វែងផលប៉ះពាល់ជាអវិជ្ជមានចំពោះមនុស្ស និង សង្គម ដែលបណ្តាលមកពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅតាមតំបន់ទីប្រជុំជន នៅក្នុងប្រទេសកម្ពុជា និងមានគោលបំណងស្នើឲ្យមានការដាក់ចេញវិធានការ និងរកស្វែងរកដំណោះស្រាយ ចំពោះបញ្ហាទាំងឡាយដែលបានកំនត់។

ការសិក្សានេះ ជាការប្រឹងប្រែងផ្តួចផ្តើមផ្តល់នូវទិដ្ឋភាពរួម ឬ ផ្តល់អោយឃើញចំៗបញ្ហា



អ្នកសិក្សាស្រាវជ្រាវ OHCHR ពិភាក្សាអំពីស្ថានភាពការតាំងទីលំនៅថ្មី ជាមួយសមាជិកសហគមន៍ អភិវឌ្ឍន៍មានជ័យ
ថ្លែងអំណរគុណចំពោះការថតរូបដោយ: R McCormack/ OHCHR

[២០] ការអង្កេតលើខណ្ឌទាំង៨ ។

[២១] ការបណ្តេញចេញបានកើតឡើងក្នុងខេត្តកំពត កណ្តាល កំពង់ធំ តាកែវ និងឧត្តរមានជ័យ (មានពីរករណីនៅ ឧត្តរមានជ័យ)។

# ជំពូកទី១ ៖ សេចក្តីផ្តើម និង បរិបទ

សំខាន់ពីចរិត លក្ខណៈនៃដំណើរការនៃការតាំងទីលំនៅថ្មី និងទីតាំងនៃការតាំងទីលំនៅថ្មីទាំងនេះនៅតំបន់ទីប្រជុំ ជន។ សង្ឃឹមថា រាជរដ្ឋាភិបាលកម្ពុជា អង្គការជំនាញ និងកម្មវិធីជំនួយនានា នឹងយកការសិក្សានេះទៅបន្តធ្វើការវាយតម្លៃឱ្យកាន់តែស៊ីជម្រៅថែមទៀត អំពីទិដ្ឋភាពមួយចំនួន នៃការតាំងទីលំនៅថ្មី ដែលបានគូសបញ្ជាក់នៅក្នុងការសិក្សានេះ និងបង្កើតជាកម្មវិធីផ្សេងៗដែលសមស្រប ។

អនុសាសន៍មួយចំនួន មានផ្តល់ជូននៅផ្នែកចុងបញ្ចប់នៃការសិក្សានេះ ( សូមមើលជំពូកទី៦) ។

សង្ឃឹមថា ការសិក្សានេះអាចឈានទៅរកការពិភាក្សានៅក្នុងប្រទេសកម្ពុជា ដោយចៀសវាងបានពីការប្រឈមមុខដាក់គ្នា តែលើការពិភាក្សាពីករណីបណ្តេញចេញជាក់លាក់មួយចំនួន សំដៅដល់ការពិភាក្សាប្រកបដោយភាពសហការគ្នា ក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ ក្នុងគោលបំណងស្វែងរកដំណោះស្រាយចំពោះបញ្ហា នៃការតាំងទីលំនៅថ្មី ក្នុងប្រទេសកម្ពុជា។ ជាការសង្ឃឹមផងដែរថា កិច្ចពិភាក្សា និងការអនុវត្តន៍ជាក់ស្តែងជាបន្តទៀត នឹងធ្វើឱ្យដំណើរការ និងកន្លែងតាំងទីលំនៅថ្មីក្លាយជាផ្នែករួមមួយ នៃកម្មវិធីអភិវឌ្ឍន៍ ដែលតាមរយៈនេះ គ្រួសារដែលតាំងទីលំនៅថ្មី ទទួលបាននូវមធ្យោបាយផ្សេងៗ ដែលមិនត្រឹមតែដើម្បីស្តារឡើងវិញ នូវមុខរបរចិញ្ចឹមជីវិតរបស់ពួកគាត់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យស្ថានភាពជិវិតរស់នៅកាន់តែល្អប្រសើរជាង ស្ថានភាពមុនពេលផ្លាស់មកតាំងទីលំនៅថ្មី និងជំនះពីភាពក្រីក្រ និងចូលរួមក្នុងការអភិវឌ្ឍន៍ជាតិថែមទៀតផង។

## ទម្រង់របាយការណ៍នៃការសិក្សានេះ

ការសិក្សានេះមានប្រាំមួយផ្នែកធំៗគឺ៖ ជំពូកទី១ បង្ហាញអំពីបរិបទដែលកំណត់ឡើងសំរាប់ការសិក្សានេះ និង អំពីហេតុផល និងគោលបំណងនៃការសិក្សា។ ជំពូកទី២ ពន្យល់អំពីវិធីសាស្រ្ត និងចំណុចសំខាន់ៗ នៃការសិក្សានេះ។ ជំពូកទី៣ បង្ហាញដោយសង្ខេបអំពីបទបញ្ញត្តិនៃច្បាប់ជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធនឹងការបណ្តេញចេញ និងការតាំងទីលំនៅថ្មី។ ជំពូកទី៤ ផ្តោតសំខាន់ទៅលើដំណើរការ និង ការអនុវត្តន៍មុន និង ក្នុងពេលបណ្តេញចេញ។ ជំពូកទី៥ ពិភាក្សាអំពីស្ថានភាពនៃកន្លែងតាំងទីលំនៅថ្មី ទៅតាមប្រធានបទ ឬសិទ្ធិដែលត្រូវគេបំពាន។ ជំពូកទី៦ សរុបខ្លឹមសារនៃការសិក្សានេះ និងផ្តល់អនុសាសន៍សំរាប់ការពិភាក្សាដល់រាជរដ្ឋាភិបាល កម្ពុជា និងដៃគូរបស់ខ្លួនក្នុងការជំរុញឱ្យមានដំណោះស្រាយ។

ជាទីបញ្ចប់ គឺ ឧបសម្ព័ន្ធទី១ បង្ហាញពីទិដ្ឋភាពទូទៅនៃដំណើរការ នៃការបណ្តេញចេញ / ការតាំងទីលំនៅថ្មីនៃសហគមន៍ ដែលបានតាំងទីលំនៅថ្មី ដែលស្ថិតក្រោមការសិក្សានេះ។ ឧបសម្ព័ន្ធទី២ មានសេចក្តីពណ៌នា និងរូបភាពនៃឯកសារទាំងឡាយ ដែលបានចេញឱ្យគ្រួសារប្រជាពលរដ្ឋទាក់ទងទៅនឹងកម្មសិទ្ធិដីធ្លី និងឧបសម្ព័ន្ធទី៣មាននិយាយអំពីឯកសារយោង។



ទំនាស់រវាងសហគមន៍ដីក្រហមជាមួយអាជ្ញាធរ

ថ្លែងអំណរគុណចំពោះការថតរូបដោយ: OHCHR

២

# វិធីសាស្ត្រ

ជំពូកនេះបង្ហាញអំពីវិធីសាស្ត្រដែលបានប្រើប្រាស់ក្នុងការសិក្សានេះ។ ជំពូកនេះ ពន្យល់ អំពីចំណុចសំខាន់ៗ និងវិសាលភាព នៃការសិក្សា ព្រមទាំងបង្ហាញ អំពីរបៀបប្រមូលព័ត៌មាន សម្រាប់ការសិក្សានេះ និងតារាងរាយឈ្មោះ កន្លែងតាំងទីលំនៅថ្មី នៅរាជធានីភ្នំពេញ និង នៅខេត្តព្រះសីហនុ ដែលបានពិនិត្យយ៉ាងស៊ីជម្រៅ។






# ជំពូកទី ២
# វិធីសាស្រ្ត

## ចំណុចសំខាន់ៗ និងវិសាលភាពនៃការសិក្សា

ការសិក្សានេះ ផ្តោតការយកចិត្តទុកដាក់លើដំណើរការនៃការបណ្តេញចេញ និង ការតាំងទីលំនៅថ្មី ដែលកើតមាននៅតំបន់ទីប្រជុំជន ជាពិសេសដោយសារការអភិវឌ្ឍន៍ទីប្រជុំជន ឬ ការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មខ្នាតធំ។ ដំណើរការទាំងនេះ បានទាក់ទាញចំណាប់អារម្មណ៍សាធារណៈជនយ៉ាងខ្លាំងនាពេលប៉ុន្មានឆ្នាំថ្មីៗនេះហើយមានបញ្ហាស្មុគស្មាញជាច្រើន ក្នុងការអនុវត្តន៍ដំណើរការទាំងនេះ ដែលរដ្ឋាភិបាលកម្ពុជា បានប្រឈមក្នុងបរិបទបច្ចុប្បន្ននៃវិស័យនគរូបនីយកម្ម និង ការអភិវឌ្ឍន៍ប្រទេសដែលមានសន្ទុះលឿន។ ការសិក្សានេះ មិនពិនិត្យលើការបណ្តេញចេញនៅតាមតំបន់ជនបទ ក៏ដូចជា ការតាំងទីលំនៅថ្មី ដែលពាក់ព័ន្ធនឹង គំរោងសាធារណៈការធំៗ និងដែលមានការគាំទ្រពីទីភ្នាក់ងារអភិវឌ្ឍន៍នានាដូចជា ការស្តារផ្លូវដែកទេ ។

ការវាយតម្លៃ នៃការសិក្សានេះ ផ្អែកលើក្របខ័ណ្ឌសិទ្ធិមនុស្សអន្តរជាតិ។ គោលការណ៍សិទ្ធិមនុស្សដូចជា សមធម៌ ការមិនរើសអើង ការទទួលខុសត្រូវនិងការចូលរួមដោយបញ្ជាក់អំពីវិធីសាស្រ្តទូទៅ ដែលការសិក្សានេះយកមកធ្វើជាមូលដ្ឋាន។ ដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មី ត្រូវបានវាយតម្លៃ ដោយយោងតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ ជាពិសេសបទដ្ឋានទាក់ទងទៅនឹងការការពារ មិនអោយមានការបណ្តេញចេញដោយខុសច្បាប់ សិទ្ធិមានលំនៅដ្ឋានសមរម្យ និងសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច ផ្សេងៗទៀត។ ការពិភាក្សាយ៉ាងពេញលេញ អំពីបទដ្ឋានទាំងនេះ និងបញ្ញត្តិច្បាប់ដែលអាចអនុវត្តន៍នៅកម្ពុជាមានបង្ហាញនៅក្នុងជំពូកទី៣។

សកម្មភាពនៃការបណ្តេញចេញ នៅកម្ពុជា និងផលប៉ះពាល់អវិជ្ជមាន ទៅលើជនរងគ្រោះដែលត្រូវគេបណ្តេញចេញទាំងអស់ ត្រូវបានគេសរសេរចងក្រងជាឯកសារយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ មានការសរសេរ តិចតួចអំពីអ្វីដែលគ្រួសារទាំងនោះបានជួបប្រទះ នៅពេលផ្លាស់ទៅនៅទីតាំងថ្មី ក្រោយពីការបណ្តេញចេញ និងពីរបៀបនៃការស្តារជីវភាពរស់នៅរបស់គាត់ឡើងវិញ ។ ការសិក្សានេះ ផ្តោតជាសំខាន់លើ ស្ថានភាពនៃគ្រួសារ ដែលបានតាំងទីលំនៅថ្មី តែការសិក្សានេះក៏ពិភាក្សាដោយសង្ខេប អំពីដំណើរការនៅមុនពេល និងក្នុងពេលបណ្តេញចេញ និងការតាំងទីលំនៅថ្មី។

## ការប្រមូលព័ត៌មាន

ការព័ត៌មាន ត្រូវបានប្រមូលតាមវិធីសាស្ត្រដូចខាងក្រោម ៖

- ការពិនិត្យឯកសារផ្សេងៗទាក់ទង នឹងការ បណ្តេញចេញ និង ការតាំងទីលំនៅថ្មីនៅ កម្ពុជា
- ការស្ទង់មតិសហគមន៍: សម្ភាសន៍ប្រជាពលរដ្ឋម្នាក់ៗយ៉ាងលំអិត និង ពិភាក្សាជាក្រុមនៅតាមកន្លែងតាំងទីលំនៅថ្មី ដែលបានជ្រើសរើសសំរាប់ការសិក្សានេះ មាននៅរាជធានីភ្នំពេញ និងនៅខេត្តព្រះសីហនុ ដោយបានប្រព្រឹត្តទៅពី ខែតុលា ឆ្នាំ២០០៩ ដល់ខែមេសា ឆ្នាំ២០១០ និង ការបញ្ចូលកិច្ចសម្ភាសន៍ ដែលបានធ្វើពីឆ្នាំ ២០០៨ (សូមមើលតារាងខាងក្រោម)[២២]
- កិច្ចសម្ភាសន៍តាមអង្គការស្ថាប័ន :កិច្ចប្រជុំ និងកិច្ចសម្ភាសន៍ជាមួយ មន្ត្រីរដ្ឋាភិបាល នៅថ្នាក់មូលដ្ឋាន ថ្នាក់រាជធានី និងថ្នាក់ជាតិ តំណាងសហគមន៍ ក៏ដូចជា តំណាងមក ពីអង្គការផ្នែកសិទ្ធិមនុស្ស និង ផ្នែកសិទ្ធិលំនៅដ្ឋាន អង្គការផ្តល់សេវាផ្សេងៗ និង អង្គការអភិវឌ្ឍន៍នានា
- ការវាយតម្លៃផ្នែកបច្ចេកទេស អំពីស្ថានភាពទឹក និងអនាម័យ នៅកន្លែងតាំងទីលំនៅថ្មីនៅភូមិអណ្តូង ដោយបានធ្វើបទសម្ភាសន៍ជាមួយប្រជា ពលរដ្ឋ ៩៥ នាក់ និងបានផ្ញើរគំរូទឹកទៅវិទ្យាស្ថាន ប៉ាស្ទ័រ សម្រាប់ការវិភាគមីក្រូជីវសាស្ត្រ និងគីមី-រូបសាស្ត្រ ។ បញ្ជីរសំនួរអំពីតំរូវការ ទឹក និងអនាម័យ ត្រូវបានបង្កើតឡើង និងត្រូវបានប្រើប្រាស់ សំរាប់ការធ្វើសម្ភាសន៍ទាំងនេះ។
- ព័ត៌មានដកស្រង់ចេញពីករណីដែល OHCHR បានធ្វើការដោយផ្ទាល់ជាមួយ សហគមន៍ដែលបានតាំងទីលំនៅថ្មីរួចហើយ ក្រោមការសិក្សានេះ និងជាមួយករណីបណ្តេញចេញ/ការតាំងទីលំនៅថ្មីផ្សេងៗ ដូចជាករណីសហគមន៍ក្រុម ៧៨ នៅខណ្ឌចំការមន រាជធានីភ្នំពេញជាដើម។

## ការជ្រើសរើសទីតាំង

ការជ្រើសរើសយកមកធ្វើការសិក្សានូវកន្លែងតាំងទីលំនៅថ្មីទាំងនេះមិនបានទូលំទូលាយទេ ។ ជំរើសទីតាំងសម្រាប់ការសិក្សានេះ គឺជ្រើសរើសពីក្នុងចំណោមកន្លែងតាំងទីលំនៅថ្មី ដែលមានស្រាប់ក្នុងគោលបំណងបង្ហាញ រូបភាពដែលមានតុល្យភាពនៃលំនាំនាពេលថ្មីៗ នៃការតាំងទីលំនៅថ្មីតាមរយៈទីតាំងជាតំណាងភាគច្រើន ។ សូមមើលខាងក្រោមសេចក្តីសង្ខេប អំពីកន្លែងតាំងទីលំនៅថ្មីមួយចំនួនដែលបានលើកយកមកធ្វើការសិក្សា។ សូមកត់សំគាល់ថា ចំនួនប៉ាន់ស្មានអំពីគ្រួសារប្រជាពលរដ្ឋ និងឈ្មោះរបស់ទីតាំងដើម គ្រាន់តែនិយាយយោងដល់ សហគមន៍ទាំងឡាយ ដែលបានលើកយកមកធ្វើការសិក្សាផ្ទាល់ នៅក្នុងរបាយការណ៍នេះ តែប៉ុណ្ណោះ ហើយទីតាំងខ្លះ មានដូចជា ទួលសំបូរ និងដំណាក់ត្រយឹង ដែលមានគ្រួសារប្រជាពលរដ្ឋបានផ្លាស់ចូលមកពីទីតាំងផ្សេងទៀត មិនមែនជាផ្នែកមួយនៃការសិក្សានេះទេ។ សេចក្តីពន្យល់កាន់តែលំអិតអំពីករណីនីមួយៗ និងអំពីតួលេខប៉ាន់ស្មានមាននៅក្នុងឧបសម្ព័ន្ធទី១។ សូមមើលផងដែរផែនទីកន្លែងតាំងទីលំនៅថ្មីនៅរាជធានីភ្នំពេញ នៅ

[២២] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សូមអរគុណដល់បុគ្គលិក សមាគមន៍ផាងត្នោត សម្រាប់ ការស្រាវជ្រាវ និងបទសម្ភាសន៍ដ៏ទូលំទូលាយ ដែលបានធ្វើឡើងក្នុងឆ្នាំ២០០៨។

តារាងលេខ១៖ ព័ត៌មានសង្ខេបអំពីសហគមន៍ដែលបានតាំងទីលំនៅថ្មី និងដែលបានជ្រើសរើសសម្រាប់ការសិក្សានេះ

| ឈ្មោះ និង ទីតាំង នៃ កន្លែង តាំងទីលំនៅ ថ្មី | ចំនួនគ្រួសារ សរុប នៅទី តាំងថ្មី | កាលបរិច្ឆេទ នៃការបណ្តេញ ចេញ/ ការតាំងទី លំនៅថ្មី | ទីតាំងដើម | ចំនួនកិច្ចសម្ភាសន៍ជាមួយប្រជាពលរដ្ឋ |
|---|---|---|---|---|
| **រាជធានីភ្នំពេញ** | | | | |
| **អភិវឌ្ឍន៍មានជ័យ ឬ “វេង ស្រេង”** ខណ្ឌមានជ័យ | ១២៩ | ខែមករា ឆ្នាំ ២០០៩ | **នៅលើផ្លូវ នៅ ទួលស្វាយព្រៃ** ខណ្ឌចំការមន | កិច្ចសម្ភាសន៍ ចំនួន៣០ និង ពិភាក្សាជា ក្រុម ចំនួន១ ជាមួយប្រជាពលរដ្ឋ ៨នាក់ |
| **អណ្តូង** ខណ្ឌដង្កោ | ៨០០ ទៅ ១,៨០០ | ខែមិថុនា ឆ្នាំ ២០០៦ | **សំបុកចាប** ខណ្ឌចំការមន | កិច្ចសម្ភាសន៍ចំនួន៧០ និង ពិភាក្សាជាក្រុមចំនួន៥ ជាមួយ ប្រជាពលរដ្ឋ ពី៤ទៅ៦នាក់ |
| **ដំណាក់ ត្រយឹង ឬបុរីសន្តិភាព ២** ខណ្ឌដង្កោ | ៩១ (ទទួលបាន ផ្ទះល្វែង) និងជាង៣០០ នាក់ នៅលើ ចញ្ចើមផ្លូវ | ខែមករា ឆ្នាំ ២០០៩ | **ដីក្រហម** ខណ្ឌចំការមន | កិច្ចសម្ភាសន៍ ចំនួន ២០ និង ពិភាក្សាជាក្រុម ចំនួន៧ ជាមួយ ប្រជាពលរដ្ឋ ពី៣ ទៅ ៨ នាក់ ក្នុងមួយក្រុមៗ |
| **ទួលសំបូរ** ខណ្ឌដង្កោ | ៤២គ្រួសារជា អ្នកផ្ទុក មេរោគ អេដស៍/ជំងឺអេដស៍ | ខែមិថុនា/ កក្កដា ឆ្នាំ២០០៩ | **បូរីកីឡា** ខណ្ឌ៧មករា | កិច្ចសម្ភាសន៍ ចំនួន ២០ និង ពិភាក្សា ជាក្រុម ចំនួន២ ជាមួយប្រជាពលរដ្ឋពី ៤ ទៅ ៦ នាក់ ក្នុងមួយ ក្រុមៗ |
| **ត្រពាំងអញ្ចាញ** ខណ្ឌដង្កោ | ៧០០ ទៅ ១,៥០០ | ខែឧសភា ឆ្នាំ ២០០៦ | **សំបុកចាប** ខណ្ឌចំការមន | កិច្ចសម្ភាសន៍ ចំនួន៥៣ និង ពិភាក្សាជាក្រុម ចំនួន៤ ជាមួយ ប្រជាពលរដ្ឋពី ៣ទៅ ៥នាក់ ក្នុងមួយក្រុមៗ |

តារាងលេខ១៖ ព័ត៌មានសង្ខេបអំពីសហគមន៍ដែលបានតាំងទីលំនៅថ្មី និងដែលបានជ្រើសរើសសម្រាប់ការសិក្សានេះ

| ឈ្មោះ និង ទីតាំង នៃ កន្លែង តាំងទីលំនៅ ថ្មី | ចំនួនគ្រួសារ សរុប នៅទីតាំងថ្មី | កាលបរិច្ឆេទ នៃការបណ្តេញចេញ/ ការតាំងទីលំនៅថ្មី | ទីតាំងដើម | ចំនួនកិច្ចសម្ភាសន៍ជាមួយប្រជាពលរដ្ឋ |
|---|---|---|---|---|
| **ខេត្ត កណ្តាល** | | | | |
| **ភូមិ ស្រះពោធិ** ស្រុកពញាឮ | ៣០០ ទៅ ៥១០ | ខែធ្នូ ឆ្នាំ២០០៩ | **ដំណាក់ ត្រយឹង** (អាជីវករ និង អ្នកជួលផ្ទះ) ដែលត្រូវបានបណ្តេញចេញពី ដីក្រហម ពីពេលមុន | កិច្ចសម្ភាសន៍ ចំនួន ៤ និង ពិភាក្សាជាក្រុម ចំនួន២ ជាមួយប្រជាពលរដ្ឋពី ៣ ទៅ ៨នាក់ ក្នុងមួយក្រុមៗ |
| **ខេត្តព្រះសីហនុ** | | | | |
| **អូរកម្ពុជា** ខណ្ឌព្រៃនប់ | ៤៦ | ខែមេសា ឆ្នាំ ២០០៩ | **ក្បាល ហាង** ខណ្ឌព្រៃនប់ | កិច្ចសម្ភាសន៍ ចំនួន ២ និង ពិភាក្សាជាក្រុមចំនួន១ ជាមួយប្រជាពលរដ្ឋពី ២០ទៅ២៥នាក់ |
| **ស្ពានឆេះ ខណ្ឌ** មិត្តភាព | ៧១ | ខែមេសា ឆ្នាំ ២០០៧ | **ស្ពានឆេះ** ខណ្ឌមិត្តភាព | កិច្ចសម្ភាសន៍ ចំនួន២៩ និង ពិភាក្សាជាក្រុមចំនួន២ ជាមួយប្រជាពលរដ្ឋពី ៤ ទៅ៥នាក់ |




ផែនទីរាជធានីភ្នំពេញ ភ្ជាប់ជាមួយចំនុចបញ្ជាក់ពីទីតាំងនៃកន្លែងតាំងទីលំនៅថ្មីនានារបស់ការសិក្សានេះ

ផែនទីយោងតាមឯកសាររបស់សមាគមន៍ ផាង ត្នោត

# ៣

# ក្របខ័ណ្ឌគតិយុត្តិ

ការសិក្សានេះត្រូវបានផ្អែកលើ ក្របខ័ណ្ឌសិទ្ធិមនុស្សអន្តរជាតិ។ ជាពិសេស លើបទដ្ឋានសិទ្ធិមនុស្ស ដែលពាក់ព័ន្ធនឹងសិទ្ធិមានលំនៅដ្ឋានសមរម្យ និងកាតព្វកិច្ចជាក់លាក់ ក្នុងការអនុវត្តនិងលទ្ធផលនៃការបណ្តេញចេញនិងការតាំងទីលំនៅថ្មី។ ជំពូកនេះនិយាយ សេចក្តីសង្ខេបអំពីកាតព្វកិច្ចនិងបង្ហាញអំពីប្រភពកាតព្វកិច្ចទាំងនោះ។ ជំពូកនេះក៏ពិនិត្យផងដែរលើការប្តេជ្ញាចិត្ត ពាក់ព័ន្ធមួយចំនួនក្រោមច្បាប់ជាតិ និងពន្យល់យ៉ាងច្បាស់នៅផ្នែកខាងក្រោយអំពីពាក្យដែលត្រូវបានប្រើប្រាស់ទាំងនៅក្នុងភាសាអង់គ្លេស ទាំងនៅក្នុងភាសាខ្មែរ អំពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី។






# ជំពូកទី៣
# ក្របខ័ណ្ឌគតិយុត្តិ

## សិទ្ធិមានលំនៅដ្ឋានសមរម្យ

ខណៈដែលប្រជាជនច្រើនជាងពាក់កណ្តាលនៃចំនួនប្រជាពលរដ្ឋលើពិភពលោករស់នៅក្នុងទម្រង់ជាបរិស្ថានទីប្រជុំជន មានប្រជាជនជាច្រើនលាននាក់ទៀតរស់ នៅក្នុងស្ថានភាពដែលកំពុងតែមានការគំរាមកំហែងដល់ជីវិត ឬ សុខភាព ពោលគឺ រស់នៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជន ឬក៏តំបន់រស់នៅមិនរៀបរយ ហើយពួកគេមិនបានទទួលនូវលក្ខខ័ណ្ឌអប្បបរមាលំនៅដ្ឋានដែលមានលក្ខណៈ "សមរម្យ" ពិតប្រាកដឡើយ។

សហគមន៍អន្តរជាតិ បានទទួលស្គាល់ "សិទ្ធិមានលំនៅដ្ឋានសមរម្យ" ជាផ្នែកមួយនៃសិទ្ធិក្នុងការទទួលបានកំរិតជីវភាពគ្រប់គ្រាន់ តាំងពីដើមឆ្នាំ ១៩៤៨ នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងបន្ទាប់មកត្រូវបានទទួលស្គាល់ដោយកតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (មាត្រា១១(១))។ វាបានទទួលស្គាល់ថា លំនៅដ្ឋាន មិនមែនគ្រាន់តែជាសំណង់រូបវន្តដែលមានដំបូល និងជញ្ជាំងជាមូលដ្ឋាននោះទេ ប៉ុន្តែតាមទស្សនៈ ទូលំទូលាយជាងនេះ វាគ្របដណ្តប់លើធាតុសំភារៈ និង ធាតុមិនមែនសំភារៈ មួយចំនួនដែលសំខាន់ចាំបាច់ ដើម្បីបង្កើតបានជាទីកន្លែងរស់នៅមានផាសុខភាព និង មានសុវត្ថិភាព។

## បទដ្ឋានអន្តរជាតិផ្សេងៗដែលទាក់ទងទៅនឹងការបណ្តេញចេញនិងការតាំងទីលំនៅថ្មី

តាមកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សិទ្ធិមានលំនៅដ្ឋានសមរម្យ រួមបញ្ចូលទាំងសុវត្ថិភាពក្នុងការកាន់កាប់ក្នុងនោះមានដូចជាការការពារមិនឱ្យមានការបណ្តេញចេញដោយខុសច្បាប់ និងការវាយកំទេចនិងការបំផ្លិចបំផ្លាញ លំនៅដ្ឋានរបស់អ្នកណាម្នាក់តាមទំនើងចិត្ត។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏ហាមមិនឱ្យមានការជ្រៀតជ្រែករំខានដល់សិទ្ធិឯកជន គ្រួសារនិងលំនៅដ្ឋានតាមទំនើងចិត្ត ឬខុសច្បាប់ដែរ (មាត្រា១៧ (១))។

# ជំពូកទី៣ ៖ ក្របខ័ណ្ឌគតិយុត្តិ



គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទទួលបន្ទុកឃ្លាំមើលការអនុវត្តកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅក្នុង "សេចក្តីពន្យល់រួម ស្តីពី សិទ្ធិមានលំនៅដ្ឋានសមរម្យ ការបណ្តេញចេញដោយបំពាន"[២៣] បានកំនត់យ៉ាងច្បាស់នូវបទដ្ឋានអប្បបរមា ដែលតម្រូវឱ្យមានក្នុងការអនុវត្តការបណ្តេញចេញ ។ គណៈកម្មាធិការនេះបានកត់សម្គាល់ថា ប្រសិនបើការការពារតាមផ្លូវច្បាប់ និងតាមនីតិវិធីនេះមិនត្រូវបានគេគោរពតាមទេ យោងតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ការបណ្តេញចេញនោះ នឹងខុសច្បាប់ ហើយចាត់ទុកជា"ការបណ្តេញចេញដោយបំពាន"។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកខាងសិទ្ធិមានលំនៅដ្ឋានសមរម្យ បានបញ្ជាក់យ៉ាងច្បាស់ក្នុង "គោលការណ៍គ្រឹះ និងគោលការណ៍ណែនាំស្តីពីការ

## ប្រអប់លេខ១: កំណត់សម្គាល់អំពីពាក្យបច្ចេកទេស និងការបកប្រែ

ពាក្យ "eviction" ជាទូទៅត្រូវបានបកប្រែជាភាសាខ្មែរថា" ការបណ្តេញចេញ" ដែលពាក្យនេះក្លាយមកពីកិរិយាស័ព្ទថា "ដេញចេញ" មានន័យថា "ដេញនរណាម្នាក់ចេញ"។ វាបង្កប់អត្ថន័យអវិជ្ជមានស្រាប់ ដែលស្ទើរតែមិនចាំបាច់ត្រូវតែផ្ទៀងផ្ទាត់ន័យរបស់ពាក្យនេះជាមួយនឹងពាក្យច្បាប់" ការបណ្តេញចេញ" ក្នុងភាសាអង់គ្លេសទេ ហើយបើទោះបីជាការបណ្តេញចេញនោះស្របច្បាប់ និងមានហេតុផលសមស្របក៏ដោយ ក៏វាតែងតែផ្តល់នូវការឈឺចាប់។

មានអ្នកខ្លះ ឬស្ថាប័នខ្លះប្រើពាក្យ "ការផ្លាស់ប្តូរទីតាំងថ្មី" ជំនួសអោយពាក្យ "ការបណ្តេញចេញ" ដែលតាមន័យត្រង់មានន័យថា" ផ្លាស់ទៅទីតាំងថ្មី" ដូច្នេះហើយបើបកប្រែទៅជាភាសាអង់គ្លេសគួរតែប្រើជាពាក្យថា "relocation" វិញ។ ស្រដៀងគ្នានេះដែរ មានអ្នកខ្លះទៀតប្រើប្រាស់ពាក្យ "**ការតាំងទីលំនៅថ្មី** "ដែលមានន័យថា "ទៅតាំងទីលំនៅនៅក្នុងទីកន្លែងថ្មី" ហើយបកប្រែជាភាសាអង់គ្លេសថា "resettlement"។ ក្នុងខណៈដែល ការផ្លាស់ប្តូរទីតាំងថ្មី ឬការតាំងទីលំនៅថ្មី ដំណើរការទៅ ដោយត្រូវមានការបណ្តេញចេញ ក៏វាមិនមែនសុទ្ធតែមានការបណ្តេញចេញគ្រប់ករណីនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ពាក្យទាំងពីរនេះមិនបានបង្ហាញអោយបានក្បោះក្បាយពីដំណើរការដែលប្រជាពលរដ្ឋត្រូវគេបង្ខំឱ្យចាកចេញពីលំនៅដ្ឋានរបស់ពួកគាត់ទេ។ ពាក្យទាំងពីរនេះអាចត្រូវគេប្រើប្រាស់ជំនួសគ្នាទៅវិញទៅមកបាននៅក្នុងកម្រិតណាមួយ។ នៅក្នុងការសិក្សានេះយើងប្រើពាក្យ "ការតាំងទីលំនៅថ្មី" ដែលមានន័យបង្ហាញអំពីស្ថានភាពរយៈពេលវែង ដែលពាក់ព័ន្ធនឹង ការផ្លាស់ទៅទីតាំងថ្មី។ យើងប្រើពាក្យ "ការផ្លាស់ទីតាំង" ក្នុងន័យប្រាប់ជាក់លាក់អំពីសកម្មភាពនៃការផ្លាស់ទៅកន្លែងថ្មី។

ពាក្យជាភាសាអង់គ្លេសថា "forced eviction"នៅមិនទាន់មានការបកប្រែជាផ្លូវការជាភាសាខ្មែរនៅឡើយទេ។ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ផ្ទាល់ក៏បានជជែកគ្នាថា ពាក្យ "forced eviction" ក្នុងភាសាអង់គ្លេសដែលមានន័យជាភាសាខ្មែរថា "**ការបណ្តេញចេញ ដោយបំពាន**" មិនចាំបាច់គ្របដណ្តប់លើខ្លឹមសារទាំងអស់ដែលចេញពីអត្ថន័យច្បាប់នៃពាក្យនេះទេ ប៉ុន្តែពាក្យនេះត្រូវបានជ្រើសរើសយកមកប្រើប្រាស់ ដើម្បីកំនត់អោយឃើញពីអត្ថន័យផ្សេងពីការបណ្តេញចេញទាំងឡាយណាដែលអាចស្របច្បាប់ និងតាមច្បាប់អន្តរជាតិ។ ដោយសារតែការសិក្សានេះមិនផ្តោតជាសំខាន់ទៅលើទិដ្ឋភាពគតិយុត្តនៃការបណ្តេញចេញ ដូច្នេះពាក្យ "ការបណ្តេញចេញ"

[២៣] គណៈកម្មាការសិទ្ធិសេដ្ឋកិច្ច វប្បធម៌និងសង្គមកិច្ច, សេចក្តីពន្យល់រួមលេខ ៧ស្តីពីសិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ(មាត្រា១១(១))ការបណ្តេញចេញដោយបំពាន E/1998/22 ឧបសម្ពន្ធ័IV [CESCR សេចក្តីពន្យល់រួមលេខ៧]

បណ្តេញចេញនិងការចាកចេញដោយបង្ខំចិត្ត ផ្អែកលើគម្រោងអភិវឌ្ឍន៍" (២០០៧) របស់គាត់ដោយបង្ហាញយ៉ាងជាក់លាក់ពីបញ្ហាសិទ្ធិមនុស្ស កើតចេញពីការបណ្តេញ ចេញ និង ការចាកចេញដោយបង្ខំចិត្តផ្អែកលើការអភិវឌ្ឍន៍។[២៤]

គោលការណ៍ណែនាំទាំងពីរ ខាងលើផ្តល់នូវមូលដ្ឋានវិធីសាស្រ្ត និងមូលដ្ឋានច្បាប់ សំរាប់ការសិក្សានេះ។

បទដ្ឋានអន្តរជាតិ តម្រូវឱ្យអាជ្ញាធរអនុវត្តតាមគោលការណ៍នៃការពារតាមផ្លូវច្បាប់ និង តាមនីតិវិធីម៉ត់ចត់ដើម្បីធានាអោយបានថា ការបណ្តេញចេញប្រព្រឹត្ត ទៅដោយមិនមានការរំលោភសិទ្ធិមនុស្សរបស់ជនទាំងឡាយ ដែលរងផលប៉ះពាល់ និង ដើម្បីគោរពតាមគោលការណ៍នៃនីតិវិធីត្រឹមត្រូវ ភាពសមហេតុផល និង ភាពសមាមាត្រ។ ការការពារតាមផ្លូវច្បាប់ និងតាមនិតិវិធី មានទាំងការផ្តល់ឱកាស ឱ្យមានការពិគ្រោះយោបល់ត្រឹមត្រូវពិតប្រាកដ ចៀសវាងបានការប្រើកម្លាំងគ្មានភាពសមាមាត្រ សេចក្តីជូនដំណឹងត្រូវមានមូលហេតុច្បាស់លាស់ និងពេលវេលាគ្រប់គ្រាន់ និងលទ្ធភាពរកដំណោះស្រាយតាមផ្លូវច្បាប់។ លើសពីនេះទៀត លទ្ធផលនៃការបណ្តេញចេញមិនត្រូវនាំឱ្យប្រជាជនក្លាយទៅជាពលរដ្ឋគ្មានផ្ទះសំបែងរស់នៅ ឬធ្លាក់ក្នុងស្ថានភាពយ៉ាប់យ៉ឺនជាង ពីពេលមុនមានការបណ្តេញចេញទេ។ នៅឯកន្លែងតាំងលំនៅថ្មីត្រូវតែធានាឱ្យមានស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ និងសេវាអប្បបរមា។

សុវត្ថិភាពខាងការកាន់កាប់ដីធ្លី ក៏ត្រូវបានគេដាក់បញ្ចូលទៅក្នុង គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ក្រោមគោលដៅទី៧ដែរ (និរន្តរភាពបរិស្ថាន)។[២៥]

## ការប្តេជ្ញា និងតព្វកិច្ចក្រោមច្បាប់ជាតិ

ដូចរដ្ឋដទៃទៀតដែរ កម្ពុជាមានកាតព្វកិច្ចច្បាប់ ត្រូវអនុវត្តសន្ធិសញ្ញាអន្តរជាតិនានា ដែលខ្លួនបានផ្តល់សច្ចាប័ន។ គោលការណ៍គ្រឹះ និងកាតព្វកិច្ចច្បាប់នេះ ត្រូវបានបញ្ជាក់ជាថ្មីនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ កម្ពុជា។ មាត្រា ៣១ បញ្ចូលសន្ធិសញ្ញាសិទ្ធិមនុស្សនានា ដែលកម្ពុជាបានផ្តល់សច្ចាប័ន ជាច្បាប់ជាតិរបស់ខ្លួន។ ក្នុងនាមជាភាគីមួយនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (ICESCR) និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) និង សន្ធិសញ្ញាសិទ្ធិមនុស្សដទៃទៀត រដ្ឋាភិបាល បានសន្យាធានាការពារសិទ្ធិមានលំនៅដ្ឋានសមរម្យ និង ការការពារប្រឆាំងការជ្រៀតជ្រែករំខានតាមទំនើងចិត្ត ដល់សិទ្ធិលំនៅដ្ឋានរបស់បុគ្គល ត្រូវបានទទួលស្គាល់នៅក្នុងសន្ធិសញ្ញាទាំងនេះ។ ការសន្យានេះ ក៏ត្រូវបាន បញ្ជាក់ជាថ្មីផងដែរ នៅក្នុងសេចក្តីព្រាងគោលនយោបាយជាតិស្តីពីលំនៅដ្ឋាន ដែលមាននៅក្នុងសេចក្តីផ្តើមនៃសេចក្តីព្រាងគោលនយោបាយនេះ ៖ រដ្ឋាភិបាលកម្ពុជា សន្យាអនុវត្តគោលការណ៍សិទ្ធិមនុស្ស ជា

---

[២៤] អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីលំនៅដ្ឋានសមរម្យជាផ្នែកនៃសិទ្ធិមានជីវភាពសមរម្យ និងស្តីពីសិទ្ធិមិនរើសអើងនៅក្នុងបរិបទនេះ គោលការណ៍គ្រឹះនិងគោលការណ៍ណែនាំស្តីពី ការបណ្តេញចេញ និងការចាកចេញដោយបង្ខំចិត្ត ផ្អែកលើគម្រោងអភិវឌ្ឍន៍ A/HRC/4/18 ឧបសម្ព័ន្ធទី ១] ចាប់ពីពេលនេះតទៅ ៖ គោលការណ៍ណែនាំជាមូលដ្ឋាន របស់អ្នករាយការណ៍ពិសេស[។

[២៥] សូមមើលគោលដៅទី១១ (ការពង្រឹងគុណភាពជីវិតរបស់ប្រជាជនយ៉ាងហោចណាស់១០០លាននាក់រស់នៅតាម សំណង់មិនរៀបរយ) និងសន្ទស្សន៍៣១(សមាមាត្រនៃប្រជាជនដែល មានសុវត្ថិភាពខាងការកាន់កាប់ដីធ្លី)។ http://www.undp.org/mdg/goal7.shtml

ពិសេស “សិទ្ធិមានលំនៅដ្ឋានសមរម្យ” សំរាប់ប្រជាពលរដ្ឋគ្រប់រូបដោយបង្កើតយុទ្ធសាស្រ្តផ្សេងៗ [...] សំដៅធានា សិទ្ធិមានលំនៅដ្ឋានសមរម្យសំរាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ជាពិសេស ក្រុមប្រជាពលរដ្ឋក្រីក្រ និង ក្រុមដែល ងាយរងគ្រោះ”។[២៦] សេចក្តីព្រាងគោលនយោបាយជាតិស្តីពីលំនៅដ្ឋាននេះ ផ្អែកលើគោលការណ៍ណែនាំដូចតទៅ ៖

ក. ដោះស្រាយសេចក្តីត្រូវការនៅថ្ងៃអានាគតសំរាប់សំណង់លំនៅដ្ឋានថ្មី ដោយផ្តោតជាពិសេសលើគ្រួសារ ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប និង មធ្យម និង ក្រុមដែលងាយរងគ្រោះ ។

ខ. អនុញ្ញាតឲ្យសហគមន៍ និង អ្នកតាំងទីលំនៅមិនរៀបរយ កាន់កាប់ទីតាំងរបស់ខ្លួន សំរាប់រយៈពេលមួយជាក់លាក់ដើម្បីសិក្សាស្ថានភាពជាក់ស្តែងនៅកន្លែងតាំងទីលំនៅបណ្តោះអាសន្ននីមួយៗ ។

គ. ពិនិត្យការឲ្យទៅតាំងទីលំនៅថ្មី ជាជំរើសចុងក្រោយបំផុត ដែលត្រូវអនុវត្តស្របតាមគោលការណ៍ អភិបាលកិច្ចល្អ (ការចូលរួម តម្លាភាព គណនីយភាព និរន្តរភាព )។

ឃ. គាំទ្រ និងផ្តល់សិទ្ធិអំណាចឲ្យប្រជាពលរដ្ឋ និង សហគមន៍មូលដ្ឋាន ចូលរួម

ង. បញ្ចូលគំរោងតាំងទីលំនៅថ្មី ក្នុងផែនការប្រើប្រាស់ដី ឃុំ/សង្កាត់ និង ក្រុង/ទីប្រជុំជន។

ច. ធានានិរន្តរភាពសង្គម វចនាសម្ព័ន្ធ និង ការប្រព្រឹត្តទៅនៃកន្លែងតាំងទីលំនៅចាស់ និង ថ្មី ។

ឆ. បង្កើតគំរោងលំនៅដ្ឋានជាមូលដ្ឋាន ក៏ដូចជាបទដ្ឋានសេវា និង ហេដ្ឋារចនាសម្ព័ន្ធ ក្នុងករណីនៃការតាំងទីលំនៅជាបណ្តោះអាសន្ន ដោយសហការជិតស្និទ្ធិជាមួយសហគមន៍នានា។[២៧]

ច្បាប់ជាតិនៃព្រះរាជាណាចក្រកម្ពុជាមានបញ្ញត្តិ ស្តីពីកិច្ចការពារមិនឱ្យមាន ការបណ្តេញចេញដោយបំពាន និង ការដកហូតសិទ្ធិទ្រព្យសម្បត្តិដោយខុសច្បាប់បន្ថែមទៀត។ ទាំងរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់ភូមិបាលឆ្នាំ២០០១ ទទួលស្គាល់សិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យ ។ ការដកហូតសិទ្ធិដីធ្លីឬទ្រព្យសម្បត្តិអាចប្រព្រឹត្តទៅបានតែដើម្បីផលប្រយោជន៍ សាធារណៈប៉ុណ្ណោះ និង ទៅតាមល័ក្ខខ័ណ្ឌតម្រូវឱ្យមាន សំណងសមរម្យ និង យុត្តិធម៌ជាមុន។[២៨] ការកាន់កាប់លើដីឯកជនរបស់រដ្ឋដោយសន្តិវិធី និង គ្មានការជំទាស់ (ដែលអាចជាការកាន់កាប់ស្របច្បាប់) រយៈពេលតិចបំផុតប្រាំឆ្នាំមុនពេលអនុម័តច្បាប់ភូមិបាលឆ្នាំ២០០១ នាំឱ្យមានសិទ្ធិ“ភោគៈ” ហើយភោគីមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ។[២៩] ច្បាប់ភូមិបាល ក៏បានការពារបន្ថែមលើភោគីស្របច្បាប់ ពីការការជ្រៀតជ្រែកលើសិទ្ធិភោគៈ រហូតដល់ទទួលបានសិទ្ធិជាកម្មសិទ្ធិករពេញលេញ។ ជាការពិត មាត្រា២៤៨ ហាមរាល់អំពើប្រព្រឹត្តរាំងអ្នកកាន់កាប់ដោយសន្តិវិធី នៅក្នុងតំបន់ដែលមិនទាន់មានប្លង់សុរិយោដី។ *អានុភាពនៃបទប្បញ្ញត្តិនេះគឺ រហូតដល់ពេលដែល សិទ្ធិកាន់កាប់ដោយសន្តិវិធី មិនទាន់ត្រូវបានកំណត់ឃើញនៅឡើយ នោះមិនមានការបណ្តេញចេញណាមួយ*

[២៦] លេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី សេចក្តីព្រាងលើកទី២ គោលនយោបាយជាតិស្តីពីលំនៅដ្ឋាន ថ្ងៃទី០២ខែមិនា ឆ្នាំ២០១០ ពិគ្រោះយោបល់ជាសាធារណៈថ្ងៃទី២៤ ខែមិនា ឆ្នាំ២០១០ សេចក្តីព្រាងស្ថិតនៅក្នុងការពិនិត្យដោយទីស្តីការគណៈរដ្ឋមន្ត្រី

[២៧] សេចក្តីព្រាងគោលនយោបាយជាតិស្តីពីលំនៅដ្ឋាន បញ្ជាក់ខាងលើ ទំព័រ៤

[២៨] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ (ត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ១៩៩៩) មាត្រា៤៤ និង ច្បាប់ភូមិបាល ឆ្នាំ ២០០១ មាត្រា៤ និង៥។

[២៩] ច្បាប់ភូមិបាល ឆ្នាំ ២០០១ មាត្រា៣០។ ភោគៈត្រូវតែបំពេញគ្រប់គ្រាន់នូវលក្ខណៈវិនិច្ឆ័យប្រាំចំណុចគឺ ការកាន់កាប់ដោយគ្មានអាក់ខាន ដោយសន្តិវិធី ដោយសុចរិត ដោយពិតប្រាកដ និងដឹងឮជាសាធារណៈ (មាត្រា៣៨)។ មាត្រា១៦ និង៤៣ ចែងពីល័ក្ខខ័ណ្ឌដែល មិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិ។

*ដែលស្របច្បាប់ទេ។*

ច្បាប់អស្សាមិករណ៍ ត្រូវបានអនុម័តកាលពីខែកុម្ភៈ ឆ្នាំ២០១០។ ច្បាប់នេះបានកំនត់ពីសំណាងសមរម្យនិងយុត្តិធម៌ ត្រូវផ្តល់ជាមុនឱ្យកម្មសិទ្ធិករហើយត្រូវតាមតម្លៃទីផ្សារ ឬក៏តម្លៃជំនួស (ដែលក្នុងមាត្រា៩បានរាប់បញ្ចូលទាំង "ភោគី") ដូច្នេះរឹតតែពង្រឹងដល់ការការការពារសិទ្ធិទាំងនេះ ដែលមានចែងនៅក្នុងច្បាប់ភូមិបាលស្រាប់។ ច្បាប់នេះក៏កំណត់កម្រិតដល់ការដកហូតទ្រព្យសម្បត្តិ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ចំពោះតែក្នុងករណីដែលបំពេញបាន និយមន័យនៃ "ប្រយោជន៍សាធារណៈ" (មាត្រា៥)។ នៅខែឧសភា ឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តសារាចរ លេខ ០៣ ស្តីពី "ការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន"។ សារាចរនេះផ្តល់ដំណោះស្រាយ ដែលគាំទ្រដល់ការអភិវឌ្ឍន៍ តំបន់ក្រីក្រតាមទីប្រជុំជន ដែលត្រូវគេចាត់ទុកថា តាំងទីលំនៅខុសច្បាប់ និង កំណត់បទដ្ឋានអប្បបរមាសម្រាប់ទីតាំងនៃការតាំងទីលំនៅថ្មី។

ក៏ប៉ុន្តែ ច្បាប់នេះមិនបានចែងពីកិច្ចការពារតាមផ្លូវច្បាប់គ្រប់គ្រាន់ សម្រាប់ការតាំងទីលំនៅថ្មីនៅឡើយ។ គោលនយោបាយស្តីពីលំនៅដ្ឋាន ក៏កំពុងត្រូវបានតាក់តែងជាសេចក្តីព្រាងដែរ។ សេចក្តីព្រាងចុងក្រោយបំផុត នៃគោលនយោបាយនេះដែលបង្ហាញជាសាធារណៈ មានចែងសេចក្តីយោងអំពីសិទ្ធិមានលំនៅដ្ឋានសមរម្យ និង បង្ហាញពីជម្រើសជាច្រើនសម្រាប់ធានាសុវត្ថិភាពខាងការកាន់កាប់ និងមានលំនៅដ្ឋានសមរម្យ។

មាត្រា៣១នៃរដ្ឋធម្មនុញ្ញ បានចែងកាន់តែទូលំទូលាយថែមទៀតថា ប្រជាពលរដ្ឋគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ និង មានសិទ្ធិសេរីភាព និងករណីកិច្ចដូចៗគ្នា ដោយឥតប្រកាន់ពីស្ថានភាពផ្សេងៗឡើយ។ រដ្ឋធម្មនុញ្ញក៏ចែងអំពីកាតព្វកិច្ចរបស់រាជរដ្ឋាភិបាល ក្នុងការធានាសិទ្ធិកុមារ និងស្ត្រី ពោលគឺសិទ្ធិទទួលបានការអប់រំ និងសិទ្ធិទទួលបានការថែទាំសុខភាព និងត្រូវចាត់វិធានការខាងសង្គមកិច្ចមួយចំនួន ដើម្បីលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា។ កាតព្វកិច្ចទាំងនេះពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងដំណើរការនៃការតាំងទីលំនៅថ្មី។

៤

# ដំណើរការមុនពេលបណ្តេញចេញ និងសកម្មភាពក្នុងពេលបណ្តេញចេញ

ជំពូកនេះនឹងពិនិត្យលមើលដំណើរការនានាដែលកើតឡើងមុនពេល និងក្នុងអំឡុងពេលបណ្តេញចេញ។ មានករណីភាគច្រើនក្រោមការសិក្សានេះ បង្ហាញថាការបណ្តេញចេញបានធ្វើឱ្យមានឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងទៅលើក្រុមគ្រួសារដែលរងផលប៉ះពាល់។

- ផ្នែកទី៤.១ ពិភាក្សាអំពី ហេតុផលផ្តល់ដោយអាជ្ញាធរដើម្បី អនុវត្តការបណ្តេញចេញ។ ក្នុងករណីខ្លះ បង្ហាញថាប្រជាពលរដ្ឋជាច្រើនគ្រួសារត្រូវបានបណ្តេញចេញមុនពេលដែលអាជ្ញាធរពាក់ព័ន្ធបានពិនិត្យឱ្យបានត្រឹមត្រូវល្អិតល្អន់អំពីស្ថានភាពគតិយុត្តិនៃដី និងការអះអាងរបស់គ្រប់ភាគីទាំងអស់។

- ផ្នែកទី៤.២ ពិនិត្យលើលក្ខណៈនៃការអនុវត្តការបណ្តេញចេញ ដោយប្រៀបធៀបទៅនឹងបទដ្ឋានអន្តរជាតិ។ ដោយសារតែការបណ្តេញចេញអាចងាយបង្កឱ្យមានអំពើហិង្សា ឬក៏ការរងរបួសផ្សេងៗ ការគោរពការការពារតាមនីតិវិធីពិតជាមានភាពចាំបាច់ណាស់ ដូចជា ការផ្តល់នូវឱកាសសម្រាប់ពិគ្រោះយោបល់ពិតប្រាកដ ការចៀសវាងពីការប្រើប្រាស់កម្លាំងមិនសមាមាត្រ ការផ្តល់សេចក្តីជូនដំណឹងដែលមានលក្ខណៈគ្រប់គ្រាន់ និងមានមូលហេតុត្រឹមត្រូវ និងការធានានូវលទ្ធភាពរកដំណោះស្រាយតាមផ្លូវច្បាប់ជាដើម។ ឧទាហរណ៍ជាក់ស្តែងមួយចំនួននៃការបណ្តេញចេញដែលខ្វះការការពារបែបនេះត្រូវបានលើកយកមកពិភាក្សា។

- ផ្នែកទី៤.៣ ពិនិត្យមើលថា តើសហគមន៍ដែលទទួលរងផលប៉ះពាល់ អាចរកបានដំណោះស្រាយតាមផ្លូវច្បាប់ដែរឬទេ និងតើមានការផ្តល់សំណងសម្រាប់ ការបាត់បង់ដីធ្លី ឬក៏ទ្រព្យសម្បត្តិ ដោយរបៀបណាខ្លះ។

- ផ្នែកទី៤.៤ ពិភាក្សាអំពីរបៀបដែលសមាជិកសហគមន៍ និងអ្នកតំណាងសហគមន៍ត្រូវបានគេបំភិតបំភ័យក្នុងអំឡុងពេលនៃកិច្ចចរចា និងទទួលការចោទប្រកាន់ ចាប់ខ្លួន និងឃុំខ្លួន។

- ផ្នែកទី៤.៥ ពិនិត្យអំពីការចូលរួមរបស់សហគមន៍ (ឬក៏ខ្វះការចូលរួម) ក្នុងដំណើរការនៃការបណ្តេញចេញ ឬក៏ការតាំងទីលំនៅថ្មី។

   

# ជំពូកទី៤
# ដំណើរការមុនពេលបណ្តេញចេញនិងសកម្មភាពក្នុងពេលបណ្តេញចេញ

ករណីបណ្តេញចេញភាគច្រើនបំផុត ដែលត្រូវបានវាយតម្លៃក្នុងការសិក្សានេះ មានឥទ្ធិពលជាអវិជ្ជមាន ទៅលើសហគមន៍ដែលទទួលរងផលប៉ះពាល់។ ក្នុងករណីជាច្រើន ការបណ្តេញចេញមានពាក់ព័ន្ធនឹងការបង្ខិតបង្ខំ និងការបំភិតបំភ័យ។ ការការពារតាមនីតិវិធី មិនត្រូវបានគោរពទេ។ ការចូលរួមពីសហគមន៍ត្រូវបានហាមឃាត់។ មធ្យោបាយនៃការដោះស្រាយសំណងខូចខាត និងយន្តការដែលមានស្រាប់សម្រាប់ដោះស្រាយជម្លោះដីធ្លី មិនបានផ្តល់នូវដំណោះស្រាយសម្រាប់សហគមន៍ដែលទទួលរងគំរាមកំហែងពីការបណ្តេញចេញទាំងនោះទេ។ ជាការពិត ករណីមួយចំនួនតូចមានរឿងរ៉ាវផ្ទុយពីនេះបានកើតឡើង ដោយតុលាការតាមចោទប្រកាន់សមាជិកសហគមន៍អំពីបទព្រហ្មទណ្ឌ នៅពេលដែលពួកគាត់កំពុងតែព្យាយាមការពារសិទ្ធិកាន់កាប់ដីធ្លីដែលពួកគាត់កំពុងរស់នៅ។ សូមមើលការរៀបរាប់របស់ស្រ្តីម្នាក់ដែលត្រូវគេបណ្តេញចេញពីលំនៅដ្ឋានរបស់គាត់នៅស្ពានឆេះ៖

"ខ្ញុំអស់សង្ឃឹមខ្លាំងណាស់ តឹងទ្រូង ហើយឈឺចាប់ចំពោះរឿងរ៉ាវដែលកើតឡើងចំពោះ ពួកខ្ញុំ។ ការបណ្តេញចេញប្រព្រឹត្តទៅយ៉ាងសាហាវដោយមិនអាចរកពាក្យអ្វីមកនិយាយរ៉ាយរ៉ាប់បាន។ ផ្ទះ និងរបស់របរ ដែលរកបានមកពីការខិតខំធ្វើការតាំងពីបាទដៃទទេ និងដោយញើសឈាម របស់យើង ជិត ២០ឆ្នាំមកហើយនោះ ត្រូវបានកងកម្លាំងប្រដាប់អាវុធវាយកំទេចចោលអស់ នៅក្រោមក្រសែភ្នែករបស់ពួកយើង ក្នុងរយៈពេលតែពីរ-បីម៉ោងតែប៉ុណ្ណោះ។ គេវាយពួកយើងនិងឆក់ខ្សែភ្លើងពួកយើង។ ពួកយើងជាច្រើននាក់ត្រូវគេចាប់ដាក់គុក។ រាល់ថ្ងៃខ្ញុំព្រួយបារម្ភណាស់ ដោយសារពួកយើងរស់នៅតាមចិញ្ចើមផ្លូវ ពួកយើងរកចំណូលបានមិនគ្រប់គ្រាន់សម្រាប់ការរស់នៅទេ ហើយពួកយើងមិនមានអាហារគ្រប់គ្រាន់សម្រាប់ហូបទេ។"

ចាន់ ជាស្រ្តីវ័យចំណាស់អាយុ៥៤ឆ្នាំ មកពីសហគមន៍ស្ពានឆេះ ខេត្តព្រះសីហនុ។[៣០]

## ៤.១ ហេតុផលសំអាងសំរាប់ការបណ្តេញចេញ

តាមការពិនិត្យនៅក្នុងការសិក្សានេះបានឱ្យដឹងថា អាជ្ញាធររដ្ឋាភិបាលផ្តល់ហេតុផលផ្សេងៗយ៉ាងច្រើនជាសំអាងសំរាប់ការបណ្តេញចេញ ឬការ

[៣០] ឈ្មោះពិតរបស់សមាជិកក្នុងសហគមន៍នេះ និងសហគមន៍ផ្សេងទៀតដែលត្រូវបានសម្ភាសន៍ នៅក្នុងរបាយការណ៍នេះ ត្រូវបានជំនួសដោយឈ្មោះមិនពិត ដើម្បីការពារអត្តសញ្ញាណរបស់ពួកគាត់។

ផ្លាស់ប្តូរទីតាំងថ្មី។ ហេតុផលដែលអជ្ញាធរ លើកឡើងជាញឹកញាប់នោះគឺ ប្រជាពលរដ្ឋរស់នៅលើដីសាធារណៈរបស់រដ្ឋ ដូចជាក្នុង ករណីដីក្រហម[៣១] ឬថា គេត្រូវការដីដើម្បីប្រើជាប្រយោជន៍សាធារណៈ ឬសម្រាប់ធ្វើជាស្ថាប័នរដ្ឋាភិបាល ដូចជា ករណីបុរីកីឡា[៣២] និង ក្រុម៧៨ នៅរាជធានីភ្នំពេញ និង ករណី ចំនុចក្បាលហុង នៅខេត្តព្រះសីហនុ។[៣៣]

ក្រុម៧៨ បានទទួលសេចក្តីជូនដំណឹងទាំងអស់ចំនួន៦លើក ដែលសេចក្តីជូនដំណឹងនោះ និយាយយោងទៅលើការអភិវឌ្ឍន៍ ដើម្បីប្រយោជន៍សាធារណៈ។ ជាឧទាហរណ៍ សេចក្តីជូនដំណឹងដែលចុះថ្ងៃទី១៤ និង ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៦ បានបញ្ជាក់ថា គោលបំណងនៃការរុះរើនោះគឺដើម្បី "រៀបចំអភិវឌ្ឍន៍ប្រព័ន្ធលូឱ្យបានល្អ ពង្រីកផ្លូវ រៀបចំដាក់ភ្លើងបំភ្លឺផ្លូវ រៀបចំសួនច្បារ កែលំអរបរិដ្ឋាន និងរៀបចំសោភ័ណភាពសម្រាប់ទេសចរណ៍" ក៏ដូចជាផ្តល់ហេតុផលថា តំបន់នោះស្ថិតនៅតាមមាត់ទន្លេ និង នៅជិតក្រសួងសំខាន់ៗ[៣៤]។ ហេតុផលដូចគ្នានេះមួយទៀតគឺថា "ចាំបាច់ត្រូវតែធ្វើការរុះរើ "សម្រាប់ការអភិវឌ្ឍន៍" ឬក៏ "សម្រាប់ការកែលំអរសោភ័ណភាពទីក្រុង។"[៣៥]

រាជរដ្ឋាភិបាលកម្ពុជា មានសិទ្ធិគ្រប់បែបយ៉ាងក្នុងការជំរុញការអភិវឌ្ឍន៍ ទៅតាមក្របខ័ណ្ឌច្បាប់ ក៏ប៉ុន្តែ រាជរដ្ឋាភិបាលក៏ត្រូវតែ អនុវត្តដោយគោរពកិច្ចការពារខាងនីតិវិធី ហើយការដកហូតសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិពី កម្មសិទ្ធិករ ឬ ភោគី អាចធ្វើបានតែ ដើម្បីផលប្រយោជន៍សាធារណៈតំរូវប៉ុណ្ណោះដូចដែលបានកំណត់ដោយរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីអស្សាមិករណ៍។ ក្នុងករណីជាច្រើន ដែលបានពិនិត្យ ទោះបីជាការបណ្តេញចេញត្រូវបានធ្វើឡើងទៅតាមហេតុផលដូចមាន អះអាងមែនថា សំរាប់ប្រយោជន៍សាធារណៈ ឬថាដីនោះជាដីសាធារណៈរបស់រដ្ឋ តែក្រោយមកគេឃើញថាដីនោះត្រូវគេយកទៅធ្វើជាប្រយោជន៍ឯកជន។ ឧទាហរណ៍ ក្រុមហ៊ុន7NG ទទួលបានដីក្រហម ហើយក្រុមហ៊ុនសួរ ស្រ៊ុន ទទួលបានដីតំបន់សំបុកចាប។ ដីពីរកន្លែងនេះនៅទំនេររហូតដល់បច្ចុប្បន្ន។

ក្នុងករណីខ្លះទៀត គេអះអាងថា ដីនោះពិតជាកម្មសិទ្ធិរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ឯកជនឬជារបស់បុគ្គលទៅវិញ ដូចជានៅក្នុងសេចក្តីជូនដំណឹងលើក



[៣១] យោងតាមរាជរដ្ឋាភិបាកម្ពុជា ទីតាំងតំបន់ដីក្រហមគឺជាដីសាធារណៈរបស់រដ្ឋ ដោយសារវាស្ថិតនៅក្បែរស្ថាប័នរដ្ឋាភិបាលសំខាន់ៗ និងនៅក្នុងតំបន់ទេសចរណ៍។ កាលពីពេលកន្លងមក ទីតាំងនេះត្រូវបានប្រើប្រាស់សម្រាប់ប្រព្រឹត្តសកម្មភាពល្មើស ដែលបង្កផលប៉ះពាល់ដល់សន្តិសុខមូលដ្ឋាន និងសណ្តាប់សង្គម។ របាយការណ៍ប្រចាំឆ្នាំ ២០០៨-២០០៩ OHCHR ប្រចាំកម្ពុជា, ដោយមាន សេចក្តីពន្យល់ ដោយរាជរដ្ឋាភិបាលកម្ពុជា ទំព័រទី៤៨។

[៣២] ក្រុមគ្រួសារប្រជាពលរដ្ឋនៅបុរីកីឡា អ្នកដែលរស់នៅ" ផ្ទះខៀវ" ត្រូវគេប្រាប់អោយផ្លាស់ទៅរស់នៅទីតាំងថ្មី នៅទួលសំបូរ ព្រោះថា ផ្ទះខៀវនេះស្ថិតនៅលើដី របស់ក្រសួងទេសចរណ៍។

[៣៣] មុនពេល សហគមន៍ធ្វើការផ្លាស់ប្តូរទីលំនៅទៅអូរកម្ពុជា កងទ័ពជើងទឹកបានអះអាងថា ដីដែលសហគមន៍ក្បាលហុងកាន់កាប់ជាដី របស់អង្គភាពកងទ័ពជើងទឹក ហើយក្រសួងការពារជាតិត្រូវការដីនេះ ដើម្បីកសាងសាលាកងទ័ពជើងទឹក។

[៣៤] សេចក្តីជូនដំណឹងលេខ ០៦០/០៦ និងលេខ០៦២/០៦ ដែលលិខិតទាំងពីរនេះចុះហត្ថលេខាដោយសាលាខ័ណ្ឌចំការមន

[៣៥] កាសែតភ្នំពេញប៉ុស្ត៍ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៩ បានដកស្រង់សំដីឯ.ឧ .ម៉ាន់ ឈឿន អភិបាលរងសាលារាជធានីភ្នំពេញ ដែលមានប្រសាសន៍ថា: "សកម្មភាពនៃការ រុះរើលំនៅដ្ឋាននៅឯតំបន់ដីក្រហម ពុំមែនជាការបណ្តេញចេញទេ ប៉ុន្តែជាការខិតខំ ប្រឹងប្រែងសម្អាតទីតាំងដើម្បីអភិវឌ្ឍន៍" សាលាក្រុង ក្រុមហ៊ុនអភិវឌ្ឍន៍ កំទេចលំនៅដ្ឋាននៅតំបន់ដីក្រហម '។ ករណីក្រុម៧៨ ក្នុងសេចក្តីជូនដំណឹងលើកទី១របស់សាលារាជធានី និយាយយោងទៅលើ សេចក្តីត្រូវការ កែលម្អសោភ័ណភាពទីក្រុង) សេចក្តីជូន ដំណឹងលេខ០៥៥/០៦ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ ចេញដោយសាលាខ័ណ្ឌចំការមន( តែនៅទីបំផុត ដីត្រូវបានដាក់បញ្ចូលជា ផ្នែកនៃការសាងសង់ផ្លូវថ្មីទៅកាន់ តំបន់អភិវឌ្ឍន៍ លំនៅដ្ឋានទំនើបនៅលើកោះពេជ្រ។

[៣៦] សេចក្តីជូនដំណឹងពីការបណ្តេញចេញលើកទីប្រាំមួយ បានបញ្ជាក់ថា ផ្នែកខ្លះនៃដីដែលប្រជាពលរដ្ឋក្រុម៧៨ បានរស់នៅ "ជាកម្មសិទ្ធិ របស់ក្រុមហ៊ុន សួរ ស្រ៊ុន" ចំណែកឯដីដែលនៅសល់គឺជា"ផ្លូវសាធារណៈ" ។ សេចក្តីជូនដំណឹងដោយអភិបាលរាជធានីភ្នំពេញ លេខ ១៩ ស.ច.ណ.ស ,ចុះថ្ងៃទី

ទី៦អំពីការរុះរើលំនៅដ្ឋាន ប្រជាពលរដ្ឋក្រុម៧៨[៣៦] ក៏ដូចជាករណីសហគមន៍មន្ទីរពេទ្យមុនីវង្ស ក្នុងសង្កាត់ផ្សារថ្មី៣ ខ័ណ្ឌដូនពេញ សហគមន៍ចុងជ្រោយនៅជ្រោយចង្វា ខ័ណ្ឌឫស្សីកែវ[៣៧] និងសហគមន៍ស្ពានឆេះ នៅខេត្តព្រះសីហនុ។[៣៨]

ការបណ្តេញប្រជាពលរដ្ឋក្រីក្រ ដែលរស់នៅតំបន់សំណង់ក្រីក្រ ឬ មិនរៀបរយ ឬ " ការតាំងទីលំនៅក្រៅ ផ្លូវការ" ជារឿយៗត្រូវបានលើកបដិសេធដោយសំអាងកំណត់ថាតើពួកគាត់មាន ឬគ្មានសិទ្ធិស្របច្បាប់លើដីធ្លីដែលពួក គាត់រស់នៅ។ សហគមន៍នានា ដែលជាគោលដៅនៃការបណ្តេញចេញ ជូនកាលត្រូវបានគេនិយាយបង្កាច់បង្ខូចថាជា "អ្នកតាំងទីលំនៅខុសច្បាប់" "អ្នកតាំងទីលំនៅអនាធិបតេយ្យ" "ពួកអនាធិបតេយ្យ" ហើយថាអោយស្លាក ការតាំងទីលំនៅរបស់ជាពួកគាត់បង្កភាពអសីលធម៌ ដូចជា បទល្មើស អំពើពេស្យាចារ និងការប្រើប្រាស់សារធាតុញៀន និង ការជួញដូរមនុស្ស ជាដើម។ ទន្ទឹមនឹងនេះមានករណីជាច្រើនដែលប្រជាពលរដ្ឋមួយចំនួន បានព្យាយាមប្រើប្រាស់ករណីទំនាស់ដីធ្លីទាំងនេះ ដើម្បីស្វែងរកប្រយោជន៍មិនសមស្របក្នុងរូបភាពជាសំណង ក៏គេសង្កេតឃើញមានករណីជាច្រើន ដែលអ្នកភូមិ អាចបង្ហាញភស្តុតាងពីសិទ្ធិភោគ:ស្របច្បាប់ បើទោះជាមិនមានសិទ្ធិជាម្ចាស់ក្តី ក៏គប្បីទទួលការការបណ្តេញចេញតាមទំនើងចិត្តដែរ។

ការសិក្សានេះមិនមានគោលបំណងពិនិត្យស៊ីជម្រៅ ឬធ្វើការវិនិច្ឆ័យលើ នីត្យានុកូលភាពនៃការបណ្តេញចេញ និង ហេតុផលសំអាងសំរាប់ការបណ្តេញចេញនោះទេ។ ថាតើការបណ្តេញចេញប្រព្រឹត្តឡើងដោយផ្ទុយ ឬមិនផ្ទុយនឹងមាត្រា៥ នៃច្បាប់ភូមិបាល (ដែលផ្តល់នូវការធានាការពារដល់ម្ចាស់កម្មសិទ្ធិ) ឬមាត្រា២៤៨ (ដែលផ្តល់ការធានាការពារដល់ភោគី) នេះគឺត្រូវពិនិត្យមើលទៅតាមករណីនិមួយៗ ហើយដែលជាការទទួលខុសត្រូវរបស់អាជ្ញាធរពាក់ព័ន្ធ ដូចជា តុលាការ និងគណ:កម្មការសុរិយោដី។ ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បាននិងកំពុងធ្វើការលើករណីជាច្រើន ដែលស្ថានភាពផ្នែកច្បាប់មានលក្ខណ:មិនច្បាស់លាស់ ទាក់ទងនឹងដីធ្លី និងលំនៅដ្ឋាន ដូច្នេះជំរុញឱ្យអាជ្ញាធរមានសមត្ថកិច្ចផ្អាកការបណ្តេញចេញសិន រហូតដល់មានការកំណត់ពីស្ថានភាពផ្លូវច្បាប់ច្បាស់លាស់។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ការវាយតម្លៃដើម្បីកំណត់ពីស្ថានភាពផ្លូវច្បាប់នេះមិនត្រូវបានធ្វើឡើងទេ នៅក្នុងករណីជាច្រើនដែលបានពិនិត្យឃើញ ដូចជាករណីនៅសហគមន៍ដីក្រហម ក្រុម៧៨ និង ស្ពានឆេះ (សូមមើលប្រអប់លេខ៤)។[៣៩]

## ៤.២ សកម្មភាពក្នុងកំឡុងពេលនៃការបណ្តេញចេញ

"ការបណ្តេញចេញ បានធ្វើឱ្យមនុស្សគ្រប់គ្នាភ័យខ្លាច។ ក្មេងៗបានស្រែកយំ។ ខ្ញុំមើលអ្វីមិនឃើញទេ និងទន់ដៃជើងមិនអាចរៀបចំប្រមែប្រមូលរបស់របរបានទេ ដោយសារតែគេបាញ់ឧស្ម័នបង្ហូរទឹកភ្នែក។ ខ្ញុំប្រមូលបានតែកូនៗរបស់ខ្ញុំប៉ុណ្ណោះ។ ដោយសារតែឧស្ម័នបង្ហូរទឹកភ្នែក កូនរបស់ខ្ញុំពីរនាក់

[៣៧] ចំពោះដីសហគមន៍មន្ទីរពេទ្យមុនីវង្ស ក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប បានអះអាងថាជាដីរបស់ខ្លួន ហើយប្រជាពលរដ្ឋ១៦៨គ្រួសារ ត្រូវបានបណ្តេញចេញកាលពីថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០៦ ហើយទៅនៅទីតាំងថ្មី នៅស្រុកអង្គស្នួល ក្នុងខេត្តកណ្តាល។ ចំពោះដីសហគមន៍ ចុង ជ្រោយ ក្រុមហ៊ុនសូគីមិច បានអះអាងថាជាដីរបស់ខ្លួន ហើយ ប្រជាពលរដ្ឋ១៣២គ្រួសារ ត្រូវបានបណ្តេញចេញ កាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០០៧ ហើយទៅនៅទីតាំងថ្មី នៅត្រពាំងអញ្ចាញ។ របាយការណ៍អង្គការលីកាដូ ខែ ឧសភា ឆ្នាំ២០០៩ :ការរំលោភយកដីធ្លី និងភាពក្រីក្រនៅកម្ពុជា: ការអភិវឌ្ឍន៍ក្លែងក្លាយ ទំព័រ៨។

[៣៨] សូមមើល *មិនទទួលបានកម្មសិទ្ធិ* ទំព័រ១៣។

[៣៩] សូមមើល *មិនទទួលបានកម្មសិទ្ធិ* និង ប្រអប់លេខ ៤ ខាងក្រោម ។

ផ្លាក់ខ្លួនឈឺ ហើយពួកគេបានក្អួតចង្អោ២ថ្ងៃជាប់ៗគ្នា។ មកដល់ពេលនេះ កូនៗរបស់ខ្ញុំនៅតែភ័យខ្លាចនៅឡើយ នៅពេលដែលពួកគេឃើញគ្រឿងចក្រឈូសឆាយដី។ ពួកគេសួរខ្ញុំថា តើគ្រឿងចក្រនោះនឹងមកឈូសផ្ទះពួកយើងទៀតមែនទេ។"

កុម្ភៈ អាយុ៤០ឆ្នាំ ជាម្តាយដែលមានកូន៤នាក់ ត្រូវគេបណ្តេញចេញពី សហគមន៍ដីក្រហម កាលពីខែមករា ឆ្នាំ២០០៩។

ការបណ្តេញចេញ គប្បីត្រូវប្រព្រឹត្តទៅដោយមានការគោរពយ៉ាងពេញលេញទៅតាមលក្ខខ័ណ្ឌនៃនីតិវិធី ដែលបានកំណត់ដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ទោះបីជាការប្រើកម្លាំងស្របច្បាប់ណាក៏ដោយ ក៏ត្រូវតែគោរពគោលការណ៍ចាំបាច់ និង សមាមាត្រ។[៤១]

ខណៈពេល ដែលក្រុមគ្រួសារត្រូវបានផ្លាស់ប្តូរទៅទីតាំងថ្មីដោយគ្មានអំពើហិង្សា នៅទួលសំបូរ និងអភិវឌ្ឍន៍មានជ័យ ( ក្នុងករណីអភិវឌ្ឍន៍មានជ័យ ការផ្លាស់ប្តូរទីតាំងត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត) ចំណែកឯករណីបណ្តេញចេញផ្សេងៗទៀតក្រោម ករណីពាក់ព័ន្ធនឹងការសិក្សានេះ គឺកម្រិតនៃការបង្ខិតបង្ខំនិងការបំភិតបំភ័យមានប្លែកៗគ្នា។ ក្នុងករណីសហគមន៍ដីក្រហម សហគមន៍

**ប្រអប់លេខ២: ការបណ្តេញចេញនៅស្ពានឆេះ ខេត្តព្រះសីហនុ ឆ្នាំ២០០៧**

សហគមន៍ស្ពានឆេះបានធ្វើការប្រឆាំងនឹងការប៉ុនប៉ងបណ្តេញចេញ និងសេចក្តីជូនដំណឹងចំនួនពីរលើកអំពីការបណ្តេញចេញនៅឆ្នាំនិង ២០០៦ដើមឆ្នាំ២០០៧។ នៅថ្ងៃទីខែ ២០មេសា ឆ្នាំ២០០៧សហគមន៍នេះត្រូវគេបណ្តេញចេញ ខណៈពេលដែលក្រុមគ្រួសារប្រជាពលរដ្ឋកំពុងតែរីករាយនឹងពីធីបុណ្យចូលឆ្នាំថ្មី ហើយពួកគាត់ខ្លះនៅឯខេត្តនៅឡើយ។ កងកម្លាំងប្រដាប់ដោយអាវុធប្រហែលជា១៥០នាក់មានទាំងតម្រួតយោធានគរបាល និងកងយុទ្ធពលខេមរភូមិន្ទប្រដាប់ដោយកាំភ្លើង ដំបងឆក់ ខែល និងឧស្ម័នបង្ហូរទឹកភ្នែក បានចុះអនុវត្តការបណ្តេញចេញនោះ។ពួក គេបានបាញ់កាំភ្លើងភ្ជុងទៅនឹងដី និងបានបាញ់បញ្ឆិតលើក្បាលប្រជាពលរដ្ឋ។ សមាជិកសហគមន៍ដែលបានព្យាយាមតស៊ូត្រូវគេវាយនឹងដំបងឈើនិងដំបងឆក់។ ស្ត្រីម្នាក់អាយុ៥៤ឆ្នាំ ដែលបានព្យាយាមចូលទៅក្នុងផ្ទះដើម្បីយកអង្ករខ្លះ ត្រូវតម្រួតយោធាបួននាក់ វាយនិង ប្រើដំបងឆក់ ឆក់ជើងរបស់គាត់ និងច្រានគាត់ផ្តួលទៅនឹងដីធ្វើឱ្យបាក់ដៃរបស់គាត់។ បុរសម្នាក់ទៀតអាយុ៧៧ឆ្នាំត្រូវកងកម្លាំងប្រើ ដំបងឆក់ ឆក់ត្រង់ថ្វាសរបស់គាត់ដែលក្រោយមកត្រូវបញ្ជូនទៅមន្ទីរពេទ្យ។ សរុបមកមានស្ត្រីចំនួនប្រាំនាក់និងបុរស ១៣នាក់បានរងរបួស។ លំនៅដ្ឋានទាំងអស់ត្រូវគេដុតនិងកំទេចចោលក្នុងពេលបណ្តេញចេញនោះ។ អ្នកភូមិក៏បានឱ្យដឹងថា កម្លាំងនគរបាលបានប្រើឡានទឹកបាញ់ប្រេងទៅលើផ្ទះដើម្បីធ្វើឱ្យដុតឆេះបានកាន់តែឆាប់។ សមាជិកសហគមន៍១៣នាក់ត្រូវបានចាប់



*ការដុតផ្ទះសំបែងកំឡុងពេលបណ្តេញចេញនៅថ្ងៃទី២០ខែ មេសាឆ្នាំ២០០៧*
*ថ្លែងអំណរគុណចំពោះការថតរូបដោយ: អនាមិក*

[៤០] កំនត់ហេតុរបស់ OHCHR និង របស់អ្នកឃ្លាំមើលពីអង្គការក្រៅរដ្ឋាភិបាល ឆ្នាំ (២០០៦-២០០៧)

[៤១] គោលការណ៍ណែនាំជាមូលដ្ឋាន របស់អ្នករាយការណ៍ពិសេស កថាខ័ណ្ឌ ៤៥ដល់៥១។ សូមមើល ឧបសម្ព័ន្ធទី១។

ស្ពានឆេះ ( សូមមើលប្រអប់លេខ២ និងលេខ៣ ខាងក្រោម) និងសំបុកចាប[៩២] អាជ្ញាធរមិនបានជូនដំណឹងដល់ប្រជាពលរដ្ឋបានត្រឹមត្រូវទេ មុនពេលបណ្តេញចេញជាក់ស្តែង។ ពួកគេបានអនុវត្តការបណ្តេញចេញនៅពេលយប់ ឬក៏ពេលព្រឹកព្រលឹម ហើយទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ត្រូវបានបំផ្លិចបំផ្លាញ ហើយចំពោះករណីដីក្រហម និងស្ពានឆេះ មានប្រើប្រាស់កម្លាំងយ៉ាងច្រើនលើសលុបមិនសមាមាត្រកំលាំង ដោយគ្មានភាពចាំបាច់ ។ ករណីទាំងនេះឆ្លុះបញ្ចាំងឱ្យឃើញ អំពីការមិនគោរពការការពារតាមនីតិវិធីក្នុងកំឡុងពេលបណ្តេញចេញ។ ប្រជាពលរដ្ឋដែលត្រូវបានសម្ភាសន៍ទាំងអស់គ្នា សុទ្ធតែបញ្ជាក់សង្កត់ធ្ងន់ថា ការបណ្តេញចេញជាក់ស្តែង ជាបទពិសោធន៍ដ៏សែនមហន្តរាយសំរាប់ពួកគាត់ ជាពិសេសពេលដែលគេប្រើអំពើហិង្សាហួសហេតុ ឬ អំពើអយុត្តិធម៌ផ្សេងៗ ។

ចំពោះប្រជាពលរដ្ឋក្រុម៧៨ សាលារាជធានីភ្នំពេញដោយមានការគាំទ្រពី OHCHR បានប្រឹងប្រែងក្នុងការបញ្ចៀសបានពីការបណ្តេញចេញដោយអំពើហិង្សា និង មានការចរចានៅថ្ងៃបណ្តេញចេញ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ការផ្លាស់ប្តូរទៅទីតាំងថ្មីនោះ មិនមែនធ្វើដោយស្ម័គ្រចិត្តទេពីព្រោះក្រុមគ្រួសារ និងប្រជាពលរដ្ឋបានចាកចេញទៅដោយបង្ខំចិត្ត។[៩៣] សហគមន៍ក្បាលហុងនៅខេត្តព្រះសីហនុ គ្មានជម្រើសអ្វីក្រៅពីត្រូវតែរើចេញពីលំនៅដ្ឋានរបស់ពួកគាត់ទៅកាន់កន្លែងថ្មីនៅអូរកម្ពុជាដោយខ្លួនឯងក្រោមសម្ពាធឱ្យធ្វើដូច្នេះដោយយោធាជើងទឹក និង អាជ្ញាធរមូលដ្ឋាននោះឡើយ។

## ៤.៣ ការទទួលបានការដោះស្រាយដោយប្រសិទ្ធភាព និង ការទទួលបានសំណង

មនុស្សគ្រប់រូបដែលត្រូវគេគំរាមកំហែងបណ្តេញចេញដោយបំពាន ឬត្រូវគេបណ្តេញចេញដោយបំពាន មានសិទ្ធិទទួលបានការដោះស្រាយតាមផ្លូវច្បាប់ ដូចជា សវនាការដោយយុត្តិធម៌នៅតុលាការ ទទួលបានប្រឹក្សាផ្នែកច្បាប់ ជំនួយផ្នែកច្បាប់ ការអោយត្រលប់មកទីតាំងដើមវិញ ការសងអោយដូចដើមវិញ (បរិទាន) ការតាំងទីលំនៅថ្មី ការស្តារនីតិសម្បទា និងសំណង។[៩៤] ប៉ុន្តែសហគមន៍ដែលស្ថិតនៅក្រោមការគំរាមកំហែងដែលបានដាក់បណ្តឹងតវ៉ាប្តឹងទាមទារ ព្រមទាំងបានតវ៉ាជាសាធារណៈ នៅចំពោះមុខអាជ្ញាធរគ្រប់ជាន់ថ្នាក់ រួមទាំងសមាជិកសភា នាយករដ្ឋមន្ត្រី និងតុលាការផងនោះ បានទទួលជោគជ័យតិចតួចណាស់។ ស្ថាប័នសំរាប់ដោះស្រាយបញ្ហា និងយន្តការសំរាប់ដោះស្រាយ

[៩២] ការបណ្តេញប្រជាពលរដ្ឋនៅសំបុកចាបចេញពី តំបន់បាសាក់ បានប្រព្រឹត្តទៅនៅដើមខែឧសភា ឆ្នាំ ២០០៦។ ពីថ្ងៃទី៣ ដល់៥ ខែឧសភា អាជ្ញាធរដោយ មានជំនួយពីកម្លាំងសន្តិសុខបំពាក់ដោយកាំភ្លើង និងដំបងឆក់ បានកំទេចលំនៅដ្ឋានរបស់ក្រុមគ្រួសារ ប្រជាពលរដ្ឋ ដែលទទួលបានដីឡូត៍នៅកន្លែងតាំងទីលំនៅថ្មី នៅត្រពាំងអញ្ចាញ។ គ្រួសារប្រជាពលរដ្ឋទាំងនោះត្រូវរើចេញដោយ ការបង្ខិតបង្ខំ ទៅកន្លែងតាំងទីលំនៅថ្មីនោះ ។ បន្ទាប់ពីការកំទេចលំនៅដ្ឋាន នៅសំបុកចាបទាំងអស់រួច គេធ្វើរបងបិទបាំងទីនោះ ពីសាធារណៈជន ហើយអ្នកជួលផ្ទះដែលមិនមានសិទ្ធិទទួលបានដីនៅឯត្រពាំងអញ្ចាញនៅតែបន្តរស់នៅ លើទីតាំងនោះដោយ គ្មានជំរកអស់រយៈពេលមួយខែ ។ នៅព្រលឹម ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៦ កម្លាំងប៉ូលិសក្រុង និង តម្រួតយោធាប្រហែលជា មួយពាន់នាក់ បានមកជួបជុំគ្នា ខាងមុខ សំបុកចាប ដោយប្រដាប់ដោយកាំភ្លើងខ្លី កាំភ្លើងវែង ដំបងឆក់ របាំងមុខការពារឧស្ម័ន និងគ្រឿងឧបករណ៍ការពារកុប្បកម្ម។ នៅម៉ោង ៦ ព្រឹក បុគ្គលិកក្រុមហ៊ុនអមដោយកម្លាំងសន្តិសុខទាំងអស់នេះ បានចាប់ផ្តើមបណ្តេញ អ្នកជួលផ្ទះចេញពីសំបុកចាប ។ គ្រួសារប្រជាពលរដ្ឋ ត្រូវគេដាក់បញ្ចូលឡាន ហើយដឹកទៅភូមិអណ្តូង។ [៩២]សូមមើលសេចក្តីថ្លែងការណ៍របស់ OHCHRនៅគេហទំព័រនេះ http://cambodia.ohchr.org/EN/PagesFiles/NewsIndex/NewsArchives2009.htm

[៩៣] គោលការណ៍ណែនាំជាមូលដ្ឋានរបស់ អ្នករាយការណ៍ពិសេស កថាខ័ណ្ឌទី៥៩ ,CESCR សេចក្តីពន្យល់រួមទី ៧

[៩៤]*របាយការណ៍ អង្គការ លីកាដូ/លីកាដូកាណាដា ឆ្នាំ២០០៨ :សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ ដីក្រហម ទំព័រទី ១៤-១៥ (ចាប់ពីពេលនេះតទៅហៅ: របាយការណ៍លីកាដូ អំពី សហគមន៍ដីក្រហម)* ។

ជម្លោះដីធ្លី ដែលមានស្រាប់មិនបានផ្តល់ដំណោះស្រាយដល់សហគមន៍នានា ដែលបានទទួលរងការគំរាមកំហែងដោយការបណ្តេញចេញទេ ដូចជាករណីសហគមន៍ក្រុម៧៨(សូមមើលប្រអប់លេខ៤) និងសហគមន៍ដីក្រហម[៩៦] បានបង្ហាញច្បាស់ ។

*សំណង*

## ប្រអប់លេខ៣: ការបណ្តេញចេញនៅសហគមន៍ដីក្រហម នៅភ្នំពេញ ឆ្នាំ២០០៩

សហគមន៍ដីក្រហមបានស្ថិតនៅក្រោមការគំរាមកំហែងនៃការបណ្តេញចេញតាំងពីឆ្នាំ២០០៦មកម្លេះ។ នៅពេលដែលស្ថានភាពនាំទៅដល់ការបណ្តេញចេញ កាន់តែមានភាពខ្លាំងក្លាឡើងៗ OHCHR បានទទួលជោគជ័យក្នុងការលើកទឹកចិត្តសាលារាជធានីភ្នំពេញអោយផ្តល់ពេលវេលា គ្រប់គ្រាន់សំរាប់ការចរចារវាងក្រុមហ៊ុនអភិវឌ្ឍន៍7NG និងសហគមន៍។ហើយជាលទ្ធផលការបណ្តេញចេញត្រូវបានពន្យាពេលមួយរយៈដើម្បីអោយធ្វើការចរចាបញ្ចប់។ ប៉ុន្តែនៅពាក់កណ្តាលខែមករា ឆ្នាំ២០០៩កិច្ច ចរចាត្រូវបានបញ្ឈប់ភ្លមៗទៅវិញហើយការបណ្តេញចេញក៏កើតឡើងនៅប៉ុន្មានថ្ងៃបន្ទាប់។ ការបណ្តេញចេញនេះបានកើតឡើងនៅពេលយប់និងព្រឹកព្រលឹម ថ្ងៃទី២៣និងខែ ២៤មករា ឆ្នាំ២០០៩។ ប្រជាពលរដ្ឋនៅដីក្រហមមិនត្រូវបានគេជូនដំណឹងអំពីនិង ថ្ងៃម៉ោងពិតប្រាកដនៃការបណ្តេញចេញនេះទេ ប៉ុន្តែពួកគាត់ត្រូវបានគេប្រាប់ប៉ុន្មានថ្ងៃមុនថានឹងមានការបណ្តេញចេញ“នៅថ្ងៃណា”មួយ។ កងនគរបាលកងរាជអាវុធហត្ថ និងបុគ្គលិកក្រុមហ៊ុន បានប្រើកម្លាំងគំរាមកំហែងនិងបណ្តេញប្រជាពលរដ្ឋចេញ។ គ្រឿងចក្រធំៗ ដូចជាគ្រឿងចក្រឈូសឆាយដីត្រូវបានប្រើប្រាស់ដើម្បីកំទេចលំនៅដ្ឋាននិងទ្រព្យសម្បត្តិ។ នគរបាលបានសំរុកទៅវាយអ្នកភូមិ ពេលនោះប្រជាពលរដ្ឋក៏គប់ដុំថ្មតបមកលើក្រុមនគរបាលវិញ។ នគរបាលបានបាញ់ឧស្ម័ន បង្ហូរទឹកភ្នែកនៅកំពស់ត្រឹមចង្កេះដោយមិនបាញ់ទៅលើអាកាសទេហើយ នគរបាលខ្លះទៀតត្រូវបានគេមើលឃើញថា កំពុងគប់អ្នកភូមិនឹងដុំថ្មដែរ។ កងនគរបាលផ្សេងទៀត ព្រមទាំងក្រុមកម្មករសំរុកទៅរកអ្នកភូមិនិងវាយដំពួកគាត់។ ស្ត្រីម្នាក់ទទួលរងរបួសពេល ដែលគ្រឿងចក្រឈូសបំផ្លាញផ្ទះដែលគាត់កំពុងនៅក្នុងនោះ។ បុគ្គលិកម្នាក់មកពីអង្គការលីកាដូត្រូវគេចាប់ផ្តួលទៅលើដីនិងត្រូវគេវាយដំ។ ពេលដែលគេកំពុងកំទេចលំនៅដ្ឋាន និងពេលដែលប្រជាពលរដ្ឋត្រូវគេបណ្តេញចេញនោះ ពួកគាត់ភាគច្រើនគ្មានឱកាសក្នុងការយករបស់របរផ្ទាល់ខ្លួនរបស់ពួកគាត់ចេញមកទេ ។



*ប៉ូលីស ទាហាន និងកម្មករក្រុមហ៊ុនបានបណ្តេញប្រជាពលរដ្ឋនៅថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៩ ថ្លែងអំណរគុណចំពោះការថតរូបដោយ: J.S. Lee.*

[៩៥] កំណត់ហេតុ របស់ OHCHR និង របស់អ្នកឃ្លាំមើលពីអង្គការមិនមែនរដ្ឋាភិបាល (ឆ្នាំ ២០០៨-២០០៩)

[៩៦] របាយការណ៍ អង្គការ លីកាដូ/លីកាដូកាណាដា ឆ្នាំ២០០៨ :សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ ដីក្រហម ទំព័រទី ១៤-១៥ (ចាប់ពីពេលនេះតទៅហៅ: របាយការណ៍លីកាដូ អំពី សហគមន៍ដីក្រហម) ។

យោងទៅតាមច្បាប់អន្តរជាតិ និងតាមការឆ្លុះបញ្ចាំងទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ភូមិបាល និងច្បាប់ស្តីពីអស្សាមិករណ៍ សំណងដល់ម្ចាស់អចលនវត្ថុត្រូវតែ “សមរម្យនិងយុត្តិធម៌” ឬមានលក្ខណៈ “ពេញលេញ” ហើយត្រូវផ្តល់សំណងជាមុន។ គឺថាសំណងទាំងនោះមិនត្រូវលើស ឬតិចជាងតម្លៃនៃការបាត់បង់ ដែលបណ្តាលមកពីការដកហូតដីនោះទេ។ សំណងត្រូវតែគិតដោយបូកបញ្ចូលគ្រប់ការបាត់បង់ខូចខាតគ្រប់ប្រភេទ គឺថាបន្ថែមពីលើដីនិងអគារ ត្រូវគិតបញ្ចូលការខាតបង់ទាំងអស់លើជីវភាពរស់នៅ ក៏ដូចជាលើតំលៃខូចខាតមិនមានលក្ខណៈសេដ្ឋកិច្ច ឬការរំខានផ្សេងៗ (ដូចជា ការរុះរើផ្ទះឬអគារ ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ចំណាយលើការធ្វើអាជីវកម្ម ការខាតបង់/ថយចុះប្រាក់ឈ្នួល/ប្រាក់ចំណូល សម្ភារៈផ្សេងៗជាដើម) ។

គួរតែមាន ដំណោះស្រាយតាមស្ថានភាពជាក់ស្តែងមួយ ក្នុងការកំណត់សំណង សំរាប់ប្រជាពលរដ្ឋ ដែលមិនមានសិទ្ធិស្របច្បាប់លើដីដែលពួកគាត់រស់នៅ ដោយផ្អែកលើគោលការណ៍សមធម៌ និងស្មើភាព។ អ្នកដែលត្រូវគេបណ្តេញចេញគ្រប់រូបមិនថាពួកគាត់ជាអ្នកមានប័ណ្ណកម្មសិទ្ធិលើដីធ្លីរបស់ខ្លួន ឬក៏មិនមាននោះទេ គួរតែមានសិទ្ធិទទួលសំណងសម្រាប់ការខាតបង់ ការជួយស្រោចស្រង់ និង ជួយដឹកជញ្ជូនទ្រព្យសម្បត្តិ ដែលរងផលប៉ះពាល់រួមទាំងលំនៅដ្ឋាន និងដីដែលបានបាត់បង់ ឬខូចខាត នៅក្នុងដំណើរការនៃការបណ្តេញចេញនោះ។ [៤៧]

វាមានការលំបាក ក្នុងការពិភាក្សាអំពីអ្វីដែលនឹងបង្កើតចេញជា សំណង “សមរម្យ” សម្រាប់គ្រប់ករណីក្រោមការសិក្សានេះ នៅពេលដែលស្ថានភាពផ្លូវច្បាប់នៃដីធ្លី និងសិទ្ធិភោគៈរបស់ប្រជាពលរដ្ឋមិនបានកំណត់ច្បាស់លាស់ ពីអាជ្ញាធរដែលទទួលខុសត្រូវ។ ខណៈដែលមិនទាន់គិតពីសំណងថាតើ គួរ ឬ មិនគួរ មានតម្លៃដល់តម្លៃទីផ្សារនៅឡើយនោះ គឺត្រូវតែប្រកាន់ខ្ជាប់នូវបទដ្ឋានអប្បបរមានៃភាពសមរម្យ ដោយត្រូវពិគ្រោះយោបល់ ជាមួយសហគមន៍នានា ដើម្បីធានាថាមានការដោះស្រាយលើ ការខាតបង់ផ្សេងៗរបស់ក្រុមគ្រួសារដែលរងផលប៉ះពាល់។ ច្បាប់ស្តីពីអស្សាមិករណ៍នាពេលថ្មីៗនេះ ក៏បានចែងពីការទទួលស្គាល់ជាពិសេសចំពោះសិទ្ធិរបស់ភោគី បន្ថែមលើម្ចាស់អចលនទ្រព្យ ក្នុងការទទួលបានសំណងមានតម្លៃស្មើនឹងតម្លៃទីផ្សារ ឬ តម្លៃដែលអាចជំនួសបាន។

ក្នុងករណី ដែលបានពិនិត្យភាគច្រើន សំណង ដែលផ្តល់ជូនក្រុមគ្រួសារដែលត្រូវគេបណ្តេញចេញមិនសមរម្យទេ ហើយនៅពេលមានការផ្តល់សំណង គឺគេផ្តោតតែលើការបាត់បង់លំនៅដ្ឋានតែប៉ុណ្ណោះ ដោយមិនបានគិតអំពីការខាតបង់ដទៃទៀតទេ។ ជាទូទៅ សំណងដែលផ្តល់ដោយអាជ្ញាធរសាលារាជធានីភ្នំពេញមានបីប្រភេទគឺៈ (ក) ដីឡូត៍ នៅឯកន្លែងតាំងទីលំនៅថ្មី នៅជាយក្រុង (ខ) ដីឡូត៍ទំហំតូច បូកនិងប្រាក់សុទ្ធបន្ថែមខ្លះ ឬ (គ) សំណងជាប្រាក់សុទ្ធក្នុងតម្លៃទាបដែលទាបជាងតម្លៃទីផ្សារ ឬថ្លៃដែលអាចជំនួសបាន។ ការផ្តល់សំណងថ្មីៗរបស់សាលារាជធានីភ្នំពេញ ជាពិសេសចំពោះរឿងក្តីធំៗ បង្ហាញពីភាពរីកចម្រើនខ្លះចំពោះការផ្តល់សំណង បើប្រៀបធៀបទៅនឹងការអនុវត្តពីពេលមុន និង ការអនុវត្តនៅក្រុងព្រះសីហនុដែលនៅទីនោះ គ្មានការផ្តល់សំណងអ្វីទាំងអស់ ឬ មានផ្តល់សំណងតិចតួចបំផុត។ ជាការពិត



[៤៧] គោលការណ៍ណែនាំជាមូលដ្ឋានរបស់ អ្នករាយការណ៍ពិសេស កថាខ័ណ្ឌទី ៦០-៦៣, អង្គការ FAO “ការតំរូវអោយដកហូតដីធ្លី និងសំណង” ការសិក្សាលេខ ១០ស្តីពី ការកាន់កាប់ដី (ឆ្នាំ២០០៨) ។

## ប្រអប់លេខ៤: កិច្ចខិតខំប្រឹងប្រែងរបស់ក្រុម ៧៨ ដើម្បីទទួលបានដំណោះស្រាយ

ប្រជាពលរដ្ឋ“ ក្រុម៧៨ ”ដែលរស់នៅក្នុងភូមិ១៤ក្នុងសង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ មានភស្តុតាងយ៉ាងរឹងមាំ ដើម្បីបង្ហាញថា ការកាន់កាប់លំនៅដ្ឋាននិងដីធ្លីរបស់ពួកគាត់បានបំពេញតាមល័ក្ខខ័ណ្ឌនៃសិទ្ធិភោគៈ ដែលកំនត់ក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ដូចជាលក្ខខ័ណ្ឌដែលចែងថា ភោគៈនោះត្រូវតែបានកាន់កាប់ "ដោយពិតប្រាកដ ដោយសន្តិវិធី និងដឹងឮជាសាធារណៈ ដោយគ្មានអាក់ខាន និងដោយសុចរិត"។[៤៨] នៅឆ្នាំ២០០៤ ប្រជាពលរដ្ឋក្រុម៧៨ ជាច្រើននាក់ បានដាក់ពាក្យស្នើសុំទៅអាជ្ញាធរសុរិយោដី ដើម្បីសុំប័ណ្ណកម្មសិទ្ធិលើដីធ្លី (តាមរយៈ ដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ)។ សំណើរបស់ពួកគាត់មិនទទួលបាននូវចម្លើយតបពីសំណាក់អាជ្ញាធរសង្កាត់ និងគណៈកម្មការសុរិយោដីខ័ណ្ឌទេ ដូច្នេះនៅខែមិថុនា ឆ្នាំ២០០៦ ពួកគាត់បានធ្វើពាក្យបណ្តឹងដាក់ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ។ នៅខែកក្កដា ឆ្នាំ២០០៦ គណៈកម្មការសុរិយោដីថ្នាក់ជាតិបានបញ្ជូនពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋក្រុម៧៨ទៅគណៈកម្មការសុរិយោដីក្រុង។[៤៩] ប៉ុន្មានសប្តាហ៍ក្រោយមក ប្រជាពលរដ្ឋក្រុម៧៨ ក៏ទទួលបានសេចក្តីជូនដំណឹង លើកដំបូង ស្តីពីការរោយរុះរើលំនៅដ្ឋាន ។ ក្រោយពីមានសេចក្តីជូនដំណឹងលើកទី១នេះ មានសេចក្តីជូនដំណឹងដល់ប្រជាពលរដ្ឋ ជាបន្តបន្ទាប់ចំនួនប្រាំទៀត ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ហើយដែលសេចក្តីជូនដំណឹងចុងក្រោយគឺ នៅខែមេសា ឆ្នាំ២០០៩។[៥០]

សមាជិកក្រុម៧៨ បានស្វែងរកដំណោះស្រាយពីតុលាការសាលាដំបូងរាជធានី ចំពោះ សេចក្តីជូនដំណឹងអំពីការរុះរើលំនៅដ្ឋានទាំងនោះ ទាំងក្នុងឆ្នាំ២០០៦ និងឆ្នាំ២០០៩ ហើយក៏បានរកជំនួយពីសមាជិករដ្ឋសភា និងស្ថាប័នដទៃទៀត តែមិនបានទទួលជោគជ័យទេ។ តុលាការសាលាដំបូងរាជធានី បានបញ្ជូនពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋក្រុម៧៨ ទៅគណៈកម្មការសុរិយោដីរាជធានី (នៅឆ្នាំ២០០៦) ឬក៏បានច្រានចោលពាក្យបណ្តឹងទាំងនោះ(នៅឆ្នាំ២០០៩)។[៥១] មិនមានព័ត៌មានជាសាធារណៈដែលបញ្ជាក់ថា តើគណៈកម្មការសុរិយោដីរាជធានី (ដែលទាំងតុលាការ និងគណៈកម្មការសុរិយោដីថ្នាក់ជាតិបានបង្វិលពាក្យបណ្តឹងមកក្រោមសមត្ថកិច្ចខ្លួន) បានចុះធ្វើការស៊ើបអង្កេត សរសេររបាយការណ៍ ឬរៀបចំកិច្ចប្រជុំរវាងភាគីជម្លោះ តាមលក្ខខ័ណ្ឌច្បាប់ដែរឬក៏អត់ទេ។ ទាំងគណៈកម្មាការសុរិយោដីថ្នាក់ជាតិ និងថ្នាក់រាជធានី មិនបានចេញសេចក្តីសម្រេចណាមួយទាក់ទងនឹងករណីនេះទេ ។

នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ ទីស្តីការគណៈរដ្ឋមន្ត្រី បានចេញសេចក្តីជូនដំណឹងមួយដែលគាំទ្រដល់សេចក្តីជូនដំណឹងចុងក្រោយស្តីពីការរុះរើលំនៅដ្ឋាននោះ ដោយបញ្ជាក់ថា សហគមន៍ មានជម្រើសបួន សំរាប់ជ្រើសរើសយក ដែលជម្រើសទាំងបួននោះមានចាប់ពី ការផ្តល់សំណងជាប្រាក់ និងការផ្តល់សំណងដែលមានមានទាំងសាច់ប្រាក់និងដីឡូត៍។[៥២] អន្តរាគមន៍របស់ទីស្តីការគណៈរដ្ឋមន្ត្រីនេះ ធ្វើឱ្យមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះថា គណៈកម្មការសុរិយោដី នៅមិនទាន់ធ្វើសេចក្តីសម្រេចលើស្ថានភាពផ្លូវច្បាប់នៃដីនោះនៅឡើយ។ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ ប្រជាពលរដ្ឋទាំងប៉ុន្មានគ្រួសារដែលនៅសល់ត្រូវគេបណ្តេញចេញ។

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ គណៈកម្មការសុរិយោដីថ្នាក់ជាតិនៅទីបញ្ចប់ បានចេញសេចក្តីសម្រេច មួយដែលបញ្ជាក់ថា រដ្ឋាភិបាលបានសំរេចផ្តល់ជម្រើស ដែលមានជា សំណង និងការផ្លាស់ប្តូរទៅទីតាំងថ្មីហើយ ដូច្នេះ ក្រសួងរៀបចំ

[៤៨] ប្រជាជនភាគច្រើនបានរស់នៅទីនោះតាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០។ ពួកគាត់ត្រូវបានទទួលស្គាល់ជាផ្លូវការដោយ អាជ្ញាធរមូលដ្ឋាន និងការិយាល័យសុរិយោដីរាជធានីភ្នំពេញ តាមរយៈការចេញបង្កាន់ដៃស្ថិតិលំនៅដ្ឋាន នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩២។ តាំងពីពេលនោះមក ការទទួលស្គាល់ជាផ្លូវការផ្សេងៗទៀត ទាក់ទងជាពិសេសចំពោះការកាន់កាប់ដី ឬលើការកាន់កាប់ដី មានដូចជា: សំបុត្រកំណើត និង “បង្កាន់ដៃលំនៅដ្ឋាន” (ចេញដោយមន្ត្រីសង្កាត់ទន្លេបាសាក់ក្នុងទសវត្សរ៍ឆ្នាំ១៩៩០) កិច្ចសន្យាទិញ លក់ផ្ទះ កិច្ចសន្យាផ្ទេរឈ្មោះការកាន់កាប់ សៀវភៅគ្រួសារ (ចេញដោយមន្ត្រីខ័ណ្ឌក្នុងឆ្នាំ១៩៩៩) ។ ប័ណ្ណបោះឆ្នោត (ចេញដោយមន្ត្រី សង្កាត់ក្នុងឆ្នាំ ២០០៣) អត្តសញ្ញាណប័ណ្ណ (ចេញដោយសាលារាជធានីភ្នំពេញក្នុងឆ្នាំ២០០៣) និងលិខិតស្នើសុំជួសជុលលំនៅដ្ឋាន។ នៅឆ្នាំ២០០៦ គេបានធ្វើការប៉ាន់ស្មានថាមានប្រជាពលរដ្ឋ ប្រហែលជា១៤៦គ្រួសារក្នុងនោះ៧០គ្រួសារ មានបង្កាន់ដៃលំនៅដ្ឋាន ដែលចេញឱ្យពួកគាត់ ដោយអាជ្ញាធរមូលដ្ឋាននៅឆ្នាំ១៩៩២ ។

ណាស់ សហាគមន៍ស្ពានឆេះ មិនបានទទួលសំណង អ្វីទាល់តែសោះ រីឯសហាគមន៍អូរកម្ពុជាទទួលបាន តែដីទទេរ ប៉ុណ្ណោះ។

កិច្ចចរចាជុំវិញ ការបណ្តេញប្រជាពលរដ្ឋក្រុម៧៨ បានបង្ហាញពីភាពខុសគ្នាដោយអន្លើ រវាងសំណងដែលពួកគាត់បានទទួលជាមួយនិងសំណងដែលសហាគមន៍គិតថាសមរម្យ និងសំណងតាមតម្លៃទីផ្សារ។ ក្នុងឆ្នាំ២០០៦[៥៣] សំណងដែលផ្តល់អោយសហាគមន៍លើកដំបូងគឺ ដីឡូត៍ទំហំ ៥ម គុណនឹង ១២ម នៅឯត្រពាំងអញ្ចាញ។ នៅក្នុងឆមាសទីពីរនៃ ឆ្នាំ២០០៦ មេធាវីតំណាងប្រជាពលរដ្ឋក្រុម៧៨ បានជួលក្រុមហ៊ុនអចលនទ្រព្យមួយ ឱ្យធ្វើការវាយតម្លៃដីដែលតាមការវាយតម្លៃនោះបានបង្ហាញថា ដីនោះមានតម្លៃ៥០០ដុល្លារក្នុង១ម$^២$។ ការវាយតម្លៃម្តងទៀតអំពីតម្លៃដីនោះ បានប្រព្រឹត្តទៅនៅក្នុងខែតុលា ឆ្នាំ២០០៧ ដែលតាមការវាយតម្លៃលើកនេះបានបង្ហាញថា ដីនោះកើនឡើងដល់១,២០០ដុល្លារក្នុង១ម$^២$។ មកដល់ឆ្នាំ២០០៩ ការផ្តល់សំណងជាប្រាក់ជាផ្លូវការ បានឡើងដល់៨,០០០ដុល្លារ។ ក្នុងខែមិថុនា ឆ្នាំ២០០៩ សហាគមន៍បានប្រកាសជាសាធារណៈថា សហាគមន៍នឹងព្រមទទួលយកសំណង ដោយគិតចុះតម្លៃ១៥ភាគរយ ពីអត្រាតំលៃទីផ្សារ ដែលនាំឱ្យតម្លៃសរុបស្មើនឹង១,១៧៦លានដុល្លារ) ដោយប្រៀបធៀបទៅនឹងតម្លៃដីប៉ាន់ស្មាន ៤,៨លានដុល្លារ ក្នុងឆ្នាំ២០០៦។ សាលារាជធានីភ្នំពេញមិនបានទទួលយកសំណើនេះទេ។ រហូតមកដល់ថ្ងៃបណ្តេញចេញគ្រួសារប្រជាពលរដ្ឋខ្លះទទួលបាន២០,០០០ដុល្លារ រីឯប្រជាពលរដ្ឋភាគច្រើនទទួលបានពី ១០,០០០ ទៅ ១២,០០០ដុល្លារ តែមិនបានដីឡូត៍ទេ។ មានប្រជាពលរដ្ឋតែពីរបីគ្រួសារទេ ដែលព្រមទទួលយកប្រាក់សុទ្ធតិចតួច ប្លុក និង ដីឡូត៍។

សំរាប់សំណងដែលគេផ្តល់ជាលើកដំបូងអោយប្រជាពលរដ្ឋ នៅសហាគមន៍ដីក្រហម គឺផ្ទះល្វែងនៅដំណាក់ត្រយឹង ។ មានបីបួនរយគ្រួសារបានយល់ព្រមចេញទៅរស់នៅ ដំណាក់ត្រយឹង ក្នុងឆ្នាំ២០០៦។ ក្នុងឆ្នាំ២០០៧ មានការផ្តល់សំណងជាប្រាក់សុទ្ធ (៧,០០០ដុល្លារ) ជាលើកដំបូងដល់ប្រជាពលរដ្ឋនៅដីក្រហម នៅខណ:ពេលដែលសហាគមន៍បានរៀបចំ និង ទាមទារនូវសំណងប្រសើរជាងមុន។ គិតមកទល់ឆ្នាំ២០០៨ មានគ្រួសារចំនួន១,៣៧៤ (ស្មើ ៩៣%នៃចំនួនប្រជាពលរដ្ឋទាំងអស់ នៅក្នុងសហាគមន៍ដីក្រ



[៤៩] តាមរយៈលិខិតជូនដំណឹងលេខ៧២២ ចុះថ្ងៃទី ២៤ កក្កដា ឆ្នាំ ២០០៦

[៥០] សេចក្តីជូនដំណឹងពីការបណ្តេញចេញលើកដំបូង ចេញនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ ដោយអភិបាលខ័ណ្ឌចំការមន តម្រូវឱ្យ ប្រជាពលរដ្ឋផ្លាស់ប្តូរទីតាំងទៅត្រពាំងអញ្ចាញ។ សេចក្តីជូនដំណឹងលើកទីប្រាំមួយ ចេញដោយសាលារាជធានីភ្នំពេញ។

[៥១] ជាការឆ្លើយតបទៅនឹងពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋក្រុម៧៨ សុំមោឃភាពសេចក្តីជូនដំណឹងពីការបណ្តេញចេញលេខ ០៥៥/០៦ ខែតុលា ឆ្នាំ២០០៦ តុលាការរាជធានីភ្នំពេញបានចេញសេចក្តីសម្រេចលេខ ៩១១៨ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៦ ដោយបញ្ជូនករណីនេះទៅអោយ សមត្ថកិច្ច គណ:កម្មការសុរិយោដីរាជធានីភ្នំពេញ(សំណុំរឿងលេខ៩៥០ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៦) ។ នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ តុលាការដដែលនេះ បានច្រានចោលពាក្យស្នើសុំរបស់ប្រជាពលរដ្ឋ ក្រុម៧៨ ដែលស្នើសុំតុលាការចេញដីកាកិច្ចការប្រញាប់ បន្ទាប់ពីមានការចេញសេចក្តីជូនដំណឹងលើកទីប្រាំមួយ កាលពីថ្ងៃទី ២០ ខែ មេសា។ នៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៩ សាលាឧទ្ធរណ៍បានតម្កល់សេចក្តីសម្រេចរបស់តុលាការរាជធានី ដោយមិនចេញ ដីកាកិច្ចការប្រញាប់នោះទេ ព្រមទាំងបានសម្រេចពីភាពស្របច្បាប់នៃ សេចក្តីជូន ដំណឹងអំពីការបណ្តេញចេញនោះថែមទៀត ដោយទោះបីជាគ្មានការស្នើសុំ នៅក្នុងបណ្តឹងឧទ្ធរណ៍នោះក៏ដោយ ដោយបញ្ជាក់ថា សេចក្តីជូនដំណឹងអំពីការបណ្តេញចេញ របស់សាលារាជធានី ភ្នំពេញ ចុះថ្ងៃទី ២០ ខែ មេសា មានលក្ខណ:ស្របច្បាប់។

[៥២] សេចក្តីជូនដំណឹង ស.ជ.ណ ៨២០ ។

[៥៣] ប្រជាពលរដ្ឋក្រុម៧៨ លើកជាសំណើសំរាប់តម្លៃដីរបស់សហាគមន៍ ទៅសាលារាជធានីភ្នំពេញ ក្នុងតម្លៃ ១,១០៥ដុល្លារ ក្នុង១ម$^២$ ដែលចុះពីតម្លៃទីផ្សារ១៥ភាគរយ តាមការវាយតំលៃដីដោយក្រុមហ៊ុនអចលនទ្រព្យ ប៊ុណ្ណា រៀលធី គ្រុប (១.២០០ដុល្លារ)។" សេចក្តីប្រកាសព័ត៌មាន ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០០៩ របស់ប្រជាពលរដ្ឋក្រុម៧៨ ។

ហាម) បានព្រមទទួលយកសំណង។[៥៤] សំណងជាប្រាក់សុទ្ធ បានកើនឡើង នៅទីចុងក្រោយបង្អស់ដល់ទៅ ២០,០០០ដុល្លា តែប៉ុន្មានថ្ងៃមុនការបណ្តេញចេញនៃខែមករា ឆ្នាំ២០០៩ ។ ប្រជាពលរដ្ឋ ដែលមិនព្រមចាកចេញ ដែលនៅរហូតដល់ថ្ងៃបណ្តេញចេញ(១៩៤គ្រួសារ ) ត្រូវគេបដិសេធមិនផ្តល់ឱ្យសំណងជាប្រាក់សុទ្ធនោះទេ ហើយគេផ្តល់ឱ្យតែផ្ទះមួយល្វែងប៉ុណ្ណោះ នៅឯភូមិដំណាក់ត្រយឹង។

សហាគមន៍ផ្សេងៗទៀត ដែលការអះអាងតាមផ្លូវច្បាប់ មានភាពទន់ខ្សោយ ឬជាសហាគមន៍ដែលមិនសូវមានគេដឹងឮច្រើន តែងតែទទួលបានសំណងតិចតួចបំផុត។ ឧទាហរណ៍ សហាគមន៍ចុងជ្រោយនៅជ្រោយចង្វា ដែលត្រូវបានបណ្តេញចេញក្នុងឆ្នាំ២០០៧ បានទទួលសំណងតែ២០០ដុល្លារ និង ដីមួយឡូត៍នៅឯត្រពាំងអញ្ចាញប៉ុណ្ណោះ។[៥៥]

នៅក្នុងគ្រប់ករណី ដែលបានលើកយកមកពិនិត្យទាំងអស់ ក្រុមគ្រួសារដែលទទួលរងផលប៉ះពាល់ មិនត្រូវបានគេផ្តល់សំណងសម្រាប់ការបាត់បង់ផ្សេងៗទៀតទេដូចជា ការបាត់បង់ប្រាក់ចំណូល ឬបញ្ហាសុខភាព ដែលបណ្តាលមកពីការបណ្តេញចេញ។ គ្មាននរណាម្នាក់ ដែលត្រូវបានធ្វើសម្ភាសន៍បានស្វះស្វែងរកការដោះស្រាយចំពោះការបាត់បង់ទាំងនោះទេ។

## ៤.៤ ការបំភិតបំភ័យនិងការចោទប្រកាន់

### សហាគមន៍ពីបទព្រហ្មទណ្ឌ

ក្នុងរយៈកាលចរចា មុនពេលបណ្តេញចេញមួយចំនួន នៃករណីក្រោមការសិក្សាឃើញថា សមាជិកសកម្មបំផុតរបស់សហាគមន៍ ឬអ្នកតំណាងសហាគមន៍តែងតែត្រូវគេបំភិតបំភ័យឱ្យបញ្ឈប់ការតស៊ូមតិដើម្បីទាមទារសិទ្ធិឲ្យសហាគមន៍របស់ពួកគាត់។ ក្នុងករណីខ្លះទៀតដូចជា សហាគមន៍ដីក្រហម ឬសហាគមន៍ក្រុម៧៨ ត្រូវបានទាំងក្រុមហ៊ុនអភិវឌ្ឍន៍ និងអាជ្ញាធរ ដាក់សម្ពាធលើសកម្មជនឱ្យបញ្ឈប់ការតស៊ូមតិដើម្បីសហាគមន៍របស់ខ្លួន និងមានការនិយាយថា ក្រុមហ៊ុនអភិវឌ្ឍន៍ និងអាជ្ញាធរបានទិញទឹកចិត្តតំណាងសហាគមន៍ជាច្រើននាក់បានដោយជោគជ័យ។ ប្រជាពលរដ្ឋដែលបានផ្តល់បទសម្ភាសន៍ បាននិយាយថា តំណាងសហាគមន៍ដែលយល់ព្រមសហាការជាមួយអាជ្ញាធរ និងក្រុមហ៊ុនទាំងនោះ បានទទួលសំណងប្រសើរជាង។[៥៦]

ក្នុងករណីខ្លះទៀត សមាជិកសហាគមន៍និងអ្នកតំណាងរបស់ពួកគាត់ ត្រូវបានគេចោទប្រកាន់ពីបទល្មើសផ្សេងៗ (សូមមើលប្រអប់លេខ៥)។ នៅក្នុងឆ្នាំ២០០៥ តំណាងសហាគមន៍ពីរនាក់នៅដីក្រហម ត្រូវបានគេចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន7 NG និង ពីបទប្រើប្រាស់ឯកសារក្លែងបន្លំ ហើយតំណាងម្នាក់ក្នុងចំណោមពួកគាត់ត្រូវបានជាប់ពន្ធនាគារ អស់រយៈ

[៥៤] លិខិតចុះ ថ្ងៃទី១៩កុម្ភៈ ឆ្នាំ២០០៨ របស់អភិបាលរាជធានីភ្នំពេញ ឯកឧត្តម កែប ជុតិម៉ា ជូនចំពោះ នាយករដ្ឋមន្ត្រីដើម្បី ស្នើសុំគោលការណ៍ ដើម្បីដោះស្រាយបញ្ចប់ករណីដីក្រហម ។

[៥៥] ទិន្នន័យរបស់ OHCHR និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ។

[៥៦] ដូចជាករណី ប្រជាពលរដ្ឋក្រុម៧៨ នៅពេលកំពុងចរចាអំពីសំណងដែលគេចង់ផ្តល់អោយ ពីដើមខែកុម្ភៈ ឆ្នាំ២០០៨ តំណាងសហាគមន៍ដ៏សំខាន់ ពីរនាក់ បានព្រមព្រៀងស្ងាត់ៗ ជាមួយអាជ្ញាធរ ដែលតាមការព្រមព្រៀងនោះ ពួកគាត់សុខចិត្តចាកចេញ។ តំណាងសហាគមន៍ម្នាក់ផ្សេង ទៀត បានបញ្ចុះបញ្ចូលប្រជាពលរដ្ឋ ២៦គ្រួសារ ឱ្យចាកចេញទៅជាមួយគាត់បានដោយជោគជ័យ។ គេចោទប្រកាន់តំណាងរូបនេះថា បានទទួលកម្រៃជើងសារពីមន្ត្រីសាលារាជធានីភ្នំពេញ សម្រាប់គ្រួសារនីមួយៗ ដែលគាត់ បញ្ចុះបញ្ចូលបាន។ តំណាងដទៃទៀតមិនបានព្រមព្រៀងទេ។

ពេលប្រាំមួយខែ ក្នុងឆ្នាំ២០០៨។ នៅឆ្នាំ២០០៧ សមាជិកសហគមន៍ដីក្រហម១៥នាក់ រួមទាំងអ្នកតំណាងសហគមន៍ប្រាំពីរនាក់ផង ត្រូវគេចោទប្រកាន់ពីបទព្រហ្មទណ្ឌផ្សេងៗ នៅពេលដែលសហគមន៍បានកំពុងតែចេញមុខតវ៉ាជំទាស់ នឹងការបណ្តេញចេញជាសក្តានុពល។[៥៧] អ្នកតំណាងសហគមន៍ម្នាក់ ត្រូវជាប់ពន្ធនាគាររយៈពេលប្រាំមួយខែ។ ក្រោយមកទៀត នៅឆ្នាំដដែល អ្នកតំណាងសហគមន៍ចំនួនដប់មួយនាក់ត្រូវគេចោទពីបទព្រហ្មទណ្ឌទៀត។[៥៨] អ្នកតំណាងសហគមន៍មួយចំនួនរងនូវការចោទប្រកាន់ពីបទព្រហ្មទណ្ឌជាច្រើន ក្នុងករណីមួយចំនួន ហើយបទចោទប្រកាន់ភាគច្រើន លើពួកគាត់នៅមិនទាន់បានបើកការជំនុំជម្រះនៅឡើយ។ អានុភាពនៃការចោទប្រកាន់ទាំងនោះ គឺបានធ្វើអោយសមាជិកសហគមន៍ខ្លាចញញើត ក្នុងការចូលរួមការងារតស៊ូមតិ ដើម្បីសហគមន៍របស់ពួកគាត់។

ប្រជាពលរដ្ឋដែលបានផ្តល់បទសម្ភាសន៍សម្រាប់ការសិក្សានេះ មានអារម្មណ៍ដ៏មុតមាំថា អាជ្ញាធរមិនបានពិនិត្យមើលលើពាក្យបណ្តឹង និងក្តីកង្វល់របស់ពួកគាត់ទេ ពីព្រោះពួកគាត់ជាអ្នកក្រីក្រ។ ពួកគាត់និយាយថា ពួកគាត់បានមើលឃើញ ការអនុវត្តន៍ និងការធ្វើសេចក្តីសម្រេចចិត្តរបស់អាជ្ញាធរ និងតុលាការមានការរើសអើងចំពោះពួកគាត់ ដោយតែងតែដាក់ទណ្ឌកម្មលើពួកគាត់ និងដោយគ្មាន

### ប្រអប់លេខ៥: ការចោទប្រកាន់ពីបទព្រហ្មទណ្ឌលើ សមាជិកសហគមន៍នៅស្ពានឆេះ

សមាជិកសហគមន៍ចំនួន១៣នាក់ត្រូវបានចាប់ខ្លួនក្នុងថ្ងៃបណ្តេញចេញ ហើយត្រូវបានចោទប្រកាន់ជាបឋម ពីបទបង្ករបួសស្នាម និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិដោយចេតនា តាមមាត្រា៤១ និង៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលរបស់អ៊ុនតាក់ ។ នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៧ តុលាការខេត្តព្រះសីហនុបានបើកសវនាការ និងកាត់អោយជាប់ទោស អ្នកភូមិប្រាំបីនាក់ក្នុងចំនោមអ្នកភូមិដែលជាប់ឃុំឃាំងបណ្តោះអាសន្នទាំងនោះ ឱ្យជាប់ពន្ធនាគាររយៈពេលពី បីទៅប្រាំបីខែ ពីបទបង្កការខូចខាតទ្រព្យសម្បត្តិដោយចេតនា និងបង្ករបួសស្នាម ហើយបានលើកលែងការចោទប្រកាន់លើអ្នកភូមិប្រាំនាក់ផ្សេងទៀត។ បុគ្គលិក OHCHR ដែលខ្លាំមើលសវនាការ បានសង្កេតឃើញថា មានភាពមិនស៊ីសង្វាក់គ្នាខាងនីតិវិធី និងអង្គសេចក្តី នៅកំឡុងពេលសវនាការ។[៥៩] ដោយសារ ព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់តុលាការ ដូចនេះអ្នកភូមិត្រូវជាប់ពន្ធនាគាររយៈពេលប្រាំបួនខែទៀត។ នៅថ្ងៃទី៣ ខែមេសាឆ្នាំ២០០៨ សាលាឧទ្ធរណ៍បានតម្កល់សេចក្តីសម្រេចរបស់សាលាដំបូង ។ សមាជិកសហគមន៍ទាំងប្រាំបីនាក់នោះ បានជាប់ពន្ធនាគារ លើសកាលកំណត់ ហើយពួកគេត្រូវបានដោះលែងនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៨។

---

[៥៧] ករណីបទចោទប្រកាន់ ទាក់ទងទៅនឹងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្រុមហ៊ុន និងបំផ្លាញទ្រព្យសម្បត្តិរបស់នគរបាល(ម៉ូតូ) និងការប្លន់ទូរស័ព្ទដៃ។ សំណុំរឿងលេខ១០៩០ ចុះថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០០៧ សំណុំរឿងលេខ១៦៩៧ ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០០៧ និងសំណុំរឿងលេខ ១៦៩៨ ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០០៧ ។

[៥៨] ករណីចោទប្រកាន់ ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសង្កាត់ (បដា): សំណុំរឿងលេខ១៨០០ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៧ និងបទបំផ្លិចបំផ្លាញ ទ្រព្យសម្បត្តិ ក្រុមហ៊ុន និងបង្ករបួសស្នាមលើរាងកាយ: សំណុំរឿងលេខ ២០៧០ ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៧។

[៥៩] ជាទូទៅដំណើរការរឿងព្រហ្មទណ្ឌ មានគោលបំណងបង្កើតការទទួលខុសត្រូវរបស់បុគ្គល ចំពោះបទល្មើសព្រហ្មទណ្ឌដែល ចោទប្រកាន់។ បុគ្គលិក OHCHR ដែលឃ្លាំមើលសវនាការ បានសង្កេតឃើញថា ព្រះរាជអាជ្ញាមិនបានបង្ហាញភស្តុតាងអំពី ការជាប់ទាក់ទងរបស់ ចុងចម្លើយទៅនឹងបទព្រហ្មទណ្ឌដែលចោទប្រកាន់ នៅក្នុងដំណាក់កាលណាមួយនៃសវនាការឡើយ ឬក៏បង្ហាញភស្តុតាងណាមួយអំពី វត្ថុដែលពាក់ព័ន្ធនឹងការចោទប្រកាន់អំពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈនោះដែរ។ មិនតែប៉ុណ្ណោះ តុលាការក៏មិនបានពិចារណា បញ្ហាទាក់ទងនឹងការអះអាងការការពារតាមផ្លូវច្បាប់ ដូចជា ការការពារខ្លួន ដែលអាចអនុវត្ត បាននៅក្នុងរឿងក្តីនេះ ដែលអាចផ្តល់ផលប្រយោជន៍ដល់ជនជាប់ចោទ ។ តុលាការ មិនបានយកចិត្តទុកដាក់ពិនិត្យមើល នីត្យានុកូលភាព នៃការបណ្តេញចេញ និងពិនិត្យលើប្រតិបត្តិការរបស់ប៉ូលិសទេ ដែលវាគួរតែជាកត្តាដែលអាច យកមកពន្យល់បាន ក្នុងកំរិតណាមួយ អំពីហេតុការណ៍ផ្ទុះឡើងនៃអំពើហិង្សាកាលពីថ្ងៃទី ២០ ខែមេសា ។ តាមកំនត់ហេតុ OHCHR ។

ផ្អែកលើមូលដ្ឋានច្បាប់ ឬ មូលហេតុសមរម្យឡើយ ហើយធ្វើសេចក្តីសម្រេចដោយលំអៀងទៅអ្នកមានទ្រព្យសម្បត្តិ និងអ្នកមានអំណាច។ ចំពោះការយល់ឃើញនេះ វាអាចដោះស្រាយបានតាមមធ្យោបាយខ្លះ ដូចជាការធានាយ៉ាងខ្ជាប់ខ្ជួនការអនុវត្តតាមនីតិវិធីច្បាប់ និង នីតិវិធីព្រហ្មទណ្ឌដែលមានស្រាប់ ហើយនឹងធ្វើអោយប្រសើរឡើង ការបញ្ចូលសហគមន៍ទៅក្នុងដំណើរការនៃការចរចានិងដំណើរការនៃការបណ្តេញចេញ។

## ៤.៥ ការចូលរួម និង ការរួបរួមគ្នារបស់សហគមន៍

ការចូលរួម និង ការបញ្ចូលប្រជាពលរដ្ឋដែលរងផលប៉ះពាល់ទៅក្នុងដំណើរការ និង ក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលពាក់ព័ន្ធ ឬ ប៉ះពាល់ដល់ពួកគាត់ គឺជាគោលការណ៍ស្នូលនៃច្បាប់សិទ្ធិមនុស្ស និង ជាគន្លឹះក្នុងការធានាដល់ដំណើរការនៃការផ្លាស់ប្តូរទីលំនៅ ប្រកបដោយការចូលរួមនិងនិរន្តរភាព។ ក្រុម និង បុគ្គលទាំងអស់ដែលទទួលរងផលប៉ះពាល់ មានសិទ្ធិទទួលបានព័តមានពាក់ព័ន្ធមានសិទ្ធិទទួលការពិគ្រោះយោបល់ យ៉ាងពេញលេញ និង ចូលរួមក្នុងគ្រប់ដំណើរការទាំងអស់តាំងពីដំបូងរហូតដល់ចប់ ព្រមទាំងមានសិទ្ធិស្នើឡើងនូវជម្រើសផ្សេងៗ ក្រៅពីការបណ្តេញចេញដែលអាជ្ញាធរ គប្បីត្រូវពិចារណាឱ្យបានសព្វគ្រប់។[៦០] ដើម្បីចូលរួមប្រកបដោយអត្ថន័យសហគមន៍ចាំបាច់ត្រូវតែមានភាពរឹងមាំ និង ឯកភាពគ្នាជាផ្លូវមួយ។ ប៉ុន្តែករណីជាច្រើន ដែលបានសិក្សាបង្ហាញថា ការចូលរួមរបស់សហគមន៍ក្នុងដំណើរការមុនពេលបណ្តេញចេញ មានភាពទន់ខ្សោយថែមទាំងមានភាពបែកបាក់គ្នាទៀតផង។

មុនពេលបណ្តេញចេញ ក្រុមគ្រួសារ និងសហគមន៍ទាំងនោះ តែងតែទៅរកអង្គការមិនមែនរដ្ឋាភិបាលនិងអជ្ញាធរពាក់ព័ន្ធ តាំងពីថ្នាក់ឃុំ/សង្កាត់រហូតដល់ថ្នាក់ជាតិ ដោយសង្ឃឹមថា ពួកគេនឹងជួយពួកគាត់ក្នុងការចរចា និងចូលរួមក្នុងកិច្ចពិភាក្សាប្រកបដោយខ្លឹមសារ ចំពោះផែនការនៃការបណ្តេញចេញនោះ។ ទោះបីជាសហគមន៍នានាដូចជាករណីសហគមន៍ក្រុម៧៨ បានខិតខំធ្វើទំនាក់ទំនងជាមួយអាជ្ញាធរ ក្នុងដំណើរការនៃការរៀបចំផែនការក៏ដោយក៏ពួកគាត់នៅតែមិនទទួលបានចម្លើយតបដ៏មានន័យ ឬ ពិតប្រាកដណាមួយម្តងណាឡើយពីអាជ្ញាធរ។

ក្នុងករណីខ្លះ ការពិគ្រោះយោបល់ជាមួយសហគមន៍ ដែលរងផលប៉ះពាល់បានអនុវត្តជារូបភាពប៉ុណ្ណោះ ប៉ុន្តែ សហគមន៍មិនត្រូវបានអនុញ្ញាតឱ្យចូលរួមដ៏មានខ្លឹមសារគ្រប់គ្រាន់នោះទេ។ សហគមន៍នានាដែលបានព្យាយាមចងក្រងគ្នា និងរួបរួម



ប្រជាពលរដ្ឋសហគមន៍ដីក្រហមតវ៉ា ក្នុងឆ្នាំ2007

ជំពូកទី៤

[៦០] គោលការណ៍ណែនាំជាមូលដ្ឋានរបស់អ្នករាយការពិសេស កថាខ័ណ្ឌ៣៨។ សូមមើលកថាខ័ណ្ឌ៣៧ ៣៩ ៥៣ ៥៥ ៥៦(ជ)( ឈ) និង៦៥ ផង។

### ប្រអប់លេខ៦: ផែនការអភិវឌ្ឍន៍នៅនឹងកន្លែងរបស់សហគមន៍ក្រុម៧៨

បទពិសោធន៍ពីប្រជាពលរដ្ឋក្រុម៧៨ អាចត្រូវបានគេមើលឃើញថា ជាគំរូមួយសម្រាប់ការរៀបចំសហគមន៍ និងការចូលរួមក្នុងដំណើរនៃការរៀបចំការផែនការ។ សហគមន៍នេះបានរៀបចំខ្លួនដោយខ្លួនឯង ជាការឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងអំពីការរុះរើលំនៅដ្ឋានលើកទី១ ដែលពួកគាត់បានទទួលនៅឆ្នាំ២០០៦ ដោយបានជ្រើសរើសតំណាងមួយចំនួន និងបានពឹងពាក់ជំនួយផ្នែកច្បាប់ ពីមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍។

វិធីនៃការតស៊ូមតិរបស់សហគមន៍ បាននាំអោយពួកគេមានគំនិតជុំវិញ ផែនការអភិវឌ្ឍន៍នៅនឹងកន្លែង។ គម្រោងផែនការនិងការរៀបចំប្លង់នេះ គឺដោយបានគំនិតពី សហគមន៍ ពុម ម៉ាហាកាន់ នៅក្រុងបាងកក ប្រទេសថៃឡង់ដ៍។[៦១] ដំណើរការនៃគម្រោងនេះមានលក្ខណៈបើកចំហរដោយសហមគន៍ បានធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាល ស្ថាបត្យករ និងអ្នកជំនាញការនគរូបនីយកម្ម ដើម្បីគូរប្លង់ផ្ទាល់ខ្លួន សម្រាប់ផែនការអនាគតរបស់ខ្លួននៅលើទីតាំងនេះ។

សហគមន៍បានបង្ហាញ អំពីគំរោងអភិវឌ្ឍន៍របស់ខ្លួន និងគំរូប្លង់នេះ នៅក្នុងសន្និសីទសារព័ត៌មានមួយ កាលពីខែឧសភា ឆ្នាំ២០០៧ ដែលរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានអញ្ជើញឱ្យចូលរួម។[៦២] គោលបំណងរបស់សហគមន៍គឺ ដើម្បីបង្ហាញពីការខិតខំប្រឹងប្រែងដោយមនសិការ ដើម្បីកែលម្អទីតាំងរបស់ខ្លួន ដោយការអភិវឌ្ឍន៍ជាលំនៅដ្ឋានថ្មីៗ នៅនឹងកន្លែង និងដោយមានការសហការជាមួយអាជ្ញាធរ ដែលនេះជាជម្រើសមួយជំនួសអោយ ការបណ្តេញចេញ និងជាវិធីដែលជួយគាំទ្រដល់គោលបំណងនៃការ "កែលម្អសោភ័ណភាពទីក្រុង" របស់លោកអភិបាលរាជធានី ។ គំរោងអភិវឌ្ឍន៍ និងប្លង់ថតចម្លងជាច្រើនច្បាប់ ភ្ជាប់ជាមួយនឹង តម្លៃចំណាយលើការសាងសង់ផង បានដាក់ជូនសាលារាជធានីភ្នំពេញ ដើម្បីពិនិត្យផងដែរ។ មាន ក្រុមហ៊ុនចំនួនពីរ-បី បានសំដែងចំណាប់អារម្មណ៍ចំពោះគំរោងនេះ( ព្រោះថា សហគមន៍បានបញ្ចូលកិច្ចព្រមព្រៀងសាងសង់ប្រវាសដី ដែលផ្តល់ផលប្រយោជន៍ដល់ក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន) ក៏ប៉ុន្តែដោយសារគ្មានការ យល់ព្រមនិងអនុញ្ញាតិ ពីសាលារាជធានីភ្នំពេញ រាល់សកម្មភាពរបស់គម្រោងនេះមិនអាចទៅមុខរួចទេ។

រដ្ឋាភិបាលបានឆ្លើយតប ចំពោះសំណើរសុំរបស់សហគមន៍យ៉ាងឆាប់បំផុត និងដោយច្រានចោលសំណើរនេះ ។ សាលារាជធានីភ្នំពេញបានបញ្ជាក់ថា ដីដែលប្រជាពលរដ្ឋក្រុម៧៨កំពុងរស់នៅ គឺជា "ដីរបស់រដ្ឋ" ហើយត្រូវបានដាក់បញ្ចូលទៅក្នុងផែនការមេ ឆ្នាំ២០២០ របស់រាជធានី សម្រាប់ការកសាងផ្លូវ ដើម្បីធ្វើស្ពានឆ្លងភ្ជាប់ទៅកោះពេជ្រ ដូច្នេះហើយផែនការអភិវឌ្ឍន៍នៅនឹងកន្លែងមិនអាចទៅរួចទេ។[៦៣] សហគមន៍ នឹងមេធាវីរបស់ខ្លួនបានបន្តការចរចាជាមួយសាលារាជធានីភ្នំពេញ ឱ្យគាំទ្រដល់ផែនការអភិវឌ្ឍន៍នៅនឹងកន្លែងនេះ។ ផ្ទុយទៅវិញ សហគមន៍ទទួលបាននូវសេចក្តីជូនដំណឹងមួយទៀតអំពីការរុះរើលំនៅដ្ឋាន ហើយអាជ្ញាធរក្រុង និងអជ្ញាធរមូលដ្ឋានបានកម្រិតការពិភាក្សាជាមួយសហគមន៍ ដោយធ្វើការចរចាតែលើបញ្ហាសំណង និងការតាំងទីលំនៅថ្មីប៉ុណ្ណោះ។ ដោយសារតែសម្ពាធទៅលើសហគមន៍កាន់តែធ្ងន់ទៅៗ សមាជិកសហគមន៍ខ្លះបានចាប់ផ្តើមចាកចេញពីទីតាំងនោះ។ ឯសមាជិកសហគមន៍ដទៃទៀតនៅបន្តការតស៊ូមតិរបស់ខ្លួន ដើម្បីការអភិវឌ្ឍន៍នៅនឹងកន្លែង ប៉ុន្តែទោះជាមានការប្រឹងប្រែងយ៉ាងនេះក៏ដោយ ក៏ប្រជាពលរដ្ឋនៅសល់ទាំងអស់ត្រូវបាន

ពន្យល់

[៦១] សហគមន៍ ពុម ម៉ាហាកាន នៅទីក្រុងបាងកក ប្រទេសថៃឡង់ដ៍ បានចរចាដោយជោគជ័យជាមួយអាជ្ញាធរពាក់ព័ន្ធលើគំរោង ដែលផ្អែកលើផែនការជួសជុលកែលំអរ ទីតាំងដែលពួកគេរស់នៅ ដោយផ្ទាល់ខ្លួនរបស់ពួកគេ។

[៦២] ប្លង់ព្រាងជាច្រើនត្រូវបានរៀបចំ និងកែសម្រួលឡើងវិញ នៅចុងខែ មីនា ឆ្នាំ ២០០៧។ និស្សិតខាងស្ថាបត្យកម្ម បានរៀបចំគូរប្លង់ ដែល ប្លង់ព្រាងនេះបង្ហាញពី អគារប្រាំខ្នង កំពស់បួនជាន់ និងមានច្រើនបន្ទប់នៅលើទីតាំងនោះ។ គេត្រូវការតែបីអគារកន្លះប៉ុណ្ណោះ សម្រាប់អាចអោយប្រជាពលរដ្ឋក្រុម៧៨រស់នៅបានសមរម្យ ហើយអគារដែលនៅសល់ អាចឱ្យទៅក្រុមហ៊ុនអភិវឌ្ឍន៍ដែលជាការលើកទឹកចិត្តមួយដល់ក្រុមហ៊ុន អនុវត្តការសាងសង់។

[៦៣] សេចក្តីថ្លែងការណ៍ ជូនចំពោះប្រជាពលរដ្ឋក្រុម៧៨ និង លិខិតឆ្លើយឆ្លងឯកជន ខែកក្កដា ឆ្នាំ ២០០៦ ផ្ញើទៅ OHCHR ។

គ្នាដើម្បីទប់ស្កាត់ការបណ្តេញចេញ បានចុះខ្សោយទៅៗ និងងាយបែកបាក់គ្នាណាស់ដោយសារ បញ្ហាផលប្រយោជន៍ផ្សេងគ្នា និងដោយសារតែមានសម្ពាធ និងការបង្ខិតបង្ខំពីក្រុមហ៊ុន និងបុគ្គលមន្ត្រីមានសមត្ថកិច្ច ។ បន្ទាប់មកទៀត កិច្ចចរចាបានប្រព្រឹត្តទៅរវាងបុគ្គលម្នាក់ៗ ជាជាងប្រព្រឹត្តទៅដោយការចូលរួមក្នុងនាមសហគមន៍ទាំងមូល ។ ពេលខ្លះកិច្ចចរចា ក៏ត្រូវបញ្ឈប់ភ្លាមៗដោយគ្មានមូលហេតុត្រឹមត្រូវទេ និងប្រព្រឹត្តទៅដោយគ្មានតម្លាភាព ដូចជាក្នុងករណីដីក្រហម។ សាលារាជធានីភ្នំពេញ គឺជាភាគីចរចា តែមួយគត់ជាមួយប្រជាពលរដ្ឋដីក្រហម ទោះបីពួកគេស្នើសុំអោយមានការចរចាជាមួយក្រុមហ៊ុន7NG (ជាអ្នកទទួលបានដីពីពួកគេ) ផ្ទាល់ក៏ដោយ ។ នៅពាក់កណ្តាលខែមករា ឆ្នាំ ២០០៩ នៅកំឡុងពេលចរចាដោយធ្វើឡើងមួយគ្រាសារម្តងៗ សាលារាជធានី និង ក្រុមហ៊ុន 7NG បានប្រកាសជាបន្ទាន់ថា សំណងជាចុងក្រោយដែលគេអាចផ្តល់អោយគឺ ២០,០០០ដុល្លារអាមេរិក។ ពីរបីថ្ងៃក្រោយពីប្រជាពលរដ្ឋ បានដាក់សំណើសុំយកសំណងតាមការប្រកាសនេះ ឬទាមទារលើសពីចំនួននេះ ស្រាប់តែពួកគេត្រូវបានប្រាប់វិញថា "ទ្វារបានបិទទៅហើយ"។ ហើយប្រជាពលរដ្ឋទាំងនោះមិនមានត្រូវបានផ្តល់លទ្ធភាពបន្តការចរចាបានទៀតទេ។ [៦៩]

ករណីសហគមន៍អភិវឌ្ឍន៍មានជ័យ (សូមមើលប្រអប់លេខ៧ខាងក្រោម) ដែលបានចូលរួមក្នុងកិច្ចពិភាក្សាពីការផ្លាស់ប្តូរលំនៅដ្ឋាន ជាមួយអាជ្ញាធរ អង្គការមិនមែនរដ្ឋាភិបាលនិងមជ្ឈមណ្ឌលសហប្រជាជាតិដើម្បីលំនៅដ្ឋាន គឺជាករណីលើកលែង និង ជាគំរូល្អមួយដែលគួរយកតម្រាប់តាម។

[៦៩] ការបណ្តេញចេញបានកើតឡើងនៅ១០ថ្ងៃបន្ទាប់ មក ហើយអ្នកដែលត្រូវគេបណ្តេញចេញទទួលបានតែផ្ទះមួយល្វែងនៅ ដំណាក់ត្រយឹង ជំនួសសំណងជាប្រាក់ ដែលពួកគេបានស្នើសុំ ។ ឯកសារផ្ទៃក្នុង OHCHR ( ឆ្នាំ២០០៨-២០០៩) និង របាយការណ៍លីកាដូ អំពីដីក្រហម ។

# ៥

# ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី

ជំពូកនេះពិនិត្យស្ថានភាពរស់នៅនិងលំនៅដ្ឋានរបស់ក្រុមគ្រួសារ នៅតាមកន្លែង ដែលត្រូវបានតាំងទីលំនៅថ្មី។ ដោយឡែក អ្វីដែលជាការគួរឱ្យកត់សម្គាល់ គឺ ស្ថានភាពរស់នៅ របស់គ្រួសារ នៅតាមទីតាំងដែលស្ថិតក្រោមការសិក្សានេះ គឺមានសភាពយ៉ាប់យឺនជាង ស្ថានភាពពីមុនពេលបណ្តេញចេញទៅទៀត ជាពិសេសលើជីវភាពរស់នៅ សន្តិសុខស្បៀង និងលំនៅដ្ឋាន។

ស្ថានភាពរស់នៅត្រូវបានវាយតម្លៃទៅតាមប្រធានបទដូចខាងក្រោម:

- ផ្នែកទី៥.១ ពិនិត្យពីស្ថានភាពលំនៅដ្ឋាន
- ផ្នែកទី៥.២ ពិនិត្យមើលលទ្ធភាពប្រើប្រាស់ទឹកស្អាត និងអនាម័យ
- ផ្នែកទី៥.៣ ពិភាក្សាអំពីសុវត្ថិភាពខាងការកាន់កាប់ដីធ្លី និងកង្វះខាតភាពច្បាស់លាស់ទាក់ទងនឹងការសន្យាផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី
- ផ្នែកទី៥.៤ ពិភាក្សាអំពី ជីវភាពរស់នៅ និងឱកាសការងារ ព្រមទាំងមធ្យោបាយនានាដែលប្រជាពលរដ្ឋខិតខំជំនះលើបញ្ហាគ្មានការងារ និងកង្វះខាតប្រាក់ចំណូល
- ផ្នែកទី៥.៥ បង្ហាញពីវិសាលភាពនៃអសុវត្ថិភាពស្បៀង នៅកន្លែងតាំងទីលំនៅថ្មី
- ផ្នែកទី៥.៦ ពិភាក្សាអំពីបញ្ហាសុខភាព ដោយផ្តោតសំខាន់ទៅលើស្ថានភាពរបស់ប្រជាពលរដ្ឋដែលជាអ្នកអ្នកជំងឺអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍
- ផ្នែកទី៥.៧ ពិភាក្សាអំពីផលប៉ះពាល់លើការអប់រំ ដោយសារការតាំងទីលំនៅថ្មី
- ផ្នែកទី៥.៨ ពិនិត្យបញ្ហានានា ទាក់ទងនឹង បញ្ហាស៊ីវិល និង រដ្ឋបាល ដូចជា ការបោះឆ្នោត។
- ផ្នែកទី ៥.៩ ពិភាក្សាអំពី ការចូលរួម និងសមាហរណកម្មទៅក្នុងសង្គមរបស់សហគមន៍នៅតាមកន្លែងតាំងទីលំនៅថ្មី

ឧទាហរណ៍អំពីសហគមន៍អភិវឌ្ឍន៍មានជ័យ ត្រូវបានពិភាក្សាដោយឡែក នៅក្នុងប្រអប់លេខ៧ ដែលវាអាចជាតំណាងអោយដំណើរការល្អនៃការតាំងទីលំនៅថ្មី។



# ជំពូកទី៥ ៖
# ការចាប់ផ្ដើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី

## សេចក្ដីផ្ដើម

តាមការសិក្សានេះបានបង្ហាញថា គ្រួសារប្រជាពលរដ្ឋ នៅតាមកន្លែងតាំងទីលំនៅថ្មី ជួបប្រទះបញ្ហាលំបាក ប្រហាក់ប្រហែលគ្នាជាច្រើន ទាំងបញ្ហាចំពោះមុខភ្លាមៗ បន្ទាប់ពីការបណ្ដេញចេញ និងបញ្ហាក្នុងពេលច្រើនឆ្នាំខាងមុខទៀត។ ជាការគួរឱ្យកត់សម្គាល់នោះ លើកលែងតែ ករណីដូចជា សហគមន៍អភិវឌ្ឍន៍មានជ័យ និងថ្មីៗនេះទៀត ក្រុមគ្រួសារប្រជាពលរដ្ឋនៅទួលសំបូរ ចេញ គឺស្ថានភាពរស់នៅសម្រាប់គ្រួសារ ដែលបានផ្លាស់ប្ដូរទីតាំងថ្មីទាំងនេះ មានសភាពយ៉ាប់យ៉ឺនជាងស្ថានភាពមុនពេលមានការបណ្ដេញចេញ។ ចំពោះគ្រួសារខ្លះ ពិតជាជួបស្ថានភាពខុសគ្នាយ៉ាងខ្លាំងដ៏គួរកត់សម្គាល់ ឧទាហរណ៍ដូចជា គ្រួសារប្រជាពលរដ្ឋនៅស្ពានឆេះ គឺពួកគេមានលំនៅដ្ឋាន និងរស់នៅក្នុងជីវភាពសមរម្យ មុនពេលមានការបណ្ដេញចេញ ប៉ុន្តែតាំងពីពេលបណ្ដេញចេញមក ពួកគេបាន និងកំពុងរស់នៅក្នុងជីវភាពដុនដាបលើដីដែលគ្មានអ្វីសោះនៅតាមចិញ្ចើមថ្នល់។

ស្ថានភាពរស់នៅត្រូវបានវាយតម្លៃទៅតាមប្រធានបទផ្សេងៗ ដើម្បីបង្ហាញពីទិដ្ឋភាពនៃធាតុសំខាន់ៗទាំងអស់ដែលប៉ះពាល់ដល់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋ ដែលរាប់តាំងពីលំនៅដ្ឋានសមរម្យ សេវាចាំបាច់និងហេដ្ឋារចនាសម្ព័ន្ធ សុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ជីវភាពរស់នៅ និងឱកាសការងារ សន្តិសុខស្បៀងអាហារ សុខភាព ការអប់រំ បញ្ហាផ្នែកស៊ីវិល និង ការចូលរួមទៅក្នុងសង្គម។ ឧទាហរណ៍នៃករណី សហគមន៍អភិវឌ្ឍន៍មានជ័យ ត្រូវបានពន្យល់ដោយឡែកនៅក្នុងប្រអប់លេខ៧ ដែលបង្ហាញពីដំណើរការល្អ ក្នុងការតាំងទីលំនៅថ្មី ដែលមានការចូលរួម គោរពតាមការជ្រើសរបស់សហគមន៍ (ដូចជា ទីតាំងនៃកន្លែងតាំងទីលំនៅថ្មី) និងទុកពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើផែនការ និងការរៀបចំ។

## ៥.១ លំនៅដ្ឋានសមរម្យ

សិទ្ធិមានលំនៅដ្ឋានសមរម្យ មានសមាសធាតុ ៧ ចំនុច (សូមមើលប្រអប់លេខ៨) ដែល រដ្ឋាភិបាលជាអ្នកទទួលខុសត្រូវជាចម្បង ធានាអោយមានសមាសធាតុទាំងនេះ ។ ក្រុមគ្រួសារ ដែលបានតាំងទីលំនៅថ្មី បានសង្កត់ធ្ងន់លើសមាសធាតុ ប្រាំនៃសិទ្ធិមានលំនៅដ្ឋានសមរម្យ ថាមានសារៈសំខាន់ជាពិសេសចំពោះពួកគេដែលរួមមាន ភាពអាចមានបាន ភាពអាចលៃលកទិញបាន ភាពអាចរស់នៅបាន ភាពសមស្របនៃទីតាំង និងសុវត្ថិភាពខាងការកាន់កាប់ដីធ្លី។ ទីតាំង នឹងត្រូវលើកយកមកពិភាក្សា

ក្រោមប្រធានបទ ឱកាសការងារ (ក្នុងផ្នែកទី៥.៨) ចំនែកឯសុវត្ថិភាពខាងការកាន់កាប់ដីធ្លី នឹងពិភាក្សាក្នុងផ្នែកដាច់ដោយឡែក គឺផ្នែក៥.៣ ដោយសារតែសារៈសំខាន់របស់ចំនុចនេះ ក្នុងបរិបទនៃប្រទេសកម្ពុជា។ តាមច្បាប់អន្តរជាតិស្តីពី សិទ្ធិមនុស្ស គ្មានជនណាម្នាក់ ត្រូវគេធ្វើអោយមានស្ថានភាពយ៉ាប់យឺន ក្រោយពីការបណ្តេញចេញនោះទេ ហើយបទដ្ឋានអប្បបរមានៃភាពសមរម្យនៃលំនៅដ្ឋាន ត្រូវតែបានធានាគ្រប់ពេលវេលា ។

### *ទំហំនិងហេដ្ឋារចនាសម្ព័ន្ធលំនៅដ្ឋាន*

ភាគច្រើននៃករណីក្រោមការសិក្សាឃើញថា លំនៅដ្ឋាននៅកន្លែងតាំងទីលំនៅថ្មី មិនមាន លក្ខណៈសមរម្យទេ។ ជាការពិត ចំពោះករណីដែលយើងបានពិនិត្យជាច្រើន គឺមិនមានទីជម្រក ឬលំនៅដ្ឋានណាមួយ ត្រូវបានផ្តល់ជូនក្រុមគ្រួសារប្រជាពលរដ្ឋនៅទីតាំងថ្មីនោះទេ។ ក្នុងករណីដែលមានសង់ទីជម្រកអោយ គឺគេមិនបានបំពេញតាមលក្ខខ័ណ្ឌ និងតម្រូវការផ្សេងៗគ្នារបស់ប្រជាពលរដ្ឋដែលទទួលផលប៉ះពាល់ទេ ឧទាហរណ៍ ប្រជាពលរដ្ឋជាអ្នកជំងឺអេដស៍ ឬ ក្រុមគ្រួសារមានចំនួនសមាជិកច្រើន ដែលត្រូវការទំហំទីកន្លែងរស់នៅធំ ។ ទំហំដីឡូត៍ ឬលំនៅដ្ឋានដែលបានផ្តល់អោយគ្រួសារប្រជាពលរដ្ឋ ជាទូទៅមានកំរិតក្រោម បទដ្ឋានបច្ចេកទេសសំណង់ ដែលបានកំណត់ដោយក្រសួងរៀបចំដែនដី (ដោយហេតុថា ផ្ទះល្វែងនៅតំបន់ទីក្រុង គប្បីមានទំហំយ៉ាងហោចណាស់ ១២ម៉ែតក្រឡា សម្រាប់មនុស្សម្នាក់ រួមទាំងបង្គន់ផង) ។[៦៥]

### ប្រអប់លេខ៧: សមាសធាតុនៃសិទ្ធិមានលំនៅដ្ឋានសមរម្យ[៦៦]

- *សុវត្ថិភាពខាងការកាន់កាប់ដីធ្លី:* លំនៅដ្ឋានមានលក្ខណៈមិនសមរម្យទេ ប្រសិនបើអ្នក កាន់កាប់ មិនមានសុវត្ថិភាពខាងការកាន់កាប់ដីធ្លី ក្នុងកម្រិតណាមួយ ដែលធានាដល់ ការការពារតាមផ្លូវច្បាប់ មិនឱ្យមានការបណ្តេញចេញដោយបំពាន ការរំខាន និងកត្តា គំរាមកំហែងផ្សេងៗទៀត
- *ភាពអាចមានបាន នៃសេវាកម្ម* សម្ភារៈ អគារ និងហេដ្ឋារចនាសម្ព័ន្ធៈ លំនៅដ្ឋានមានលក្ខណៈ មិនសមរម្យទេ ប្រសិនបើអ្នកកាន់កាប់ គ្មានទឹកផឹកដែល មានសុវត្ថិភាព អនាម័យសមរម្យ ថាមពលសម្រាប់ចំអិនអាហារ គ្រឿងឧបករណ៍ សំរាប់កំដៅ គ្រឿងឧបករណ៍សំរាប់បំភ្លឺ មធ្យោបាយរក្សាទុកម្ហូបអាហារ ឬក៏សេវា ចោលសំរាម
- *ភាពអាចលៃលកបាន:* លំនៅដ្ឋានមិនសមរម្យទេ ប្រសិនបើតំលៃផ្ទះគំរាមកំហែង ឬ ធ្វើអោយមានផលអាក្រក់ដែលប៉ះពាល់ដល់សិទ្ធិមនុស្សផ្សេងៗទៀត
- *ភាពអាចរស់នៅបាន:* លំនៅដ្ឋានមិនសមរម្យទេ ប្រសិនបើវាមិនធានាសុវត្ថិភាព ផ្លូវកាយ ឬផ្តល់ទីធ្លាគ្រប់គ្រាន់ព្រមទាំងការពារទប់ទល់នឹងអាកាសធាតុត្រជាក់ សំណើម កំដៅ ភ្លៀង ខ្យល់ ការគំរាមកំហែងផ្សេងទៀតដល់សុខភាព និង អន្តរាយខាងរចនាសម្ព័ន្ធ
- *ភាពអាចទៅប្រើប្រាស់បាន:* លំនៅដ្ឋានមិនសមរម្យទេ ប្រសិនបើតម្រូវការជាក់លាក់ របស់ក្រុមប្រជាពលរដ្ឋដែលបាត់បង់សមត្ថភាព និងទន់ខ្សោយ មិនត្រូវបានគេគិតគូរទេ
- *ទីតាំង:* លំនៅដ្ឋានមិនសមរម្យទេ ប្រសិនបើវាត្រូវបានកាត់ផ្តាច់ចេញ ពីឱកាសការងារ សេវាថែទាំសុខភាព សាលារៀន មជ្ឈមណ្ឌលគាំពារទារកនិងកុមារ និងកន្លែងផ្តល់សេវាសង្គមផ្សេងៗទៀត ឬប្រសិនបើវាស្ថិតក្នុងតំបន់មានបរិស្ថានកខ្វក់ ឬតំបន់មានគ្រោះថ្នាក់។
- *ភាពសមស្របផ្នែកវប្បធម៌:* លំនៅដ្ឋានមិនសមរម្យទេ ប្រសិនបើវាមិនគោរព និង មិនត្រូវបានគេគិតអំពីអត្តសញ្ញាណវប្បធម៌ទេ។

[៦៥] បច្ចុប្បន្ននេះ គ្មានបទដ្ឋានជាក់លាក់ សំរាប់ តំបន់ក្រៅក្រុងទីក្រុងទេ តាមពត៌មានពីក្រសួងរៀបចំដែនដី នគរូបណីយកម្ម និងសំណង់។

[៦៦] CESCR សេចក្តីពន្យល់រួមលេខ៤ និងលេខ៧។

# ជំពូទី៥ ៖ ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី

**ប្រអប់លេខ៨: សហគមន៍អភិវឌ្ឍន៍មានជ័យលទ្ធផលជាវិជ្ជមាននៅពេលដែលអាជ្ញាធរ សហគមន៍ និងអង្គការនានាធ្វើការរួមគ្នា**

*សាវតារ*

សហគមន៍អភិវឌ្ឍន៍មានជ័យ ដែលគេស្គាល់ផងដែរថា **វេង ស្រេង** ស្ថិតនៅចម្ងាយ៥គ.ម ភាគនិរតីនៃរាជធានីភ្នំពេញ។ ទីតាំងនេះត្រូវបានគេជ្រើសរើសក្នុងឆ្នាំ១៩៩៧ សម្រាប់ផ្លាស់ប្តូរ ទីលំនៅប្រជាពលរដ្ឋចំនួន ១២៩គ្រួសារ ដែលកំពុងរស់នៅលើផ្លូវក្បែរស្ពានទួតចិន ក្នុងសង្កាត់ ទួលស្វាយព្រៃ ឱ្យទៅរស់នៅ។ សហគមន៍នេះបាន ប្រឈមនឹងការគំរាមកំហែងបណ្តេញចេញ នៅឆ្នាំ១៩៩៦ ក្នុងអំឡុងពេលបុណ្យចូលឆ្នាំខ្មែរ គឺនៅពេលដែលគ្រឿងចក្រដីមួយគ្រឿង បានប៉ុនប៉ងឈូសឆាយលំនៅដ្ឋាន សម្រាប់គម្រោងធ្វើលូបង្ហូរទឹកសម្អុយ ដោយគ្មាន សេចក្តីជូនដំណឹងជាមុនឡើយ។ សហគមន៍នេះក៏ស្នើសុំឱ្យអាជ្ញាធរមូលដ្ឋានរកជម្រើសផ្សេងពី ការបណ្តេញចេញនេះ ហើយក៏មានការឯកភាពគ្នា។ មេដឹកនាំសហគមន៍ក៏បានស្វះស្វែងរក ជំនួយគាំទ្រពីអង្គការនានា រួមមាន សម្ព័ន្ធសិទ្ធិលំនៅដ្ឋានអាស៊ី(ACHR) និងមជ្ឈមណ្ឌល សហប្រជាជាតិដើម្បីលំនៅដ្ឋាន (បច្ចុប្បន្ន UN Habitat)។

*ការចូលរួម និងការគាំទ្រពីសាលារាជធានីភ្នំពេញ*

កិច្ចពិភាក្សារវាងសហគមន៍និងសាលារាជធានីភ្នំពេញ ដែលសម្របសម្រួលដោយ មជ្ឈមណ្ឌលសហប្រជាជាតិដើម្បីលំនៅដ្ឋាន បានប្រព្រឹត្តទៅពីរលើក គឺនៅខែឧសភា និងខែសីហា ឆ្នាំ១៩៩៦។ សាលារាជធានីភ្នំពេញ ដំបូងបានស្នើផ្តល់ប្រាក់២០០ដុល្លារ សម្រាប់មួយគ្រួសារនីមួយៗ ប៉ុន្តែសហគមន៍បាន បដិសេធន៍ សំណើរនេះ ដោយពួកគាត់ស្នើសុំដីជំនួសប្រាក់នោះ វិញ។ មេដឹកនាំសហគមន៍បានស្នើសុំឱ្យ អភិបាលរាជធានី ជួយផ្តល់ប្រាក់បន្ថែមបន្តិចទៀតពីលើចំនួនប្រាក់ដែលគិតផ្តល់អោយគ្រួសារ ទាំងអស់សរុបទៅស្មើនឹង ២៥,៣០០ដុល្លារ ដើម្បីឱ្យសហគមន៍អាចមានលទ្ធភាពទិញដី មួយកន្លែង។ ជាការឆ្លើយតបលោកអភិបាលរាជធានីបាន ស្នើផ្តល់ដីមួយកន្លែនៅឯទួលសំបូរ ឬនៅអន្លង់គង ប៉ុន្តែសហគមន៍បានបដិសេធ ហើយបានស្នើសុំការអនុញ្ញាត រកដីដែល សមស្រប ដោយខ្លួនឯងវិញ។ បន្ទាប់មកទៀត លោកអភិបាលបានយល់ព្រមផ្តល់ប្រាក់ ៣០.០០០ដុល្លារ ដល់សហគមន៍ ដើម្បីទិញដី។ ចំណែកឯអង្គការពាក់ព័ន្ធដទៃទៀត បានយល់ព្រមផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ដំណើរការតាំងទីលំនៅថ្មីនេះ។ ក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៧ កិច្ចព្រមព្រៀងមួយត្រូវបានចុះហត្ថលេខា រវាងភាគីពាក់ព័ន្ធ។

*ការចូលរួមយ៉ាងពេញលេញរបស់សហគមន៍ និងការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ*

តាំងពីដើមឆ្នាំ១៩៩៦មក សមាជិកសហគមន៍បានបង្កើតជាក្រុមសន្សំប្រាក់មួយ ក្រោមការជួយ ពីសហព័ន្ធសាមគ្គីភាព សហគមន៍អ្នកក្រីក្រក្នុងទីក្រុង (SUPF) ដែលវាទំនងជាបានពង្រឹង សមត្ថភាពរបស់សហគមន៍ ក្នុងការរៀបចំបន្ថែមទៀត។ សមាជិកសហគមន៍ដោយមាន ការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល និងមជ្ឈមណ្ឌលសហប្រជាជាតិដើម្បីលំនៅដ្ឋានបាន ពិនិត្យទីតាំងដីជាច្រើនកន្លែង ហើយនៅទីបំផុត ក៏បានសម្រេចចិត្តយកទីតាំងមួយកន្លែងដែលស្ថិតនៅចម្ងាយ៥គ.ម ពីទីតាំងចាស់ ដោយមានតម្លៃទាប គឺ ៣ ដុល្លារក្នុងមួយម៉ែត្រការេ ។ ទំហំដីនោះ អាចផ្តល់ដីទំហំ៤៥ម$^{២}$សម្រាប់មួយគ្រួសារៗ។

គណៈកម្មាធិការសហគមន៍ ត្រូវបានបង្កើតឡើង ដើម្បីចាត់ចែងការងារ ដូចជា ការរៀបចំប្លង់ និងហេដ្ឋារចនាសម្ព័ន្ធ និងដើម្បីអនុវត្តកិច្ចសន្យានានារវាងសហគមន៍ និង មជ្ឈមណ្ឌលសហប្រជាជាតិដើម្បីលំនៅដ្ឋាន ។ អង្គការពាក់ព័ន្ធផ្សេងៗ និងមជ្ឈមណ្ឌលសហប្រជាជាតិ ដើម្បីលំនៅដ្ឋាន បានបណ្តុះបណ្តាលផ្នែកបច្ចេកទេសដល់សមាជិកសហគមន៍ (ដូចជាការផលិត ឥដ្ឋ) ហើយបង់ថ្លៃឈ្នួលការងារដល់ ពួកគាត់នៅឯការដ្ឋានសាងសង់។ អាជ្ញាធរមូលដ្ឋានបាន ជួយផ្តល់ការការពារសន្តិសុខ និងសុវត្ថិភាព។ ការរៀបចំរចនាប្លង់លំនៅដ្ឋាន និងទីតាំង លំនៅដ្ឋានថ្មីទាំងមូល មានការចូលរួមយ៉ាងពេញលេញពីសមាជិកសហគមន៍។ គ្រួសារប្រជាពលរដ្ឋភាគច្រើនបានផ្លាស់មកទីតាំងថ្មីនេះ កាលពីខែមករា ឆ្នាំ១៩៩៩ ដោយមាន ជំនួយពីសាលារាជធានីភ្នំពេញ និងនៅពេលដែលការងារហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និង អនាម័យត្រូវបានបញ្ចប់។ ក្នុងខែមេសា ឆ្នាំ២០០០ "សហគមន៍អភិវឌ្ឍន៍មានជ័យ" ត្រូវបានសម្ពោធជាផ្លូវការ ដោយនាយករដ្ឋមន្ត្រី។

*លទ្ធផល:*

*ការពេញចិត្ត និងការបន្តរស់នៅលើទីតាំងថ្មី មានកំរិតខ្ពស់:* ប្រជាពលរដ្ឋដែលបានផ្តល់ បទសម្ភាសន៍ក៏ជាទូទៅបាននិយាយថា ពួកគាត់ពេញចិត្តនឹងដំណើរការ និងលទ្ធផលនៃការតាំងទី លំនៅថ្មីនេះ។ ពួកគាត់បានបញ្ជាក់ថា តាំងពីមករស់នៅទីតាំងថ្មីនេះមក ពួកគាត់មានចំណង ខាងសង្គមយ៉ាងរឹងមាំ និងមានឱកាសការងារជាច្រើន។ ប្រជាពលរដ្ឋ ដឹងគុណចំពោះ សាលា រាជធានី

---

[៦៧] ក្នុងឆ្នាំ២០០០ អាជ្ញាមូលដ្ឋានបានចេញសៀវភៅស្នាក់នៅឱ្យគ្រួសារនីមួយៗ។ ក្នុងឆ្នាំ ២០០២ សហគមន៍ទទួលបាន "ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ" ដែលចេញដោយមន្ទីររៀបចំដែនដី រាជធានីភ្នំពេញ។ ក្នុងឆ្នាំ ២០០៩ សហគមន៍នេះ ទទួលបានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ (ប្លង់ដី( តាមរយៈការចុះបញ្ជីដីមានលក្ខណ:ជាប្រព័ន្ធ។

## ជំពូទី៥ ៖ ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី



លំនៅដ្ឋាននៅអភិវឌ្ឍន៍មានជ័យ, ទួលសំបូរ, និង ដំណាក់ត្រយឹង ,ថ្លែងអំណរគុណចំពោះការថតរូបដោយ: OHCHR និង LICADHO

គំរូដែលល្អបំផុត មានបង្ហាញច្បាស់ក្នុងករណីសហគមន៍អភិវឌ្ឍន៍មានជ័យ(សូមមើលប្រអប់លេខ៧)។ នៅក្នុងករណីនេះ សហគមន៍ បានចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តអំពី ទំហំដីឡូត៍ និង លំនៅដ្ឋាន ការគូរប្លង់ និង ប្រភេទលំនៅដ្ឋាន សម្ភារប្រើប្រាស់ និងលំនៅដ្ឋានត្រូវបានសាងសង់ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងជំនួយបច្ចេកទេស ពីអាជ្ញាធររាជធានី អង្គការមិនមែនរដ្ឋាភិបាល និង អង្គការសហប្រជាជាតិ។

ក្នុងករណីអណ្តូង (សូមមើលប្រអប់លេខ៩) ករណី អាជីវករលក់ដូរ និងអ្នកជួលផ្ទះ មកពីសហគមន៍ដីក្រហម ស្ពានឆេះ អូរកម្ពុជា និងត្រពាំងអញ្ចាញ ប្រជាពលរដ្ឋត្រូវបានគេដាក់ឱ្យនៅលើដីទទេ ដោយគ្មានទីជម្រក សេវា ឬ ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗឡើយ។ គ្មានការតភ្ជាប់ប្រព័ន្ធផ្គត់ផ្គង់ទឹក អគ្គិសនី និងគ្មានអនាម័យទេ។ នៅក្នុងទីតាំងទាំងនេះ ប្រជាពលរដ្ឋត្រូវតែសង់លំនៅដ្ឋានរបស់ពួកគាត់ដោយខ្លួនឯង ដោយមានការជួយឧបត្ថម្ភពីអង្គការមិនមែនរដ្ឋាភិបាលជាចំបង(សូមមើលផ្នែកភាពគ្មានផ្ទះសំបែង និងដីធ្លីទំព័រទី ៦៣)។

នៅឯដំណាក់ត្រយឹង និងទួលសំបូរ ផ្ទះល្វែង ឬទីជម្រក ត្រូវបានសាងសង់ (ដោយក្រុមហ៊ុន 7NG នៅដំណាក់ត្រយឹង និងដោយសាលារាជធានីភ្នំពេញ នៅទួលសំបូរ) មុនពេលប្រជាពលរដ្ឋបានផ្លាស់មកទីតាំងទាំងនេះ។ ផ្ទះល្វែង ឬ ទីជម្រក ផ្តល់ការការពារជាអប្បបរមា ទប់ទល់នឹងលក្ខខ័ណ្ឌអាកាសធាតុ ប៉ុន្តែសម្រាប់ដំណោះស្រាយរយៈពេលយូរអង្វែង លំនៅដ្ឋានទាំងនេះត្រូវការកែលម្អ ដើម្បីផ្តល់ភាពដែលអាចរស់នៅបាន និង ស្ថានភាពសមរម្យ សម្រាប់ក្រុមគ្រួសារទាំងនោះ។

ផ្ទះល្វែងនៅឯ ដំណាក់ត្រយឹង មានទំហំ (៤ X១០=40 ម៉ែត្រការ៉េ) (មានបង្គន់នៅក្រៅផ្ទះ ភ្ជាប់នឹងតួផ្ទះផ្នែកខាងក្រោយ)។ ប្រជាពលរដ្ឋបានត្អូញត្អែរអំពីគុណភាពអន់នៃលំនៅដ្ឋាននោះ និង ការបារម្ភអំពីបញ្ហាសន្តិសុខ ដោយសារបង្គន់នៅខាងក្រៅផ្ទះ។ ពួកគាត់ក៏ បាននិយាយដែរថា ទឹកលិចតាមដំបូលនៅពេលមានភ្លៀង។ ម៉្យាងទៀត គ្រួសារមួយចំនួន ដែលទទួលបានផ្ទះល្វែង ប៉ុន្មានសប្តាហ៍ក្រោយការបណ្តេញចេញកាលពីខែមករា ឆ្នាំ២០០៩ មិនមានទឹកប្រើប្រាស់ ដែលតភ្ជាប់ពីបណ្តាញទឹកនៅទីនោះទេ។ គ្រួសារខ្លះបានធ្វើការជួសជុលកែលំអរផ្ទះល្វែងទាំងនោះ រួមមាន តដំបូលបន្ថែមខាងមុខផ្ទះដើម្បីកាត់បន្ថយកំដៅ សង់ភ្ជាប់បង្គន់ អោយនៅក្នុងតួផ្ទះវិញ និងសង់បន្ថែមឡៅតឿ ឬសង់បន្ថែមមួយជាន់ទៀត ដើម្បីតំរូវទៅនឹងសមាជិកគ្រួសារដែលមានគ្នាច្រើន។

នៅឯទួលសំបូរ អាគារប្រក់ដំបូល និងជញ្ជាំងស័ង្កសីចំនួន៦អាគារ ដែលអាគារនីមួយៗមានដប់បន្ទប់ ត្រូវបានសាងសង់ឡើងសម្រាប់ប្រជាពលរដ្ឋ៤២គ្រួសារដែលជាអ្នកជំងឺអេសដ៍ និង

# ជំពូទី៥ ៖ ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី

**ប្រអប់លេខ៩: គម្រោងសាងសង់លំនៅដ្ឋាននៅ អណ្តូង**

ដោយសារ ក្រុមគ្រួសារប្រជាពលរដ្ឋបានផ្លាស់មកទីតាំងនេះ ដែលជាដីទទេ ដូច្នេះពួកគាត់ត្រូវ តែសង់ទីជម្រកខ្លួនដោយខ្លួនឯង ឬដោយមានជំនួយខាងហិរញ្ញវត្ថុ ឬខាងសម្ភារ: ពីអង្គការមិនមែនរដ្ឋាភិបាលជាច្រើន។[៦៨] តាំងពីឆ្នាំ ២០០៧ មក សាលារាជធានីភ្នំពេញបានសហការជាមួយ UPDF ក្នុងការសាងសង់ផ្ទះល្វែងទំហំ ៤ម គុណ ៥ម (២០ម$^{២}$) នៅអណ្តូង។ រហូតដល់ពេលនេះ ផ្ទះប្រមាណជា ២០០ ល្វែងត្រូវបានសាងសង់ រួចហើយ។ សាលារាជធានីមានផែនការសាងសង់ផ្ទះល្វែង ៤០០ ល្វែងទៀត នៅលើដីដែលនៅសល់។[៦៩] គ្រួសារប្រជាពលរដ្ឋដែលបានផ្តល់បទសំភាសន៍ ដែលជាអ្នកទទួលបានផ្ទះល្វែង ជាទូទៅមាន សេចក្តីពេញចិត្តចំពោះផ្ទះល្វែង ព្រោះផ្ទះទាំងនោះមានបង្គន់ក្នុងផ្ទះ និងអាចការពារកំដៅថ្ងៃ និងភ្លៀងបាន។ ប្រជាពលរដ្ឋក៏មានអារម្មណ៍ផងដែរថា ផ្ទះល្វែងទាំងនេះផ្តល់សុវត្ថិភាពខាងការកាន់កាប់ ជាងផ្ទះដែលសាងសង់ដោយមានជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ពីព្រោះ ពួកគាត់មើលឃើញថាការប្រគល់អោយខ្លួននូវផ្ទះល្វែងនេះជាការទទួលស្គាល់ជាផ្លូវការលើការកាន់កាប់ ដែលតាមពិតទៅ អាជ្ញាធរបានសន្យាជាមួយក្រុមគ្រួសារប្រជាពលរដ្ឋថា នៅពេល ដែលពួកគាត់បានបង់រំលោះប្រាក់កម្ចីសង់ផ្ទះ ដល់ UPDF អស់ ពួកគាត់នឹងទទួលបានឯកសារផ្លូវការ បញ្ជាក់ពីភាពជាកម្មសិទ្ធលើផ្ទះល្វែងនោះ (សូមមើល ឧបសម្ព័ន្ធទី ២)។

ក្រុមគ្រួសារដែលមិនទាន់បានទទួលផ្ទះល្វែង បានសម្តែងក្តីកង្វល់អំពីលទ្ធភាពបង់រំលោះ ប្រាក់កម្ចី (១០០០ដុល្លារដែលត្រូវបង់រំលោះក្នុងរយៈពេលប្រាំឆ្នាំ) ដោយសារតែពួកគាត់ ភាគច្រើនរកប្រាក់ចំណូល មិនបានល្មម សម្រាប់ហូបចុកអោយគ្រប់គ្រាន់ទេ។ [៧០] គ្រួសារ ដទៃទៀត ដែលផ្ទះត្រូវបានសាងសង់ឡើង ដោយមានសម្ភារ: ឧបត្ថម្ភពីអង្គការមិនមែនរដ្ឋាភិ បាល បានបញ្ជាក់ថា ពួកគាត់ចង់រក្សាផ្ទះរបស់ពួកគាត់ជាង ព្រោះវាមានទំហំធំជាង (ជាទូទៅ ក្រុមគ្រួសារ បានធ្វើឡៅតឿបន្ថែមមួយថ្នាក់ទៀត ដែលនេះជាទំលាប់របស់ប្រជាពលរដ្ឋកម្ពុជារស់នៅតាមទីប្រជុំជន ហើយដែលឡៅតឿនេះមិនអាចសង់បានទេ សំរាប់ផ្ទះល្វែងដែលសាលា រាជធានីភ្នំពេញសង់អោយ)។

ក្រុមគ្រួសារប្រជាពលរដ្ឋបាននិយាយថា អាជ្ញាធរក្រុងមិនដែលបានពិភាក្សា អំពីគម្រោងផ្ទះល្វែងនោះជាមួយ ពួកគាត់ទេ ។ អាជ្ញាធរបានប្រាប់ប្រជាពលរដ្ឋថា គម្រោងផ្ទះល្វែងនេះកំពុងដំណើរការ ហើយអ្នកដែលមិនចង់ បានផ្ទះល្វែងគួរតែផ្លាស់ទៅកន្លែងផ្សេងទៀត។ អង្គការមួយដែលជួយផ្តល់សម្ភារៈសំរាប់ធ្វើផ្ទះដល់ក្រុមគ្រួសារប្រជាពលរដ្ឋ ត្រូវបានគេប្រាប់ ឱ្យបញ្ឈប់ការឧបត្ថម្ភសាងសង់នេះ ពីព្រោះផ្ទះល្វែងដែលគ្រោងសង់ អាចនឹងត្រូវបាន សាងសង់នៅលើដីដែលមានសង់ផ្ទះទាំងនោះ ។[៧១] បញ្ហាមួយទៀតនោះគឺ ហានិភ័យនៃការដែលក្រុមគ្រួសារ នៅអណ្តូងនាបច្ចុប្បន្ន អាចមានចំនួនច្រើនជាងចំនួនដីឡូត៍ដែលមាន។ ដូច្នេះ វាមិនប្រាកដទេថា ផ្ទះល្វែងនឹងមានផ្តល់ដល់គ្រប់គ្រួសារទាំងអស់ ហើយក្នុងពេលសរសេររបាយការណ៍នេះ ភាពមិនប្រាកដប្រជាអំពីចំនួនគ្រួសារនៅអណ្តូងនៅតែមាន។[៧២]

ករណីខាងលើនេះបង្ហាញអំពី សេចក្តីត្រូវជាបន្ទាន់ សម្រាប់សម្របសម្រួលនិងពិគ្រោះយោបល់ រវាងភាគីពាក់ព័ន្ធនានា រួមទាំងក្រុមគ្រួសារដែលទទួលផលប៉ះពាល់ផង ក្នុងពេលរៀបចំសំរាប់គម្រោងលំនៅដ្ឋាន និងសំរាប់ការកែលំអរលំនៅដ្ឋាននៅកន្លែងតាំងទីលំនៅថ្មី។



---

[៦៨] អង្គការ Habitat for Humanity បានផ្តល់កម្ចីលំនៅដ្ឋានដល់៧គ្រួសារនៅអណ្តូង។ អង្គការ Friends បានជួយសាងសង់ផ្ទះអោយ ៤០ គ្រួសារ ។ ព្រះវិហារកូរ៉េ និងអង្គការអភិវឌ្ឍន៍ប្រជាជនកម្ពុជា (DPC) បានផ្តល់សម្ភារ:សាងសង់ផ្ទះអោយដល់ គ្រួសារក្រីក្រ ជាង ១០០គ្រួសារ។

[៦៩] កិច្ចសម្ភាសន៍ជាមួយ ឯ.ឧ.ម៉ាន់ ឈឿន អភិបាលរងរាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកុម្ភ: ឆ្នាំ ២០១០] ចាប់ពីពេលនេះទៀតហៅ: កិច្ចសម្ភាសន៍ជាមួយអភិបាលរង[។

[៧០] កាលពីពេលកន្លងមក មានប្រជាពលរដ្ឋប្រមាណជា ៣០ គ្រួសារ បានទទួលជំនួយហិរញ្ញវត្ថុ ពី NGO មួយ ដែលជួយបង់រំលោះ ប្រាក់កម្ចី នោះ។ ក្នុងពេលកំពុងសរសេររបាយការណ៍សិក្សានេះ គ្មាន NGO ណាមួយ ជួយក្រុមគ្រួសារលើប្រាក់កម្ចីទៀតទេ ទោះបីជា ឯ.ឧ.អភិបាលរង ម៉ាន់ ឈឿន បានមានប្រសាសន៍ថា ឯកឧត្តមនឹងពិនិត្យមើលបញ្ហានេះ ហើយនឹងរកជំនួយពី NGO ដើម្បីជួយក្រុម គ្រួសារប្រជាពលរដ្ឋក្រីក្របំផុត ។ កិច្ចសម្ភាសន៍ជាមួយអភិបាលរង។

[៧១] តាមពិតទៅ លំនៅដ្ឋានមួយចំនួនសាងសង់ឡើង ដោយជំនួយពីអង្គការមួយ ត្រូវបានបំផ្លាញចោល និងត្រូវបានសង់ជំនួសដោយ ផ្ទះល្វែង រួចទៅហើយ ។



តំរង់ជួរដើម្បីយកទឹក, នៅតំបន់អណ្តូងបន្ទាប់ពីផ្លាស់ប្តូរទីតាំងថ្មីៗ ថ្លែងអំណរគុណចំពោះការថតរូបដោយ: Licadho

អ្នកផ្ទុកមេរោគអេដស៍ ដែលបានផ្លាស់ទីលំនៅមកពីបុរីកីឡា។ ទំហំដីឡូត៍នៃបន្ទប់ (៤.៨ម x ៣.៥ម = ១៦.៨ម$^{២}$) គឺពិតជាតូចមែនទែនសម្រាប់មួយគ្រួសាររស់នៅ គឺតូចជាងទំហំដែលកំនត់ក្នុងបទដ្ឋានមនុស្សធម៌អប្បរមា។[៧៣] ភាពតូចចង្អៀតនេះ កាន់តែចង្អៀតថែមទៀត ដោយ សារខ្វះខាត ទីធ្លាផ្នែកខាងក្រៅផ្ទះនិមួយៗ និងទីធ្លារួម (លើកលែង តែផ្ទះដែលមាននៅផ្នែកខាងចុង សងខាងនៃអាគារទាំងប្រាំមួយ)។ លំនៅដ្ឋានគ្មានសុវត្ថិភាពទេ ព្រោះថាបន្ទប់ទាំងអស់នៅ ក្នុងអាគារចំហរផ្នែកខាងលើ ហើយជញ្ជាំងបិទបាំង ដោយសន្លឹកស័ង្កសីស្តើងពណ៌បៃតងកម្រាស់២មម ដែលអាចងាយនឹងទំលុះទំលាយ (ជញ្ជាំងបន្ទប់របស់គ្រួសារខ្លះត្រូវបាន ទំលាយគ្រាន់តែក្នុងប៉ុន្មានសប្តាហ៍បន្ទាប់ពីពួកគាត់ផ្លាស់មកនៅទីនេះ)។ អាគារទាំងនេះមិនបាន ការពារក្រុមគ្រួសារពួកគាត់ពីកំដៅថ្ងៃទេ។ ប្រជាពលរដ្ឋបានត្អូញត្អែរថា ពួកគាត់ឆាប់អស់កម្លាំង និងឆាប់មានជំងឺ ដោយសារតែក្តៅខ្លាំងពេក ហើយថា កំដៅថ្ងៃ



[៧២] នៅពេលមានការបណ្តេញចេញ សាលារាជធានីភ្នំពេញបានគូសបែងចែកដីជាឡូត៍ប្រហែល ៧៧៧ឡូត៍ ក្នុងទំហំ ៤ម គុណ ៦ម ដើម្បីបែងចែកឱ្យគ្រួសារនីមួយៗ ។ ក៏ប៉ុន្តែ អភិបាលរងបានទទួលស្គាល់ថា មានគ្រួសារប្រជាពលរដ្ឋរហូតដល់ប្រហែលជា ១៥០០ គ្រួសារ រស់នៅ អណ្តូង ហើយថា ដំណោះស្រាយត្រូវតែរកឱ្យបានសម្រាប់ពួកគាត់ ។

[៧៣] នៅក្នុងប្រតបត្តិការជំនួយសង្គ្រោះ ទំហំអប្បបរមា សម្រាប់មនុស្សម្នាក់)(ដោយមិនរាប់បញ្ចូល បង្គន់ និងបន្ទប់ទឹក) ត្រូវបាន កំណត់ទំហំ ៤.៥ម$^{២}$ ទៅ ៥.៥ម$^{២}$ សំរាប់ក្នុងបរិយាសត្រជាក់ ឬ ក៏សំរាប់ស្ថានភាពក្នុងទីក្រុង ដែលត្រូវមានផ្ទះបាយ និងបន្ទប់ ងូតទឹក។ បទដ្ឋាននេះកំណត់ទំហំ ៣.៥ ម$^{២}$ នៅក្នុងបរិយាកាសក្តៅ និងត្រូវមានទីធ្លាខាងក្រៅសមរម្យសម្រាប់ការចំអិន ម្ហូប ហើយដែលជាទូទៅ មិនមានដូចការជាករណីនេះ នៅតាមកន្លែងតាំងទីលំនៅថ្មីក្រោមការសិក្សានេះ ទេ។ វាជាបទដ្ឋានសំរាប់ ឆ្លើយតបទៅនឹងបញ្ហាបន្ទាន់ ប៉ុន្តែវាអាចផ្តល់ជាបទដ្ឋានអប្បរមាល្អមួយ ដើម្បីធ្វើការប្រៀបធៀបលំនៅដ្ឋាននៅតាមកន្លែងតាំងទីលំនៅថ្មីនានា។ ផ្ទះនៅ ទួលសំបូរ មិនអាចអោយគ្រួសារដែលមានសមាជិកគ្រួសារ ៤នាក់ រស់នៅបានទេ បើផ្អែកតាមបទដ្ឋានដែលកំណត់ទំហំ ៤.៥ម$^{២}$ សំរាប់មនុស្សម្នាក់ ។ សូមមើលសៀវភៅ Sphere Project "ធម្មនុញ្ញមនុស្សធម៌ និងបទដ្ឋានអប្បបរមា ក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ" តាមរយ:សៀវភៅ[ពីពេលនេះហៅ: សៀវភៅ Sphere Project] និង UNHCR "សៀវភៅណែនាំសំរាប់សង្គ្រោះបន្ទាន់" អត្តបទបោះពុម្ពផ្សាយលើកទី2 ជំពូកទី ១២] ពីពេលនេះហៅ: សៀវភៅ UNHCR ]។

បានបំផ្លាញថ្នាំពន្យាអាយុជីវិត (ARV) របស់ពួកគាត់។

ទីភ្នាក់ងារអង្គការសហប្រជាជាតិនិងអង្គការមិនមែនរដ្ឋាភិបាលបានក្រើនរំឭកដល់អាជ្ញាធរថ្នាក់ជាតិ និង រាជធានី អំពីភាពមិនសមរម្យនៃអាគារទាំងនេះនៅទួលសំបូរ។ គម្រោងដ៏មានសារៈសំខាន់មួយ ដើម្បីកែលំអរអោយប្រសើឡើងនូវលំនៅដ្ឋាន និង ហេដ្ឋារចនាសម្ព័ន្ធ នៅទីតាំងនោះទីបំផុត ត្រូវបានព្រមព្រៀងរវាងក្រុមទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេស អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សាលារាជធានីភ្នំពេញ និង អង្គការCaritas ។ នៅពេលសរសេរពីការសិក្សានេះ អង្គការ Caritas ដោយមានជំនួយបច្ចេកទេសពីទីភ្នាក់ងារអង្គការសហប្រជាជាតិ កំពុងតែបញ្ចប់ការសាងសង់ផ្ទះល្វែងសង់ពីឥដ្ឋសម្រាប់ ក្រុមគ្រួសារទាំងនេះ។ សាលារាជធានីភ្នំពេញបានផ្តល់ដីបន្ថែមទៀតដើម្បី សាងសង់ផ្ទះល្វែងអោយបានធំទូលាយ ។ លំនៅដ្ឋាន និងជីវភាពរស់នៅរបស់ក្រុមគ្រួសារទាំងនោះ នឹងបានល្អប្រសើរឡើងច្រើន ដោយសារតែគម្រោងនេះ។ (សូមមើលផងដែរប្រអប់លេខ ១៣ និង១៤)

*អគ្គីសនី*

លំនៅដ្ឋានសមរម្យរាប់ទាំង ថាមពលសម្រាប់ ចំអិនអាហារ សំរាប់ផ្តល់កំដៅ និង បំភ្លឺ។ ប្រជាពល រដ្ឋកម្ពុជាក្រីក្រនៅជនបទភាគច្រើនមិនមានអគ្គិសនីប្រើប្រាស់ក្នុងរយៈពេលជាយូរមកហើយ។ ដូច្នេះ អគ្គិសនី អាចត្រូវបានគេចាត់ទុកថាវាមិនមែនជាអាទិភាព នៅទីតាំងនៃកន្លែងតាំងទីលំនៅថ្មីទេ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋដែលបានផ្តល់បទសម្ភាសន៍ ពិតជាបានចាត់ទុកអគ្គិសនីថាជាផ្នែកមួយនៃសេវាសំខាន់ៗ ដែលត្រូវការនៅតាមទីតាំង ទាំងនេះ។ ជាបញ្ហានោះ គឺកង្វះខាតអគ្គិសនីរដ្ឋសម្រាប់ប្រើប្រាស់ ( អគ្គិសនីកម្ពុជា-EDC) ដែលអគ្គីសនីរដ្ឋផ្គត់ផ្គង់តាមផ្ទះ លក់ក្នុងតម្លៃ ៧២០ រៀលក្នុងមួយគ.វ.ម (ប្រហែល 0.17 ដុល្លាអាមេរិក)។[៧៤] ការផ្គត់ផ្គង់របស់ EDC នៅមានកម្រិត គឺច្រើនតែមាននៅតាមទីក្រុងនិងទីប្រជុំជន ។ ការភ្ជាប់បណ្តាញ អគ្គិសនី នៅតំបន់មួយចំនួនដែលនៅក្បែរខ្សែ បណ្តាញមេ អាចធ្វើទៅបានតាមការស្នើសុំ ប៉ុន្តែថ្លៃតភ្ជាប់បណ្តាញអាចមានតម្លៃខ្ពស់ពេក ដែលប្រជាពលរដ្ឋក្រីក្រគ្មានលទ្ធភាពបង់ថ្លៃនេះបាន។

នៅអណ្តូងនិងត្រពាំងអញ្ចាញគ្មានបណ្តាញតភ្ជាប់ពី EDC ទេ។ ក្រុមគ្រួសារ ប្រជាពលរដ្ឋភាគច្រើនប្រើចង្កៀងប្រេងកាតសម្រាប់បំភ្លឺ រីឯគ្រួសារមួយចំនួនបានទិញអគ្គិសនី ពីឯកជនដែលមានម៉ាស៊ីនភ្លើង ក្នុងតម្លៃថ្លៃ និង មានតែរយៈពេលប៉ុន្មានម៉ោងប៉ុណ្ណោះ។ នៅអណ្តូង ប្រជាពលរដ្ឋទិញអគ្គីសនីតម្លៃ៣០០០រៀល ក្នុង១គ.វ.ម ឬ៥០០ រៀលសម្រាប់អំពូលភ្លើងមួយ ចាប់ពីម៉ោង ៦ល្ងាច ទៅម៉ោង១០ យប់។ នៅឯត្រពាំងអញ្ចាញ មានឯកជនផ្គត់ផ្គង់អគ្គិសនីដូចគ្នានេះដែរ ក្នុងម្លៃ១០០០រៀលក្នុង១គ.វ.ម ពីម៉ោង ៦ល្ងាច ដល់ ម៉ោង៩យប់។ អាជ្ញាធរបានប្រកាសថា ប្រជាពលរដ្ឋនៅត្រពាំងអញ្ចាញនឹងទទួលបានអគ្គិសនីពីបណ្តាញ EDC នៅខែមិថុនា ក៏ប៉ុន្តែនៅពេលកំពុងសរសេររបាយការណ៍នេះ ការរៀបចំតបណ្តាញបានដំណើរការខ្លះៗ ហើយ។ នៅតំណាកត្រ់យឹង គ្រួសារមួយចំនួនដែលរស់នៅលើចិញ្ចើមផ្លូវ និងអាចលៃលកបង់ថ្លៃអគ្គិសនី ទៅអ្នកជំនួញឯកជន បានទទួលអគ្គីសនីប្រើប្រាស់រយៈពេលពីរ-បីខែដែរ។ ប៉ុន្តែ ការផ្គត់ផ្គង់នេះ ក៏ត្រូវបានគេកាត់ផ្តាច់ទៅវិញ ក្រោយពីមានសេចក្តីប្រកាសថា

[៧៤] មកដល់ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១០ អត្រាប្តូរប្រាក់គឺ ១ដុល្លារ ស្មើនឹង៤២០០រៀល។

ក្រុមគ្រួសារទាំងនោះ នឹងត្រូវបានបណ្តេញចេញម្តងទៀត។ ចំពោះអ្នកដែលរស់នៅក្នុងផ្ទះល្វែងមានអគ្គិសនីប្រើប្រាស់ពីបណ្តាញ EDC។ នៅ ទួលសំបូរ មួយភាគធំ មានតភ្ជាប់អគ្គិសនីពី បណ្តាញ EDC ដូច្នេះ វាជាបញ្ហាក្នុងការតភ្ជាប់ចរន្ត អគ្គីសនីចូលទៅលំនៅដ្ឋាននីមួយៗដែលក្រុមគ្រួសារមួយចំនួនមានលទ្ធភាពលៃលកបាន និងមួយចំនួនទៀតមិនមានលទ្ធភាពទេ។ អង្គការ Caritas បានផ្តល់ប្រាក់កម្ចី ៥០ភាគរយ នៃប្រាក់កក់តំលៃ៧០ដុល្លារ ជាលក្ខខណ្ឌតំរូវសម្រាប់តបណ្តាញអគ្គិសនីចូលផ្ទះ ដើម្បីឱ្យប្រជាពលរដ្ឋអាចតភ្លើង អគ្គីសនីបាន និងត្រូវសងរំលោះប្រាក់កម្ចីនោះតាមក្រោយ។

ថាមពលសម្រាប់ការចម្អិនម្ហូបអាហារ មិនមែនជាក្តីកង្វល់ទេ។ ដោយសារ នៅតាមតំបន់ជាច្រើននៃប្រទេសកម្ពុជា អុស និងធ្យូង ត្រូវបានយកមកប្រើប្រាស់សំរាប់ការចម្អិនម្ហូបអាហារ។ ជាទូទៅការរកវាមកប្រើប្រាស់មិនមែនជាបញ្ហាទេ។ ក្រុមគ្រួសារដែលរស់នៅកន្លែងតាំងទីលំនៅថ្មី នៅភ្នំពេញទិញអុស-ធ្យូងមួយចំនួនពីផ្សារ ហើយពួកគាត់ខ្លះទៅរកអុសពីតំបន់នៅក្បែរៗនោះ។ ក្រុមគ្រួសារនៅខេត្តព្រះសីហានុ អាចរកអុសបានដោយមិនបាច់ទិញ។

## ៥.២ ទឹកស្អាត និងអនាម័យ

សុវត្ថិភាពទឹក និងការទទួលបានទឹកប្រើប្រាស់ដ៏គត់ម៉ត់ និង អនាម័យ មិនមែនគ្រាន់តែមានសារៈសំខាន់ ដោយសារថា វាជាកត្តាដែលត្រូវការជាចាំបាច់ប៉ុណ្ណោះទេ ប៉ុន្តែការខ្វះខាត វាអាចបណ្តាលឡើងនូវបញ្ហាជាច្រើន។ មានជំងឺជាច្រើនបង្កឡើងដោយសារការមិនទទួលបាន បរិស្ថានរស់នៅមានអនាម័យ និងទឹកប្រើប្រាស់ដែលចាំបាច់សម្រាប់អនាម័យខ្លួនប្រាណ។ អសុវត្ថិភាពខាងអនាម័យក៏ជាបុព្វហេតុចម្បងធ្វើឱ្យបំពុលដល់ប្រភពផ្គត់ផ្គង់ទឹក ។

ទឹកនិងអនាម័យនៅតែជាបញ្ហាចម្បង នៅតាមកន្លែងតាំងទីលំនៅថ្មីភាគច្រើន ក្រោមការសិក្សានេះ ទាំងជាបញ្ហាចំពោះមុខ និង បញ្ហារយៈពេលយូរអង្វែង ប្រសិនបើ អាជ្ញាធរមិនចាត់វិធានការកែប្រែស្ថានភាពនេះទេ។ ជាទូទៅ ច្រើនតែខ្វះទឹកស្អាតគ្មានប្រព័ន្ធលូ និងប្រព័ន្ធ ប្រមូលសំរាម គ្មានបង្គន់សាធារណៈ ឬ មានដែរប៉ុន្តែយកតំលៃប្រើប្រាស់ថ្លៃ។ ជាលទ្ធផល ក្រុមគ្រួសារជាច្រើនបានរស់នៅក្នុងស្ថានភាពគ្មានអនាម័យ តាំងពីពេលពួកគេផ្លាស់ប្តូរទីតាំងមក។ ស្ត្រី និងកុមារ ជាអ្នកទទួលរងផលប៉ះពាល់ខ្លាំងបំផុត ដោយសារពួកគេ ចំណាយពេលនៅឯកន្លែងតាំងទីលំនៅថ្មីនេះច្រើនជាងបុរស។

### *ការទទួលបានទឹកស្អាតប្រើប្រាស់*

ការខ្វះទឹកស្អាត ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ក្រុមគ្រួសារប្រជាពលរដ្ឋនៅ អណ្តូង និងទំហំនៃការប៉ះពាល់អាចតិចជាងនេះ សំរាប់គ្រួសារប្រជាពលរដ្ឋនៅត្រពាំងអញ្ចាញ ដំណាក់ត្រយឹង ស្ពានឆេះ និងអូរកម្ពុជា។ ទឹកមិនងាយស្រួលរកបានយកមកប្រើប្រាស់ទេ ជាពិសេសក្នុងរដូវប្រាំង (នៅរដូវវស្សាប្រជាពលរដ្ឋភាគច្រើនត្រងទឹកភ្លៀងទុកសម្រាប់ប្រើប្រាស់)។

មិនមានការភ្ជាប់បណ្តាញផ្គត់ផ្គង់ទឹក ពីទីក្រុងទៅដល់ ក្រុមគ្រួសារប្រជាពលរដ្ឋ ខេត្តព្រះសីហានុ ដែលរស់នៅលើទីតាំងក្រោមការសិក្សានេះទេ ។ នៅឯស្ពានឆេះ ប្រជាពលរដ្ឋ ជាទូទៅប្រើទឹកអណ្តូងនៅលើចិញ្ចើមផ្លូវ នៅក្បែរទីតាំងដែលគេកំពុងរស់នៅ ដែលវាត្រូវបានជនបរទេសម្នាក់ចេញថ្លៃស្តារអណ្តូងនោះ ដើម្បីអោយប្រជាពលរដ្ឋអាច

# ជំពូកទី៥ ៖ ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី

ប្រើប្រាស់ទឹកបាន ។ នៅពេលដែលអណ្តូងនេះផ្តល់ទឹកមិនគ្រប់គ្រាន់ ប្រជាពលរដ្ឋ ត្រូវទៅរកដងទឹកនៅអណ្តូងឆ្ងាយៗ នៅក្នុងភូមិជិតខាង។ នៅ អូរកម្ពុជា អ្នកភូមិទៅដងទឹកអូរដែលមានចម្ងាយ ២គ.ម ពីភូមិ ពីព្រោះអណ្តូងដែលពួកគាត់បាននាំគ្នាជីកតាំងពីដំបូងនោះ មិនមានជំរៅជ្រៅល្មមដែលអាចផ្តល់ទឹកគ្រប់គ្រាន់តាមតម្រូវការរបស់ពួកគាត់ទេ។

នៅតាមកន្លែង តាំងទីលំនៅថ្មីភាគច្រើននៅភ្នំពេញ ការផ្គត់ផ្គង់ទឹកត្រូវបានគ្រប់គ្រងដោយ អ្នក អ្នកជំនួញឯកជន ដែលមានសិទ្ធិផ្តាច់មុខក្នុងការគ្រប់គ្រងការផ្គត់ផ្គង់ទឹកនៅទីនោះ។ ជាទូទៅ ប្រជាពលរដ្ឋត្រូវទិញទឹកដែលមាន ក្នុងតម្លៃខ្ពស់ជាងតម្លៃទឹកដែលគេទិញប្រើប្រាស់ កាលពីមុនពេលមិនទាន់ត្រូវបានគេបណ្តេញចេញមកទីតាំងទាំងអស់នេះ និង មានតម្លៃទ្វេដង ឬ ខ្ពស់ជាងតម្លៃទឹករបស់រដ្ឋាករទឹកស្វ័យយ័ត (WSA) ។[៧៥]

នៅត្រពាំងអញ្ចាញ ក្រុមហ៊ុន សួរ ស្រ៊ុន កាលពីដំបូងបាននាំធុងទឹកធំៗចំនួន១៦មកដាក់នៅទីតាំងថ្មីនេះ។ ប៉ុន្មានខែក្រោយពីការផ្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋមក ក្រុមហ៊ុនបានតភ្ជាប់បណ្តាញទឹក របស់ WSA ចូលមកទីតាំងនេះ និងបានម៉ៅការបន្តទៅឱ្យអ្នកជំនួញឯកជន។ គេបង្កើតកន្លែងចែក

### ប្រអប់លេខ១០: ការវាយតម្លៃលើគុណភាពទឹកនៅអណ្តូង

ក្រោយពីប្រជាពលរដ្ឋបានមកដល់ អណ្តូងភ្លាម អង្គការ UNICEF បានផ្គត់ផ្គង់ទឹកស្អាត ដោយដាក់ធុងទឹក ប្រហែលជា ២០ នៅកន្លែងផ្សេងៗគ្នា នៃទីតាំងនោះ។ ការផ្គត់ផ្គង់ទឹក បានដំណើរការរយៈពេលតែពីរបីខែប៉ុណ្ណោះ។ តាំងពីពេលនោះមក ប្រជាពលរដ្ឋទិញទឹកពី អ្នកលក់ទឹកឯកជន ឬក៏ប្រើប្រាស់ប្រភពទឹកធម្មជាតិ ចេញពីអណ្តូងមួយ និងស្រះទឹកពីរ។

អណ្តូងទឹកចំណាស់នៅមូលដ្ឋាន មានទឹកថ្លា។ វាស្ថិតនៅចម្ងាយប្រហែលជា ១០០ម៉ែត្រពី អណ្តូង ហើយត្រូវ បានប្រើប្រាស់ដោយសហគមន៍មូលដ្ឋានផង និងដោយក្រុមគ្រួសារប្រជាពលរដ្ឋដែលបានផ្លាស់ប្តូរទីតាំងមក រស់នៅទីនេះផង ជាទូទៅគឺសម្រាប់ការចំអិនម្ហូប និងបរិភោគ។ អណ្តូងផ្តល់ទឹកមានកម្រិត ដោយសារតែ ទឹកវាត្រូវចេញតាមខ្សែទឹកនៅក្រោមដីតាមធម្មជាតិរបស់វា ហើយដោយសារគេដងទឹកច្រើនញឹកញាប់ផងដែរ។ ដូច្នេះ វាមិនអាចឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ប្រចាំថ្ងៃរបស់អ្នកភូមិបានទេ ជាពិសេស នៅរដូវប្រាំង។ បុគ្គលិករបស់ OHCHR ដែលចុះទៅពិនិត្យទីតាំងនោះ កាលពីខែកុម្ភៈ ឆ្នាំ២០១០ បានសង្កេតឃើញអ្នកភូមិតម្រង់ជួរគ្នារង់ចាំដងទឹកពីអណ្តូង ដែលទឹកនាពេលនោះ មាន កំពស់តែ៣០០មម ប៉ុណ្ណោះពីបាតអណ្តូង។ ក្មេងប្រុសយួរធុងទឹកចំណុះ២០លីត្រម្នាក់ បាននិយាយថា គាត់ត្រូវតែយួរទឹកចំណុះស្មើៗគ្នារបៀបនេះ ប្រាំដងក្នុងមួយថ្ងៃ ដើម្បីបំពេញ តម្រូវការរបស់គ្រួសារគាត់។ អ្នកភូមិខ្លះ កំពុងតែបោកសម្លៀកបំពាក់ នៅក្បែរអណ្តូងទឹក ដែលជាហេតុនាំអោយអាចបំពុលប្រភពទឹកនៅក្រោមដីក្នុងពេលអនាគត។ ស្រះទឹកទីមួយស្ថិត នៅចម្ងាយប្រហែល ១៣០ម ពីអណ្តូង ដែលទឹកនៅទីនោះមិនស្អាតទេ។ មានតែ ២០ ទៅ ៣០ភាគរយនៃគ្រួសារដែលបានផ្តល់សម្ភាសន៍ប៉ុណ្ណោះ បានប្រើប្រាស់ទឹកស្រះនោះ ជាទូទៅសម្រាប់បោកគក់ ងូត និងជួនកាលសម្រាប់បរិភោគ។ ស្រះនោះគ្មានសុវត្ថិភាព ឬគ្មានការការពារទេ មានអ្នកភូមិម្នាក់បានលង់ទឹក នាពេលកន្លងទៅ ដែលនេះ ហាក់បីដូចជាមូលហេតុ មួយផ្សេងទៀតដែលគ្រួសារប្រជាពលរដ្ឋភាគច្រើន មិនប្រើប្រាស់ទឹកស្រះនេះ។ ស្រះទឹកទីពីរ ស្ថិតនៅចម្ងាយប្រហែល ២០០ ម៉ែត្រពីអណ្តូង ហើយប្រជាពលរដ្ឋជាងពាក់កណ្តាលដែលបានផ្តល់សម្ភាសន៍ បានប្រើប្រាស់ទឹកស្រះនេះ។ ប្រជាពលរដ្ឋដែលបានផ្តល់ការសម្ភាសន៍ទាំងនោះយល់ថា ស្រះទីពីរនោះ នៅជិតល្មមសម្រាប់ពួកគាត់ ហើយស្រះនេះមានបរិមាណទឹកគ្រប់គ្រាន់។ ក៏ប៉ុន្តែ ពួកគាត់បានសំដែងនូវក្តីកង្វល់អំពីកង្វះខាតទឹក និងគុណភាពទឹក ទៅថ្ងៃខាងមុខ ព្រោះមានប្រជាពលរដ្ឋច្រើនគ្រួសារណាស់មកប្រើប្រាស់ស្រះនេះ។ អ្នកជំនួញលក់ទឹកឱ្យអ្នកភូមិ ក៏មកបូមទឹកពីស្រះនេះ និងយកទឹកមកពីបឹងដែលនៅឆ្ងាយពីទីនេះ។

[៧៥] WSA កំណត់អត្រាតម្លៃទឹក បួនប្រភេទ អាស្រ័យលើការប្រើប្រាស់តាមផ្ទះនិមួយៗ មានលំដាប់ពី ៥៥០រៀល ទៅ១២៧០រៀល ក្នុងមួយម៉ែតគូប។

ចាយទឹកតែមួយកន្លែងប៉ុណ្ណោះ សម្រាប់ចែកចាយទឹកដល់ទៅ ប្រជាពលរដ្ឋប្រមាណជា ៧០០-៨០០ គ្រួសារដែលរស់នៅជាប្រចាំលើទីតាំងនេះ។ ប្រជាពលរដ្ឋ ត្រូវមកត្រងទឹកដាក់ធុង និង ជញ្ជូនទឹកទៅផ្ទះខ្លួនដោយខ្លួនឯង ដោយបង់ថ្លៃ ៧០០រៀល ក្នុងមួយធុង ដែលមាន ចំណុះប្រហែល២២០លីត្រ។ តម្លៃនេះស្មើនឹង ៣៥០០ រៀលក្នុង១ ម៉ែត្រគូប ខណៈដែរតម្លៃទឹកទាប បំផុតកំណត់ដោយ WSA គឺ៥៥០ រៀលក្នុង១ម៉ែត្រគូប ។ ជំរើសផ្សេងទៀត គឺប្រជាពលរដ្ឋ អាចជួលនរណាម្នាក់ក្នុងតម្លៃទ្វេរដង សម្រាប់ជញ្ជូនទឹកមកឱ្យ ពួកគេដល់ផ្ទះ។ ការមកដឹកជញ្ជូនទឹកយកទៅប្រើប្រាស់ត្រូវការពេលវេលាច្រើនណាស់ ជាពិសេសមាន តែធុងទឹកចំនួនដប់ ប៉ុណ្ណោះដែលអ្នកជំនួញឯកជនដាក់អោយប្រជាពលរដ្ឋប្រើប្រាស់សំរាប់ជញ្ជូនទឹកនៅទីតាំងនេះ។[៧៦] នេះគឺជាបន្ទុកយ៉ាងធ្ងន់ ជាពិសេសសម្រាប់ប្រជាពលរដ្ឋដែលត្រូវ ទៅតំបន់ប្រជុំជនក្នុងទីក្រុងដើម្បីធ្វើការ ពីព្រោះគាត់ត្រូវតែក្រោកពីព្រលឹម ដើម្បីដឹកជញ្ជូនទឹកមកទុកប្រើប្រាស់ ហើយនៅតែ ត្រូវទៅធ្វើការយឺតពេលជាញឹកញាប់ ។ អ្នកគ្រប់គ្រងទឹកមិនបើកទឹកនៅពេលយប់ទេ។



ស្រះទឹក នៅភូមិអណ្ដូង ថ្លែងអំណរគុណចំពោះការថតរូបដោយ: B.Keat/OHCHR

លទ្ធផលពិសោធន៍ពីការវិភាគទឹកនៅវិទ្យាស្ថានប៉ាស្ទ័របង្ហាញថា ប្រភពទឹកទាំងបី សុទ្ធតែ មិនអាចបរិភោគបានទេ។ ក៏ប៉ុន្តែ ដោយសារតែទឹកនោះមិនមានកម្រិតជាតិដែក ឬក៏អាសេនិកខ្ពស់ ដូច្នេះវាមានសុវត្ថិភាពអាចបរិភោគបាន នៅពេលដែលបានដាំពុះដល់កម្រិត១០០អង្សា ឬក៏ត្រូវបាន បន្សុតជាមួយនឹងតម្រងសេរ៉ាមិក។ ប្រជាពលរដ្ឋគ្រប់គ្រួសារដែលបានផ្ដល់សម្ភាសន៍ សុទ្ធតែបានដាំ ឬបន្សុតទឹកនេះ។

ជាធម្មតា អ្នកភូមិប្រើប្រាស់ធុងចំណុះ ២០ លីត្រ ដើម្បីដឹកទឹកពីប្រភពទឹកទាំងនេះ ទៅលំនៅដ្ឋាន។ ស្មើរតែ ៦០ ភាគរយក្នុងចំណោមប្រជាពលរដ្ឋដែលបានផ្ដល់សម្ភាសន៍ មានពាងសម្រាប់ស្តុកទឹក។ ចំណែកឯ៤០ភាគរយ ទៀតមានតែធុងជ័រចំណុះ២០លីត្រមួយចំនួន ប៉ុណ្ណោះសម្រាប់ស្តុកទឹក។ ប្រជាពលរដ្ឋអាចប្រើប្រាស់ទឹកពីស្រះ និងអណ្ដូងដោយគ្មាន ការគិតថ្លៃទេ។ អ្នកជំនួញឯកជន លក់ទឹក តម្លៃ២០០រៀល ក្នុង ២០លីត្រ ។ ប្រសិនបើ យកទៅឱ្យដល់ផ្ទះរបស់ប្រជាពលរដ្ឋផ្ទាល់ ទឹកមានតម្លៃចន្លោះពី៣០០០ ទៅ ៤០០០រៀល ក្នុងមួយពាងដែលជាធម្មតាពាងទឹកដែលប្រជាពលរដ្ឋ ប្រើប្រាស់មានចំណុះ២០០ លីត្រ។ ទឹកមួយពាងប្រើបានប្រហែលជា ២ទៅ៧ថ្ងៃ អាស្រ័យទៅតាមគ្រួសារនីមួយ។ ជិត៦០ភាគរយនៃ ក្រុមគ្រួសារប្រជាពលរដ្ឋប្រើប្រាស់ទឹក១៥លីត្រក្នុង១ថ្ងៃសម្រាប់មនុស្សម្នាក់ និង ៤០ភាគរយ ទៀតប្រើតែ ១០ លីត្រប៉ុណ្ណោះក្នុងមួយថ្ងៃសម្រាប់មនុស្សម្នាក់។

[៧៦] អ្នកមកដឹកជញ្ជូនទឹក ត្រូវដាក់វេណគ្នាប្រើធុងទឹកដែលមានដោយត្រូវរង់ចាំនៅកន្លែងចែកចាយទឹករហូតដល់ពេលបាន ធុងដើម្បីដឹកជញ្ជូនទឹកទៅផ្ទះខ្លួនដោយខ្លួនឯង ។

# ជំពូកទី៥ ៖ ការចាប់ផ្ដើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី

នៅដំណាក់ត្រយឹង មានហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកសម្រាប់ប្រើប្រាស់។ ប្រព័ន្ធផ្គត់ផ្គង់ទឹកនេះត្រូវបានគ្រប់គ្រង ដោយអ្នករកស៊ីឯកជនប្រជាពលរដ្ឋត្រូវតែបង់ថ្លៃតភ្ជាប់បណ្ដាញចូល ផ្ទះល្វែងរបស់ពួកគេ។ វាអាស្រ័យទៅ តាមទីតាំងនៃផ្ទះល្វែង អ្នកផ្គត់ផ្គង់ទឹកអាចបដិសេធការតភ្ជាប់បណ្ដាញទឹកចូលផ្ទះ ដែលការនេះបានបង្ខំឱ្យប្រជាពលរដ្ឋត្រូវទៅដងទឹក ពីអណ្ដូង ក្នុងភូមិជិតខាង ឬទិញទឹកជាធុងឬជាប៉ោត។ អ្នកផ្គត់ផ្គង់ទឹកក៏អាចគិតថ្លៃទ្វេដងលើតម្លៃរបស់ WSA ដែរ។ ប្រជាពលរដ្ឋបានត្អូញត្អែរថា កុងទ័រទឹកដើរលឿនជាង កាលពីពេលដែលពួកគាត់ធ្លាប់ប្រើទឹកដែលភ្ជាប់បណ្ដាញរបស់ WSA នៅក្នុងទីក្រុង ហើយថាទឹកមិនមានចេញគ្រប់គ្រាន់ទេ។ អាជីវករ និង អ្នកជួលផ្ទះ ដែលបានរស់នៅតាមចិញ្ចើមផ្លូវរហូតមកដល់ ខែធ្នូ ឆ្នាំ២០០៩ ត្រូវតែទិញទឹកមួយប៉ោត ចំណុះ ២០លីត្រ ពីអ្នកជំនួញឯកជនតម្លៃ២០០ទៅ៣០០រៀល។

នៅ ទួលសំបូរ មិនមានទឹកស្អាតទេក្នុងរយៈពេលជាច្រើនខែក្រោយពីការផ្លាស់ប្ដូរទីលំនៅ។ ប្រជាពលរដ្ឋប្រើទឹកអណ្ដូង ដែលត្រូវបានវាយតម្លៃថាមិនអាចផឹកបាន សម្រាប់ងូត និងសំអាតសំលៀកបំពាក់ (ជួនកាលសម្រាប់ចំអិនម្ហូបអាហារនិងផឹក)។[៧៧] សម្រាប់ការចំអិនអាហារ និងផឹក ប្រជាពលរដ្ឋភាគច្រើនបានទិញទឹក តម្លៃ១២០០រៀល ក្នុង២០លីត្រ ដែលប្រើបានមិន លើសពី២ទៅ៣ថ្ងៃទេ។ ស្ថានភាពមិនមាននិរន្តរភាពទេ ប៉ុន្តែបានផ្លាស់ប្ដូរគួរឱ្យកត់សម្គាល់ នៅពេលដែលអង្គការ Caritas រៀបចំជីកអណ្ដូងថ្មីមួយ និងដាក់ធុងទឹកធំមួយ សម្រាប់ផ្គត់ផ្គង់ទឹកទៅសហគមន៍ដោយឥតគិតថ្លៃ។ តាមផែនការដែលបានគ្រោងទុក ដល់ខែកក្កដា ឆ្នាំ២០១០នេះ ការថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកនេះ នឹងត្រូវប្រគល់ឱ្យសហគមន៍ ដែលត្រូវរួមគ្នា កំណត់តម្លៃសមរម្យមួយសម្រាប់ការប្រើប្រាស់ទឹក ។ ថវិកាដែលបានប្រមូលបានមកពីថ្លៃទឹក នឹងត្រូវប្រើប្រាស់សំរាប់សកម្មភាពសហគមន៍ ។

កាលពីពេលថ្មីៗនេះ សាលារាជធានីភ្នំពេញបានប្រកាសថា សហគមន៍នៅអណ្ដូង និងត្រពាំងអញ្ចាញ នឹងត្រូវតភ្ជាប់បណ្ដាញផ្គត់ផ្គង់ទឹកមេពីWSA តាមរយៈមូលនិធិដែលផ្ដល់ ដោយសមាគមអន្តរជាតិនៃបណ្ដាទីក្រុងនិយាយភាសាបារាំង។ គម្រោងនេះ គ្រោងនឹងចាប់ផ្ដើមដំណើរការនៅក្នុងខែមីនា ឆ្នាំ២០១០នេះ ប៉ុន្តែមកដល់ខែមិថុនា គម្រោងនេះនៅមិនទាន់ចាប់ផ្ដើម នៅឡើយទេ។ តំណាងសហគមន៍នៅអណ្ដូង បាននិយាយថា ការតភ្ជាប់បណ្ដាញទឹកអាចនឹងត្រូវពន្យាពេល រហូតដល់ ពេលដែលសាលារាជធានីភ្នំពេញសង់ផ្ទះល្វែងរួចរាល់ ។ ការតភ្ជាប់បណ្ដាញទឹក គឺជាការកែលម្អដ៏សំខាន់សម្រាប់គ្រួសារប្រជាពលរដ្ឋ ហើយក៏ជួយពួកគាត់ក្នុងការកាត់បន្ថយចំណាយសម្រាប់ជីវភាពរស់នៅ។(សូមមើលផងដែរ ប្រអប់លេខ១០) ។

ដោយសារតែកត្តាលំបាកក្នុងការរកទឹកស្អាត និងតម្លៃថ្លៃដែលប្រជាពលរដ្ឋត្រូវចំណាយលើវា ដូច្នេះប្រជាពលរដ្ឋ បានកាត់បន្ថយការប្រើប្រាស់ទឹករបស់ពួកគាត់ បើប្រៀបធៀបទៅនឹងការប្រើប្រាស់ទឹក មុនពេលបណ្ដេញចេញ។ ឧទាហរណ៍ ប្រជាពលរដ្ឋនៅអណ្ដូង បានឱ្យដឹងថា ឥឡូវនេះពួកគាត់ប្រើប្រាស់ទឹកតែ១០ទៅ១៥លីត្រ ប៉ុណ្ណោះក្នុងមួយថ្ងៃសម្រាប់សមាជិកម្នាក់។ យោងទៅតាមអ្នកជំនាញឯករាជ ស្ដីពីកាតព្វកិច្ចសិទ្ធិមនុស្សទាក់ទងទៅនឹងការប្រើប្រាស់បាន ទឹកស្អាត និងសុវត្ថិភាពអនាម័យ បញ្ជាក់ថា បរិមាណទឹក២០លីត្រក្នុងមួយ

[៧៧] អង្គការ Samaritan's Purse ការវាយតំលៃពីគុណភាពទឹក ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ ។

ថ្ងៃសម្រាប់មនុស្សម្នាក់គឺជា រង្វាស់អប្បរមាដែលត្រូវការចាំបាច់ដើម្បី ធ្វើអោយប្រជាពលរដ្ឋទទួលបានកំរិតចាំបាច់ជាអប្បរមានៃសិទ្ធិទទួលបានទឹកប្រើប្រាស់ ប៉ុន្តែទោះជានៅក្នុងកម្រិតនេះក្តីក៏កង្វល់ពីបញ្ហាសុខភាពនៅតែមានដដែល។ រដ្ឋាភិបាលគួរតែមានគោលជំហរធានាឱ្យប្រជាពលរដ្ឋខ្លួនទទួលបានទឹកប្រើប្រាស់យ៉ាងហោចណាស់ ៥០ ទៅ១០០លីត្រក្នុងមួយថ្ងៃសម្រាប់មនុស្សម្នាក់។[៧៨]

### *អនាម័យ*

អនាម័យត្រូវគេប្រើដើម្បីនិយាយអំពីទិដ្ឋភាពផ្សេងជាច្រើននៃអនាម័យទាក់ទងនឹងរាងកាយ ដូចជា ការមានបង្គន់ប្រើប្រាស់ និងមានកន្លែងចោលសំរាម ឬដុតសំរាម។ បទដ្ឋានសង្គ្រោះបន្ទាន់អន្តរជាតិបានណែនាំឱ្យ ប្រើបង្គន់មួយសម្រាប់មនុស្សយ៉ាងច្រើន២០នាក់ ដែលជាការឆ្លើយតបនឹងករណីនៃស្ថានភាពគ្រោះមហន្តរាយ ដើម្បីរក្សាបានបទដ្ឋានអប្បបរមានៃសុខភាព សុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងសុខុមាលភាព។[៧៩] កន្លែងតាំងទីនៅលំនោះថ្មី និងលំនៅដ្ឋានភាគច្រើន ស្ថិតក្រោមការសិក្សានេះ មិនមានសូម្បីតែបង្គន់សាធារណៈ។ មានតែនៅសហគមន៍អភិវឌ្ឍន៍មានជ័យ ទួលសំបូរ និងផ្ទះល្វែងនៅដំណាក់ត្រយឹងទេ ដែលមានសង់បង្គន់ជាប់នឹងផ្ទះនីមួយៗ។ ស្ថានភាពនេះជាការឆ្លុះបញ្ចាំងក្នុងកម្រិតណាមួយ លើស្ថានភាពទូទៅនៅទូទាំងប្រទេស ដែលតាមការប៉ាន់ស្មាន ថានៅឆ្នាំ២០០៤ មានប្រជាពលរដ្ឋកម្ពុជាប្រហែលជា ១៧ភាគរយប៉ុណ្ណោះដែលមានបង្គន់ប្រើប្រាស់ស្របតាមបទដ្ឋានសមរម្យ។[៨០]

ប្រជាពលរដ្ឋនៅអណ្តូង ដំណាក់ត្រយឹង និងត្រពាំងអញ្ចាញ បន្ទោរបង់ពាសវាលពាសកាលនៅជុំវិញកន្លែងតាំងទីលំនៅថ្មីរបស់ខ្លួន ឬនៅលើវាលស្រែនៅក្បែរៗនោះ(ឬក្នុងករណីដំណាក់ត្រយឹងនៅតាមផ្ទះល្វែង ដែលគេកំពុងសង់មិនទាន់រួចរាល់នៅជិតទីតាំងនោះ)។ ស្ត្រីច្រើនតែទៅបន្ទោរបង់ពេលទៀបភ្លឺ ឬ ទៅបន្ទោរបង់ពេលព្រលប់ដោយមូលហេតុនៃការខ្មាស់អៀន ។ ការបន្ទោរបង់ បែបនេះ មានករណីខ្លះបានបង្កឱ្យមានភាពតានតឹងជាមួយនឹងសហគមន៍មូលដ្ឋាន ដែលមើលឃើញថាក្រុមគ្រួសារដែលមករស់នៅថ្មីនេះ ធ្វើឱ្យមានការខូចខាតដល់វាលស្រែ ឬ មានការគំរាមកំហែងដល់បរិស្ថានរស់នៅរបស់ខ្លួនគាត់ ហើយម្ចាស់ស្រែបានស្រែកដេញអ្នកមកបន្ទោរបង់នៅលើ ឬ ក្បែរស្រែខ្លួនឱ្យចេញទៅឆ្ងាយ។ ការបន្ទោបង់ពាសវាលពាសកាលបង្កឱ្យមានហានិភ័យយ៉ាងពិតប្រាកដ ជាមិនខាន ហើយនៅឯអណ្តូងស្ថានភាពពិតជាធ្ងន់ធ្ងរ។ ក្លិនលាមកធុំសាយភាយខ្លាំង នៅពេលចូលទៅក្បែរ ឬចូលទៅខាងក្នុងទីតាំងនោះ។ លាមកត្រូវហូរចូលទៅក្នុងតំបន់ ផ្ទះសំបែងដែលមនុស្សរស់នៅវិញ នៅពេលមានភ្លៀង និងទឹកលិច។

មានបង្គន់អនាម័យ ប្រហែលជា១០ (មានពីរជួរ) នៅអណ្តូង[៨១] ប៉ុន្តែបង្គន់ទាំងនោះ ត្រូវចាក់សោរ ហើយប្រជាពលរដ្ឋដែលប្រើប្រាស់បង្គន់ត្រូវបង់ប្រាក់ ២០០រៀល ពេលចូលប្រើម្តងៗ។ នៅ

[៧៨] http://www2.ohchr.org/english/issues/water/iexpert/docs/watersant.pdf

[៧៩] សៀវភៅ Sphere Project ជំពូកទី ២ ។

[៨០] ធនគារពិភពលោក កម្មវិធីទឹកស្អាត និងអនាម័យ – តំបន់អាស៊ីអាគ្នេយ៍ និងប៉ាអាស៊ីហ្វិក, "ផលប៉ះពាល់សេដ្ឋកិច្ចដោយ កត្តាអនាម័យនៅប្រទេសកម្ពុជា ការសិក្សាលើប្រទេសចំនួន៥មាន កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ហ្វីលីពីន និងវៀតណាម (ឆ្នាំ២០០៨) [ពីពេលនេះតទៅហៅ: ការសិក្សាពីកត្តាអនាម័យដោយធនាគារពិភពលោក] ។

[៨១] បង្គន់ត្រូវបានសាងសង់ដោយ មូលនិធិពីអង្គការរបស់សង្ឃបូរី និង ដោយមានការគាំទ្រពីសាលារាជធានីភ្នំពេញ នាយកដ្ឋានថៃទាំសុខភាពជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ និង អង្គការទឹកភ្លៀងកម្ពុជា ។

ដំណាក់ត្រយឹង ប្រជាពលរដ្ឋដែលរស់នៅតាមដងផ្លូវ ត្រូវបង់ ៣០០ រៀល សម្រាប់ការប្រើប្រាស់បង្គន់មួយលើកៗ។ ប្រជាពលរដ្ឋភាគច្រើនបានដឹងថា មានបង្គន់អនាម័យ នៅទីតាំងដែលខ្លួនរស់នៅ ប៉ុន្តែមិនប្រើប្រាស់វាទេ ព្រោះពួកគាត់ក្រីក្រខ្លាំងណាស់ ដែលគ្មានលទ្ធភាពបង់ប្រាក់ថ្លៃប្រើប្រាស់នោះទេ ហើយសុខចិត្តទុកប្រាក់ចំណាយលើការទិញទឹកវិញ ។

នៅឯស្ពានឆេះ ប្រជាពលរដ្ឋក៏ទៅរកដីទំនេរ និងគុម្ពោតព្រៃនៅក្បែរៗ ដើម្បីបន្ទោរបង់ដែរ។

ក្រៅពីដំណាក់ត្រយឹង ដែលមានក្រុមហ៊ុនប្រមូលសំរាម "ស៊ីនទ្រី" ពីភ្នំពេញចូលទៅប្រមូលសំរាម មិនមានសហគមន៍ណាមួយមានប្រព័ន្ធប្រមូលសំរាមបែបនេះទេ។ ជាលទ្ធផលប្រជាពលរដ្ឋចោលសំរាមនៅជុំវិញខ្លួន នៅក្នុងតំបន់តាំងទីលំនៅថ្មីនោះ ឬអ្នកខ្លះដុតវាចោល ។ ប្រការនេះធ្វើឱ្យសុខភាពសហគមន៍ ដែលកំពុងតែដុនដាបស្រាប់កាន់តែទ្រុឌទ្រោមថែមទៀត។ មិនមានប្រព័ន្ធលូ ឬបណ្តាញបង្ហូរទឹកកាកសំណល់ នៅកន្លែងតាំងទីលំនៅថ្មីនេះ ឬនៅ ក្បែរៗនោះទេ។ នៅរដូវភ្លៀងទីនោះលិចទឹក និងគ្មានប្រព័ន្ធលូ ឬប្រឡាយបង្ហូរទឹកកាក សំណល់ចេញពីកន្លែងតាំងទីលំនៅថ្មីនេះទេ។ ជារឿយៗ ប្រជាពលរដ្ឋគ្មានមធ្យោបាយ ដើម្បីការពារផ្ទះសំបែងរបស់ពួកគាត់ពីការលិចទឹកទេ ដែលធ្វើឱ្យសុខភាព ប្រឈមនឹង គ្រោះថ្នាក់កាន់ច្រើនឡើង។

គ្រូពេទ្យ ដែលផ្តល់សេវាថែទាំសុខភាពជាប្រចាំដល់សហគមន៍ដែលមកតាំងទីលំនៅថ្មី បានឃើញលក្ខខ័ណ្ឌជាច្រើន ដែលមានជាប់ទាក់ទងជាទូទៅ ទៅនឹងទីតាំងដែលខ្វះអនាម័យ ហើយដែលជាលទ្ធផលនាំមកនូវការខ្វះខាតអនាម័យរាងកាយយ៉ាងធ្ងន់ធ្ងរ(សូមមើលផ្នែកទី ៥.៦ សុខភាព)។

## ៥.៣ សុវត្ថិភាពខាងការកាន់កាប់ដីធ្លី

យោងទៅតាមក្រុមគ្រួសារប្រជាពលរដ្ឋដែលបានតាំងទីលំនៅថ្មី ការមានសុវត្ថិភាពខាងការកាន់កាប់ដីធ្លី មានន័យថា ត្រូវបានការពារពីការដកហូតយកដី ឬលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត លើកលែងតែតាមរយៈនីតិវិធីច្បាប់ និង ជាការកាន់កាប់ដោយគ្មានការបំភិតបំភ័យនិងការគំរាមកំហែងផ្សេងៗទៀត ដែលជាអាទិភាពចម្បងមួយក្នុងចំណោមអាទិភាពចម្បងៗដទៃទៀត។ នៅគ្រប់កន្លែងតាំងទីលំនៅថ្មីទាំងអស់ ប្រជាពលរដ្ឋបានបង្ហាញពីសារៈសំខាន់នៃការមានដីឡូត៍ និងលំនៅដ្ឋានប្រកប ដោយសុវត្ថិភាព ដើម្បីឱ្យពួកគាត់រស់នៅដោយអារម្មណ៍ស្ងប់ និងដើម្បីអោយ ពួកគេមានលទ្ធភាពគិតគូរពីការរកការងារធ្វើ និងធ្វើផែនការសម្រាប់ អនាគត។ វិធានការផ្តល់សុវត្ថិភាពខាងការកាន់កាប់ដីធ្លី ជូនប្រជាពលរដ្ឋនៅតាមកន្លែងតាំងទីលំនៅថ្មីទាំងអស់ មានលក្ខណៈខុសប្លែកគ្នាពីកន្លែងមួយទៅកន្លែងមួយទៀត។

### *អារម្មណ៍គ្មានសុវត្ថិភាព របស់ប្រជាពលរដ្ឋដែលបានមកតាំងទីលំនៅថ្មី*

ដោយខ្វះភាពប្រាកដនិយមចំពោះការកាន់កាប់ដីធ្លីដែលពួកគាត់កំពុងរស់នៅ មានសហគមន៍ ក្រោមការសិក្សានេះ មួយចំនួន បង្ហាញថា ពួកគេមានភាពស្ទាក់ស្ទើរ ដើម្បីការរស់នៅជាប់លាប់ នៅកន្លែងតាំងទីលំនៅថ្មីនេះ ឧទាហរណ៍ ដូចជា មិនហ៊ានដាក់ទុនធ្វើជំនួញ ឬក៏សង់ផ្ទះរឹងមាំ ជាដើម ជាពិសេសចំពោះករណីនៃបណ្តាសហគមន៍ ដែលមិនបានទទួលដីជាផ្លូវការ ក្រោយពីការបណ្តេញចេញ ដូចជាករណី សហគមន៍ស្ពានឆេះ (ដែលកំពុង រស់នៅតាមចិញ្ចើមផ្លូវ តាំងពីឆ្នាំ ២០០៧) អាជីវករ និង អ្នកជួលផ្ទះ នៅដំណាក់ត្រយឹង ក៏ដូចជា ប្រជាពលរដ្ឋដែលកំពុងរង់ចាំទទួលដីឡូត៍ផ្លូវការនៅអណ្តូង( អ្នកមិនទាន់ចូលឡូត៍)ជាដើម។

**ប្រអប់លេខ១១: អណ្ដូង: ទ្វេរគ្រោះនៃចំនួនប្រជាពលរដ្ឋ និង ដីឡូដីដែលមានការទទួលស្គាល់ និង មិនទាន់មានការទទួលស្គាល់**

ក្រុមគ្រួសារប្រជាពលរដ្ឋនៅ អណ្ដូង ត្រូវបានបែងចែករវាងអ្នកដែលរស់នៅលើ “ដីឡូតិ៍ផ្លូវការ” (អ្នកចូលឡូតិ៍)និងអ្នកដែលរស់នៅលើ “ដីឡូតិ៍មិនផ្លូវការ”(អ្នកមិនទាន់ចូលឡូតិ៍)។ ក្នុងរយៈពេលប៉ុន្មានសប្ដាហ៍នៃការបណ្ដេញចេញ អាជ្ញាធរបានកំណត់បែងចែកដីជា ៧៧៧ ឡូតិ៍ ដែលមួយឡូត៍ៗ មានទំហំ ៤ម គុណ ៦ម ក្នុងគោលបំណង ផ្ទេរវាជាផ្លូវទៅឱ្យប្រជាពលរដ្ឋ។ សាលារាជធានីភ្នំពេញ និង អាជ្ញាធរមូលដ្ឋាន បានចែក“ ដីឡូត៍ផ្លូវការ” ទាំងនោះ តាមរូបភាពជាច្រើន ដូចជា នៅឯពិធីមួយ កាលពីថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០០៦ (នៅពេលដីចំនួន៣០៦ឡូត៍ ត្រូវបានប្រគល់ជូនប្រជាពលរដ្ឋ)[៨២] ឬតាមរយៈការចុះឈ្មោះគ្រួសារនីមួយៗ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ឬក៏តាមរយៈការ ចែកផ្ទះល្វែងដែលសាងសង់ដោយមូលនិធិ UPDF ។ យោងតាមអភិបាលរងសាលារាជធានី ដីឡូត៍ផ្លូវការ ត្រូវបានប្រគល់ជូនក្រុមគ្រួសារ ដែលមកពីសំបុកចាប ក្នុងសង្កាត់ទន្លេបាសាក់ និងដែលបានទទួលស្គាល់ដោយអាជ្ញាធរ ។ ប្រជាពលរដ្ឋ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការទទួលដីឡូតិ៍ផ្លូវការនេះ អាចមានចំនួនរហូតដល់ ៦០០គ្រួសារ ចំណែកឯប្រជាពលរដ្ឋដទៃទៀតសុទ្ធតែអ្នកមកពីតំបន់ផ្សេងៗ[៨៣] ប្រជាពលរដ្ឋដែលបានទទួល ដីឡូត៍ផ្លូវការ ទទួលបាន “ប័ណ្ណ” មានបោះត្រាមួយដែលបញ្ជាក់ពីលេខដីឡូតិ៍និងឈ្មោះអ្នកទទួលដីពីអាជ្ញាធរថ្នាក់ស្រុក។ ក៏ប៉ុន្តែ ចំពោះ អ្នកដែលនៅមិនទាន់បង់រំលោះប្រាក់កម្ចីទិញផ្ទះល្វែងUPDF ចប់សព្វគ្រប់ នៅមិនទាន់ទទួលបានឯកសារជាផ្លូវការណាមួយពីអជ្ញាធរ នៅឡើយ។ យោងតាមអ្នកតំណាងសហគមន៍ បានឱ្យដឹងថា មកដល់ឆ្នាំ ២០០៩ មានប្រជាពលរដ្ឋ៥២៥គ្រួសារ បានទទួលដីឡូតិ៍ផ្លូវការ តាមវិធីផ្សេងៗគ្នាទាំងនេះ។ ប្រជាពលរដ្ឋជាច្រើនគ្រួសារ ដែលបានផ្ដល់បទសម្ភាសន៍ និង ដែលបានអះអាងថាខ្លួនជាប្រជាពលរដ្ឋ មកពីសំបុកចាបពិតប្រាកដ បានសំដែងពីក្ដីកង្វល់ចំពោះការដែលពួកគាត់នៅមិនទាន់ទទួលបានដីឡូតិ៍ផ្លូវការនៅឡើយ។

មិនដឹងច្បាស់ទេថាតើ បច្ចុប្បន្នមានប្រជាពលរដ្ឋប៉ុន្មានគ្រួសារដែលរស់នៅ អណ្ដូង។ យោងតាមសាលារាជធានីភ្នំពេញថា អាចនឹងមានរហូតដល់ទៅ ១,៥០០គ្រួសារ។ ក៏ប៉ុន្តែ តំណាងសហគមន៍បាននិយាយដោយយោងលើការស្រង់ស្ថិតិប្រជាពលរដ្ឋមួយ ដែលធ្វើឡើង ក្នុងឆ្នាំ២០០៩ ដែលរកឃើញថា មានប្រជាពលរដ្ឋ ៨៣២គ្រួសារ រស់នៅជាអចិន្ត្រៃយ៍នៅ អណ្ដូង។ ប្រធានភូមិ និងជំនួយការភូមិ បានប៉ាន់ស្មានថា មានប្រជាពលរដ្ឋប្រមាណពី ១,៦០០ ទៅ១,៨០០ គ្រួសារ នៅចុងឆ្នាំ២០០៩។ ដោយសារតែតួលេខខុសគ្នាដូច្នេះ អាជ្ញាធរចាំបាច់ គួរតែចុះធ្វើស្ថិតិមួយដើម្បីកំណត់ឱ្យច្បាស់អំពីចំនួនគ្រួសារដោយសារចំនួនផ្ទះនៃគ្រួសារដែលរស់នៅទីនេះ មានផលប៉ះពាល់ដោយផ្ទាល់ទៅលើផែនការលំនៅដ្ឋាននាពេល



[៨២] នៅឯពិធីមួយប្រហែលជាប៉ុន្មានសប្ដាហ៍ក្រោយការផ្លាស់ប្ដូរទីលំនៅ អាជ្ញាធរក្រុងនិងខ័ណ្ឌបានអានប្រកាសឈ្មោះ ប្រជាពលរដ្ឋ ៣១៦ គ្រួសារ ដែលមានសិទ្ធិទទួលដីឡូតិ៍ ។ តំណាងគ្រួសារត្រូវបានគេហៅម្ដងម្នាក់ៗ ឱ្យឈរនៅចំពោះមុខហ្វូងមនុស្ស ហើយបន្ទាប់ មកគេធ្វើការអះអាងជាសាធារណៈថាតើគ្រួសារនិមួយៗពិតជាអ្នកដែលបានរស់នៅក្នុងសំបុកចាប មុនការបណ្ដេញចេញមែនឬទេ ហើយ អ្នកសំបុកចាបពិតប្រាកដ ទទួលបានដីមួយឡូតិ៍នៅអណ្ដូង។ នៅចុងពិធីនោះ ប្រជាពលរដ្ឋច្រើនជាង ១០ គ្រួសារត្រូវបាន លប់ឈ្មោះចេញពីបញ្ជី ដោយអាជ្ញាធរ ដោយសារថាបានក្លែងបន្លំ ដែលនាំឱ្យចំនួនប្រជាពលរដ្ឋចុះមកនៅចំនួន ៣០៦ គ្រួសារ ។

[៨៣] កិច្ចសម្ភាសន៍ជាមួយអភិបាលរង ។

# ជំពូកទី៥ ៖ ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី



ស្ត្រីមួយក្រុមមកពីសហគមន៍ស្ពានឆេះបានពន្យល់ថា:

> "ប្រសិនជាពេលណាគេអោយដីយើង យើងត្រូវតែមានឯកសាររឹងមាំច្បាស់លាស់ ដើម្បីការពារខ្លួនយើងពីការបណ្តេញចេញទៀត។ ហើយបើមានដីមានសុវត្ថិភាពហើយ យើងក៏អាចធ្វើដំណើរទៅរកស៊ី ឬរកការងារធ្វើនៅទីជិត ឬឆ្ងាយតាមដែលយើងចង់ ដោយមិនគិតបារម្ភអំពីការបាត់បង់ដីរបស់យើង ឬបារម្ភថានឹងមានរឿងអ្វីកើតឡើងដល់កូនចៅរបស់យើង នៅពេលដែលយើងមិននៅផ្ទះ" ។

សហគមន៍ស្ពានឆេះ បានទាក់ទងដល់អាជ្ញាធរថ្នាក់ខេត្ត និងជាតិ រួមទាំងនាយករដ្ឋមន្ត្រីទៀត ដើម្បីសុំឱ្យមានការផ្តល់ដីអោយពួកគាត់ ដែលរហូតមកដល់ពេលនេះពួកគាត់នៅកំពុងតែ រង់ចាំចម្លើយនៅឡើយ។[៨៥] អាជីវករ និង អ្នកជួលផ្ទះ ដែលរស់នៅឯដំណាក់ត្រយឹងរហូតទាល់តែគេផ្តល់ដីអោយក្នុងខែធ្នូ ឆ្នាំ២០០៩ ក៏បាននិយាយឱ្យដឹងដូចគ្នានេះដែរ ពីអារម្មណ៍មិនមានសុវត្ថិភាព និង គ្មានលទ្ធភាពបន្តរស់នៅក្នុងជីវភាពរបស់ពួកគេបែបនេះ តទៅទៀតបាន។

ប្រជាពលរដ្ឋដែលរស់នៅលើដី "មិនផ្លូវការ" (សូមមើលប្រអប់លេខ១១ ខាងក្រោម) នៅ អណ្តូងមានអារម្មណ៍ថា ពួកគាត់ក៏គ្មានសុវត្ថិភាពខាងការកាន់កាប់ដី ផងដែរ។ គេប្រាប់ពួកគាត់ថា ពួកគាត់ត្រូវរស់នៅអោយជាប់លាប់នៅលើដីនេះ រយៈពេល ៥ឆ្នាំ ដើម្បីទទួលបានបណ្ណ័កម្មសិទ្ធិស្ថាពរ។ ក៏ប៉ុន្តែពួកគាត់មិនដែលបានទទួលឯកសារដែលមានការបញ្ជាក់ទទួលស្គាល់ពីការកាន់កាប់ដី ពីអាជ្ញាធរទេ។ គ្រួសារប្រជាពលរដ្ឋភ័យខ្លាចថា ពួកគាត់អាចនឹងត្រូវគេបណ្តេញចេញទៀត និងបានបញ្ជាក់ថា មានពាក្យចចាមអារ៉ាមនិយាយតៗគ្នាថា អាជ្ញាធរនឹងផ្លាស់ប្តូរទីតាំងរបស់ ពួកគាត់ទៀត អោយទៅរស់នៅស្រុកឱរាល់ ក្នុងខេត្តកំពង់ស្ពឺ ឬទៅតំបន់ណាមួយនៅតាមខេត្ត។ ប្រជាពលរដ្ឋបានសំដែងចេញនូវ ក្តីកង្វល់ថាពាក្យចចាមអារ៉ាមបែបនេះអាចជាការពិត ពីព្រោះពួកគាត់ដឹងថា ចំនួនគ្រួសារប្រជាពលរដ្ឋដែលរស់នៅអណ្តូង ប្រហែលជាមានច្រើនជាងដីឡូត៍ដែលមាន ។

សុវត្ថិភាពខាងការកាន់កាប់ដីធ្លី អាចសម្រួលដល់ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ។ ផ្ទុយទៅវិញកង្វះ សុវត្ថិភាពខាងការកាន់កាប់ដីធ្លី ធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិមានការងារធ្វើ និងលទ្ធភាពស្វែងរកការងារធ្វើ។ គ្រួសារមួយរស់នៅតាមចិញ្ចើមផ្លូវ នៅដំណាក់ត្រយឹង បាននិយាយឱ្យដឹងអំពី របៀបដែលកូនស្រីច្បងរបស់គាត់អាចធ្វើការនៅរោងចក្រនៅក្បែរនោះបាន ដោយសារគាត់និយាយភូតកុហក់ អំពីទីតាំងដែលគាត់កំពុងរស់នៅ។ ម្តាយរូបនេះបាននិយាយថា "ខ្ញុំត្រូវតែកុហក ដើម្បីឱ្យកូនស្រីរបស់ខ្ញុំបានការងារធ្វើ ពីព្រោះខ្ញុំបានលឺពីបុគ្គលិកក្រុមហ៊ុននិយាយថា ក្រុមហ៊ុន7 NG មិនចង់ជ្រើសរើសប្រជាពលរដ្ឋ ដែលរស់នៅក្នុងតង់តាមចិញ្ចើមផ្លូវឱ្យធ្វើការទេ ទោះជាការងាររោងចក្រ ឬ ការងារសំណង់ក៏ដោយព្រោះ "គេមិនចង់ឱ្យប្រជាពលរដ្ឋដែលរស់នៅក្នុងតង់មានប្រាក់ចំណូលល្អប្រសើរ និងរស់នៅទីនេះ" ទេ។ ដូច្នេះប្រជាពលរដ្ឋភាគច្រើនដែលធ្វើការនៅរោងចក្រ គឺជាអ្នករស់នៅតាមផ្ទះល្វែង។ មានការអះអាងថាអ្នកដែលរស់នៅតាមចិញ្ចើមផ្លូវដែលបានការងារ

[៨៥] កាលពីដើមឆ្នាំ ២០១០ ក្រុមគ្រួសារប្រជាពលរដ្ឋត្រូវបានគេប្រាប់ថា អាជ្ញាធរថ្នាក់ជាតិបានណែនាំអាជ្ញាធរខេត្ត ឱ្យស្វែងរក ដី ដើម្បីចែកឱ្យពួកគាត់ ។ ក៏ប៉ុន្តែ នៅពេលដែលតំណាងសហគមន៍ទៅជួបអាជ្ញាធរខេត្ត ពួកគាត់ត្រូវបានគេប្រាប់ថា សហគមន៍ត្រូវតែ បង្ហាញនូវលិខិតចេញដោយថ្នាក់ជាតិ ។ ប្រធានភូមិបានប្រាប់បុគ្គលិក OHCHR កាលពីខែវិច្ឆិកា ឆ្នាំ ២០០៩ ថា សាលាខេត្ត កំពុងពិចារណាអំពីការផ្តល់ដីជូនអ្នកភូមិប្រហែលជា ៧០គ្រួសារ នៅក្នុងសង្កាត់ផ្សេងមួយទៀត ។

ធ្វើជាកម្មករសំណង់ ទទួលបានប្រាក់តិចជាងអ្នកដែលរស់នៅផ្ទះល្វែង។

ការខ្វះសុវត្ថិភាពខាងការកាន់កាប់ដីធ្លី ជាចំណែកដែលបណ្តាលឱ្យប្រជាពលរដ្ឋ រស់នៅដោយ ក្តីបារម្ភនិងមានអារម្មណ៍តានតឹង។ អតីតអាជីវករនិងអ្នកជួលផ្ទះ ពីសហគមន៍ដីក្រហម ក្នុងពេលដែលរស់នៅឯដំណាក់ត្រយឹង ស្ទើរតែពេញមួយឆ្នាំ២០០៩ បានបង្ហាញថា ពួកគាត់តែងតែភ័យខ្លាចថា ថ្ងៃណាមួយគេបណ្តេញពួកគាត់ចេញពីនេះទៀត។ អតីតអាជីវករម្នាក់ បាននិយាយថា:

> "ឥឡូវនេះ ខ្ញុំមានតែពឹងលើទេវតាទេ។ ខ្ញុំគ្មានសង្ឃឹមទេ។ ពួកយើងបានត្រឹមតែ មួយរស់ពីមួយថ្ងៃទៅមួយថ្ងៃប៉ុណ្ណោះ។ ខ្ញុំចង់មានកន្លែងរស់នៅមានសុវត្ថិភាព ដើម្បីខ្ញុំអាចគិតពីផែនការសំរាប់គ្រួសារ និងការប្រកបរបរចិញ្ចឹមជីវិត"។

សីហា មានប្រពន្ធនិងកូនបីនាក់រស់នៅដំណាក់ត្រយឹង

ប្រជាពលរដ្ឋដែលបានផ្តល់បទសម្ភាសន៍ក៏បាននិយាយដែរថា ពួកគាត់ ឬសមាជិកក្នុងគ្រួសារដែលពេញវ័យម្នាក់ ត្រូវនៅចាំផ្ទះជាប្រចាំ ដើម្បីធានាថា ពួកគាត់នឹងមិនខកខានពីការទទួលដំណឹងអំពីការបណ្តេញចេញ ឬអំពីការផ្តល់ដីនៅកន្លែងផ្សេងទៀត ព្រោះព្រឹត្តិការណ៍បែបនេះ អាចកើតមានគ្រប់ពេល។ អតីតអាជីវករម្នាក់ ឈ្មោះ តុលា អាយុ ៤៨ ឆ្នាំ បាននិយាយថា:

> "ខ្ញុំត្រូវការដីដែលមានសុវត្ថិភាព និងមានផ្ទះរស់នៅ។ ខ្ញុំមានកូនច្រើននាក់ ដូច្នេះ ខ្ញុំត្រូវការដី។ ខ្ញុំបានរង់ចាំទទួលដីជិតមួយឆ្នាំហើយ ដោយរស់នៅជាបណ្តោះអាសន្ន ក្នុងតង់នៅតាមចិញ្ចើមផ្លូវ។ ខ្ញុំមិនបានទៅរកការងារធ្វើទេ។ ខ្ញុំស្នាក់នៅទីនេះរាល់ថ្ងៃ ដើម្បីធានាថាគ្រួសាររបស់ខ្ញុំទទួលបានដី នៅពេលដែលអាជ្ញាធរ និង ក្រុមហ៊ុន7NG ផ្លាស់ប្តូរពួកខ្ញុំទៅទីតាំងថ្មី។ ខ្ញុំនឹងទៅរកការងារធ្វើភ្លាម នៅពេលដែលខ្ញុំទទួលបានដី"។

ទីបំផុត នៅខែធ្នូ ឆ្នាំ២០០៩ ប្រជាពលរដ្ឋភាគច្រើនបានផ្លាស់ទៅនៅទីតាំងថ្មី ដែលក្រុមហ៊ុន 7NG ផ្តល់ដីឱ្យ នៅក្នុងភូមិស្រះពោធិ៍ ឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្តាល ដែលនៅទីនោះ ប្រជាពលរដ្ឋទទួលបានដីមួយឡូត៍មានទំហំ ៤ម គុណ ៦ម ជាដីទំនេរនៅឯតំបន់ដាច់ស្រយាល។ នៅទីនោះគ្មានហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ឬទឹកស្អាតសម្រាប់ប្រើប្រាស់ទេ ហើយផ្នែកមួយនៃកន្លែងនោះងាយលិចទឹកណាស់។ ខណ:ដែលក្រុមហ៊ុន7 NG បានសង់រោងមួយធ្វើជាផ្សារនៅលើដីទួលខ្ពស់ ក្រុមហ៊ុនមិនបានជួយដល់ក្រុមគ្រួសារនៅលើដីទាប សាងសង់ផ្ទះសំបែងទេ។ ប្រជាពលរដ្ឋបានត្អូញត្អែរថាផ្នែកខ្លះនៃតំបន់នេះលិចទឹករហូតដល់ត្រឹមជង្គង់ នៅពេលមានភ្លៀងកក់ខែនៅខែមករា ឆ្នាំ២០១០។ តាំងនេះក៏នៅឆ្ងាយពីកន្លែងដែលមានឱកាសរកការងារផងដែរ។ ទាំងនេះគឺជា សញ្ញាបង្ហាញថា ការរៀបចំលំនៅដ្ឋានថ្មីនេះមិនមាននិរន្តរភាពទេ ដូច្នេះហើយសុវត្ថិភាពខាងការកាន់កាប់ដីធ្លី មិនត្រូវបានធានាទេ ។

ខ្វះសុវត្ថិភាពខាងការកាន់កាប់ដីធ្លី ក៏ប៉ះពាល់ដែរទៅដល់លទ្ធភាពទទួលបានសេវាចាំបាច់ជាមូលដ្ឋាន ដូចជា សេវាសុខភាពជាដើម។ ស្ត្រីមានគភ៌ និងកុមារដែលរស់នៅជា បណ្តោះអាសន្ននៅតាមចិញ្ចើមផ្លូវនៅដំណាក់ត្រយឹង មិនអាចប្រើប្រាស់បានកម្មវិធីចាក់ថ្នាំ វ៉ាក់សាំងទេ ពីព្រោះពួកគាត់ស្ថិតក្នុងស្ថានភាពរដ្ឋបាលមិនច្បាស់លាស់ ហើយពឹងផ្អែកលើ ជំនួយពីអង្គការមិនមែនរដ្ឋាភិបាល (សូមមើលផ្នែកទី ៥.៦ អំពីសុខភាពផង)។

# ជំពូទី៥ ៖ ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី



អាជីវករ និងអ្នកជួលផ្ទះនៅសហគមន៍ដីក្រហមពីមុន ស្ថិតនៅលំនៅដ្ឋានបណ្តោះអាសន្នដែលពួកគេបានសាងសង់នៅដំណាក់ត្រយឹង ថ្លែងអំណរគុណចំពោះរូបថតដោយយោះLICADHO

## ភាពគ្មានផ្ទះ*សំបែង* និង*ដីធ្លី*

ការបណ្តេញចេញមិនគួរនាំឱ្យប្រជាពលរដ្ឋគ្មានផ្ទះសំបែងរស់នៅ ឬ ងាយរងគ្រោះដោយការរំលោភសិទ្ធិផ្សេងៗទៀតនោះទេ។ ទីណាដែលប្រជាពលរដ្ឋ រងផលប៉ះពាល់មិនអាចជួយខ្លួនឯងបាន រដ្ឋជាភាគីត្រូវតែចាត់គ្រប់វិធានការសមស្រប រហូតដល់កម្រិតអតិបរមានៃធនធានដែលរដ្ឋមាន ដើម្បីធានាអោយមានជំរើសលំនៅដ្ឋានសមរម្យ ការតាំងទីលំនៅថ្មី ឬការទទួលបានដីដែលមានផលិតភាពទៅតាមករណីជាក់ស្តែង សម្រាប់ប្រជាពលរដ្ឋ។[៨៥]

ការបណ្តេញចេញ សហគមន៍ស្ពានឆេះ នៅខេត្តព្រះសីហានុ ក៏ដូចជា អាជីវករនិងអ្នកជួលផ្ទះនៅដីក្រហមនៅរាជធានីភ្នំពេញ បណ្តាលឱ្យពួកគាត់ក្លាយជាជនគ្មានលំនៅដ្ឋាន និងដីធ្លី។ សហគមន៍ស្ពានឆេះបានរស់នៅ ក្នុងជម្រកប្រក់តង់ នៅតាមចិញ្ចើមផ្លូវ តាំងពីខែមេសា ឆ្នាំ ២០០៧ ចំណែកឯអាជីវករ និងអ្នកជួលផ្ទះ មកពីសហគមន៍ដីក្រហមក៏បានរស់នៅតាមចិញ្ចើមផ្លូវ នៅឯដំណាក់ត្រយឹងអស់រយៈពេលជិតមួយឆ្នាំ មុនពេលដែលពួកគាត់ផ្លាស់ទីតាំងទៅ ភូមិស្រះពោធិ៍ ក្នុងខេត្តកណ្តាលកាលពីខែធ្នូ ឆ្នាំ២០០៩។ ក្រុមគ្រួសារដែលបានផ្លាស់ប្តូរទីលំនៅទៅអណ្តូង ត្រពាំងអញ្ចាញ និងអូរកម្ពុជាមិនត្រូវបាន គេផ្តល់ទីជំរក ឬផ្ទះសំបែងអោយភ្លាមៗបន្ទាប់ពីការបណ្តេញចេញទេ។

ប៉ុន្មានឆ្នាំក្រោយពីការអោយផ្លាស់ទីលំនៅមានភស្តុតាងខ្លះបង្ហាញថា ប្រជាពលរដ្ឋនៅកន្លែងតាំងទីលំនៅថ្មីទាំងនេះ បានក្លាយទៅជាអ្នកគ្មានផ្ទះ

[៨៥] CESCR សេចក្តីពន្យល់រួមលេខ ៧ វាក្យខ័ណ្ឌ១៦។

# ជំពូទី៥ ៖ ការចាប់ផ្ដើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី

សំបែងរស់នៅជាលើកទី២ តាំងពីពេលដែលពួកគាត់មកដល់ទីនោះ។ OHCHR បានដឹងអំពីករណីមួយដែលគ្រួសារមួយត្រូវបានដកហូតសិទ្ធិពីការទទួលបានផ្ទះ ដោយសារតែ ការព្រមព្រៀងជាលក្ខណ: បុគ្គលរវាងបុគ្គលម្នាក់ និង អ្នកមានសមត្ថកិច្ចនៅកន្លែងតាំងទីលំនៅថ្មី។[៨៦] ប៉ុន្តែក្នុងករណីដែលបានពិនិត្យភាគច្រើ ឃើញថា ក្រុមគ្រួសារប្រជាពលរដ្ឋបានក្លាយទៅជាអ្នកគ្មានផ្ទះសំបែង ដោយសារគាត់លក់ដីរបស់គាត់ ដើម្បីបង់ថ្លៃព្យាបាលជំងឺ ឬ ដោយសារម្ចាស់បំណុល ឬធនាគារ ដកហូតយកដីរបស់គាត់ ដោយសារតែការប្រាក់កើនឡើង និងខ្វះចំណូលដើម្បីសងប្រាក់បំណុលវិញ។ ប្រជាពលរដ្ឋជាច្រើនគ្រួសារនៅតាមទីកន្លែងតាំងទីលំនៅថ្មីនោះ ហាក់បីដូចជាបានខ្ចីប្រាក់ពីស្ថាប័ន ឥណទានសាធារណ: ឬឯកជនផ្សេងៗ ឬអង្គការមិនមែនរដ្ឋាភិបាល (ក្នុងអត្រាការប្រាក់ ខុសៗគ្នា) ដើម្បីជួសជុលកែលម្អផ្ទះសំបែង ឬ ដើម្បីបើកមុខរបរបន្តិចបន្តួច ឬ ចំណាយលើ ការព្យាបាលជំងឺជាបន្ទាន់។ ប្រជាពលរដ្ឋស្ទើរតែគ្រប់រូបដែល បានផ្តល់បទសម្ភាសន៍សម្រាប់ការសិក្សានេះ បានប្រើប្រាស់ឯកសារដីរបស់ពួកគាត់ដើម្បី ដាក់ធានាខ្ចីប្រាក់។ អ្នកខ្លះ បានសំដែងក្តីកង្វល់អំពីការបាត់បង់ដីរបស់ពួកគាត់ ប្រសិនបើពួកគាត់មិនអាចសងប្រាក់ទៅម្ចាស់បំណុល វិញទេ។

## *ការសន្យាផ្ដល់បណ្ណ័កម្មសិទ្ធិស្ថាពរ ៖ សន្យា "ប្រាំឆ្នាំ"*

ក្រុមគ្រួសាប្រជាពលរដ្ឋ ដែលទទួលបានដីជាលក្ខណៈផ្លូវការ នៅឯកន្លែងតាំងទីលំនៅថ្មី ត្រូវបានប្រាប់ថា ឱ្យរស់នៅកម្មសិទ្ធិ លើទីតាំងនោះរយៈពេល៥ឆ្នាំ ដើម្បីទទួលបានបណ្ណ័កម្មសិទ្ធិស្ថាពរ និងត្រូវហាមមិនឱ្យលក់ដីក្នុង រយៈពេលនេះទេ។ គេប្រាប់ពួកគាត់អំពី“ គោលការណ៍ប្រាំឆ្នាំ” ដោយផ្ទាល់មាត់ (នៅទួលសំបូរ អូរកម្ពុជា ដំណាក់ត្រយឹង និង អភិវឌ្ឍន៍មានជ័យ) និងដោយលាយលក្ខណ៍អក្សរ (នៅត្រពាំងអញ្ចាញ និង អណ្តូង)។ ប្រជាពលរដ្ឋសហគមន៍ស្ពានឆេះ អ្នកដែលរស់នៅតាមចិញ្ចើមផ្លូវនៅដំណាក់ត្រយឹង មិនទទួលបាន ការសន្យាណាមួយទេ។ អាជ្ញាធរថ្នាក់មូលដ្ឋាន និងថ្នាក់រាជធានី ផ្តល់សេចក្តីពន្យល់ខុសៗគ្នា អំពីគោលការណ៍ប្រាំឆ្នាំនេះ ដោយនិយាយថា វាមានគោលបំណងធានាមិនអោយប្រជាពលរដ្ឋក្លាយទៅជាជនគ្មានដីធ្លី (ដោយការលក់ដីភ្លាមៗ) ប៉ុន្តែក៏ដើម្បីធ្វើឱ្យប្រាកដថាប្រជាពលរដ្ឋមិនកេងបន្លំយកចំណេញលើដំណើរការបណ្តេញចេញ ដើម្បីទទួលបានបណ្ណ័កម្មសិទ្ធិស្ថាពរ។

អាជ្ញាធរហាក់ដូចជាបានយកគំរូសម្បទានដីសង្គមកិច្ចមកអនុវត្ត ដូចជា យន្តការតាមផ្លូវច្បាប់ក្នុងការផ្ទេរដីឯកជនរបស់រដ្ឋ ទៅឱ្យប្រជាពលរដ្ឋក្រីក្រដែលគ្មានដី សម្រាប់គោលបំណងសង់លំនៅដ្ឋាន និង/ឬគោលដៅធ្វើកសិកម្មជាលក្ខណ:គ្រួសារ ដែលវាជាហេតុផលសំអាង ដើម្បីកំនត់ពីគោលការណ៍ប្រាំឆ្នាំ។[៨៧] អាជ្ញាធរភាគច្រើនដែលបានផ្តល់បទសម្ភាសន៍បាននិយាយយោងទៅលើគំរូនេះ។ ក៏ប៉ុន្តែតាមឧបសម្ព័ន្ធទី២ បង្ហាញថា ក្នុងឯកសារផ្លូវការ នានា



[៨៦] បូពា ស្ត្រីអាយុ ៣៥ ឆ្នាំជាអ្នកជំងឺអេដស៍ នៅ អណ្តូង ផ្ទះរបស់គាត់ ដែលបានសង់ឡើងដោយជំនួយពី NGO មួយនាដើមឆ្នាំ ២០០៧ ត្រូវបានរុះរើនៅពេលដែលគាត់មិននៅផ្ទះ ហើយបានជំនួសដោយផ្ទះល្វែងUPDF ។ គាត់បាននិយាយថា: “នៅពេលដែលខ្ញុំត្រឡប់មកអណ្តូងវិញ ប្រហែលជាមួយខែក្រោយមក ខ្ញុំបានឃើញផ្ទះល្វែងមួយខ្នងសង់នៅលើដីរបស់ ខ្ញុំ ហើយមានគេរស់នៅក្នុងនោះ ។ តំណាងសហគមន៍បានរក្សាទុករបស់របររបស់ខ្ញុំឱ្យខ្ញុំ ហើយពួកគេបានប្រាប់ខ្ញុំឱ្យរង់ចាំទទួល ផ្ទះល្វែងថ្មី នៅពេលដែលផ្ទះល្វែងដទៃទៀតត្រូវបានសាង់សង់ ។ ពួកគេប្រាប់ខ្ញុំឱ្យរស់នៅជាបណ្តោះអាសន្ននៅតាមផ្លូវក្បែរ អតីតដីរបស់ ខ្ញុំ ។ ខ្ញុំបានរស់នៅក្រោមតង់តាំងពីពេលនោះមក” ។

[៨៧] មាត្រា ២ (ក) អនុក្រិតលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច( SLC) ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ។

# ជំពូកទី៥ ៖ ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី

កម្រមានការយោងទៅអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចនេះណាស់ ដូច្នេះបានទុកឱ្យប្រជាពលរដ្ឋដែលបានតាំងទីលំនៅថ្មី មានស្ថានភាពផ្លូវច្បាប់មិនច្បាស់លាស់ ។[៨៨] តាមការពិនិត្យគ្មានទីតាំងណាមួយបង្ហាញថាបានចុះបញ្ជីត្រឹមត្រូវជាសម្បទានដីសង្គមកិច្ចទេ។

បញ្ហាមួយទៀតគឺថា គោលការណ៍ប្រាំឆ្នាំហាក់ដូចជាមិនអនុវត្តគិតចាប់ពីថ្ងៃផ្លាស់ប្តូរទីតាំងទេ ប៉ុន្តែគិតចាប់ពីថ្ងៃដែលចេញឯកសារបញ្ជាក់ទទួលស្គាល់ការកាន់កាប់ដីទៅវិញ។ ឧទាហរណ៍ប័ណ្ណទទួលស្គាល់ម្ចាស់ដីឡូត៍ ដែលចេញជូនប្រជាពលរដ្ឋនៅត្រពាំងអញ្ចាញ បានយោងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ដោយហាមអ្នកទទួលដីពីការលក់ដូរ ដាក់បញ្ចាំ ផ្ទេរសិទ្ធិ ឬ ធ្វើអំណោយអោយអ្នកដទៃ ក្នុងរយៈពេលប្រាំឆ្នាំ គិតចាប់ពីថ្ងៃចេញប័ណ្ណ (ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៨)។ ដោយសារកាលបរិច្ឆេទនៃការចេញឯកសារអោយប្រជាពលរដ្ឋអាស្រ័យលើកត្តាជាច្រើន ដែលវាស្ថិតនៅក្រៅពីការអាចគ្រប់ គ្រងបានរបស់ប្រជាពលរដ្ឋ ដូច្នេះពួកគាត់មិនគួរជាអ្នកទទួលខុសត្រូវ ចំពោះការពន្យាពេលណាមួយ ដែលអាជ្ញាធរបង្កឡើងក្នុងការចេញឯកសារនោះទេ ដូច្នេះហើយគោលការណ៍ប្រាំឆ្នាំ គួរតែអនុវត្តចាប់ពីថ្ងៃនៃការផ្លាស់ប្តូរទីតាំង។

ដោយសារតែប្រជាពលរដ្ឋដែលបានផ្លាស់មកកន្លែងតាំងទីលំនៅថ្មី (តាមទីតាំងដែលបានពិនិត្យ ប៉ុន្តែជាទូទៅ) អាចមានស្ថានភាពផ្លូវច្បាប់លើដីខុសៗគ្នា មុនពេលបណ្តេញចេញ ដូច្នេះភាពខុសគ្នានៃស្ថានភាពផ្លូវច្បាប់នេះ ក៏គួរតែកំនត់ឡើងរវាងក្រុមគ្រួសារដែលមានសិទ្ធិភោគៈ នៅទីតាំងមុនរបស់ពួកគាត់ ដែលត្រូវបានដកហូត និង ក្រុមគ្រួសារដែលមិនមានសិទ្ធិសោះ។

### *ការធានា និងឯកសារដែលផ្តល់ដោយអាជ្ញាធរ*

ឯកសារ និងកិច្ចធានានានា ពីអាជ្ញាធរមានលក្ខណៈខុសប្លែកគ្នាខ្លាំងណាស់ ពីកន្លែងតាំងទីលំនៅថ្មីមួយ ទៅកន្លែងមួយទៀត និងនៅក្នុងកន្លែងតាំងទីលំនៅថ្មីតែមួយ។ OHCHR ទទួលបានឯកសារប្រាំបួនខុសៗគ្នា ដែលអាជ្ញាធរបានចេញឱ្យគ្រួសារនីមួយៗនៅភ្នំពេញ និងនៅខេត្ត ព្រះសីហនុ ដើម្បីផ្ទេរសិទ្ធិកាន់កាប់ដី ឬផ្ទះល្វែង និងមានឯកសារពីរទៀតដែលមានតែហត្ថលេខាក្រុមហ៊ុន 7NG (សម្រាប់គ្រួសារដែលផ្លាស់ប្តូរទីតាំងទៅ ស្រះពោធិ៍ នៅខេត្ត កណ្តាល និងក្រុមហ៊ុន សួរ ស្រ៊ុន សម្រាប់អតីតប្រជាពលរដ្ឋសំបុកចាបដែលឥឡូវនេះ រស់នៅត្រពាំងអញ្ចាញ)។ ចំណែកឯប្រជាពលរដ្ឋដែលផ្ទុកមេរោគអេដស៍នៅទួលសំបូរ មិនបានទទួលឯកសារជាបុគ្គលទេ តែមានឈ្មោះ និង ដីពាក់ព័ន្ធចុះក្នុងបញ្ជីផ្លូវការរួម។ គ្រួសារនៅស្ពានឆេះមិនបានទទួលឯកសារអ្វីទេ សូម្បីតែការនិយាយធានាថា ពួកគាត់អាចរស់នៅកន្លែងដែលពួកគាត់កំពុងរស់នៅ។

ឯកសារទាំងនេះត្រូវបានប្រើប្រាស់ ដើម្បីទទួលបានប្រាក់កម្ចី ហើយត្រូវបានស្ថាប័នផ្តល់ប្រាក់កម្ចីទទួលយករួចហើយ ។ ឯកសារទាំងនេះក៏ត្រូវបានប្រើប្រាស់ ដើម្បីលក់ និងផ្ទេរដីផងដែរ។

មានការពិបាក នឹងមើលឃើញពីការសម្របសម្រួល ឬភាពត្រូវគ្នាណាមួយ នៅថ្នាក់មូលដ្ឋាន ឬ

[៨៨] ត្រូវកំណត់សម្គាល់ថា បញ្ញត្តិផ្សេងៗ នៃអនុក្រិតស្តីពីសម្បទានដីសង្គមកិច្ចមិនត្រូវបានយកមកអនុវត្តតាមទេ (ដូចជា ការចូលរួម និង ការជូនដំណឹងជាសាធារណៈ)។ ជាមួយគ្នានេះដែរ គោលការណ៍ប្រាំឆ្នាំ ហាក់ដូចជាត្រូវបានប្រើប្រាស់ដោយ សាលារាជធានី ភ្នំពេញ មុនការអនុម័តអនុក្រិត ។ ជាការពិតក្នុងឆ្នាំ ១៩៩៩ អាជ្ញាធរបានប្រាប់សហគមន៍អភិវឌ្ឍន៍មានជ័យ ឱ្យរស់នៅលើដីនេះ ជាបន្តបន្ទាប់ រយៈពេលប្រាំឆ្នាំ ។

ថ្នាក់រាជធានី ក្នុងការចេញឯកសារទាំងនេះណាស់។ អាជ្ញាធរនិងសហគមន៍ដែលទទួលរងផលប៉ះពាល់ គប្បីទទួលបានប្រយោជន៍ ពីប្រព័ន្ធដ៏ឯកភាពមួយ ពីព្រោះវានឹងជួយអោយមានដំណើរការឯកភាពគ្នា មួយដែលនឹងផ្តល់អោយនូវភាពប្រាកដប្រជា និង សុវត្ថិភាព ជូនប្រជាពលរដ្ឋដែលបានតាំងទីលំនៅថ្មី។ អ្នកដែលបានផ្តល់បទសម្ភាសន៍ មិនបានដឹងច្បាស់ថា តើពួកគាត់នឹងទទួលប័ណ្ណកម្មសិទ្ធិបន្ទាប់ពីរយៈពេលប្រាំឆ្នាំ តាមការសន្យាដែរឬទេ តើឯកសារប្រភេទណា ដែលអាជ្ញាធរនឹងចេញឱ្យពួកគាត់ក្នុងពេលនេះ និងតើឯកសារទាំងនោះមានគោលបំណងផ្តល់នូវស្ថានភាពផ្លូវច្បាប់ច្បាស់លាស់អ្វីខ្លះ ដល់ពួកគាត់។

សេចក្តីពិពណ៌នា និង រូបភាពពិតប្រាកដនៃឯកសារទាំងនោះមាននៅក្នុងឧបសម្ព័ន្ធទី២។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឯកសារជាឧទាហរណ៍ដែលបានទទួលស្គាល់ផ្តល់អោយអ្នកតាំងទីលំនៅថ្មី។ សូមមើលឧបសម្ព័ន្ធ២សំរាប់ឧទាហរណ៍ផ្សេងទៀត

### *ការលក់ដី និងការផ្លាស់ទីតាំងចុះឡើង*

ទោះបីជាមាន"គោលការណ៍ប្រាំឆ្នាំ"ដែលហាមឃាត់ការលក់ដីក្នុងរយៈពេលប្រាំឆ្នាំក៏ដោយប្រតិបត្តិការទិញលក់ដី មុនពេលទទួលបានបណ្ណ័កម្មសិទ្ធិស្ថាពរ ហាក់ដូចជាកើតមានជាទូទៅ។ ក្រុមគ្រួសារដែលបានមកតាំងទីលំនៅថ្មី និងអ្នកតំណាងសហគមន៍ដែលបានផ្តល់បទសម្ភាសន៍ បានអះអាងថាពិតជាមានការទិញលក់ដី។ ប្រធានភូមិ អណ្តូងបានប៉ាន់ស្មានថា យ៉ាងហោចណាស់អ្នករស់នៅកន្លែងតាំងទីលំនៅថ្មី ៥០ភាគរយ"បានលក់ដីហើយវិលទៅទីប្រជុំជនក្នុងទីក្រុងវិញ"។

ដូច្នេះមិនច្បាស់ថាតើ" គោលការណ៍ប្រាំឆ្នាំ" ត្រូវបានអនុវត្តយ៉ាងណានៅឡើយទេ ព្រោះថា អាជ្ញាធរមូលដ្ឋាន និងអ្នកតំណាងសហគមន៍ជាញឹកញាប់តែងតែពាក់ព័ន្ធនឹងការចុះហត្ថលេខា ឬធ្វើជាសាក្សីលើកិច្ចព្រមព្រៀងទិញលក់ដី ហើយដែលជាការអនុញ្ញាតដល់ ការទិញលក់នេះ។ ឯ.ឧ អភិបាលរង ម៉ាន់ ឈឿន បានមានប្រសាសន៍ថា អាជ្ញាធរយល់ថា នៅក្នុងកាលៈទេសៈខ្លះដូចជា ករណីព្យាបាលជំងឺ ឬករណីបន្ទាន់ផ្សេងៗទៀត ប្រជាពលរដ្ឋត្រូវលក់ដីរបស់ខ្លួន មុនពេលនៃរយៈពេលប្រាំឆ្នាំ ដោយខុសពីឆន្ទៈខ្លួន។[៥៩] ក៏ប៉ុន្តែបទសម្ភាសន៍ជាមួយឯកឧត្តម និង អាជ្ញាធរមូលដ្ឋានដទៃទៀត មិនបានបញ្ជាក់ច្បាស់ថា តើអ្នកដែលទិញដីដោយសុចរិត នៅក្នុងអំឡុងពេល នៃការកំណត់ប្រាំឆ្នាំ នឹងត្រូវបានទទួលស្គាល់ដោយស្របច្បាប់ ហើយទីបំផុតនឹងទទួលបានបណ្ណ័កម្មសិទ្ធិដីធ្លីដែរឬទេ ហើយ ប្រសិនបើដូច្នេះមែន តើវាត្រូវមានរយៈពេលយូរប៉ុណ្ណាទៀត ។

ហាក់ដូចជាមិនទាន់មានសេចក្តីណែនាំ ឬគោលការណ៍ណែនាំច្បាស់លាស់នៅឡើយទេ នៅ



[៥៩] កិច្ចសម្ភាសន៍ជាមួយអភិបាលរង ។ .

ថ្នាក់មូលដ្ឋាន ថ្នាក់រាជធានី និងថ្នាក់ជាតិ អំពីរបៀបកំណត់សិទ្ធិរបស់អ្នកដែលទិញដីពីម្ចាស់ដើមនោះទេ។ ជាក់ស្តែង តំណាងសហគមន៍នៅអណ្តូង បាននិយាយថា គាត់ជឿថា អ្នកដែលបានទិញដីពីម្ចាស់ដើមនឹងមិនប្រឈមមុខនឹងបញ្ហាអ្វីទេ ហើយនឹងមានលទ្ធភាពទទួលបានបណ្ណ័កម្មសិទ្ធិស្ថាពរតាមពេលវេលាដូចគ្នានឹងម្ចាស់ដើមដែរ។ ក៏ប៉ុន្តែការលើកឡើងនេះ មិនទាន់ត្រូវបានបញ្ជាក់ជាផ្លូវការ ថាពិតនោះទេ។

ក្រុមគ្រួសារខ្លះ បានប្តូរទីតាំងរស់នៅពីកន្លែង មួយទៅកន្លែងមួយទៀតនៅ អណ្តូង ខណៈពេលដែលមានគ្រួសារផ្សេងៗជាច្រើនទៀតបានផ្លាស់មករស់ទីនោះ ពីកន្លែងតាំងទីលំនៅថ្មី ដទៃទៀត ដូចជា មកពីត្រពាំងអញ្ចាញ ឬអន្លង់ក្ងាន ឬពីទីតាំងផ្សេងៗទៀតនៅភ្នំពេញ។ អ្នកដែលមកទីនេះបានទិញដីនៅអណ្តូង ឬសូកប៉ាន់តំណាងសហគមន៍ដើម្បីទទួលបានការ អនុញ្ញាតអោយស្នាក់នៅលើដីតូចៗដែលនៅសេសសល់ ឬដីមិនមានកំណត់ជាផ្លូវការសម្រាប់ អោយប្រជាពលរដ្ឋរស់នៅ។ យោងទៅតាមប្រធានភូមិភូមិអណ្តូង ប្រជាពលរដ្ឋដែលជាអ្នកមកពីសំបុកចាប ជាច្រើនគ្រួសារដែលបានទទួលដីឡូតិ៍ បានលក់វាទៅឱ្យអ្នកមកពីខាងក្រៅដែលមានបំណងទិញទុកលក់ចំណេញ ឬលក់ឱ្យប្រជាពលរដ្ឋដែលផ្លាស់មកពីកន្លែង តាំងទីលំនៅថ្មីផ្សេងៗទៀត។

មានហេតុផ្សេងៗជាច្រើនដែលនាំអោយប្រជាពលរដ្ឋជាច្រើនគ្រួសារផ្លាស់មក អណ្តូង: ភាគច្រើន ដោយសារតែដីមានតម្លៃថោកល្មមអាចទិញ ឬជួលបាន (ថ្លៃទាបជាងនៅទីកន្លែងតាំងទីលំនៅថ្មីដទៃទៀត ឬនៅក្នុងក្រុង)។ គ្រួសារមួយបាន ផ្លាស់មកទីនេះ ព្រោះគាត់គិតថា សហគមន៍នេះ ធំល្មមអាចបង្កើតមុខរបរតូចតាចមួយបាន[៩០] ហើយ អ្នកខ្លះទៀត ដោយសារតែពួកគាត់មិនអាចរស់នៅ និងមានលទ្ធភាពនៅឯទីតាំងដទៃផ្សេងទៀតបាន ករណីដូចជានៅ ត្រពាំងអញ្ចាញជាដើម។ ស្រ្តីម្នាក់ ត្រូវតាមមក ធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលមួយ និងគ្រួសារខ្លះទៀតជាអ្នកផ្ទុកជំងឺអេដស៍ បានផ្លាស់មកពីអន្លង់ក្ងានមករស់នៅជាមួយសាច់ញាតិនៅ អណ្តូងវិញ ដើម្បីទទួលបានជំនួយឧបត្ថម្ភប្រសើរជាងមុន ពីអង្គការមិនមែនរដ្ឋាភិបាលនៅទីនេះ។ ការផ្លាស់ប្តូរទីលំនៅបែបនេះ បណ្តាលឱ្យមានការលំបាក ក្នុងការផ្តល់នូវស្ថិតិច្បាស់លាស់មួយ អំពីចំនួនប្រជាពលរដ្ឋនៅអណ្តូង និង នៅកន្លែងតាំងទីលំនៅថ្មីដទៃទៀត។

នៅត្រពាំងអញ្ចាញ ទិន្នន័យផ្លូវការបង្ហាញថា មានប្រជាពលរដ្ឋ ១៤៣៧ គ្រួសារមកពី បូរីកីឡា សំបុកចាប ច្បារអំពៅក្នុងខ័ណ្ឌមានជ័យ ជ្រោយចង្វាក្នុងខ័ណ្ឌឫស្សីកែវ និងក្រុម៧៨ ប៉ុន្តែតំណាងសហគមន៍ និងសមាជិកសហគមន៍ បានប៉ាន់ស្មានថា មានប្រជាពលរដ្ឋ ប្រហែលជា ៧០០-៨០០ គ្រួសារ ប៉ុណ្ណោះរស់នៅជាអចិន្ត្រៃយ៍នៅទីនោះ ។ អ្នកផ្សេងទៀតបានលក់ដី ឬទុកដីចោល ដោយសារពួកគាត់ត្រលប់ទៅរស់នៅក្នុងក្រុងភ្នំពេញវិញ ដើម្បីរកការងារធ្វើ។[៩១] ឧទាហរណ៍ អ្នកជួលផ្ទះនៅបូរីកីឡា ដែលបានស្ម័គ្រចិត្តផ្លាស់ប្តូរទីលំនៅ មករស់នៅត្រពាំងអញ្ចាញកាលពីពីរឆ្នាំមុន ប៉ុន្តែដោយគាត់មិនអាចរកប្រាក់ចំណូលសម្រាប់ ជីវភាពរស់នៅបាន គាត់ក៏បានលក់ដីរបស់គាត់ដើម្បីទិញម៉ូតូមួយគ្រឿង

[៩០] គ្រួសាររបស់ បូរមី ត្រូវបានបណ្តេញចេញពីសំបុកចាបមកត្រពាំងអញ្ចាញ ក្នុងឆ្នាំ ២០០៦ ។ គាត់បានផ្លាស់ពីត្រពាំងអញ្ចាញ ទៅរស់នៅឯអណ្តូងវិញកាលពីពីរឆ្នាំមុន ។ គាត់បានទិញដី ពីរកន្លែងជាប់គ្នា និងបើកមុខរបរនៅនឹងផ្ទះនៅអណ្តូង ដោយលក់ទំនិញផ្សេងៗ ។ គាត់ផ្លាស់ទៅ អណ្តូង ដោយសារតែដីនៅទីនោះមានតំលៃថោកជាងនៅកន្លែងផ្សេងៗទៀត និង ដោយមាន ប្រជាជនរស់នៅច្រើននៅ អណ្តូងនេះហើយ ជាមូលហេតុដែលគាត់អាចរស់នៅបានប្រសើរជាងមុនជាមួយនឹងមុខរបរតិចតួចរបស់គាត់ ។

[៩១] បទសម្ភាសន៍ជាមួយនឹង ឈឹន សារិទ្ធ តំណាងសហគមន៍ នៅត្រពាំងអញ្ចាញ កាលពីថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៩ ។

ធ្វើជាអ្នករត់ម៉ូតូឌុប នៅក្នុងក្រុងភ្នំពេញ។ គ្រួសារនេះនៅតែបន្តរស់នៅទីនោះនៅឡើយ ព្រោះថាអ្នកទិញដីរបស់គាត់ ជាមនុស្សមានចិត្តសប្បុរសបានឱ្យគាត់រស់នៅជាបណ្តោះអាសន្ន រហូតដល់គាត់អាចរកបានកន្លែងផ្សេងរស់នៅ។

ប្រជាពលរដ្ឋខ្លះបានលក់ដីរបស់ពួកគាត់ ដោយសារតែមានបញ្ហាសុខភាព គួបផ្សំជាមួយនឹងភាពគ្មានការងារធ្វើ និងគ្មានប្រាក់ចំណូល។ ស្ត្រីម្នាក់អាយុ៤៥ឆ្នាំ ឈ្មោះសុវណ្ណា ដែលជាអតីតប្រជាពលរដ្ឋនៅសំបុកចាប បានលក់ដីរបស់គាត់ ក្រោយពីគាត់មករស់នៅ ឯត្រពាំងអញ្ចាញ បានរយៈពេលមួយខែ ដោយសារមូលហេតុខ្វះប្រាក់ចំណូល និងតម្រូវការប្រាក់សម្រាប់ការព្យាបាលជំងឺ។ តាំងពីពេលនោះមក គាត់បានសុំគេរស់នៅតាមចិញ្ចើមផ្លូវនៅកន្លែងតាំងទីលំនៅថ្មីនោះ។

## ៥.៤ ជីវភាពរស់នៅ និងឱកាសការងារ

សមាសធាតុដ៏សំខាន់មួយទៀតនៃលំនៅដ្ឋានសមរម្យគឺទីតាំង ដែលអនុញ្ញាតឱ្យមាន ជំរើសការងារ។[៦២] ចំណុចនេះវាជួយពន្យល់អំពីមូលហេតុដែលគ្រួសារនៅសហគមន៍អភិវឌ្ឍមានជ័យ ពេញចិត្តនឹងល័ក្ខខ័ណ្ឌប្រកបរបរ ចិញ្ចឹមជីវិតរបស់ពួកគាត់ និងពន្យល់ថា ហេតុអ្វីបានជាការតាំងទីលំនៅថ្មី មាននិរន្តរភាព ពីព្រោះទីតាំងនេះ ស្ថិតនៅចម្ងាយ៥គ.មពីទីតាំងដើមរបស់ពួកគាត់។ ផ្ទុយទៅវិញ គ្រួសារដែលបានតាំងទីលំនៅថ្មី នៅកន្លែងផ្សេងទៀតនៅភ្នំពេញ បានត្អូញត្អែរថា ឱកាសការងារនិង ឬប្រាក់ចំណូលរបស់ពួកគាត់ ត្រូវបានធ្លាក់ចុះយ៉ាងខ្លាំងដោយការតាំងទីលំនៅថ្មី។ កត្តានេះមួយផ្នែកធំគឺដោយសារតែទីតាំងទាំងនេះ ស្ថិតនៅឆ្ងាយពីតំបន់ប្រជុំជនក្រុងភ្នំពេញ ប្រហែល២០គ.ម (សូមមើលផែនទីក្រុងភ្នំពេញ ទំព័រ១៥ ជំពូកទី២)។ ដើម្បីស្តារជីវភាពឡើងវិញ ប្រជាពលរដ្ឋត្រូវតែស្វះស្វែងរកមុខរបរដែលផ្តល់ប្រាក់ចំណូល ឬក៏ ធ្វើការងារអោយគេតាមស្រែចំការ ឬមានមុខរបរទាំងពីរតែម្តង ។

នៅក្នុងករណីដែលអាក្រក់បំផុត ការផ្លាស់ទៅកន្លែងតាំងទីលំនៅថ្មី បានបណ្តាលឱ្យគ្មានការងារធ្វើ និង បាត់បង់ប្រាក់ចំណូលយ៉ាងគំហុក។ នៅក្នុងករណីដែលល្អបំផុត ប្រជាពលរដ្ឋនាំយកការងារទៅជាមួយខ្លួន នៅកន្លែងតាំងទីលំនៅថ្មី។ ក៏ប៉ុន្តែ ជាញឹកញាប់វាបានបង្ហាញឱ្យឃើញថា វាកាន់តែមានការលំបាក ឬចំណាយកាន់តែខ្ពស់ដើម្បីបន្តសកម្មភាពរបស់ខ្លួន (ដូចជា ការលក់របស់របរដែលខ្លួនផលិតបានជាដើម) ដោយសារមានកត្តាកំណត់ជាច្រើន ដូចជា ថ្លៃដឹកជញ្ជូន និងលទ្ធភាពចូលទៅកាន់ទីផ្សារកាន់តែចង្អៀត។ មានករណីជាច្រើន ដែលប្រជាពលរដ្ឋត្រូវតែវិលត្រឡប់មកទីប្រជុំជនក្រុងវិញ ដើម្បីរកការងារធ្វើ។

ស្ត្រីហាក់ដូចជាបានបាត់បង់ការងារ និងប្រភពផ្សេងៗសំរាប់ចិញ្ចឹមជីវិត ច្រើនជាងបុរស។ ហេតុផលយ៉ាងធំគឺបណ្តាលមកពីទីតាំង និងលក្ខណៈនៃមុខរបរ។ ប្រភេទនៃមុខរបររបស់ស្ត្រី មុនពេលបណ្តេញចេញ (ដូចជាលក់នំចំណី នៅតាមមុខផ្ទះ ឬនៅតាមផ្លូវក្បែរៗផ្ទះ របស់ពួកគាត់) អាស្រ័យលើ អតិថិជនមានច្រើននៅទីប្រជុំជនក្នុងក្រុង។ សកម្មភាពមុខរបរខ្លះ អាចប្រព្រឹត្តទៅបានតែនៅតាមទីប្រជុំជនក្នុងក្រុងប៉ុណ្ណោះ ដូចជាការដើររើសអេតចាយ ជាដើម។ ការងារដូចគ្នានេះ នៅឯតំបន់តាំងទីលំនៅថ្មី មិនអាចឱ្យពួកគាត់រកប្រាក់ចំណូលចិញ្ចឹមជីវិតបានទេ។ ជាបន្ថែមទៀត មានករណីខ្លះដូចជា សហគមន៍ស្ពានឆេះ ឬករណីអាជីវករ និងអ្នកជួលផ្ទះ នៅដំណាក់ត្រយឹង ដោយសារតែការភ័យខ្លាចថា មានការបណ្តេញចេញជាថ្មី គ្រួសារប្រជាពលរដ្ឋបានសម្រេចចិត្តទុកមេគ្រួសារ ជាទូទៅគឺជា

# ជំពូកទី៥ ៖ ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី

**ប្រអប់លេខ ១២: ជម្រើសមុខរបរចិញ្ចឹមជីវិតនៅតំបន់ពាក់កណ្តាលជនបទពាក់កណ្តាលទីក្រុង នៅខេត្ត ព្រះសីហនុ**

សហគមន៍ស្ពានឆេះពឹងផ្អែកទាំងស្រុងទៅលើការនេសាទសម្រាប់ចិញ្ចឹមជីវិត។ សមាជិក សហគមន៍ខ្លះប្រកបរបរ ជាអ្នករត់ម៉ូតូឌុប ធ្វើជាកម្មករនៅលើទូកនេសាទឯកជន ឬជាកម្មករ សំណង់នៅក្នុងទីរួមខេត្ត។ ប៉ុន្តែ នៅទីនេះមិនសូវមានការងារដែលរកធ្វើបានទេ ដូចជាការងារ នៅការដ្ឋានសំណង់ គេអាចរកការងារជាកម្មករសំណង់បានធ្វើតែ ២-៣ថ្ងៃ ក្នុងមួយខែ និងមានរយៈពេលតែ២-៣ខែប៉ុណ្ណោះ។ មុនពេលបណ្តេញចេញ ក្រៅពីការនេសាទ គ្រួសារភាគច្រើនបំផុតមានដីសម្រាប់ធ្វើស្រែ ដាំដើមឈើហូបផ្លែ និងដាំដំណាំសំរាប់លក់ដូរ ដូចជា ឪឡឹក ហើយពួកគាត់ក៏ចិញ្ចឹមសត្វដែរ។ បើសិនជាគ្មានមុខរបរនេសាទទេ គ្រួសារភាគច្រើន មិនអាចទ្រាំរស់បាននឹងស្ថានភាពនៅតាមចិញ្ចើមផ្លូវបានទេ។ ពីមុនពេលបណ្តេញចេញ និង តាំងពីពេលនោះមក សហគមន៍ ស្ពានឆេះ បានស្នើឱ្យអាជ្ញាធរផ្តល់ដីឱ្យពួកគាត់ (យ៉ាងហោចណាស់មានទំហំ ២០ម គុណ ៣០ម) នៅតំបន់ដែល នៅក្បែរសមុទ្រ ដើម្បីពួកគាត់ អាចនេសាទ និងមានដីគ្រប់គ្រាន់សម្រាប់ចិញ្ចឹមសត្វ និងដាំបន្លែ ប៉ុន្តែ រហូតមកដល់ពេលនេះ គ្មានលទ្ធផលអ្វីទេ។

គ្រួសារដែលត្រូវរងទំពជើងទឹកបណ្តេញចេញ រស់នៅអូរកម្ពុជា បានទទួលដីទំហំ ២០ម គុណ ៣០ម ដែលអាច ឱ្យពួកគាត់ចិញ្ចឹមសត្វមាន់ទា ឬដាំដំណាំរួមផ្សំ សំរាប់ជាអាហារបានខ្លះ ប៉ុន្តែពួកគាត់បានត្អូញត្អែរថា ទំហំដីនេះមិនធំល្មមសម្រាប់គ្រួសារដែលមានសមាជិកច្រើន (មុនពេលបណ្តេញចេញ សហគមន៍បានស្នើសុំដីទំហំ ៥០ម គុណ ៥០)។

ស្ត្រីឱ្យនៅចាំផ្ទះជាប្រចាំ ដើម្បីធានាទទួលបានដី ។ នេះជាហេតុដែលរារាំងស្ត្រីមិនឱ្យទៅរកការងារធ្វើនៅឯទីប្រជុំជនក្នុងទីក្រុង។

## *ការងារនៅកន្លែងតាំងទីលំនៅថ្មី*

ប្រជាពលរដ្ឋមួយចំនួននៅកន្លែងតាំងទីលំនៅថ្មីបានស្វែងរកការងារធ្វើនៅតាមសហគមន៍មូលដ្ឋាន។ ការងារទូទៅ គឺជាការងារនៅតាមវាលស្រែនៅក្នុងរដូវស្ទូង និង រដូវច្រូតកាត់ ដែលផ្តល់ឱកាសការងារសម្រាប់រយៈពេល២-៣សប្តាហ៍ក្នុងមួយរដូវ ដែលអាចទទួលបានកម្រៃប្រហែលជា ១០,០០០ រៀលក្នុងមួយថ្ងៃ។

ជម្រើសមួយទៀត គឺការធ្វើជំនួញតូចតាច។ ភាគច្រើនស្ត្រីជាអ្នកប្រកបរបរបែបនេះ ដោយលក់នំចំណី និងរបស់របរផ្សេងៗនៅមុខផ្ទះ ឬនៅឯផ្សារដែលគេបង្កើតឡើងនៅនឹងកន្លែងតាំងទីលំនៅថ្មី ដែលជាមុខរបរពួកគាត់បានបន្តពីកន្លែងរស់នៅមុនពេលបណ្តេញចេញ។ អតិថិជនជាទូទៅគឺមានត្រឹមតែគ្រួសារដែលជាអ្នកជិតខាងតែប៉ុណ្ណោះ។ ស្ត្រីម្នាក់លក់ដូររបស់របរនៅផ្ទះរបស់គាត់ នៅត្រពាំងអញ្ចាញបានត្អូញត្អែរថា:

> "ខ្ញុំលក់ដូរនេះមិនចំណេញទេ។ ខែខ្លះខ្ញុំខាត ពីព្រោះមានអ្នកទិញជំពាក់ រហូតដល់គាត់រកប្រាក់បានទើបសងវិញ ដូច្នេះជួនកាលគេមិនសងខ្ញុំរហូតដល់ទៅ២-៣ខែឯណោះ ហើយជួនកាលទៀតគេ មិនសងតែម្តង ដោយសារតែពួកគេចាកចេញពីកន្លែងតាំងទីលំនៅថ្មីនេះទៅបាត់។ ខ្ញុំកំពុងតែគិតថា នឹងឈប់លក់ដូរហើយ។ ខ្ញុំបានលក់ដូរទំនិញដូចគ្នានេះនៅបូរីកីឡា ហើយនៅទីនោះខ្ញុំអាចរកលុយចិញ្ចឹមជីវិត បាន ប៉ុន្តែនៅទីនេះខ្ញុំមិនអាចរកចំណូលបានទេ"។

# ជំពូទី៥ ៖ ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី



សមាជិកសហាគមន៍ទូលសំបូរចាក់ផលិតផលជាផ្នែកនៃគំរោងប្រកបរបរចិញ្ចឹមជីវិតគាំទ្រដោយសាលារាជធានីភ្នំពេញ
ថ្លែងអំណរគុណចំពោះការថតរូបដោយ: B.Keat/OHCHR

នៅដំណាក់ត្រយឹង អតីតគ្រួសាររស់នៅដីក្រហម បានបន្តមុខរបរលក់ម្ហូបឆ្អិនស្រាប់។ សមាជិកគ្រួសារនេះបានត្អូញត្អែរថាពួកគាត់មិនអាចសន្សំប្រាក់ពីមុខរបរនេះបានខ្លះនោះទេ កាលពីពេលនៅដីក្រហម ពួកគាត់អាចសន្សំប្រាក់បានប្រហែល ៤០,០០០រៀលក្នុងមួយថ្ងៃ។

ប្រជាពលរដ្ឋមួយចំនួនរកចំណូលពីមុខរបររបស់ខ្លួននៅកន្លែងតាំងទីលំនៅថ្មីនោះមិនបានទេ ហើយត្រូវជំពាក់បំណុលគេ ដែលបន្ថែមការលំបាករបស់ពួកគាត់ថែមទៀត។ ខៀវ អាយុ ២៨ ឆ្នាំ អតីតប្រជាពលរដ្ឋនៅសំបុកចាប បានចាប់ផ្តើមលក់ត្រី និង បន្លែ (ដែលគាត់មកទិញពីផ្សារនៅទីប្រជុំជនក្រុងភ្នំពេញ) នៅឯផ្សារ នៅត្រពាំងអញ្ចាញ ដោយយកប្រាក់សន្សំទាំងអស់មកធ្វើជាដើមទុនក្នុងមុខរបរថ្មីនេះ។ រយៈពេលបីខែក្រោយពីចាប់ផ្តើមមុខរបរនេះ គាត់ខាតបង់ប្រាក់អស់ ប្រហែលជា ៥០០ដុល្លារ ដោយសារតែគេទិញជំពាក់ ហើយគេមិនសងតាមសន្យា និង ដោយសារតែគាត់លក់មិនដាច់អស់ជារៀងរាល់ថ្ងៃ។ គាត់ត្រូវលក់ដីរបស់គាត់ តម្លៃ ៧០០ដុល្លារ ហើយបច្ចុប្បន្នកំពុងរស់នៅលើចិញ្ចើមផ្លូវនៅត្រពាំងអញ្ចាញ។ ដោយមានប្រាក់ពីការលក់ដីនោះ គាត់បានទិញម៉ូតូមួយគ្រឿងសំរាប់ប្តីរបស់គាត់ប្រកបរបររត់ម៉ូតូឌុប។ ខៀវឈប់ប្រកបមុខរបរនេះទៀតហើយ ហើយគ្រួសារគាត់កំពុងរស់នៅទាំងត្រដាបត្រដួស។

ឧទាហរណ៍ខាងលើនេះបង្ហាញពីស្ថានភាពដែលករណីភាគច្រើននៃការតាំងទីលំនៅថ្មី ប៉ះពាល់ដល់សមត្ថភាពប្រជាពលរដ្ឋក្នុងការរកបានជំរើស

មុខរបរដែលមាននិរន្តរភាពមានតម្លៃ និងមានសុវត្ថិភាព ។

### *ការវិលត្រឡប់ទៅទីប្រជុំជនក្នុងទីក្រុងវិញដើម្បីរកការងារធ្វើ*

ជាលទ្ធផលដោយសារមានការលំបាកក្នុងការធានាសកម្មភាពរកប្រាក់ចំណូល នៅឯកន្លែងតាំងទីលំនៅថ្មី ប្រជាពលរដ្ឋបានវិលត្រឡប់ទៅក្នុងទីប្រជុំជននៃទីក្រុងវិញ ដើម្បីប្រកបមុខរបរ។ បុរស ភាគច្រើនធ្វើជាអ្នករត់ម៉ូតូឌុប កម្មករសំណង់ ឬ កម្មករ ចំណែកឯស្រ្តីវិញ លក់ខ្ទៅខ្ទង/លៀសហាល ចំណីអាហារកំប៉ិកកំប៉ុក ឬ ដើររើសអេតចាយតាមផ្លូវ។

ប្រជាពលរដ្ឋជាច្រើននាក់ចាកចេញពីផ្ទះឯកន្លែងតាំងទីលំនៅថ្មី ពីព្រលឹម និងវិលត្រឡប់មកវិញនៅពេលព្រលប់។ ប៉ុន្តែការធ្វើបែបនេះត្រូវចំណាយប្រាក់អស់ច្រើន។ ប្រជាពលរដ្ឋបានត្អូញត្អែរអំពីប្រាក់ចំណូលតិចតួចដែលនៅសេសសល់ពីថ្លៃចំណាយ លើការធ្វើដំណើរដែលជូនកាលមិនគ្រប់គ្រាន់សម្រាប់ទិញម្ហូបអាហារឡើយ។ បុរសម្នាក់ នៅតំណាក់ត្រយឹង ប្រាប់ថា គាត់មិនអាចសន្សំប្រាក់បានទេ នៅកន្លែងតាំងទីលំនៅថ្មីនេះ ពីព្រោះ "លុយរកបានត្រូវបានចំណាយលើសាំង និង អាហារអស់" ។ ចិត ជាអតីតប្រជាពលរដ្ឋរស់នៅបូរីកីឡា និងបានបន្តរត់ម៉ូតូឌុបតាំងពីពេលដែលគាត់ផ្លាស់មកនៅទួលសំបូរបាននិយាយថា:

> "ខ្ញុំមិនដែលសន្សំលុយបានទេ ពីព្រោះខ្ញុំត្រូវចំណាយជិត ៨០០០ រៀលលើថ្លៃសាំង ដើម្បីធ្វើដំណើរ ទៅមក ពីទួលសំបូរ ទៅទីប្រជុំជនក្នុងទីក្រុង។ ថ្ងៃខ្លះ ខ្ញុំរកបានសំរាប់តែថ្លៃសាំង ប៉ុណ្ណោះ ហើយថ្ងៃខ្លះទៀតរកមិនបានហើយខាតលុយថ្លៃសាំងទៀត"។

ប្រជាពលរដ្ឋដទៃទៀតបារម្ភអំពីគ្រោះថ្នាក់ចរាចរណ៍ នៅពេលដែលពួកគាត់ត្រូវធ្វើដំណើរផ្លូវឆ្ងាយ ហើយខ្លះទៀតបានឱ្យដឹងថា ពួកគាត់ធ្លាប់មានគ្រោះថ្នាក់ចរាចរណ៍រួចហើយ។ អ្នកដែលធ្វើការជាកម្មករនៅភ្នំពេញអាច នឹងត្រូវគេកាត់ប្រាក់ឈ្នួលប្រចាំថ្ងៃរហូតដល់ ៥០ ភាគរយ ប្រសិនបើពួកគាត់បង្ហាញខ្លួន ឬ មកដល់កន្លែងធ្វើការយឺត។

ដើម្បីទប់ទល់នឹងបញ្ហានេះ ប្រជាពលរដ្ឋមួយចំនួនបានសម្រេចចិត្តចាកចេញពីកន្លែងតាំងទីលំនៅថ្មី រយៈពេលវែង ជាច្រើនថ្ងៃ ឬ ជាច្រើនសប្តាហ៍។ អ្នកផ្សេងជាច្រើនទៀត សម្រេចចិត្តផ្លាស់ទៅជួលកន្លែងរស់នៅ ដែលមានតំលៃថោកនៅទីប្រជុំជនក្នុងទីក្រុង ដើម្បីបាននៅជិតកន្លែងធ្វើការ ។ ធ្វើរបៀបនេះពួកគាត់អាចកាត់បន្ថយចំណាយបាន ។ ប្រជាពលរដ្ឋដែលបានផ្តល់បទសម្ភាសន៍ បានពន្យល់ថា សម្រាប់ពួកគាត់អាចមានភាពងាយស្រួល ដែលពួកគាត់ជួលបន្ទប់ តម្លៃថោកនៅក្នុងទីក្រុង ដែលស្មើនឹងថ្លៃធ្វើដំណើរពីកន្លែងតាំងទីលំនៅថ្មី ទៅក្នុងទីប្រជុំជន។ នៅក្នុងទីប្រជុំជនក្នុងក្រុងពួកគេក៏អាចសន្សំពេលវេលានិងកម្លាំងខ្លះ ហើយនៅក្បែរសេវាសាធារណៈ និងកន្លែងលក់ដូរសំខាន់ៗជាច្រើន។

សុខ ដែលជាអតីតម្ចាស់ផ្ទះរស់នៅដីក្រហម និងសុភាព ជាភរិយា បានចាកចេញពីផ្ទះល្វែងនៅដំណាក់ត្រយឹង ពីព្រោះវាមានការលំបាកក្នុងការបើកមុខរបរនៅទីនោះ ដោយសារតែគ្មានអតិថិជន និងចំណាយបន្ថែមលើការជួលតូបផ្សារ។ គ្រួសារប្តីប្រពន្ធនិង កូនមួយនេះ បានជួលបន្ទប់ស្នាក់នៅមួយនៅម្តុំបឹងត្របែក ខ័ណ្ឌចំការមន។ ធ្វើបែបនេះ សុខអាចមានពេលច្រើនម៉ោង ក្នុងការរត់ម៉ូតូឌុបនៅក្បែរៗកន្លែងរស់នៅរបស់គាត់ ចំណែក

សុភាព វិញ អាចលក់ម្ហូបអាហារ និងកាហ្វេនៅពីមុខផ្ទះជួលរបស់ខ្លួន។ ចំណូលរបស់ពួកគាត់ អាចដោះស្រាយថ្លៃជួលផ្ទះ រួមទាំងម្ហូបអាហារ ហើយចំណូលរបស់សុខ(តិចបំផុត ១៥,០០០ រៀលក្នុង១ថ្ងៃ) ជាការរួមចំណែកលើចំណាយបន្ថែម និងការសន្សំ។ ប្រសិន បើពួកគាត់ រស់នៅឯដំណាក់ត្រយឹង សុខនឹងត្រូវចំណាយសាំង២លីត្រ ដើម្បីទៅមក (ប្រហែលជា ៨,០០០ រៀល) ហើយគាត់នឹងមានពេលវេលារត់ម៉ូតូឌុបតិច ព្រោះគាត់ត្រូវត្រឡប់ទៅដំណាក់ត្រយឹងវិញមុនពេលងងឹត។ ដូច្នេះ គាត់មិនអាចសន្សំប្រាក់បានទេ។

### *បែកក្រុមគ្រួសារ*

ក្រុមគ្រួសារជាច្រើនត្រូវតែចាត់ចែងសមាជិកក្នុងក្រុមគ្រួសារ ដើម្បីរកចំណូលអោយបាន ជាអប្បបរមា ដែលការចាត់ចែងនេះមានផលប៉ះពាល់ ដល់ទំនាក់ទំនងគ្រួសារ និងកូនៗរបស់ពួកគេ ។ ឪពុកម្ដាយដែលធ្វើការនៅទីប្រជុំជនក្នុងទីក្រុងនៅពេលថ្ងៃ ជាទូទៅទុកកូនតូចៗនៅឯផ្ទះនៅកន្លែងតាំងទីលំនៅថ្មី ដោយទុកកូនច្បងមើលថែទាំប្អូនៗនិងដោយមានអ្នកជិតខាងជួយមើល។ នៅ អណ្ដូង ស្ត្រីម្នាក់បាននិយាយថា គាត់ចាក់សោទុកកូនៗរបស់គាត់នៅខាងក្នុងផ្ទះកន្លះថ្ងៃ ឬ ពេញមួយថ្ងៃ នៅពេលដែលគាត់ចេញទៅរើសអេតចាយនៅតាមទីប្រជុំជនក្នុងទីក្រុង។ អ្នកខ្លះទៀត ស្នាក់នៅពី ពីរទៅបីថ្ងៃ ឬមួយសប្ដាហ៍នៅក្នុងទីប្រជុំជននៃទីក្រុង ទើបត្រឡប់មកកន្លែងតាំងទីលំនៅថ្មីវិញ។ ស្ត្រីមេម៉ាយអាយុ៥៨ឆ្នាំម្នាក់ទុកកូនស្រី អាយុ១០ឆ្នាំរបស់គាត់ជាមួយអ្នកជិតខាងនៅទួលសំបូរ ដើម្បីគាត់អាចធ្វើការនៅទីប្រជុំជនក្នុងទីក្រុងបាន ហើយគាត់មកមើលកូនស្រីវិញ តែនៅចុងសប្ដាហ៍ប៉ុណ្ណោះ។

អង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋដែលបានផ្ដល់បទសម្ភាសន៍ បានសំដែងនូវក្ដីកង្វល់អំពីការរស់នៅបែកគ្នាបែបនេះ ដែលធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់ទំនាក់ទំនង គ្រួសារ ហើយការរស់នៅបែកគ្នា អាចបង្កឱ្យមានបញ្ហា ដូចជា ការប្រឈមនឹងមេរោគអេដស៍ (តាមរយៈប្ដីដែលធ្វើការនៅទីប្រជុំជនក្នុងទីក្រុង និងមានទំនាក់ទំនងផ្លូវភេទជាមួយដៃគូរផ្សេងទៀត) ប្រឈមការប្រើប្រាស់គ្រឿងញៀនក្នុងចំណោមក្មេងជំទង់ៗ ដែលធ្វើការនៅក្នុងទីក្រុងទីប្រជុំជនក្នុង និង ផលប៉ះពាល់អវិជ្ជមានមកលើសុខុមាលភាពនៃកុមារដែលទុកចោលនៅឯកន្លែងតាំងទីលំនៅថ្មីនោះ។

គ្រួសារខ្លះទៀតបង្ខំចិត្តត្រូវតែនៅបែកគ្នាដើម្បីរស់រានបាន ដោយបញ្ជូនសមាជិកគ្រួសារខ្លះទៅរស់នៅជាមួយឪពុក ម្ដាយ ឬបងប្អូន នៅតាមខេត្ត ឬនៅទីដែលនៅឆ្ងាយៗ។ ឧត្តរ ជាអតីតប្រជាពលរដ្ឋនៅដីក្រហមប្រាប់អ្នកធ្វើសម្ភាសន៍ទាំងក្ដុកក្ដួលថា:“ពួកយើងមិនអាចរស់បានទេប្រសិនបើយើងរស់នៅជួបជុំគ្នា។ យើងមិនមានមុខរបរដូចកាលពីមុនពេល គេបណ្ដេញចេញនោះទេ។ មុខរបរថ្មីរបស់ខ្ញុំបានផ្ដល់ឱ្យខ្ញុំនូវប្រាក់ចំណូលមិនទៀងទាត់ទាល់តែសោះ ហើយខ្ញុំត្រូវស្នាក់នៅជាមួយមិត្តភ័ក្រនៅទីប្រជុំជនក្នុងទីក្រុង ដើម្បីរកប្រាក់។ ដូច្នេះ ខ្ញុំបញ្ជូនប្រពន្ធនិងកូនៗរបស់ខ្ញុំឱ្យទៅរស់នៅជាមួយឪពុកម្ដាយរបស់ខ្ញុំនៅប្រទេសវៀតណាមខាងត្បូង រហូតដល់ពេលដែលខ្ញុំអាចសន្សំប្រាក់បានល្មម នឹងហៅពួកគេឱ្យត្រឡប់មករស់នៅជួបជុំគ្នាទីនេះវិញ”។

### *ការពឹងផ្អែកលើអង្គការមិនមែនរដ្ឋាភិបាល*

សហគមន៍ដែលបានតាំងទីលំនៅថ្មី បានខិតខំប្រឹងប្រែង ក្នុងការរកប្រាក់ចំណូលដើម្បីរស់នៅក្នុងស្ថានភាពដ៏លំបាកបំផុត។ នេះគឺជាសំនួរ

ដែលចោទសួរថា តើស្ថានភាពបៀបនេះមាននិរន្តរភាពដែរឬទេ។ ចំពោះមនុស្សជាច្រើនយល់ថា មានតែជំនួយពីខាងក្រៅទេ ដូចជាពីអង្គការមិនមែនរដ្ឋាភិបាលជាដើម ទើបស្ថានភាព របស់ប្រជាពលរដ្ឋអាចល្អប្រសើរឡើងវិញ។ នៅអណ្តូង និងនៅកន្លែងផ្សេងៗទៀត អង្គការមិនមែនរដ្ឋាភិបាលដូចជាអង្គការមិត្តសំឡាញ់/ Friends International ផ្តល់ប្រាក់ចំណូលដល់ប្រជាពលរដ្ឋមួយចំនួន ដូចជាតាមការអោយផលិតកាបូប និងផលិតរបស់របរផ្សេងៗទៀត ដើម្បីលក់នៅទីផ្សារទេសចរណ៍។ ក៏ប៉ុន្តែ គម្រោងទាំងនេះមិនបានទៅដល់ប្រជាពលរដ្ឋភាគច្រើននៅឯ កន្លែងតាំងទីលំនៅថ្មីជាច្រើនទេ។

ស្ថានភាពសហគមន៍ទួលសំបូរត្រូវបានគេមើលឃើញថា បានល្អប្រសើរឡើងវិញ នៅពេលដែលអង្គការ Caritas កំពុងតែ ជួយក្រុមគ្រួសារឱ្យទទួលបាននូវជំនាញថ្មីៗ ដើម្បីរកប្រាក់ ចំណូលនៅទីនោះ។ កាលពីពេលភ្លាមៗបន្ទាប់ ពីការផ្លាស់ប្តូរទៅកន្លែងតាំងទីលំនៅថ្មីនេះ ក្រុមគ្រួសារជាច្រើនបានប្រឈមមុខនឹងស្ថានភាពបន្ទាន់មួយ ទាក់ទងទៅនឹងសុវត្ថិភាពស្បៀង និងសុខភាព។ ពួកគាត់អស់សង្ឃឹម និងមិនអាចរកវិធីរកប្រាក់នៅទីនោះបានទេ។ ប៉ុន្តែ រយៈពេលប្រាំមួយខែក្រោយមក នៅពេលដែលអង្គការ Caritas បានជួយប្រជាពលរដ្ឋក្នុងការវាយតម្លៃលើជម្រើស និងជំនាញសមស្របសម្រាប់ប្រកបរបរចិញ្ចឹមជីវិត ពួកគាត់អាចកំនត់បានពីការងារជាច្រើនប្រភេទដែលពួកគាត់អាចធ្វើបាន ដើម្បីចិញ្ចឹមជីវិត ដូចជា ការកាត់ដេរ និងការផលិតទឹកសាប៊ូ ជាដើម។ សាលារាជធានីភ្នំពេញ ក៏បានបង្កើតគម្រោង មុខរបរចិញ្ចឹមជីវិតតូចៗសម្រាប់ប្រជាពលរដ្ឋផងដែរ។ ជាសរុប បច្ចុប្បន្ន ប្រជាពលរដ្ឋហាក់ដូចជា មានទស្សនៈវិជ្ជមាន ក្នុងការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់ ទៅអនាគត នៅទួលសំបូរ។ ជាការកត់សម្គាល់ជាពិសេសនោះគឺ ក្រុមគ្រួសារប្រជាពលរដ្ឋទាំងនេះ បានទទួលជំនួយស្បៀងអាហារប្រចាំខែ ពីអង្គការមិនមែនរដ្ឋាភិបាលតាំងពីពេលមកតាំងទីលំនៅថ្មី និងពួកគាត់មិនចំណាយអ្វីទាក់ទងនឹងលំនៅដ្ឋានទេ ដូចជា ទឹក និង ការថែទាំសុខភាព។ កត្តាទាំងនេះពិតជាបានរួមចំណែកដល់សមត្ថភាពរបស់ក្រុមគ្រួសារប្រជាពលរដ្ឋក្នុងការធ្វើផែនការ និងធ្វើការសំដៅទៅរករបរចិញ្ចឹមជីវិតកាន់តែមានស្ថិរភាព។

សេចក្តីពិភាក្សាខាងលើបង្ហាញពីតម្រូវការសម្រាប់ជម្រើសមុខរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ដែលជា ផ្នែកយ៉ាងសំខាន់នៃដំណើរការនៃការផ្លាស់ប្តូរទីតាំង។

## ៥.៥ សន្តិសុខស្បៀង

សុវត្ថិភាពនិងសន្តិសុខក្នុងការទទួលបានស្បៀងអាហារចាំបាច់សំរាប់ក្រុមគ្រួសារ ត្រូវតែមានការធានា ចំពោះប្រជាពលរដ្ឋដែលបានផ្លាស់មកកន្លែងតាំងទីលំនៅថ្មី ដូចជាជំនួយសង្គ្រោះបន្ទាន់ជាពិសេស ចំពោះអ្នកដែលមិនមានសមត្ថភាពផ្គត់ផ្គង់ខ្លួនដោយខ្លួនឯងបាន ក្រោយពីពេលបណ្តេញចេញ។[៩៣] វាជាការចាំបាច់ត្រូវវាយតម្លៃលើកម្រិតនៃភាពអសុវត្ថិភាពស្បៀងនៅក្នុងសហគមន៍ សំរាប់រយៈពេលខ្លី និងរយៈពេលវែង ពីព្រោះភាពអសុវត្ថិភាពស្បៀង គឺជាបុព្វហេតុយ៉ាងសំខាន់មួយនៃកង្វះអាហារូបត្ថម្ភ។ នៅកន្លែងតាំងទីលំនៅថ្មី ហាក់ដូចជាបង្ហាញថា ខ្វះអាហារចាំបាច់ហើយដែលគួបផ្សំជាមួយនឹងការរស់នៅក្នុងបរិស្ថាន គ្មានអនាម័យនិង

[៩៣] គោលការណ៍ណែនាំជាមូលដ្ឋានរបស់អ្នករាយការណ៍ពិសេស កថាខ័ណ្ឌទី៥២។

មិនមានសុខភាពល្អផង បណ្ដាលឱ្យសុខភាពប្រជាពលរដ្ឋកាន់តែទ្រុឌទ្រោមទៅៗ ។

បន្ទាប់ពីការបណ្ដេញចេញភ្លាមៗ ក្នុងករណីភាគច្រើន អាជ្ញាធរមូលដ្ឋាន និងរាជធានី ឬក្រុមហ៊ុនដែលទទួលផលប្រយោជន៍ពីការបណ្ដេញចេញនោះ បានផ្ដល់ជំនួយស្បៀងអាហារតែម្ដងទេ ដល់ក្រុមគ្រួសារប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់។ ជាក់ស្ដែង ក្រុមគ្រួសារជាច្រើនដែលបានផ្លាស់ទីលំនៅទៅរស់នៅឯ អណ្ដូង ក្នុងខែមិថុនា ឆ្នាំ ២០០៦ ទូលបានតង់មួយផ្ទាំង អង្ករ១០គីឡូ ទឹកត្រី និងទឹកស៊ីអ៊ីវ២-៣ដប សារុង១ និងប្រាក់ ១០,០០០ រៀលពីសាលារាជធានីភ្នំពេញ។ គ្រួសារដែលមកពីបូរីកីឡាដែលផ្លាស់ទីលំនៅទៅ ទួលសំបូរ បានទទួលអង្ករមួយបាវ ៥០គីឡូក្រាម ទឹកត្រី ទឹកស៊ីអ៊ីវ និងធុងទឹកជ័រ២ ពីសាលារាជធានីភ្នំពេញ (ប្រាក់ ២៥០ដុល្លារបន្ថែម ដែលផ្ដល់ដោយក្រសួងទេសចរណ៍ ជាករណីពិសេស) ។ ក្រុមហ៊ុន7 NG បានផ្ដល់អង្ករ២០គីឡូ ទឹកត្រីនិងទឹកស៊ីអ៊ីវប៉ុន្មានដប និងប្រាក់ ៧៧០.០០០ រៀល សម្រាប់តភ្ជាប់ចរន្តអគ្គិសនី សម្រាប់ក្រុមគ្រួសារមកពីដីក្រហម ដែលទទួលបានផ្ទះល្វែង។ ក្រុមគ្រួសារដែលបានផ្លាស់ទៅកន្លែងតាំងទីលំនៅថ្មី ផ្សេងៗទៀត នៅភ្នំពេញ ក៏បានទទួលកញ្ចប់អំណោយប្រហាក់ប្រហែលគ្នានេះដែរ។ ប៉ុន្តែ សហគមន៍ នៅស្ពានឆេះ និងអូរកម្ពុជា នៅក្រុងព្រះសីហនុ មិនបានទទួលបានអ្វីទាំងអស់។



កូនត្រីនិង កំពឹសដែលរកបានពីស្រះនៅភូមិអណ្ដូង,
ថ្លែងអំណរគុណចំពោះការថតរូបដោយ: B. Keat/ OHCHR

ក្នុងគ្រប់ករណីទាំងអស់ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសាសនាផ្សេងៗ បានផ្ដល់ស្បៀងអាហារ (ជាទូទៅ មាន អង្ករ អាហារកំប៉ុង ឬកញ្ចប់) ដល់ក្រុមគ្រួសារដែលទទួលរងនូវ ផលប៉ះពាល់ ជាដំណោះស្រាយជំនួយសង្គ្រោះបន្ទាន់។ អង្គការមិនមែនរដ្ឋាភិបាលជាច្រើន បន្តផ្ដល់ជំនួយជាស្បៀងអាហារដល់ប្រជាពលរដ្ឋ ដែលបានមករស់នៅកន្លែងតាំងទីលំនៅថ្មី។ ប៉ុន្តែ ជំនួយពីអង្គការមិនមែនរដ្ឋាភិបាលទាំងនេះ គឺបានមកពីធនធានមានកំណត់របស់ខ្លួន ដូច្នេះជំនួយមិនបានគ្រប់គ្រាន់ទេ។ គ្មានករណីណាមួយ ដែលអាជ្ញាធរផ្ដល់ជំនួយស្បៀងអាហារសម្រាប់ រយៈពេលវែងនៅឡើយ។

ផលប៉ះពាល់នៃការបណ្ដេញចេញបានបង្កឱ្យមានក្ដីកង្វល់យ៉ាងខ្លាំងអំពីស្បៀងអាហារ មិនមែនតែចំពោះ ក្រោយពេលបណ្ដេញចេញភ្លាមៗនោះទេ ប៉ុន្តែចំពោះរយៈពេលជាច្រើនខែ ឬ ច្រើនឆ្នាំក្រោយពីការបណ្ដេញចេញ។ មូលហេតុមួយគឺខ្វះប្រាក់ចំណូលដែល អាចរកបានពីមុខរបរនៅកន្លែងតាំងទីលំនៅថ្មីទាំងនោះ សម្រាប់ទិញស្បៀងអាហារ ចំណែកឯនៅប្រជុំជនក្នុងទីក្រុងវិញ មានការងារច្រើនជាង រួមទាំងការងារតូចតាច ដូចជា ការដើររើសអេតចាយ និងលក់អេតចាយ:

> "ប្រសិនបើយើងគ្មានអ្វីហូបនៅទីនេះទេ យើងគ្មានជម្រើសអ្វី ក្រៅតែពីត្រូវដេកអត់នោះឡើយ។ នៅក្នុងក្រុង នៅពេលខ្ញុំរកលុយមិនបានពីមុខរបរតូចតាចរបស់ខ្ញុំ ខ្ញុំឬកូនៗរបស់ខ្ញុំ ទៅដើររើសអេតចាយនៅ

# ជំពូកទី៥ ៖ ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី

តាមផ្លូវ ដែលខ្ញុំអាចលក់បានតម្លៃ ពីរបីរយ ឬ ពីរបីពាន់រៀល ហើយពេលបានលុយមក ខ្ញុំអាចទិញអង្ករដាំបាយហូបរួចមួយថ្ងៃ"។

មិនា អាយុ ៥០ឆ្នាំ ជាស្ត្រីមេគ្រួសាដែលមានកូនប្រាំពីរនាក់នៅអណ្តូង រកស៊ីលក់ សៀសហាលនៅទីប្រជុំជនក្នុងទីក្រុង។

ប្រជាពលរដ្ឋនៅកន្លែងតាំងទីលំនៅថ្មីដទៃទៀតបាន ថ្លែងបញ្ជាក់ស្រដៀងគ្នានេះដែរ ជាពិសេសក្នុងចំណោមស្ត្រីមេគ្រួសារដែលត្រូវតែខិតខំកាន់តែខ្លាំងឡើង ដើម្បីធានាអោយមានស្បៀងអាហារសម្រាប់កូនៗរបស់ពួក គាត់។

ប្រជាពលរដ្ឋដែលនៅកន្លែងតាំងទីលំនៅថ្មី និងដែលមានការងារមានប្រាក់ចំណូលទាប ឬអ្នកដែល មិនអាចរកការងារបានធ្វើ បានកាត់បន្ថយទាំងគុណភាព និងបរិមាណម្ហូបអាហារ ដែលពួកគាត់បរិភោគរៀងរាល់ថ្ងៃ។ ជាទូទៅ ប្រជាពលរដ្ឋកម្ពុជា បរិភោគបាយរាល់ពេល ដោយមានបន្លែ សាច់ត្រី សាច់មាន់ សាច់ជ្រូក ឬសាច់គោ ហើយនឹងបង្អែមនិងផ្លែឈើ។ ប៉ុន្តែ ក្រុមគ្រួសារជាច្រើនបានបញ្ជាក់ច្បាស់ៗថា ពួកគាត់មិនមានប្រាក់សម្រាប់ទិញ អាហារហូបបែបនេះទៀតទេ ដូច្នេះហើយ ពួកគាត់បរិភោគតែបាយទទេឬបាយជាមួយអំបិល ទឹកត្រី ឬទឹកស៊ីអ៊ីវ។ ប្រជាពលរដ្ឋខ្លះព្យាយាមដើររកស្បៀងអាហារដែលមិនចំណាយប្រាក់ នៅក្បែរៗផ្ទះ ដូចជាត្រកួន កូនត្រី កំពឹស ខ្ចៅ ខ្យង កង្កែប ឬក្តាមស្រែ ជាដើម ប៉ុន្តែ ម្ហូបអាហារបែបនេះជាទូទៅមានតែនៅក្នុងរដូវវស្សាតែប៉ុណ្ណោះ។ ប្រជាពលរដ្ឋមួយចំនួនដែល មិនមានប្រាក់ចំណូលសោះ ឆ្លៀតលក់របស់របរ ត្រី ឬ បន្លែដែលបានមកពីការដើររកបានទៅអ្នកដទៃ។

ប្រជាពលរដ្ឋបានកត់សម្គាល់ថា ពួកគាត់មិនអាចបរិភោគអាហារសំខាន់ចាំបាច់ បានគ្រប់គ្រាន់ទេ ដោយមិននិយាយដល់អាហារបំប៉ន ឬបង្អែមដែលពួកគាត់ធ្លាប់បរិភោគនោះទេ:

"ខ្ញុំលែងដឹងថា ផ្លែឈើមានរសជាតិដូចម្តេចហើយ តាំងតែពីខ្ញុំផ្លាស់មកនៅ ដំណាក់ត្រយឹង។ ខ្ញុំត្រូវទុកលុយសំរាប់ ទិញអាហារដែលសំខាន់ចាំបាច់ ដូចជា អង្ករជាដើម"។

កុម្ភៈ ម្តាយមានកូន៤នាក់ អតីតម្ចាស់ផ្ទះនៅដីក្រហម។

ប្រជាពលរដ្ឋជាច្រើននាក់ ត្អូញត្អែរ ដូចគ្នានេះដែរ។

នៅ អណ្តូង ការស្វែងរកអាហារនៅក្នុងភូមិជិតខាងកាន់តែលំបាកទៅៗ ពីព្រោះប្រជាពលរដ្ឋបានប្រើប្រាស់ធនធានមិនចំណាយប្រាក់ទាំងនេះអស់ជាច្រើនឆ្នាំមកហើយ។ ដូចជាស្ត្រីអ្នកផ្ទុកមេរោគអេដស៍ម្នាក់ ឈ្មោះ រចនា បាននិយាយថា "ខ្ញុំធ្លាប់ទៅម្តងម្កាលដែរជាមួយ ប្រជាពលរដ្ឋដទៃទៀតដើម្បីរក ត្រី ខ្យង ក្តាម បន្លែ។ ខ្ញុំមិនអាចទៅញឹកញាប់ដូចអ្នកផ្សេងទេ ពីព្រោះថាយើងត្រូវដើរទៅទំនប់កប់ស្រូវដែលនៅឆ្ងាយ] ដើរ១-២ម៉ោង [ហើយប្រជា ពលរដ្ឋត្រូវទៅតាំងពីព្រលឹម ។ ឥឡូវ អាហារទាំងនេះនៅក្បែរៗ អណ្តូង រកលែងបានហើយ"។ អ្នកផ្តល់បទសម្ភាសន៍ ដែលរស់នៅអណ្តូង ៨០ភាគរយជឿថា កូនៗរបស់ពួកគាត់មាន បញ្ហាខ្វះអាហាររូបត្ថម្ភមកពីបរិភោគអាហារខ្វះជីវជាតិ ដោយសារតែពួកគាត់មិនអាចផ្តល់អាហារគ្រប់គ្រាន់ដល់កូនៗគ្រប់ពេលបាន ។

សហគមន៍ស្ពានមេះ ពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើការនេសាទតាមសមុទ្រ ជាលក្ខណៈគ្រួសារ គឺមានតែប៉ុន្មានគ្រួសារប៉ុណ្ណោះដែលរកប្រាក់ចំណូលបន្ថែមបាន តាមរយៈការងារផ្សេងៗ។ ដើម្បីទិញអង្ករបាន ពួកគាត់ត្រូវតែរកត្រីឱ្យបានច្រើនល្មមនឹង យកទៅលក់ខ្លះ។ ថ្ងៃខ្លះ ហើយភាគច្រើនពួកគាត់រកត្រីមិនសូវបានទេ ដើម្បីផ្គត់ផ្គង់ក្រុមគ្រួសារ។ ក្នុងពេលចុះពិនិត្យស្ថានភាពនៅទីនោះ OHCHR បានឃើញស្ត្រីពីរបីនាក់ កំពុងតែខ្ចីអង្ករ អ្នកជិតខាងដើម្បីដាំបាយហូបពេលអាហារល្ងាច ។ អ្នកដែលបានផ្តល់ បទសម្ភាសន៍ ដែលជាទូទៅពេញចិត្តនឹងស្ថានភាពសុខដុមរមនា មុនពេល

បណ្ដេញចេញបាននិយាយអំពីអាហារឆ្ងាញ់ៗ ដែលពួកគាត់ធ្លាប់ទទួលទានកាលពីពេលនោះ ដែលមានសាច់ និងផ្លែឈើ។ សាន ជាស្ត្រីចំណាស់ម្នាក់ បាននិយាយដោយសង្ខេបថា:

> "តាំងពីពេលបណ្ដេញចេញមក ពួកយើងមិនដែលបានទិញអាហារឆ្ងាញ់ហូបទេ។ ពួកយើងធ្លាប់បានហូបអាហារឆ្ងាញ់ៗលើសនេះ ១០ដង ឬច្រើនជាងនេះទៀត ហើយ ពួកយើងមានប្រាក់សន្សំសម្រាប់ឱ្យកូនទៅរៀន និងទៅរកពេទ្យឯកជនពេលឈឺ។ យើងមិនដែលជំពាក់បំណុលគេដូចជាសព្វថ្ងៃនេះទេ សូម្បីតែអង្ករ ពងមាន់ពងទា ឬលុយ ក៏យើងត្រូវខ្ចីគ្នាទៅវិញទៅមក ដើម្បីតែមួយចំអែតក្រពះដែរ"។

គ្រួសារដែលជាអ្នកជំងឺអេសដ៍រស់នៅឯទួលសំបូរ បានមើលឃើញថាខ្លួន កំពុងតែរស់ក្នុងស្ថានភាពល្អប្រសើរជាងគ្រួសារនៅកន្លែងផ្សេងៗទៀត ពីព្រោះពួកគាត់ទទួលបាន អង្ករ និងអាហារបន្ថែមពីអង្គការមិនមែនរដ្ឋាភិបាល ជាបន្តបន្ទាប់ និងជាប្រចាំ។[៩៤] អង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបង្ហាញពីការប្ដេជ្ញាចិត្តចូលរួមចំណែក ក្នុងការជួយឧបត្ថម្ភនេះ រហូតទាល់តែសហគមន៍ អាចម្ចាស់ការលើខ្លួនឯងបាន ពោលគឺមានការងារធ្វើនិងមុខរបរចិញ្ចឹមជីវិត។ នេះជាការដ៏គួរឱ្យកោតសរសើរ។ ការគាំទ្រផ្នែកស្បៀងអាហារ និង មុខរបរ ជាការពិតណាស់គប្បីត្រូវបញ្ចូលទៅក្នុងដំណើរការទាំងអស់នៃការតាំងទីលំនៅថ្មី។



ការជួយពិនិត្យសុខភាពគ្រូពេទ្យរបស់អង្គការលីកាដូ ថ្លែងអំណរគុណចំពោះ
ការថតរូបដោយ: B.Keat/OHCHR

## ៥.៦ សុខភាព

តាមទស្សនៈទាននៃសិទ្ធិមនុស្ស សុខភាពមិនមែនមានន័យគ្រាន់តែជាការទទួលបានសេវាថែទាំសុខភាពចាំបាច់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានរាប់បញ្ចូលកត្តាជាច្រើនទៀត ដែលអាច ជួយប្រជាពលរដ្ឋឱ្យមានជីវិតរស់នៅប្រកបដោយសុខភាពល្អ ដូចជា ទឹកផឹកមានសុវត្ថិភាព និងអនាម័យសមស្រប អាហារសមរម្យ និងលក្ខខ័ណ្ឌនិងបរិយាកាសការងារប្រកបដោយជាសុខភាពទៀតផង។ ត្រូវផ្ដល់អោយមានសេវាសុខភាពចាំបាច់ ថ្នាំពេទ្យ និងគ្រឿងបរិក្ខាពេទ្យ ដោយគ្មានការរើសអើង និងដែលមានអាចទៅរកប្រើប្រាស់បាន អាចទទួលយកបាន និង មានគុណភាពល្អ។[៩៥] គោលការណ៍ណែនាំអន្តរជាតិបានបញ្ជាក់បន្ថែមទៀតថា ការទៅរកប្រើប្រាស់បាននូវសេវាសុខភាព ប្រកបដោយសុវត្ថិភាព គួរតែ

ជំពូក ៥

[៩៤] អង្គការ Center of Hope បានផ្ដល់ជំនួយជាស្បៀងប្រចាំខែ (របបអង្ករប្រចាំខែ ១៤ គីឡូក្រាម សម្រាប់គ្រួសារគ្មានកូន និង ២៦គីឡូក្រាម សម្រាប់អ្នកដែលមានកូន ជាមួយនឹងអំបិលអ៊ីយ៉ូដ ប្រេងឆា និង ថ្នាំមួយចំនួន( សម្រាប់រយៈពេល៩ខែ តាំងពី ពេលផ្លាស់ប្ដូរ ទីតាំងរបស់ប្រជាពលរដ្ឋ ៤២គ្រួសារនេះ ។ អង្គការស្បៀងអាហារពិភពលោក បានផ្ដល់កញ្ចប់ស្បៀងតាមបទដ្ឋាន (អង្ករ ៣០គីឡូ ប្រេងឆា១លីត្រ និងអំបិលអ៊ីយ៉ូដ១.៥គីឡូក្រាម) ដល់សហគមន៍ ពីខែតុលាដល់ខែធ្នូឆ្នាំ ២០០៩ ។ តាំងពីខែមករាឆ្នាំ ២០១០ សមាគមនារីអភិវឌ្ឍន៍សេដ្ឋកិច្ច និងអនាម័យ (អង្គការ WOMEN) ជាអ្នកបន្តកិច្ចការនេះ និងដោយមានជំនួយពីអង្គការ Caritas បានផ្ដល់អង្ករ ១៤គីឡូក្រាម និង អ្នកមានកូនបានបន្ថែម ១២គីឡូក្រាម ។

[៩៥] សូមមើលអង្គការសុខាភាពពិភពលោក (WHO) និង OHCHR "សិទ្ធិខាងសុខភាព" Factsheet លេខ៣១។

ត្រូវផ្តល់ជូនភ្លាមៗក្រោយការបណ្តេញចេញ។[៩៦]

*ជំនួយសង្គ្រោះបន្ទាន់*

ក្រោយពីការបណ្តេញចេញ ជំនួយសង្គ្រោះបន្ទាន់ផ្នែកពេទ្យដែលផ្តល់អោយ គ្រួសារប្រជាពលរដ្ឋ ដែលត្រូវគេបណ្តេញចេញនៅឯកន្លែងតាំងទីលំនៅថ្មី បានមកតែពីអង្គការមិនមែនរដ្ឋាភិបាល ដូចជា លីកាដូ ឬអង្គការ Center of Hope តែប៉ុណ្ណោះ។ ច្រើនឆ្នាំបន្ទាប់ពីការផ្លាស់មកនៅកន្លែងតាំងទីលំនៅថ្មី ក្រុមគ្រួសារ ប្រជាពលរដ្ឋ នៅតែពឹងផ្អែកទាំងស្រុងលើសេវាផ្នែកពេទ្យ ផ្តល់ជូនដោយអង្គការទាំងនេះនៅឡើយ។ ជាក់ស្តែង ភ្លាមៗបន្ទាប់ពីប្រជាពលរដ្ឋ សំបុកចាប ផ្លាស់ទៅនៅ អណ្តូង គិតពីថ្ងៃទី៦ដល់ ២៨ ខែមិថុនា ឆ្នាំ២០០៦ ក្រុមគ្រូពេទ្យរបស់អង្គការលីកាដូបានព្យាបាលអ្នកជំងឺ ១,៧១៦ នាក់។ គ្រូពេទ្យម្នាក់ៗ ត្រូវមើលអ្នកជំងឺ ជាមធ្យមប្រហែលជា ៨០ករណី ក្នុង១ថ្ងៃៗនៅទីនោះ រួមទាំងថ្ងៃចុងសប្តាហ៍ផង។ គ្រូពេទ្យបានរាយការណ៍ថា ក្នុងចំណោមអ្នកជំងឺ ១,៧១៦នាក់ ដែលបានចុះឈ្មោះព្យាបាល មានកុមារ ៦៦៣នាក់ ដែលច្រើនជាងពាក់កណ្តាលនៃ កុមារទាំងនេះ មានអាយុក្រោម៥ឆ្នាំ។ (សូមមើល "សុខភាពរាងកាយ" ផ្នែកខាងក្រោម សម្រាប់ជាឧទាហរណ៍នៃជំងឺទូទៅ)។

*សេវាសុខភាពដែលមាន*

កន្លែងតាំងទីលំនៅថ្មីទាំងអស់ក្រោមការសិក្សានេះ ឃើញថា មានមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាពតាំងនៅទីនោះ(ត្រពាំងអញ្ចាញ[៩៧] ដំណាក់ត្រយឹង[៩៨]) ឬនៅជិតៗទីនោះ (អណ្តូង[៩៩] ទួលសំបូរ[១០០])។ ប្រជាពលរដ្ឋភាគច្រើនដែលបានផ្តល់បទសម្ភាសន៍ ស្គាល់មណ្ឌលសុខភាពដែលនៅជិតបំផុត ប៉ុន្តែមានប្រជាពលរដ្ឋតិចតួចណាស់ ដែលទៅប្រើសេវានៅមណ្ឌលសុខភាព។ ប្រជាពលរដ្ឋបានលើកអំពីបញ្ហានៃប្រសិទ្ធភាពរបស់មណ្ឌលសុភាព ដោយនិយាយថា មណ្ឌលសុខភាពទាំងនេះ ជាញឹកញាប់ខ្វះបរិក្ខារពេទ្យ ឬបុគ្គលិក ហើយមានលទ្ធភាពត្រឹមតែចែកថ្នាំ ចាក់វ៉ាក់សាំង និងការព្យាបាលជំងឺតូចតាចតែប៉ុណ្ណោះ។[១០១] ប្រជាពលរដ្ឋមួយចំនួនក៏បាននិយាយផងដែរថា ពួកគាត់ត្រូវបង់ថ្លៃសេវាពី ១,០០០ ទៅ ១,៥០០រៀល ដើម្បីទទួលបានការព្យាបាល ឬមើលជំងឺនៅឯមណ្ឌលសុខភាព។ ដូច្នេះ ពួកគាត់ភាគច្រើនពេញចិត្តប្រើប្រាស់សេវារបស់ អង្គការមិនមែនរដ្ឋាភិបាល ដែលតែងតែមកដល់ទីកន្លែងដែលគាត់រស់នៅជាទៀងទាត់ និងផ្តល់ការព្យាបាល និងថ្នាំដោយមិនយកកម្រៃ។ ប៉ុន្តែ ចំពោះបញ្ហាសុខភាពធ្ងន់ធ្ងរ ប្រជាពលរដ្ឋនៅតែត្រូវទៅមន្ទីរពេទ្យនៅទីក្រុង ភ្នំពេញ។

នៅមណ្ឌលសុខភាពជិត អណ្តូង គិលានុបដ្ឋាកបីនាក់ផ្តល់ថ្នាំវ៉ាក់សាំង និងព្យាបាលជំងឺស្រាលៗ រួមទាំងមានការពិគ្រោះយោបល់អំពីសុខភាពបន្តពូជ និងពិនិត្យស្ត្រីមានផ្ទៃពោះដែលមណ្ឌលសុខភាព នៅកន្លែងតាំងទីលំនៅថ្មីខ្លះគ្មានសេវានេះទេ (ដូចជា នៅត្រពាំងអញ្ចាញ) ។ យោងទៅតាម គិលា

[៩៧] នៅត្រពាំងអញ្ចាញ មណ្ឌលសុខភាព ត្រូវបានកសាងនៅលើកន្លែងតាំងទីលំនៅថ្មី ដោយសាលារាជធានីភ្នំពេញ ក្នុងឆ្នាំ ២០០៦ ។

[៩៨] ផ្ទះពីរល្វែងជាប់គ្នា ត្រូវបានធ្វើជាការិយាល័យសុខភាព ក្នុង បូរីសន្តិសភាព២ ។

[៩៩] នៅអណ្តូង មណ្ឌលសុខភាពស្ថិតនៅប្រហែល ១គ.ម ពីកន្លែងតាំងទីលំនៅថ្មី ។

[១០០] នៅទួលសំបូរ មណ្ឌលសុខភាពស្ថិតនៅចម្ងាយ១.៥គ.ម ពីកន្លែងតាំងទីលំនៅថ្មី ។

[១០១] នៅមណ្ឌលសុខភាព នៅត្រពាំងអញ្ចាញ គិលានុបដ្ឋាកប្រុសពីរនាក់ធ្វើការពីថ្ងៃច័ន្ទដល់សុក្រ ប៉ុន្តែគ្រួសារមួយចំនួនបាន ត្អូញត្អែរថា ពួកគាត់ជាញឹកញាប់មិនឃើញ គិលានុបដ្ឋាកទេ នៅពេលដែលពួកគាត់មកដល់មណ្ឌលសុខភាព ហើយសេវា មានកម្រិតត្រឹមតែជាការផ្តល់ថ្នាំវាក់សាំង និង ថ្នាំពេទ្យ

នុបដ្ឋាកម្នាក់ ក្នុងចំណោមទាំងបីនាក់នោះបានឱ្យដឹងថា ប្រជាពលរដ្ឋពី៨០ ទៅ១០០ នាក់ ដែលមកពីសង្កាត់នេះទាំងមូល ដែលមានខ្លះមកពីអណ្តូង បានទទួលសេវាសុខភាព នៅមណ្ឌលសុខភាពនេះជារៀងរាល់ខែ រីឯការគាំទ្រ (ផ្នែកហិរញ្ញវត្ថុ ឬផ្នែកផ្សេងទៀត) ពីមន្ទីរសុខាភិបាលស្រុកប្រតិបត្តិមិនគ្រប់គ្រាន់សម្រាប់ដោះស្រាយ តម្រូវការខាងសុខភាពរបស់សហគមន៍នេះទេ។

អង្គការមិនមែនរដ្ឋាភិបាល ផ្តល់សេវាសុខភាពជាច្រើន ដែលត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋដែលរស់នៅតាមកន្លែងតាំងទីលំនៅថ្មី។ ឧទាហរណ៍ ក្រុមគ្រូពេទ្យ របស់អង្គការលីកាដូ ចុះមកពិនិត្យសុខភាព បួនថ្ងៃក្នុងមួយសប្តាហ៍ នៅតាមកន្លែងតាំងទីលំនៅថ្មី (គឺថ្ងៃពុធ នៅដំណាក់ត្រយឹងថ្ងៃច័ន្ទនិងសុក្រនៅ អណ្តូង និងថ្ងៃព្រហស្បត៍ នៅត្រពាំងអញ្ចាញ) ហើយថែមទាំងផ្តល់ថ្នាំដោយឥតគិតថ្លៃផង។ អង្គការលីកាដូក៏បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាមួយជាមួយនឹងអាជ្ញាធរសុខាភិបាល (OD WEST) ដើម្បីផ្តល់វ៉ាក់សាំងដល់ស្ត្រីនិងកុមារនៅតាមកន្លែងតាំងទីលំនៅថ្មីទាំងបីនេះ និង ដើម្បីដោះស្រាយចំពោះការដែលប្រជាពលរដ្ឋផ្លាស់ប្តូរទីកន្លែងរស់នៅទាំងនេះដែលនៅមិនទាន់ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីចាក់ថ្នាំវ៉ាក់សាំងតាមបទដ្ឋាននៃអាជ្ញាធរសុខាភិបាល ។

អង្គការ Chibodia តាមរយៈគម្រោងគ្លីនិកសុខភាព "Moto Medix" បានផ្តល់សេវាសុខភាពប្រចាំសប្តាហ៍ សម្រាប់កុមារនៅសហគមន៍ដំណាក់ត្រយឹងតាំងពីឆ្នាំ២០០៩។ ទាំងអង្គការ លីកាដូ និងអង្គការ Chibodia ផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ ឬផ្នែកផ្សេងៗទៀតដល់ សមាជិក សហគមន៍ លើតម្រូវការផ្នែកពេទ្យបន្ទាន់ រួមទាំងការដឹកបញ្ជូនទៅមន្ទីរពេទ្យនៅក្រុងភ្នំពេញ ក្នុងករណីចាំបាច់។ ក្នុងខែតុលាឆ្នាំ២០០៩ អង្គការ Chibodia ក៏បានចាប់ផ្តើមកម្មវិធីពន្យាកំណើតនៅទីតាំងនេះថែមទៀត។[១០២]

តាំងពីក្រោយពេលបណ្តេញចេញភ្លាមអង្គការ Center of Hope បានបញ្ជូន ក្រុមគ្លីនិកចល័តទៅពិនិត្យសុខភាព ទូទៅជារៀងរាល់សប្តាហ៍នៅអណ្តូង ដំណាក់ត្រយឹង[១០៣] និងទួលសំបូរ។[១០៤] វេជ្ជបណ្ឌិតនៃគ្លីនិកចល័ត បានពិនិត្យសុខភាពប្រជាពលរដ្ឋពី ៣០នាក់ទៅ៥០នាក់ នៅពេលចុះពិនិត្យម្តងៗ ក្រុមការងារនេះក៏ពន្យល់ព័ត៌មានអំពីសុខភាព និងការធ្វើអនាម័យផងដែរ។

នៅខេត្តព្រះសីហនុ ភ្លាមៗបន្ទាប់ពីមានការបណ្តេញសហគមន៍ស្ពានឆេះ អង្គការលីកាដូ បានបញ្ជូនក្រុមគ្រូពេទ្យទៅទីនោះ ។ ក្រុមគ្រូពេទ្យពីអង្គការ លីកាដូ នៅភ្នំពេញ បានទៅពិនិត្យសុខភាពអ្នករស់នៅសហគមន៍ស្ពានឆេះ ម្តងក្នុងមួយខែរហូតដល់ពាក់កណ្តាលឆ្នាំ២០០៩។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកឈ្មោះថា ម្លប់តាប៉ាង "M'Lop Tapang" បានចុះពិនិត្យសុខភាព សហគមន៍ ស្ពានឆេះ ម្តងក្នុងមួយសប្តាហ៍ ហើយក៏ជួយផ្តល់ មធ្យោបាយដឹកជញ្ជូនទៅមន្ទីរពេទ្យ ដែរក្នុងករណីបន្ទាន់។ នៅគ្រប់កន្លែងតាំងទីលំនៅថ្មីទាំងអស់ អ្នកដែលបានផ្តល់បទសម្ភាសន៍ទាំងអស់ កោតសរសើរចំពោះការងាររបស់អង្គការមិនមែនរដ្ឋាភិបាល ។

[១០២] យោងតាមអង្គការវេជ្ជបណ្ឌិតអង្គការ លីកាដូ មានផែនការកម្មវិធីចាក់វ៉ាក់សាំងគេរៀបចំធ្វើឡើងសំរាប់រយៈពេលប្រាំឆ្នាំម្តង។ ក្រុមគ្រួសារដែលបានផ្លាស់ប្តូរទីលំនៅថ្មី ត្រូវតែរង់ចាំឱ្យគេបញ្ចូលទៅក្នុងផែនការកម្មវិធីរយៈពេលប្រាំឆ្នាំថ្មី ដែលនឹងត្រូវ អនុម័តដោយក្រសួងសុខាភិបាល ។

[១០៣] អង្គការ លីកាដូ និង អង្គការ Center of Hope បាន តាមទៅពិនិត្យសុខភាពអោយក្រុមគ្រួសារប្រជាពលរដ្ឋនៅឯ កន្លែងតាំងទី លំនៅថ្មី នៅភូមិស្រះពោធិ៍ ឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្តាល បន្ទាប់ពីគ្រួសារទាំងនេះ ផ្លាស់ចេញទៅទីតាំងនោះ ពីខែធ្នូ ឆ្នាំ ២០០៩ ។

[១០៤] អង្គការ Center of Hope បានចាត់ចែងអោយមានគ្លីនិកចល័ត និង ផ្តល់សេវាថែទាំសុខភាពតាមផ្ទះ ចំពោះក្រុមគ្រួសារ ដែលផ្ទុក មេរោគ HIV/ជំងឺអេដ៍ នៅទួលសំបូរ កាលពីដំបូង ។ រយៈពេលបីខែក្រោយមក អង្គការ' WOMEN' បន្តការងារថែទាំតាមផ្ទះនេះ ។

## ប្រអប់លេខ១៣: សុខភាពអ្នកជំងឺអេដស៍និងអ្នកផ្ទុកមេរោគអេដស៍

**ប្រអប់លេខ១១៣: សុខភាពអ្នកជំងឺអេដស៍ និង អ្នកផ្ទុកមេរោគអេដស៍**

ការបណ្តេញចេញនិងការតាំងទីលំនៅថ្មីរបស់ប្រជាពលរដ្ឋដែលជាអ្នកជំងឺអេដស៍ មានន័យថាធ្វើអោយពួកគាត់គ្មានលទ្ធភាពទទួលបានការព្យាបាលជំងឺបន្ទាន់ ក្នុងករណីជំងឺឱកាសនិយមធ្ងន់ធ្ងរ។ ការផ្លាស់ប្តូរទីតាំងធ្វើឱ្យប្រជាពលរដ្ឋមាន តម្រូវការថវិកា ច្រើនហួស សម្រាប់ចំណាយលើការធ្វើដំណើរ ទៅក្នុងក្រុង និង លើសេវាចាំបាច់ផ្សេងៗទៀត ដូចជា ការព្យាបាលដោយថ្នាំពន្យាអាយុជីវិតARV ។ លំនៅដ្ឋានមិនសមរម្យ និងកង្វះបរិស្ថានសមស្របនៅកន្លែងតាំងទីលំនៅថ្មី ក៏ជាផ្នែកដែលបណ្តាលឱ្យមានបញ្ហាសុខភាព និង ងាយប្រឈមនឹងជំងឺឆ្លងនានាដែរ។

***ទិន្នន័យ***

នៅអណ្តូង មានការប៉ាន់ស្មានថា មានប្រជាពលរដ្ឋដែលជាអ្នកជំងឺអេដស៍ យ៉ាងហោចណាស់ ក៏ ៥០នាក់ដែរ ហើយតាមការប៉ាន់ស្មានខ្លះទៀតថា មានរហូតដល់១០០នាក់។ នៅត្រពាំងអញ្ចាញ មានប្រជាពលរដ្ឋដែលជាអ្នកជំងឺអេដស៍ពី ១០នាក់ ទៅ ១៨នាក់ និងនៅទួលសំបូរ មានប្រជាពលរដ្ឋ ៥៦ នាក់ (ក្នុង៤២គ្រួសារ)។ ក្នុងចំណោមអ្នកដែល ធ្លាប់រស់នៅតាមចិញ្ចើមផ្លូវនៅដំណាក់ត្រយឹង រហូតដល់ខែធ្នូឆ្នាំ២០០៩ មានប្រជាពលរដ្ឋ ដែលជាអ្នកជំងឺអេដស៍ ប្រហែលជា១០ នាក់។

*ការទទួលបានការ ព្យាបាលដោយថ្នាំពន្យាអាយុជីវិត ARV*

អ្នកជំងឺអេដស៍ នៅកន្លែងតាំងទីលំនៅថ្មីត្រូវតែធ្វើដំណើរទៅក្នុងក្រុង ដើម្បីទទួលការព្យាបាលដោយថ្នាំពន្យាអាយុជីវិត ARV ឬដើម្បីព្យាបាលជំងឺធ្ងន់ធ្ងរ។ យោងតាមប្រជាពលរដ្ឋដែលបានផ្តល់បទសម្ភាសន៍ និងអ្នកផ្តល់សេវាសុខភាពបានឱ្យដឹងថា ប្រជាពលរដ្ឋមកពី កន្លែងតាំងទីលំនៅថ្មី ប្រើប្រាស់សេវាសុខភាពទាំងនេះ នៅឯមន្ទីរពេទ្យ និងគ្លីនិកផ្សេងៗនៅទីក្រុង ដូចជា មន្ទីរពេទ្យព្រះកុសុមៈ មន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត មន្ទីរពេទ្យកាល់ម៉ែត្រ និងមន្ទីរពេទ្យកុមារជាតិ (សម្រាប់កុមារ) គ្លីនិកឈូកស គ្លីនិកសុខភាពសង្គម និងមន្ទីរពេទ្យសីហនុ (អង្គការ Center of Hope)។[១០៥]

ចំណាយលើការធ្វើដំណើរមួយលើកៗគឺពី ១៥,០០០ រៀល ទៅ២០,០០០រៀល តាមម៉ូតូឌុប។ គ្រួសារខ្លះ មានសមាជិកក្នុងគ្រួសារច្រើនជាងម្នាក់ដែលមានផ្ទុកមេរោគអេដស៍ ដូច្នេះការធ្វើដំណើរទៅមន្ទីរពេទ្យត្រូវការចំណាយច្រើនណាស់។ នៅកន្លែងតាំងទីលំនៅថ្មីទាំងអស់ អង្គការមិនមែនរដ្ឋាភិបាលដូចជា ម៉ារីណុល មិត្តសំឡាញ់ អង្គការ Hope និងវិថីជីវិត ព្រមទាំងសប្បុរសជន ដទៃទៀត បានជួយផ្តល់មធ្យោបាយធ្វើដំណើរ ឬផ្តល់ថវិការសំរាប់ធ្វើដំណើរទៅក្នុងក្រុង ។

*ការថែទាំសុខភាព: ការព្យាបាលជំងឺឱកាសនិយម*

អង្គការមិនមែនរដ្ឋាភិបាលផ្តល់សេវាថែទាំតាមផ្ទះ ទៅតាមតំបន់ទីតាំងភូមិសាស្ត្ររបស់ខ្លួន។ នៅពេលដែលអ្នកជំងឺអេដស៍ផ្លាស់ចេញពីតំបន់ដែលគ្របដណ្តប់ដោយសេវានេះ ពួកគាត់លែងទទួលបានសេវាទៀតហើយ។ រហូតមកដល់បច្ចុប្បន្ន សេវាបែបនេះ មានកំរិតតែនៅតាម តំបន់ទីប្រជុំជនតែប៉ុណ្ណោះ ដែលមានន័យថា នៅតាមកន្លែងតាំងទីលំនៅថ្មី ដែលជាទូទៅជា តំបន់ពាក់កណ្តាលជនបទ ពាក់កណ្តាលទីក្រុង មិនស្ថិតនៅក្នុងតំបន់គ្របដណ្តប់របស់អង្គការណាមួយទេ។ មិនមានការសម្របសម្រួលជាប្រព័ន្ធ ទោះជាក្រោមការគាំទ្ររបស់ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឬក្នុងចំណោមទីភ្នាក់ងារផ្តល់សេវានានា ដើម្បីធានាអោយ មានការថែទាំ សុខភាពពួកគាត់ នៅពេលដែលពួកគាត់ផ្លាស់ទៅរស់នៅកន្លែងតាំងទីលំនៅថ្មី លើកលែងតែករណី អ្នកជំងឺអេដស៍នៅទួលសំបូរ។

នៅពេលដែលប្រជាពលរដ្ឋផ្លាស់ប្តូរទីតាំងពីបូរីកីឡា ទៅទួលសំបូរ កាលពីខែមិថុនា/កក្កដា ឆ្នាំ២០០៩ ក្រុមទីភ្នាក់ងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ បានសហការជាមួយ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សាលារាជធានីភ្នំពេញ និង អង្គការមិនមែនរដ្ឋាភិបាល ដើម្បីដោះស្រាយហានិភ័យ ដែលបណ្តាលមកពីការផ្លាស់ប្តូរទីតាំង ធានានិរន្តរភាពនៃសេវាព្យាបាល សេវាថែទាំតាមផ្ទះ ជំនួយស្បៀងអាហារ និងដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងលំនៅដ្ឋាន។ អង្គការ Center of Hope (ដែលបានជួយគ្រួសារប្រជាពលរដ្ឋកាលពីនៅបូរីកីឡា) បានបន្តផ្តល់សេវាថែទាំតាមផ្ទះដល់ប្រជាពលរដ្ឋនៅ ទួលសំបូរ រយៈពេលបីខែទៀត រហូតដល់ពេលដែលមានអង្គការផ្សេងគឺ អង្គការ WOMEN មកទទួលការងារនេះបន្ត។



[១០៥] សំរាប់បញ្ជីនៃទីកន្លែងផ្តល់សេវាព្យាបាលជំងឺឱកាសនិយម និង ការព្យាបាលដោយថ្នាំពន្យាអាយុជីវិត (OI & ART) នៅភ្នំពេញមើលវិបសាយ http://www.nchads.org/index.php?id=52។

នៅកន្លែងតាំងទីលំនៅថ្មីដទៃទៀត អង្គការមិនមែនរដ្ឋាភិបាល មិនអាចពង្រីកសេវារបស់ខ្លួនគ្របដណ្តប់លើ គ្រប់ប្រជាពលរដ្ឋជាអ្នកជំងឺអេដស៍ទាំងអស់ទេ ឬផ្តល់សេវាថែទាំបានទូលំទូលាយទេ។ នៅអណ្តូង អង្គការបី (វិថីជីវិត អង្គការCenter of Hope និងម៉ារីណុល) ផ្តល់សេវាថែទាំ ដល់អ្នកជំងឺអេដស៍។ នៅត្រពាំងអញ្ចាញ អង្គការវិថីជីវិត និងម៉ារីណុល ផ្តល់សេវាថែទាំតាមផ្ទះ ដល់អ្នកជំងឺអេដស៍ ៩នាក់។ ចំពោះការព្យាបាលជំងឺឱកាសនិយមវិញ អ្នកជំងឺ បានប្រើប្រាស់សេវារបស់ អង្គការមិនមែនរដ្ឋាភិបាល តាមរយៈគ្លីនិកចល័តរបស់ អង្គការ Center of Hope ឬអង្គការ លីកាដូ បើមិនដូច្នោះទេ ពួកគាត់ទៅមន្ទីរពេទ្យបង្អែក ដែលពួកគាត់មួយចំនួន ទទួលបានសេវាឥតគិតថ្លៃពីមន្ទីរពេទ្យ តាមរយៈការចូលជាសមាជិករបស់មូលនិធិសុខភាព សមធម៌ (Health Equity Fund)។ [១០៦]

### *សុខភាពផ្លូវកាយ និងផលប៉ះពាល់នៃបរិស្ថាន*

ប្រជាពលរដ្ឋជាច្រើនដែលបានផ្តល់បទសម្ភាសន៍បានត្អូញត្អែរ អំពីសុខភាពដែលចេះតែ ទ្រុឌទ្រោមទៅៗ នៅឯកន្លែងតាំងទីលំនៅថ្មី។ ខ្វះទីជម្រកសមរម្យ (គ្មានការការពារពីកំដៅថ្ងៃ ឬពីភ្លៀង និងទីតាំងងាយលិចទឹក( ខ្វះទឹកបរិភោគមានសុវត្ថិភាព ខ្វះអនាម័យសមស្រប ព្រមទាំងចំនួនប្រជាពលរដ្ឋច្រើនពេក នៅតាមកន្លែងតាំងទីលំនៅថ្មីភាគច្រើនបំផុត ដែលសុទ្ធ តែជាហេតុបណ្តាលអោយមាន លក្ខខ័ណ្ឌសុខភាពចុះខ្សោយ និងបណ្តាលឱ្យងាយប្រឈម កាន់តែខ្លាំងឡើងចំពោះជំងឺឱកាសនិយម និងជំងឺឆ្លង ដែលអាចរាលដាលពាសពេញ សហគមន៍។ អាចមានមូលហេតុមួយទៀត គឺ ចំណីអាហារមិនគ្រប់គ្រាន់ និងខ្វះអាហារូបត្ថម្ភ។

ប្រជាពលរដ្ឋជាអ្នកជំងឺអេដស៍ និង អង្គការមិនមែនរដ្ឋាភិបាល ដែលបានផ្តល់បទសម្ភាសន៍ លើកឡើងនូវក្តីកង្វល់ អំពីការធ្លាក់ចុះកំរិត CD4 សំរាប់អ្នកជំងឺអេដស៍ ដែលបានផ្លាស់ប្តូរទីតាំង។[១០៧] ទោះបីជាចំនួន កំរិត CD4 ធ្លាក់ចុះ មិនមែនជាកត្តាតែមួយគត់ក្នុងការ វាស់កំរិតស្ថានភាពសុខភាពរបស់អ្នកជំងឺ អេដស៍ក៏ដោយ ក៏នៅពេលដែលត្រូវបានវាយតម្លៃជាមួយនឹងកត្តាផ្សេងៗទៀត ដូចជា កម្រិតនៃភាពតានតឹងខាងអារម្មណ៍ ការខ្វះបរិស្ថានមានសុវត្ថិភាពនិងអនាម័យ និង ការបរិភោគអាហារមិនគ្រប់គ្រាន់ វាគឺជាកត្តាគន្លឹះនៃភាពងាយមានជំងឺ។ ស្រ្តីមេម៉ាយម្នាក់អាយុ ៤៨ឆ្នាំ ឈ្មោះ ម៉ាលីស មានកូនពីរនាក់ រស់នៅអណ្តូង បានឃើញ កំរិត CD4 របស់គាត់ធ្លាក់ចុះពី៤០០ នៅខែមករា ឆ្នាំ២០០៩ មកនៅត្រឹមតែ១០០ ក្នុងខែតុលា ក្នុងឆ្នាំដដែល។[១០៨] គាត់និយាយថា "គ្រូពេទ្យបានប្រាប់ខ្ញុំ អោយសំរាកអោយបានគ្រប់គ្រាន់ និងបរិភោគឱ្យបានប្រសើរឡើង ប៉ុន្តែវាពិបាកសម្រាប់ខ្ញុំក្នុងការធ្វើតាមពាក្យទូន្មានរបស់គ្រូពេទ្យ ពីព្រោះខ្ញុំលក់ទឹកកកបានលុយបានតែប៉ុន្មានរយរៀលប៉ុណ្ណោះក្នុងមួយថ្ងៃ ហើយថែមទាំងត្រូវចិញ្ចឹមកូនពីរ នាក់ទៀត"។

នៅទួលសំបូរ គម្រោងមួយរបស់អង្គការ Caritas ដោយមានមូលនិធិពីទីភ្នាក់ងារអង្គការសហប្រជាជាតិ កំពុងតែដោះស្រាយបានបញ្ហាលំនៅដ្ឋានដែលពីដំបូងគ្មានភាពសមរម្យ ដែលជាកត្តារួមចំណែកធ្វើឱ្យមានបញ្ហាសុខភាពមិនល្អដល់ប្រជាពលរដ្ឋ។ មកដល់ខែកក្កដា ឆ្នាះ២០១០ ប្រជាពលរដ្ឋជាច្រើនគ្រួសារនឹងទទួលបានផ្ទះធ្វើពីឥដ្ឋ ដែលអាចការពារកំដៅ និងទឹកភ្លៀង ព្រមទាំងមានទីធ្លាសមរម្យ និងអនាម័យត្រឹមត្រូវ។ លំនៅដ្ឋានថ្មីទាំងនោះ មានគុណភាព និងរូបរាងដូចគ្នា នឹងលំនៅដ្ឋានដែលសាងសង់ដោយអង្គការ Caritas សម្រាប់ប្រជាពលរដ្ឋ ដែលបាត់បង់ផ្ទះពីការបាក់ច្រាំងទន្លេ អាស្រ័យហេតុនេះដោះស្រាយ បានការយល់ឃើញពីមុនៗមក ដែលថាគ្រួសារអ្នកជំងឺអេដស៍អាចនឹងពេញចិត្តចំពោះ លំនៅដ្ឋានគ្មានលក្ខណៈបទដ្ឋានទាំងនេះ ខណៈពេលដែលលំនៅដ្ឋាន រឹងមាំត្រូវបានសាងសង់សម្រាប់ជនរងគ្រោះដោយសារគ្រោះធម្មជាតិ។ បច្ចុប្បន្ន គ្រួសារដែលមកពីតំបន់ច្រាំងទន្លេ បានចូលទៅរស់នៅក្នុងផ្ទះមួយអាគាររួចហើយគឺ នៅចន្លោះជួរផ្ទះដែលនឹងត្រូវចូលកាន់កាប់ ដោយគ្រួសារអ្នកជំងឺអេដស៍ ធ្វើដូច្នេះគឺជាការ



ផ្ទះថ្មីនៅទួលសំបូរ ថ្លែងអំណរគុណចំពោះការថតរូបដោយ:karona / OHCHR



[១០៦] គម្រោងរបស់មូលនិធិសុខភាពសមធម៌ បច្ចុប្បន្នទទួលបានហិរញ្ញវត្ថុពីដៃគូរអភិវឌ្ឍន៍ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ។ មូលនិធិនេះចេញថ្លៃព្យាបាលដល់អ្នកជំងឺក្រីក្រ ផ្តល់អាហារ មធ្យោបាយដឹកបញ្ជូន និងថ្លៃចំណាយផ្សេងៗទៀត ។ ធនាគារពិភពលោកកម្ពុជា ,ប្រតិប័ត្រព័ត៌មាន លេខ ៨ ,១/២ (ខែមករា- កុម្ភៈ ឆ្នាំ២០១០) ។

# ជំពូកទី៥ ៖ ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី

## *សុខភាពផ្លូវកាយ*

ក្រុមគ្រួសារប្រជាពលរដ្ឋនៅកន្លែងតាំងទីលំនៅថ្មី ជាទូទៅ តែងតែប្រាប់អំពីលក្ខខ័ណ្ឌសុខភាព ដែលកាន់ធ្លាក់ដុនដាបទៅៗរបស់ពួកគេ ក្រោយពីទៅរស់នៅកន្លែងតាំងទីលំនៅថ្មី។ យោងតាមតំណាងនិងបុគ្គលិកមកពី អង្គការ Center of Hope អង្គការលីកាដូ និងម្លូម់តាប៉ាង បានឱ្យដឹងថា បញ្ហាសុខភាពភាគច្រើនបំផុត នៅតាមកន្លែងតាំងទីលំនៅថ្មីទាំងអស់គឺ ជំងឺរលាកផ្លូវដង្ហើម ជំងឺរាគរូស ជំងឺសើរស្បែក និងជំងឺផ្សេងៗទៀតដែលពាក់ព័ន្ធនឹង ការបរិភោគអាហារមិនគ្រប់គ្រាន់ និង កង្វះវីតាមីនរបស់កុមារ។ ក៏មានករណីជំងឺរ៉ាំរ៉ៃ ដូចជា ជំងឺលើសឈាម ទឹកនោមផ្អែម និងរោគរបេង។ នៅរដូវវស្សា ជំងឺភាគច្រើនបំផុតរួមមាន គ្រុនក្តៅ ផ្តាសាយ រាគរូស និង គ្រុនឈាម។[109] អ្នកជំងឺភាគច្រើនបំផុត ដែលមកជួបក្រុមគ្រូពេទ្យ អង្គការមិនមែនរដ្ឋាភិបាលទាំងអស់នេះ ដើម្បីទទួលការព្យាបាលគឺជា ស្ត្រី និងកុមារ ។

ជំងឺនិងបញ្ហាទាំងនេះមានការជាប់ទាក់ទងទៅនឹងកង្វះហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជាទឹកស្អាត អនាម័យ និងលំនៅដ្ឋានសមរម្យ គួបផ្សំនឹងខ្វះចំណីអាហារ និង អាហារបំប៉នសំខាន់ៗដែរ។

ស្ថានភាពនេះពិតជាគួរឱ្យកត់សម្គាល់នៅ អណ្តូង ពីព្រោះលក្ខខ័ណ្ឌសុខភាពរបស់ប្រជាពលរដ្ឋជាច្រើនគ្រួសារមិនឃើញមានលក្ខណៈប្រសើរឡើយ ចាប់តាំងពីពេលដែលពួកគាត់ផ្លាស់មកនៅទីនេះនៅឆ្នាំ ២០០៦នោះមក។ នេះដោយសារតែ ការបន្តមាននូវលក្ខខ័ណ្ឌគ្មានការសំអាតខ្លួនប្រាណ និងអនាម័យ គ្មានប្រព័ន្ធលូ និងប្រមូលសំរាម និងគ្មានលំនៅដ្ឋានសមរម្យ។ ឧទាហរណ៍ កាលពីថ្ងៃទី២ ខែតុលា ឆ្នាំ ២០០៩ គ្រូពេទ្យអង្គការលីកាដូម្នាក់ បានពិនិត្យជំងឺដល់ប្រជាពលរដ្ឋ ចំនួន៥១ នាក់នៅអណ្តូង ដែលមានជំងឺរាគរូស រលាកប្រព័ន្ធផ្លូវដង្ហើម ជំងឺខ្វះអាហារូបត្ថម្ភ និងខ្វះវីតាមីន និងជំងឺផ្សេងៗទៀត ជាបញ្ហារ៉ាំរ៉ៃតាំងពីការផ្លាស់មកនៅកន្លែងតាំងទីលំនៅថ្មីនេះនៅឆ្នាំ ២០០៦។[110]

ការវាយតម្លៃមួយ ដែលធ្វើឡើងដោយ អង្គការ Center of Hope និងអង្គការលីកាដូ ជុំវិញស្ថានភាពសុខភាពរបស់អតីតប្រជាពលរដ្ឋនៅដីក្រហម នៅដំណាក់ត្រយឹង កាលពីខែកុម្ភៈ ឆ្នាំ ២០០៩ បានបង្ហាញឱ្យឃើញថា "នៅពេលដែលលក្ខខ័ណ្ឌ បរិដ្ឋានអនាម័យ និងអនាម័យសំរាប់ខ្លួនប្រាណ មិនស្របនឹងបទដ្ឋានមនុស្សធម៌ជាមូលដ្ឋាន

[107] ការរាប់ CD4 វាស់ចំនួនកោសិកា CD4 នៅក្នុងឈាម ហើយត្រូវបានប្រើប្រាស់ក្នុងវាយតម្លៃភាពខ្លាំងនៃប្រព័ន្ធការពាររាងកាយ។ ចំនួនកោសិកា CD4 នៅក្នុងឈាម ធ្លាក់ចុះជាបន្តបន្ទាប់ នៅពេលដែលជំងឺអេដស៍មានការវិវត្ត ដូច្នេះធ្វើឱ្យសមត្ថភាពការពារទប់ទល់នឹងជំងឺរបស់រាងកាយចុះខ្សោយ។ សូមមើល(http://data.unaids.org/Topics/Partnership-Menus/tbca_booklet-3_en.pdf) ផងដែរ ។

[108] កំរិត CD4 ធម្មតានៅក្នុងខ្លួនមនុស្សពេញវ័យមានចាប់ពី ៥០០ ទៅ ១,៥០០ កោសិកាក្នុងមួយមីក្រូលីត្រនៃឈាម ។ ជាទូទៅគ្រូពេទ្យនឹងចេញវេជ្ជបញ្ជាប្រើ ថ្នាំសំរាប់ជំងឺអេដស៍ នៅពេលដែល កម្រិត CD4 ធ្លាក់ចុះក្រោមចន្លោះពី ២០០ ទៅ ៣៥០ ។

[109] ឧទាហរណ៍ កាលពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ គ្រូពេទ្យអង្គការលីកាដូបានពិនិត្យជំងឺដល់សមាជិកសហគមន៍ ៥១ នាក់ នៅដំណាក់ត្រយឹង ភាគច្រើនជាកុមារ ស្ត្រីចំណាស់ និង ស្ត្រីមានគភ៌ ។ ជំងឺភាគច្រើនរួមមាន គ្រុនក្តៅ រាគ រលាកបំពង់ក និងករណីសង្ស័យជំងឺគ្រុនឈាមចំពោះកុមារម្នាក់: ឯកសារពិនិត្យសុខភាព របស់អង្គការលីកាដូ ។ កាលពីថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៩ អង្គការ លីកាដូ បានទទួលពិនិត្យសមាជិកសហគមន៍ជិតដល់ ៦០ នាក់ នៅត្រពាំងអញ្ចាញ ដែលភាគច្រើនជា ស្ត្រី និងកុមារ ដែលមានជំងឺ ក្អក រលាកបំពង់ក គ្រុនក្តៅ រាគ និង ជំងឺខ្វះអាហារូបត្ថម្ភ ជាពិសេសកុមារ ។

[110] ការវាយតម្លៃស្ថានភាពទឹកនិងអនាម័យ នៅអណ្តូងដោយ OHCHR ឃើញថា ប្រជាពលរដ្ឋស្ទើរតែ ៥០ ភាគរយ ដែលត្រូវបានសម្ភាសន៍បាននិយាយថាពួកគាត់មានជំងឺសើរស្បែកដែលអាចបង្កឡើងដោយទឹកដែលពួកគាត់កំពុងប្រើប្រាស់ឬ ខ្វះអនាម័យខ្លួនប្រាណ ។ ជាង៦០ភាគរយនិយាយថា មានជំងឺផ្លូវដង្ហើមដែលអាចបណ្តាលមកពីខ្វះបរិដ្ឋានអនាម័យ និង ការគ្រប់ គ្រងកាកសំណល់មិនសមស្រប ។ ភាគច្រើនពួកគាត់បាននិយាយថា ពួកគាត់មានការរាគរូសជាញឹកញាប់ ។ លើសពី ៦០ ភាគរយ នៃអ្នកត្រូវបានសម្ភាសន៍បាននិយាយថា កូនៗរបស់ពួកគាត់កើតព្រូនច្រើនណាស់ ។

ទេ នោះនឹងមាន គ្រោះថ្នាក់ និងហានិភ័យចម្រុងៗ មកលើសុខភាពរបស់ប្រជាពលរដ្ឋដែលប្រឈមនឹងបរិស្ថានបែបនោះ។ ជំងឺឆ្លងតែងតែរាលដាល និងកើតមានជាញឹកញាប់ក្នុងស្ថានភាពបែបនេះ”។[១១១]

*សុខភាពផ្លូវចិត្ត និងបញ្ហាចិត្តសាស្ត្រសង្គម*

វាជាការលំបាក ក្នុងការវាយតម្លៃសុខភាពផ្លូវចិត្តរបស់ប្រជាពលរដ្ឋដែលត្រូវគេបណ្តេញចេញ និងដែលបានតាំងទីលំនៅថ្មី។ ការវាយតម្លៃសុខភាពផ្លូវចិត្ត មិនដែលគេផ្តល់ជាអាទិភាព សម្រាប់សកម្មភាពជួយសង្គ្រោះឡើយ ហើយក៏មិនមានការវាយតម្លៃល្អិតល្អន់ ឬជាបន្តបន្ទាប់ ត្រូវបានធ្វើឡើងនៅតាមទីកន្លែងតាំងទីលំនៅថ្មីណាស់ លើកលែងតែករណីវាយតម្លៃតែម្តងគត់ ដែលបានធ្វើឡើងភ្លាមៗក្រោយពីការបណ្តេញប្រជាពលរដ្ឋនៅដីក្រហម កាលពីខែមករា ឆ្នាំ២០០៩។

ការវាយតម្លៃសុខភាពផ្លូវចិត្តរបស់ក្រុមគ្រួសារដែលត្រូវគេបណ្តេញចេញពីដីក្រហម ដោយមជ្ឈមណ្ឌលសម្រាប់សុខភាពផ្លូវចិត្តកុមារ និងមនុស្សពេញវ័យ (Caritas-CCAMH) បានបង្ហាញ ថា សហគមន៍នេះ មានបញ្ហាខាងផ្លូវចិត្តនិងផ្លូវកាយក្នុងកំរិតដ៏គួរកត់សំគាល់ ដែលបណ្តាលមកពីការបណ្តេញចេញ។ ប្រជាពលរដ្ឋភាគច្រើន កំពុងមានការលំបាកផ្លូវចិត្ត និងមានអារម្មណ៍តឹងតែងតប់ប្រមល់ ដោយបានបង្ហាញយ៉ាងច្បាស់តាមរយៈរោគសញ្ញាលើរាងកាយ និងផ្លូវចិត្ត និងការសំរាន្តមិនលក់ស្កប់ស្កល់។[១១២] ការវាយតម្លៃនេះបានបង្ហាញថា បញ្ហាសុខភាពផ្លូវចិត្តក្នុង សហគមន៍អាចមានជាប់ទាក់ទិនដោយផ្ទាល់ទៅនឹង ការដែលមិនបំពេញបាននូវសេចក្តីត្រូវការចាំបាច់របស់ពួកគាត់ ដូចជា អាហារ ទីជម្រក និងទឹកជាដើម។ កង្វល់អំពីការចាកចេញដោយបង្ខំចិត្តជាបន្តទៀត បានធ្វើឱ្យពួកគាត់មានបញ្ហាសុខភាពផ្លូវចិត្ត និងផ្លូវកាយកាន់តែធ្ងន់ធ្ងរទៅៗ។

សុខភាពផ្លូវចិត្ត អាចនឹងល្អប្រសើរ ប្រសិនបើ តម្រូវការសម្ភារៈទាក់ទងនឹង លំនៅដ្ឋាន ការងារ សុវត្ថិភាពស្បៀងអាហារ និងសុខភាពផ្លូវកាយ ត្រូវបានបំពេញតាំងពីដំបូង។ ហើយការវាយតម្លៃសុខភាពផ្លូវចិត្តនេះ ក៏បានកត់សម្គាល់លើស្ថានភាពដែលប្រជាពលរដ្ឋ ត្រូវផ្លាស់ទីតាំងទៅដំណាក់ត្រយឹង គឺថា តាមរយៈការបណ្តេញចេញដោយអំពើហិង្សា ដូច្នេះ ពួកគាត់ប្រហែលជានឹងមានបញ្ហាផ្លូវចិត្តនិងផ្លូវកាយរយៈពេលវែង បន្ថែមពីលើហានិភ័យនៃសុខភាពផ្លូវកាយដទៃទៀត។ បញ្ហាបែបនេះអាចប៉ះពាល់ខ្លាំងដល់ប្រជាពលរដ្ឋជាច្រើននៅក្នុងសហគមន៍ ហើយប្រហែលជាមានគ្រួសារជាច្រើននៅកន្លែងតាំងទីលំនៅថ្មីដទៃទៀតទទួលរងនូវផលប៉ះពាល់ ស្រដៀងគ្នានេះដែរ។

តាមកិច្ចសម្ភាសន៍កន្លងមក មានភស្តុតាងយ៉ាងរឹងមាំមួយចំនួន ដែលបង្ហាញពីបញ្ហាតានតឹង និងបញ្ហាផ្លូវចិត្តនិងផ្លូវកាយ ក្នុងចំណោមប្រជាពលរដ្ឋនៅកន្លែងតាំងទីលំនៅថ្មី។ អ្នកដែលបានផ្តល់បទសម្ភាសន៍បាននិយាយថា ពួកគាត់មានអារម្មណ៍តានតឹងណាស់ ដោយសារមានការលំបាកជាច្រើនក្នុងការស្វែងរកការងារធ្វើ និងការរកបានប្រាក់ចំណូលជាប់លាប់ ខ្វះស្បៀងអាហារសម្រាប់កូនៗ អសុវត្ថិភាពខាងការកាន់កាប់ដីធ្លី និងការភ័យខ្លាច

[១១១] អង្គការ Caritas, អង្គការ Center of Hope, CCAMH, Jesuit Refugee Service, Licadho, Samaritan’s Purse, Village Earth និងអង្គការ World Vision, “ការវាយតំលៃអំពីតំរូវការផ្នែកមនុស្សធម៌ លើប្រជាពលរដ្ឋដែលត្រូវគេបណ្តេញចេញពីតំបន់ដីក្រហម: សុខភាព ម្ហូបអាហារ អនាម័យ ការអប់រំ តំរូវការខាងថ្នាំ សង្គ្រូវ និងសុខភាពផ្លូវចិត្ត [ពីពេលនេះតទៅហៅ: ការវាយតំលៃអំពីតំរូវការ ផ្នែកមនុស្សធម៌ លើប្រជាពលរដ្ឋដែលត្រូវគេបណ្តេញចេញពីតំបន់ដីក្រហម] (ថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០០៩) ទំព័រ១២ ។

[១១២] ការវាយតំលៃអំពីតំរូវការ ផ្នែកមនុស្សធម៌ លើប្រជាពលរដ្ឋដែលត្រូវគេបណ្តេញចេញពីតំបន់ដីក្រហម។

# ជំពូទី៥ ៖ ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី

គេបណ្តេញចេញម្តងទៀត ក្រុមគ្រួសាររស់នៅបែកគ្នា មនុស្សរស់នៅច្រើនពេក និងបំណុលកាន់តែច្រើនដោយសារអសន្តិសុខស្បៀង ឬ គ្មានប្រាកចំណូល។

ក្នុងពេលចុះទៅពិនិត្យដល់កន្លែងនៅអណ្តូង និង ត្រពាំងអញ្ចាញ OHCHR បានសង្កេតឃើញមានស្ត្រីជាច្រើនស្ថិតក្នុងស្ថានភាពស្រវឹងស្រានៅពេលអាហារថ្ងៃត្រង់។ នៅក្នុងកន្លែងតាំងទីលំនៅថ្មីទាំងនោះ និងនៅដំណាក់ត្រយឹង ឃើញមានប្រជាពលរដ្ឋជាច្រើន លេងល្បែងស៊ីសង ឬលេងបៀរពេញមួយថ្ងៃ។ អំពើហិង្សាក្នុងគ្រួសារ ត្រូវបានគេនិយាយថា ជាបញ្ហាធម្មតាទៅហើយ នៅតាមកន្លែងតាំងទីលំនៅថ្មីទាំងអស់ ទោះបីជាគ្មានទិន្នន័យច្បាស់លាស់ និង បញ្ហានេះមិនត្រូវបានរាយការណ៍ក៏ដោយ។ ទន្ទឹមនឹងនេះដែរ ប្រធានភូមិអណ្តូង និង ប្រធានភូមិទួលសំបូរ បាននិយាយថា ពួកគាត់បានដឹងអំពីករណី អំពើហិង្សាក្នុងគ្រួសារដែលកើតមានភ្លាមៗក្រោយពីពួកគាត់ផ្លាស់មកនៅទីតាំងទាំងនេះ ប៉ុន្តែបានគិតថា ឥឡូវនេះមិនសូវកើតមានទេ។ មានប្រជាពលរដ្ឋជាច្រើនគ្រួសារដែលបានផ្តល់បទសម្ភាសន៍ បានឱ្យដឹងថា ពួកគាត់ក៏បានដឹងអំពីករណីអំពើហិង្សាក្នុងគ្រួសារនេះ និងក៏ជាជនរងគ្រោះផ្ទាល់ ដោយសារអំពើហិង្សាក្នុងគ្រួសារផងដែរ។ ពួកគាត់កំនត់បញ្ហានេះថា ក្នុងចំនោមកត្តាជាច្រើន គឺមកពីការខ្វះការងារធ្វើ និងអសន្តិសុខស្បៀងអាហារ ។

ស្ត្រីដែលបានផ្តល់បទសម្ភាសន៍បានកត់សម្គាល់ថា ដោយសារការបាត់បង់ប្រាក់ចំណូល និង ដោយសារមានការលំបាកទាក់ទងនឹងការផ្លាស់ទីលំនៅ បុរសៗចាប់ផ្តើមសេពគ្រឿងស្រវឹង កាន់តែច្រើនឡើង។ ជាលទ្ធផល "ជំលោះ" និងភាពតានតឹងរវាងប្តីនិងប្រពន្ធកើតមានឡើងជាញឹកញាប់ ។

ស៊ីវឡេង ស្ត្រីអាយុ៥៨ឆ្នាំបាន និយាយថា:

> "កាលពីមុនពេលបណ្តេញចេញ ប្តីរបស់ខ្ញុំជាកម្មករសំណង់ ខិតខំធ្វើការណាស់ ហើយគាត់កម្រទៅផឹកស្រាណាស់។ តាំងពីពួកយើងផ្លាស់មកកន្លែងថ្មីនេះ គាត់អាចរកការងារសំណង់ ធ្វើបានម្តងម្កាលប៉ុណ្ណោះ។ ដូច្នេះ គាត់ស្រវឹងស្ទើរតែរាល់ថ្ងៃដោយមិនទៅរកការងារធ្វើទេ។ ខ្ញុំខឹងនឹងគាត់ណាស់ ពីព្រោះខ្ញុំត្រូវទៅរកអាហារដោយខ្លួនឯង និងខំរកលុយតាមគ្រប់មធ្យោបាយដែលអាចធ្វើបាន ដើម្បីចិញ្ចឹមជីវិត។ ពេលខ្ញុំស្រែក អោយគាត់ គាត់វាយខ្ញុំ។ ពួកយើងឈ្លោះគ្នាជាញឹកញាប់ ហើយយើងមិននិយាយរកគ្នាអស់រយៈពេល ពីរអាទិត្យមកហើយ"។

ក្រុមគ្រួសារដែលបានរស់នៅលើចិញ្ចើមផ្លូវនៅដំណាក់ត្រយឹងរហូតមកដល់ខែធ្នូឆ្នាំ២០០៩នេះ បានឱ្យដឹងអំពី អារម្មណ៍អសុវត្ថិភាពជាប្រចាំ ពីព្រោះគេប្រាប់ពួកគាត់ជារឿយៗថា ពួកគាត់ នឹងត្រូវគេបណ្តេញចេញម្តងទៀត។ សហគមន៍ស្ពានឆេះក៏បានបង្ហាញពីអារម្មណ៍ដូចគ្នានេះដែរ ពីព្រោះពួកគាត់មិនបានទទួល ចម្លើយតបជាវិជ្ជមានណាមួយចំពោះញត្តិ និងសំណើរ សុំដីជាបន្តបន្ទាប់របស់ពួកគាត់ទេ។ ប្រជាពលរដ្ឋជាច្រើននាក់ដែលបានផ្តល់បទសម្ភាសន៍ បានសំដែងនូវការអស់សង្ឃឹម ដោយបាននិយាយថា ពួកគាត់មានអារម្មណ៍ថា ត្រូវគេបោះបង់ចោល និងលែងមានសង្ឃឹមតទៅទៀត។

ជាកត្តាចាំបាច់ ដែលត្រូវតែធ្វើការសិក្សាអោយល្អិតល្អន់និងទូលំទូលាយបន្ថែមទៀតលើផលប៉ះពាល់ភ្លាមៗពីការបណ្តេញចេញ ចំពោះសុខភាពផ្លូវចិត្តរបស់ប្រជាពលរដ្ឋ ក៏ដូចជាលើផលប៉ះពាល់

[១១៣] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (ICESCR) មាត្រា ១៣ ។



ក្មេងកំពុងដើរកាត់ទឹកលេចផ្លូវនៅចុងរដូវវស្សា, ភូមិអណ្តូង, ថ្លែងអំណរគុណចំពោះការថតរូបដោយ: S.Sem / OHCHR

រយៈពេលវែងដែលពាក់ព័ន្ធ នឹងការលំបាកនានាដែលកើតមាននៅកន្លែងតាំងទីលំនៅថ្មីនានា។

## ៥.៧ ការអប់រំ

ការសម្រេចបានការប្រើប្រាស់ពេញលេញសិទ្ធិទទួលបានការអប់រំ គឺមានន័យថា ជាការធានាដល់ការអប់រំកម្រិតបឋមសិក្សា ត្រូវតែជាកាតព្វកិច្ច ហើយឥតគិតថ្លៃសម្រាប់ទាំងអស់គ្នា ។ ការអប់រំកម្រិតមធ្យមសិក្សាតាមទ្រង់ទ្រាយផ្សេងៗ ត្រូវតែបើកអោយមានជាទូទៅ និងអោយមនុស្សគ្រប់គ្នាអាចចូលរៀនបាន។[១១៣] ក៏ប៉ុន្តែ ក្រោយពីការផ្លាស់ប្តូរទីតាំងថ្មី ការសិក្សារបស់កុមារ តែងតែស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់តាមរូបភាពជាច្រើន ដូចជាការសិក្សាត្រូវបានរំខានមធ្យោបាយធ្វើដំណើរទៅសាលារៀនត្រូវបានកាត់ផ្តាច់ និងការបង់ថ្លៃសាលាក្រៅផ្លូវការបន្ថែមនៅសាលារៀនថ្មី។ កុមារខ្លះបានបោះបង់ការសិក្សាចោលទាំងស្រុងក្រោយពេលបណ្តេញចេញ។

### *ការរំខានដល់ការសិក្សា និងការបោះបង់ការសិក្សា*

បញ្ហាចំបងដែលឪពុកម្តាយ និង កូនៗរបស់ពួកគេ ជួបប្រទះនោះ គឺការអាក់ខានក្នុងការរៀនសូត្រ ដោយសារតែការបណ្តេញចេញ ជាពិសេសនៅពេលដែលវាកើតឡើងក្នុងអំឡុងពេលបវេសនកាល។ ក្មេងៗមួយចំនួន ត្រូវបោះបង់ការសិក្សាជាបណ្តោះអាសន្ន ខណៈពេលដែល ឪពុកម្តាយរង់ចាំផ្ទេរឈ្មោះនិងឯកសារសិក្សាទៅសាលារៀនថ្មី។ ក្មេងៗខ្លះទៀតបានបន្ត ទៅរៀននៅសាលារៀនដើម

[១១៤] អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ជំនួយមាន: អង្គការស្ពានឆ្ពោះទៅកាន់សន្តិភាពអាស៊ីអាគ្នេយ៍ អង្គការFriends និង Village Earth ។

ជំពូកទី ៥

នៅទីក្រុង ដោយភាគច្រើនស្នាក់នៅជាមួយញាតិសណ្តាន ឬក៏មិត្តភ័ក្រ។ នេះជាបន្ទុកបន្ថែមទៅលើញាតិសណ្តាន និង គ្រួសាររបស់ក្មេង ពីព្រោះពួកគេត្រូវតែចាយវាយបន្ថែមសម្រាប់ក្មេងអាចរៀនបន្តនៅទីក្រុង ហើយក៏នាំឱ្យក្មេងរស់នៅ បែកឆ្ងាយពីក្រុមគ្រួសាររបស់ពួកគេដែរ។ ក្រោយពីការបណ្តេញចេញ ក្រុមគ្រួសារអ្នកដីក្រហម កាលពីខែមករា ឆ្នាំ ២០០៩ ដែលកើតឡើងក្នុងពេលបវេសនកាល ក្មេងបានខកខានមិនបានទៅរៀនសូត្រជាច្រើនថ្ងៃ គឺពីមួយ ទៅបីសប្តាហ៍ រហូតដល់ពេល ក្រុមអង្គការមិនមែនរដ្ឋាភិបាលបានរៀបចំអោយមាននូវមធ្យោបាយដឹកជញ្ជូនសិស្ស ដែលរស់នៅជំណាក់ត្រយឹងទៅសាលារៀននៅឯក្នុងក្រុង តាមរយៈរថយន្ត និងម៉ូតូកង់បី (Tuk Tuk)។[១១៤] ក្មេងមួយចំនួនអាចត្រឡប់ទៅរៀនវិញបាន ដោយមានជំនួយពីអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលផ្តល់មធ្យោបាយធ្វើដំណើរ ផ្តល់អាហារ និង ទីជម្រកនៅក្នុងក្រុង។ អង្គការទាំងនោះបានបញ្ឈប់ការផ្តល់ជំនួយនៅពេលចប់ឆ្នាំសិក្សា គឺនៅពេលដែលឈ្មោះ និង ឯកសារសិក្សាក្មេងៗទាំងនោះ ត្រូវបានផ្ទេរទៅសាលារៀនដែលនៅក្បែរកន្លែងតាំងទីលំនៅថ្មី ដើម្បីត្រៀមចូលរៀនឆ្នាំសិក្សាថ្មី។

ទោះបីជា មិនមានទិន្នន័យដែលបង្ហាញថាតើមានក្មេងប៉ុន្មាននាក់ បានបោះបង់ចោលការសិក្សា ដោយសារតែការបណ្តេញចេញក៏ដោយ ក៏ប្រជាពលរដ្ឋជាច្រើនគ្រួសារ ដែលបានផ្តល់បទសម្ភាសន៍បានបញ្ជាក់ថា កូនៗរបស់ពួកគាត់បានបោះបង់ការសិក្សា ដើម្បីមកជួយគ្រួសារក្នុងការរកប្រាក់ចំណូលបន្ថែម។ OHCHR បានកត់ត្រាករណីក្មេងស្រីជំទង់ ដែលបានឈប់រៀន នៅពេលដែលពួកគេត្រូវផ្លាស់ប្តូរទីតាំងទៅ ទួលសំបូរ ពីព្រោះគ្រួសារពួកគេ មិនមានលទ្ធភាពឱ្យលុយពួកគេទៅសាលារៀនទេ ហើយពួកគេត្រូវតែជួយគ្រួសាររបស់ខ្លួន ក្នុងការរកប្រាក់ចំណូលបន្ថែម។ មានសេចក្តីរាយការណ៍ថា ក្មេងស្រីជំទង់ទាំងនេះធ្វើការ "នៅពេលយប់" នៅហាងការ៉ាអូខេ។ នៅស្ពានឆេះ ម្តាយម្នាក់បាននិយាយរៀបរាប់ពីបញ្ហាដែលកូនស្រីច្បងពីរនាក់របស់គាត់បានឈប់រៀន ដើម្បីធ្វើការជាកម្មករសំណង់ ពីព្រោះប្រាក់ចំណូលក្នុងគ្រួសារមិនគ្រប់គ្រាន់សម្រាប់ចិញ្ចឹមគ្រួសារ ដែលមានសមាជិកប្រាំបីនាក់ នោះទេ។

យោងតាមនាយកសាលាបឋមសិក្សានៅក្បែរកន្លែងតាំងទីលំនៅថ្មី នៅអណ្តូង បានឱ្យដឹងថាមានកុមារដែលបានផ្លាស់ទីលំនៅពីសំបុកចាប មកអណ្តូង ប្រហែលតែជា ៨០ភាគរយ នៃតួលេខកុមារសារុប ដែលផ្តល់ដោយការិយាល័យអប់រំ បានមករៀន។ គាត់បានសង្កេតឃើញថា កុមារមកពីសហគមន៍ អណ្តូង តែងតែមករៀនយឺត ហើយមិនសូវមករៀនបានទៀងទាត់ទេ ពីព្រោះពួកគេប្រហែលជាត្រូវជួយឪពុកម្តាយនៅផ្ទះ។ ចំណែកឯកូនសិស្សនៅមូលដ្ឋានវិញ គឺមករៀនបានទៀងទាត់និងទាន់ពេល។

នៅខេត្តព្រះសីហនុ កុមារមួយចំនួនបានឈប់រៀន បណ្តាលមកពីសាលារៀននៅឆ្ងាយពី អូរកម្ពុជា និង ផ្លូវមិនល្អ។ កងទ័ពជើងទឹកបានសន្យាសង់សាលារៀននៅ ទីតាំងនោះ ប៉ុន្តែសហគមន៍នៅកំពុងតែរង់ចាំនៅឡើយ។

### *ការផ្ទេរសាលារៀនៈ ចំណាយ និងការលំបាក*

ការផ្ទេរកូនពីសាលារៀនមួយទៅសាលា

[១១៥] បទសម្ភាសន៍ជាមួយលោក ឯម ហាំយួន អនុប្រធានមន្ទីរ អប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១០ [ពីពេលតទៅ ៖ បទសម្ភាសន៍ជាមួយលោក ឯម ហាំយួ]។

រៀនមួយទៀតមានពាក់ព័ន្ធការចំណាយខ្លះៗ ដែលក្រុមគ្រួសារខ្លះ មិនមានលទ្ធភាពចំណាយទេ។ យោងតាមអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ បានឱ្យដឹងថា ការផ្ទេរពីសាលារៀនមួយ ទៅសាលារៀនមួយទៀតនៅកម្រិតបឋមសិក្សាឬមធ្យមសិក្សាមិនមានបង់ប្រាក់ទេ។[១១៥] ក៏ប៉ុន្តែគ្រួសារដែលបានផ្លាស់ទីលំនៅថ្មីជាច្រើនបានត្អូញត្អែរថា ទាំងបុគ្គលិកខាងសាលារៀនដើម និងសាលារៀនថ្មីបានសុំឱ្យពួកគាត់បង់ប្រាក់ (ក្រៅផ្លូវការ) សម្រាប់ការផ្ទេរសាលារៀនកូនៗរបស់គាត់ ។ ប្រាក់ដែលបុគ្គលិកសុំឱ្យបង់នោះចាប់ពី២.៥ដុល្លារ ឬ៥ដុល្លា ទៅ២០ដុល្លារ។

ចំនួនទឹកប្រាក់សម្រាប់ផ្ទេរសិស្សថ្នាក់វិទ្យាល័យពិតជាខ្ពស់ជាងនេះ។ ខ្មៅ ជាអតីតប្រជាពលរដ្ឋក្រុម៧៨ ដែលបានផ្លាស់ទីលំនៅទៅកាកោះ (ឬព្រៃទីទុយ) នៅខណ្ឌដង្កោ បាននិយាយថា គាត់ត្រូវគេសុំឱ្យបង់ប្រាក់ ៣០ ដុល្លារ សម្រាប់ការផ្ទេរកូនរបស់គាត់មក វិទ្យាល័យដែលនៅក្បែរកន្លែងទីតាំងលំនៅថ្មីនោះ ចំណែកឯសាលារៀនដើម នៅទីក្រុងក៏សុំឱ្យគាត់បង់ ៥០ដុល្លារ សម្រាប់រៀបចំបែបបទឯកសារផ្ទេរចេញ។

ការផ្ទេរកូនចេញពីសាលារៀនមួយទៅសាលារៀនមួយទៀត ក៏ពិតជាពិបាកដែរ សម្រាប់សិស្សវិទ្យាល័យ ពីព្រោះវិទ្យាល័យមិនសូវមាននៅក្បែរកន្លែងតាំងទីលំនៅដ្ឋានថ្មីទេ ។ ជាក់ស្តែង នៅដំណាក់ត្រយឹង វិទ្យាល័យ ដែលនៅក្បែរបំផុតគឺសាលា ហ៊ុន សែន ជម្ពូវ័ន្ត នៅផ្លូវជាតិលេខ៤ ចម្ងាយប្រហែលជា៧គីឡូម៉ែត្រ។[១១៦] ដូច្នេះ ក្រុមគ្រួសារមួយចំនួន ដែលមានកូនរៀនថ្នាក់អនុវិទ្យាល័យបានខិតខំប្រឹងប្រែង ដើម្បីឱ្យកូនបន្តរៀននៅសាលាដដែលនៅក្នុងទីក្រុង ដោយទុកឱ្យពួកគេរស់នៅជាមួយបងប្អូន ឬមិត្តភ័ក្តិ ដើម្បីធានាអោយការសិក្សាបានជាប់លាប់ និង ទំនាក់ទំនងសង្គមរបស់ពួកគេ។ ការបន្តរៀននៅសាលាដដែលក្នុងទីក្រុងក៏សម្រាប់អ្នកដែលមានបំណងបន្តការសិក្សានៅសាកលវិទ្យាល័យ ដែលមានតែនៅក្នុងទីប្រជុំជននៃទីក្រុង។

### *ចំណាយក្រៅផ្លូវការប្រចាំថ្ងៃ និងបន្ទុកហិរញ្ញវត្ថុលើក្រុមគ្រួសារ*

កូនៗរបស់ក្រុមគ្រួសារដែលបានតាំងទីលំនៅថ្មី ដែលរៀននៅសាលារដ្ឋ ជាទូទៅត្រូវបង់ថ្លៃ "ក្រៅផ្លូវការ" ឱ្យគ្រូបង្រៀនរបស់ខ្លួន។ ពួកគាត់បានជួបបញ្ហាដូចគ្នានេះដែរ កាលពីពេលនៅក្នុងទីប្រជុំជននៃទីក្រុង ព្រោះការបង់ថ្លៃ "ក្រៅផ្លូវការ" កើតមានជាទូទៅទៅហើយ។ ប៉ុន្តែ ពួកគាត់មិនមានការបារម្ភខ្លាំងអំពីបញ្ហានេះទេ ពីព្រោះពួកគាត់មានប្រាក់ចំណូលជាប់លាប់ ចំណែកឯនៅ កន្លែងតាំងទីលំនៅថ្មីវិញ ការចំណាយបែបនេះជាបន្ទុកហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរ។ ឪពុកម្តាយបានត្អូញត្អែរថា កូនរបស់ពួកគាត់ដែលទៅរៀននៅថ្នាក់បឋមសិក្សាត្រូវបង់ប្រាក់ ១០០រៀល ឬច្រើន ជាងនេះ ហើយកូនដែលរៀនថ្នាក់អនុវិទ្យាល័យបង់ប្រាក់ ១,០០០រៀល ឬច្រើន ជាងនេះ ក្នុងមួយថ្ងៃ ឱ្យគ្រូប្រចាំថ្នាក់ ដោយមិនដឹងថាគ្រូប្រមូលយកប្រាក់ដើម្បីគោលបំណង អ្វីច្បាស់លាស់ទេ។ ម្យ៉ាងទៀតកូនៗត្រូវតែបង់ប្រាក់ប្រសិនបើចង់រៀនគួរបន្ថែមបន្ទាប់ពី ម៉ោងរៀនធម្មតា។

[១១៦] អនុវិទ្យាល័យមួយផ្សេងទៀត គឺសាលារៀនជ្រលុង ត្រូវបានកសាងកាលពីពេលថ្មីៗ ហើយកំពុងដំណើរការហើយ ។ វានៅក្បែរ ដំណាក់ត្រយឹងជាងសាលាដទៃទៀត ប៉ុន្តែប្រជាពលរដ្ឋនៅតាមកន្លែងតាំងទីលំនៅដ្ឋានថ្មីមិនបានបញ្ជូនកូនទៅរៀន នៅទីនោះទេ ដោយបារម្ភពីបញ្ហាសត្វស្វាខាំ នៅតាមផ្លូវទៅសាលារៀននោះ ។ បទសម្ភាសន៍ជាមួយលោក ឯម ហាំយួន ។

# ជំពូទី៥ ៖ ការចាប់ផ្ដើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី



មករា នៅដំណាក់ត្រយឹង ដែលបានផ្ទេរកូនពីរនាក់ទៅរៀននៅវិទ្យាល័យជម្ពូវន្ដ៍នៅជាប់ ផ្លូវជាតិលេខ៤ បានត្អូញត្អែរអំពី ការដែលគាត់គ្មានប្រាក់គ្រប់គ្រាន់សម្រាប់ឱ្យកូនៗរបស់គាត់ ទៅរៀន ហើយគាត់បារម្ភថា កូនៗអាចនឹងត្រូវឈប់រៀននៅពេលអនាគត។ គាត់ត្រូវឱ្យប្រាក់ទៅកូនយ៉ាងហោចណាស់ក៏ ៥,០០០រៀលក្នុងមួយថ្ងៃ ដើម្បីពួកគេទៅរៀន។ ថ្ងៃខ្លះដែលគាត់គ្មានលុយឱ្យកូនទេ នោះកូនៗមិនទៅរៀនទេ។

គ្រួសារដែលត្រូវគេបណ្ដេញចេញជាច្រើនមានជីវភាពក្រីក្រ ដូច្នេះពួកគាត់ត្រូវតែចាត់ជាអាទិ៍ភាពលើការចំណាយ។ គ្រួសារខ្លះដែលបានផ្ដល់បទសម្ភាសន៍ដល់ OHCHR បាននិយាយថា ម្ហូបអាហារមានអាទិភាព ជាងការរៀនសូត្ររបស់កូនៗ។ គ្រួសារទាំងនោះ ក៏ប្រហែលជាត្រូវបែរទៅរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាលដែរ។ ឧទាហរណ៍ នៅសាលាបឋមសិក្សា គោករកា(ឬវត្តជុំ) នៅក្បែរអណ្ដូង ចំនួនសិស្សដែលចុះឈ្មោះចូលរៀនបានធ្លាក់ចុះពី ៨៧០នាក់ក្នុងឆ្នាំ សិក្សា២០០៧-២០០៨ មកនៅ ៦៩៧នាក់ សម្រាប់ឆ្នាំសិក្សា ២០០៩-២០១០។[១១៧] ចំនួនសិស្សធ្លាក់ចុះនៅសាលារដ្ឋ នេះប្រហែលជាបណ្ដាលមកពីក្រុមគ្រួសារ ចាកចេញពីកន្លែង តាំងទីលំនៅថ្មី ឬដោយសារការសម្រេចចិត្ដនាំ កូនៗរបស់ពួកគាត់ទៅរៀននៅតាមអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើសកម្មភាពនៅ ភូមិអណ្ដូង ដូចជា អង្គការក្ដីសង្ឃឹមនៃកម្ពុជា អង្គការអភិវឌ្ឍន៍ប្រជាជនកម្ពុជា និងវិហារកូរ៉េ។ ជាក់ស្ដែង សាលារៀនរបស់អង្គការអភិវឌ្ឍន៍ប្រជាជនកម្ពុជា មានសិស្សចំនួន២១០នាក់ ក្នុងឆ្នាំសិក្សា (២០០៩-២០១០) ហើយមានផ្ដល់អាហារពេលព្រឹកដល់កុមារ ដើម្បីកុំឱ្យសិស្សបោះបង់ការសិក្សាដោយសារភាពស្រេកឃ្លាន។[១១៨]

### *កិច្ចសម្របសម្រួលក្នុងចំនោមអាជ្ញាធរ*

ការលំបាកជាច្រើនដែលគ្រួសារប្រជាពលរដ្ឋបានជួបប្រទះ ក្នុងការធានាអោយកូនបានទៅរៀន គួរតែអាចដោះស្រាយបាន តាមរយៈការសម្របសម្រួលអោយបានប្រសើរឡើងរវាងស្ថាប័នមានពាក់ព័ន្ធនានា និង រវាងមន្ទីរ/ការិយាល័យពាក់ព័ន្ធនៃក្រសួង/ស្ថាប័នមានសមត្ថកិច្ច។ ការសម្របសម្រួលខ្លះហាក់ដូចជាបានកើតឡើងរួចទៅហើយនៅថ្នាក់រាជធានីនៅភ្នំពេញ: តំណាងមន្ទីរអប់រំ ត្រូវបានគេអញ្ជើញឱ្យចូលរួមកិច្ចប្រជុំរៀបចំដោយសាលារាជធានីភ្នំពេញ ក្នុងអំឡុងពេលជិតដល់ថ្ងៃបណ្ដេញចេញ ដើម្បីពិភាក្សាអំពីបញ្ហាពាក់ព័ន្ធនឹងការអប់រំ ដូចជា ការផ្ទេរកូនរបស់ក្រុមគ្រួសារដែលទទួលរងផលប៉ះពាល់ពីការបណ្ដេញចេញការត្រៀមថ្នាក់រៀនសម្រាប់សិស្ស ឬតម្រូវការសាងសង់អគារសិក្សាថ្មី នៅតាមកន្លែងតាំងទីលំនៅថ្មី។[១១៩] ទោះជាយ៉ាងនេះក្ដី វាហាក់ដូចជាគ្មានផែនការសកម្មភាពសមស្របណាមួយ ត្រូវបានឯកភាពគ្នាទេ នៅពេលប្រជុំនោះ ហើយមិនច្បាស់ថាតើមានកិច្ចការអ្វីបន្ទាប់មកទៀតដែលបានធ្វើ ឬតំរូវអោយអនុវត្តបន្ទាប់ពីកិច្ចប្រជុំ។

[១១៧] បទសម្ភាសន៍ជាមួយបុគ្គលិកសិក្សា(សូមមិនបញ្ចេញឈ្មោះ)។

[១១៨] បទសម្ភាសន៍ជាមួយ លោក ហង្ស អប្រាហាំស៊ីមទីង អគ្គនាយកអង្គការ DPC ។

[១១៩] ក្រោមការសម្របសម្រួលពីមន្ទីរអប់រំថ្នាក់រាជធានី និង សាលារាជធានីភ្នំពេញ សាលាបឋមសិក្សាមួយត្រូវបានកសាងឡើង នៅលើទីតាំងក្នុងត្រពាំងអញ្ចាញ ។ អាគារមួយមានបីថ្នាក់ (ថ្នាក់ទី ៧ ទី៨ និងទី៩) ត្រូវបានកសាងនៅក្នុងបរិវេណនៃសាលា បឋមសិក្សាត្រពាំងសាលា ក្នុងឆ្នាំ ២០១០ ដើម្បីទទួលសិស្សកម្រិតអនុវិទ្យាល័យ ដោយមានមូលនិធិពី សាលារាជធានីភ្នំពេញ និង ក្រុមហ៊ុន7 NG សម្រាប់ប្រជាពលរដ្ឋដែលបានផ្លាស់ប្ដូរទីតាំងទៅនៅដំណាក់ត្រយឹង ។ បទសម្ភាសន៍ជាមួយលោក ឯម ហាំយួន ។

[១២០] បទសម្ភាសន៍ជាមួយលោក ឯម ហាំយួន ។

ដំណើរការនៃការផ្ទេរសិស្សពីសាលារៀនមួយទៅសាលារៀនមួយទៀត មិនប្រព្រឹត្តទៅដោយស្វ័យប្រវត្តិទេ គឺក្រុមគ្រួសារដែលរងការប៉ះពាល់ពីការបណ្តេញចេញ ត្រូវតែធ្វើសំណើរសុំផ្ទេរ សាលារៀនអោយកូនរៀងៗខ្លួន។ តំណាងមន្ទីរអប់រំ បានបញ្ជាក់ថា ឪពុកម្តាយក្មេងជាអ្នកជ្រើសរើសសាលារៀននៅជិតៗកន្លែងតាំងទីលំនៅថ្មី ដែលពួកគាត់ចង់ផ្ទេរកូន ដូច្នេះហើយ ពួកគាត់ត្រូវដំណើរការការផ្ទេរនេះដោយខ្លួនឯង។ ជាគោលការណ៍ ឪពុកម្តាយមិនចាំបាច់ទទួលឯកសារអ្វីបន្ថែមទៀតទេ ពីព្រោះពួកគាត់ត្រូវបានចាត់ទុកថាស្ថិតក្នុងស្ថានភាពបន្ទាន់។ សាលារៀននៅតាមមូលដ្ឋាននៅជិតកន្លែងតាំងទីលំនៅថ្មីត្រូវបានជូនដំណឹងជាមុន ហើយមន្ទីរឬការិយាល័យអប់រំ គប្បីដំណើរការផ្ទេរសិស្សដោយមិនបង់ថ្លៃ។ [១២០]

ក្នុងការអនុវត្តជាក់ស្តែង វាមិនច្បាស់ទេថា មន្ទីរឬការិយាល័យអប់រំ បានជូនដំណឹងទៅសាលារៀននៅតាមមូលដ្ឋាន នៅមុនពេលមានការបណ្តេញចេញ អំពីការហូរចូលនូវចំនួនក្មេងជាច្រើននាក់មកក្នុងតំបន់នៃកន្លែងតាំងទីលំនៅថ្មី ឬបានជួយឧបត្ថម្ភដល់សាលារៀននៅតំបន់នោះ ឬក៏បានជួយដល់ឪពុកម្តាយក្មេងតាមវិធីណាមួយដែរឬទេ។ ក្រុមគ្រួសារដែលបានផ្តល់បទសម្ភាសន៍ តែងតែនិយាយថា ពួកគាត់ស្វែងរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ដើម្បីអោយជួយផ្ទេរសាលារៀនដល់កូនរបស់ខ្លួន។ បុគ្គលិកមកពីសាលារៀនមួយដែលបានផ្តល់បទសម្ភាសន៍ ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលដែលបានសម្របសម្រួលដំណើរការផ្ទេរសិស្សនៅតាមកន្លែងតាំងទីលំនៅថ្មីជាច្រើនកន្លែង បានបញ្ជាក់ថា ទាំងការិយាល័យអប់រំស្រុក ទាំងសាលារៀននៅមូលដ្ឋាន មិនបាន ទទួលដំណឹង ឬទំនាក់ទំនងអ្វីពីមន្ទីរអប់រំពាក់ព័ន្ធ ឬពីអាជ្ញាធរដទៃទៀត ដើម្បីត្រៀមលក្ខណៈជាមុន ចំពោះការផ្ទេរកូនសិស្សក្នុងចំនួនច្រើន មកសាលារៀនរបស់ខ្លួន នោះទេ។ ការផ្ទេរសិស្សភ្លាមៗក្នុងចំនួនច្រើន ជាបន្ទុកយ៉ាងធ្ងន់លើបុគ្គលិកសិក្សានៅតាម សាលារៀនមូលដ្ឋាន ពីព្រោះសាលាមិនបានទទួលជំនួយបន្ថែម ដើម្បីឆ្លើយតបទៅនឹងចំនួនសិស្សយ៉ាងច្រើនបែបនេះទេ។

ដោយមានការសម្របសម្រួលពីអង្គការមិនមែនរដ្ឋាភិបាល និងរយៈពេលជាច្រើនខែក្រោយការបណ្តេញចេញ នាយកសាលានៃសាលារៀនដែលនៅជិតកន្លែងតាំងទីលំនៅថ្មីមួយក្រោមការសិក្សានេះ បានទទួលបញ្ជីឈ្មោះសិស្ស ពីមន្ទីរអប់រំក្រុងដែលជូនដំណឹងថា មានសិស្សជាងមួយរយនាក់បន្ថែមទៀត ដែលគាត់ត្រូវទទួលឱ្យចូលរៀននៅក្នុងសាលារបស់គាត់។ លំហូរចូលបែបនេះ បានបង្កើនចំនួនសិស្សក្នុងមួយថ្នាក់ៗពី ៤០ភាគរយ ទៅ ៥០ភាគរយ ធ្វើអោយចំនួនសិស្សសរុបនៅក្នុងសាលានេះកើនឡើងយ៉ាងខ្លាំងនៅឆ្នាំសិក្សាថ្មី ។

## ៥.៨ បញ្ហាផ្នែកស៊ីវិល និង រដ្ឋបាល

ការផ្លាស់ប្តូរទីតាំងថ្មី បណ្តាលអោយគ្រួសារប្រជាពលរដ្ឋជាច្រើនគ្រួសារ ជួបប្រទះនឹងការលំបាកជាច្រើន ក្នុងការសុំសៀវភៅស្នាក់នៅ និងធ្វើអត្តសញ្ញាណប័ណ្ណ ការកែរតំរូវ ឬផ្លាស់ប្តូរព័តមានក្នុងសៀវភៅគ្រួសារ និង ការផ្ទេរឈ្មោះបោះឆ្នោតចូលបញ្ជីឈ្មោះអ្នកបោះឆ្នោត។ គ្មានការផ្តល់ជំនួយលើផ្នែកនេះទេ ប្រជាពលរដ្ឋត្រូវតែដំណើរការសុំឯកសារទាំងអស់នេះដោយខ្លួនឯង ដែលជាទូទៅ គឺត្រូវទៅរកអាជ្ញាធរមូលដ្ឋាន ទាំងអជ្ញាធរនៅកន្លែងរស់នៅមុនការបណ្តេញចេញ និងនៅកន្លែងតាំងទីលំនៅថ្មី។

# ជំពូកទី៥ ៖ ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី



ប្រជាពលរដ្ឋដែលបានផ្តល់បទសម្ភាសន៍ បានត្អូញត្អែរអំពីលក្ខណៈដ៏គួរឱ្យធុញទ្រាន់ នៃដំណើរការនេះ។ ពួកគាត់មានអារម្មណ៍ថា អាជ្ញាធរគួរតែ ជួយពួកគាត់ក្នុងការរៀបចំឯកសារ ដែលត្រូវការចាំបាច់ទាំងអស់នេះសំរាប់ពួកគាត់ ពីព្រោះការផ្លាស់ប្តូរទីលំនៅនេះមិនបាន ប្រព្រឹត្តទៅដោយស្ម័គ្រចិត្តនោះទេ។ ឧទាហរណ៍ដូចជា ដំណើរការតាមនីតិវិធីធម្មតា សម្រាប់ ប្រជាពលរដ្ឋ ក្នុងការសុំសៀវភៅស្នាក់នៅថ្មី គឺ មេគ្រួសារ ឬសាមីជន ត្រូវយកលិខិតអនុញ្ញាតផ្លាស់ប្តូទីលំនៅ និងតារាងសំរង់សមាជិកគ្រួសារ ដែលចេញដោយប៉ុស្តិ៍នគរបាលរដ្ឋបាលនៅកន្លែងរស់នៅមុន ទៅបង្ហាញប៉ុស្តិ៍នគរបាលរដ្ឋបាលជាកន្លែងដែលខ្លួន ទៅស្នាក់នៅថ្មីដោយភ្ជាប់ទៅជាមួយនូវសៀវភៅគ្រួសារបើមាន។ ចំពោះការកែរតំរូវ ឬផ្លាស់ប្តូរព័តមានក្នុងសៀវភៅគ្រួសារគឺមេគ្រួសារ ឬសាមីជន ដែលបានផ្លាស់ប្តូរទីលំនៅត្រូវតែយកសៀវភៅគ្រួសារ ដែលមានចុះហត្ថលេខានិងបោះត្រារបស់ប៉ុស្តិ៍នគរបាលរដ្ឋបាល និងប្រធានគណៈកម្មាការត្រួតពិនិត្យផ្តល់សៀវភៅគ្រួសារឃុំ/សង្កាត់នៅកន្លែងដើមយកមកបង្ហាញប៉ុស្តិ៍នគរបាលរដ្ឋបាល និងប្រធានគណៈកម្មាការត្រួតពិនិត្យផ្តល់សៀវភៅ គ្រួសារឃុំ/សង្កាត់ នៅកន្លែងដែលខ្លួនទៅស្នាក់នៅថ្មី ដើម្បីចុះហត្ថលេខានិងបោះត្រាទទួលស្គាល់ការផ្លាស់មកនៅ។[១២១]

ប្រជាពលរដ្ឋផ្សេងទៀតដែលបានផ្តល់បទសម្ភាសន៍ បានត្អូញត្អែរថា ពួកគាត់តែងតែត្រូវគេទាមទារឱ្យបង់ប្រាក់ក្រៅផ្លូវការដើម្បីទទួលបានឯកសារ ឬដើម្បីទទួលបានការចុះហត្ថលេខាយល់ព្រមលើឯកសារ។ ឧទាហរណ៍ ដើម្បីផ្ទេរឈ្មោះបោះឆ្នោតចូលទៅក្នុង បញ្ជីអ្នកបោះឆ្នោតនៅឃុំសង្កាត់នៃកន្លែងតាំងទីលំនៅថ្មី ប្រជាពលរដ្ឋត្រូវតែទៅការិយាល័យ ឃុំ/សង្កាត់ដើម ដើម្បីសុំលុបឈ្មោះពីបញ្ជីអ្នកបោះឆ្នោត បន្ទាប់មកទៀតត្រូវទៅការិយាល័យ ឃុំ/សង្កាត់នៅកន្លែងតាំងទីលំនៅថ្មី ដើម្បីសុំចុះឈ្មោះបោះឆ្នោត។ ប្រជាពលរដ្ឋបានត្អូញត្អែរ ថាពួកគាត់ត្រូវបានមន្ត្រីទាំងនៅកន្លែងដើម និងកន្លែងថ្មី ទាមទារអោយបង់ប្រាក់ពី ២០ដុល្លារ ទៅ៣០ដុល្លារ ។ អ្នកដែលគ្មានលទ្ធភាពបង់ប្រាក់ គ្មានជម្រើសអ្វីផ្សេងទេ ហើយមិនអាចផ្ទេរឈ្មោះរបស់ពួកគាត់និងទទួលបានឯកសារទេ។

ស្ថានភាពដូចគ្នានេះដែរ កើតមានចំពោះការសុំអត្តសញ្ញាណប័ណ្ណ។ ដែលប្រជាពលរដ្ឋត្រូវតែសុំអោយមន្ត្រីនគរបាលមានសមត្ថកិច្ចនៅមូលដ្ឋានពិនិត្យសំណុំបែបបទ ដើម្បីចេញអត្តសញ្ញាណប័ណ្ណ។ ប្រជាពលរដ្ឋដែលបានផ្តល់បទសម្ភាសន៍បានរាយការណ៍ថា ពួកគាត់ត្រូវបានគេទាមទារឱ្យបង់ប្រាក់ក្រៅផ្លូវការរហូតដល់ ១០០ដុល្លារ ដើម្បីទទួលបានអត្តសញ្ញាណប័ណ្ណ ហើយនៅក្នុងស្ថានភាពបែបនេះ ប្រជាពលរដ្ឋខ្លះសម្រេចចិត្តមិន ធ្វើអត្តសញ្ញាណប័ណ្ណនេះទេ។ ប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ ត្រូវទៅធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលជាលក្ខខ័ណ្ឌកំណត់ដោយ

[១២១] សូមមើល សេចក្តីណែនាំបន្ថែមស្តីពី "ការចុះបញ្ជី និងការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ" របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ចុះ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០០៤ និង ប្រកាសលេខ ៥៦៧ របស់ក្រសួងមហាផ្ទៃ ស្តីពី"សៀវភៅស្នាក់នៅ" ចុះថ្ងៃទី២២ ខែវិច្ឆកា ឆ្នាំ១៩៩៧។

[១២២] ប្រកាសរបស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពី "នីតិវិធី ល័ក្ខខ័ណ្ឌ នៃការសុំ ការផ្តល់ ការប្រើប្រាស់ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ" កំណត់ថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅត្រូវទៅធ្វើ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនៅសាលាឃុំសង្កាត់ ឬនៅតាមស្ថានីយចល័តនៃឃុំសង្កាត់របស់ខ្លួន (ប្រការ ១(។ ពាក្យសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវតែមានឯកសារភ្ជាប់មកជាមួយ ដូចជា សំបុត្រកំណើត សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ឬឯកសារឬភស្តុតាងផ្លូវការផ្សេងៗទៀត+ប្រការ ២(។ អ្នកដាក់ពាក្យសុំត្រូវបង់ថ្លៃពន្ធអាករ ទៅតាម សេចក្តីប្រកាសអន្តរក្រសួង នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ ។

ច្បាប់។ មន្ត្រីឬភ្នាក់ងារ មានសមត្ថកិច្ច ត្រូវតែធានាថា ប្រជាពលរដ្ឋអាចទទួលបានអត្តសញ្ញាណប័ណ្ណនេះដោយគ្មាន ការលំបាក និង ត្រូវគោរពតាមនីតិវិធី និងតំលៃពន្ធអាករដែលកំណត់ជាផ្លូវការ។ [១២២]

ការបង្ហាញសៀវភៅគ្រួសារ ឬអត្តសញ្ញាណប័ណ្ណ ជាលក្ខខ័ណ្ឌតម្រូវ ដើម្បីធ្វើការងារនៅតាម ក្រុមហ៊ុនផ្សេងៗ ដូចជា នៅរោងចក្រកាត់ដេរជាដើម។ វាក៏ជាលក្ខខ័ណ្ឌតម្រូវមួយដែរសម្រាប់អ្នកមានសិទ្ធិបោះឆ្នោត ក្នុងការចុះឈ្មោះរបស់ពួកគេក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត នៅតាមឃុំសង្កាត់របស់ខ្លួន។ ដូច្នេះការខ្វះឯកសារជាឧបសគ្គសម្រាប់ប្រជាពលរដ្ឋ ក្នុងការរកការងារធ្វើ ឬរារាំងពួកគេមិនឱ្យចុះឈ្មោះបោះឆ្នោតបាន។ ការអង្កេតថ្មីមួយដែលធ្វើឡើង ដោយគណៈកម្មាធិការសម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ (ខុមហ្វ្រែល) បានបញ្ជាក់អះអាងអំពីបញ្ហានេះ។ ក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោតដែលបានផ្តល់បទសម្ភាសន៍ ដែលមិន បានទៅចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោតថ្មី (២៧.៨៧ភាគរយ) មាន១៦.១៨ភាគរយ មិនបានទៅចុះឈ្មោះបោះឆ្នោត ដោយសារមិនមានឯកសារតំរូវ ដូចជា អត្តសញ្ញាណ និង សៀវភៅស្នាក់នៅជាដើម។[១២៣]

ក្រុមគ្រួសារដែលទទួលបានផ្ទះល្វែងពីក្រុមហ៊ុន7NG នៅដំណាក់ត្រយឹង កំពុងជួបការលំបាកដោយសារពួកគេបានប្រគល់ប័ណ្ណ និង សៀវភៅស្នាក់នៅ និង/ឬ សៀវភៅគ្រួសារទៅក្រុមហ៊ុនជាការប្តូរយកលិខិតបញ្ជាក់ទទួលស្គាល់ការផ្ទេរសិទ្ធិកាន់កាប់ផ្ទះល្វែង (សូមមើលឧបសម្ព័ន្ធទី២) ពីក្រុមហ៊ុន7NG ។ ក្រុមហ៊ុននេះ ហាក់ដូចជាគ្មានបំណងប្រគល់ឯកសារទាំងនោះមកឱ្យប្រជាពលរដ្ឋវិញទេ។

ទីបំផុត ការធ្វើអង្កេតថ្មីៗនេះរបស់ខុមហ្វ្រែល បានបង្ហាញអំពីការលំបាកដែលប្រជាពលរដ្ឋជាអ្នកផ្លាស់ប្តូរទីលំនៅថ្មី ដែលមានសិទ្ធិបោះឆ្នោតបានជួបប្រទះ។ ប្រជាពលរដ្ឋទាំងនេះភាគច្រើន ដែលបានផ្តល់បទសម្ភាសន៍(៧២.១៣ភាគរយនៃអ្នកផ្តល់បទសម្ភាសន៍ទាំងអស់) បានព្យាយាមទៅចុះឈ្មោះបោះឆ្នោតនៅឃុំសង្កាត់ នៃកន្លែងតាំងទីលំនៅថ្មី។[១២៤] ក្នុងចំណោមអ្នកដែលបានចុះឈ្មោះបោះឆ្នោតជាផ្លូវការនៅកន្លែងតាំងទីលំនៅថ្មី មាន ២៥ភាគរយ មិនមានឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការឆ្នាំ២០០៩ទេ ដែលនេះមានន័យថាពួកគេនឹងមិនអាចទៅបោះឆ្នោតបានទេ ក្នុងការបោះឆ្នោតលើកក្រោយនេះ។[១២៥] នៃកឯក្នុងចំណោមអ្នកមានសិទ្ធបោះឆ្នោត ដែលមិនបានទៅចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោតថ្មីនោះ មាន ៥១.៤៧ភាគរយ មិនបានទៅចុះឈ្មោះពីព្រោះតែខ្វះព័ត៌មានទាក់ទងនឹងការចុះឈ្មោះនៅ



[១២៣] របាយការណ៍ស្រាវជ្រាវអង្គការខុមហ្វ្រែល "ការអង្កេតទៅលើអ្នកមានសិទ្ធិបោះឆ្នោតដែលផ្លាស់ ទីលំនៅដោយបង្ខំ អ្នកផ្ទុក មេរោគអេដ៍ និងអ្នកជំងឺអេដ៍ ក្នុងការចុះឈ្មោះបោះឆ្នោត" (ខែឧសភា ឆ្នាំ២០១០)[ចាប់ពីពេលនេះទៅហៅ ខុមហ្វ្រែល], ទំព័រ៩។

[១២៤] ក្នុងចំណោម ៧២.១៣ភាគរយនៃអ្នកដែលត្រូវបានបណ្តេញចេញ ដែលបានទៅចុះឈ្មោះបោះឆ្នោត មាន ១.១៩ភាគរយ ត្រូវបានគេបដិសេធមិនចុះឈ្មោះអោយទេ ដោយសារខ្វះឯកសារ, ខុមហ្វ្រែល។

[១២៥] នៃចំនួនអ្នកបោះឆ្នោត ដែលបានមកតាំងទីលំនៅថ្មី ៥៨.២ភាគរយ ដែលមានឈ្មោះនិងព័តមានក្នុងបញ្ជីអ្នកបោះឆ្នោត ឆ្នាំ២០០៩, មាន១៦.៨ភាគរយ មានព័តមានអំពីអាស័យដ្ឋាន ខុសពីអាស័យដ្ឋានដែលខ្លួនកំពុងរស់នៅបច្ចុប្បន្ន ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត, និង២៥ភាគរយទៀត មិនឃើញមានឈ្មោះរបស់គាត់នៅក្នុងបញ្ជីផ្លូវការទេ, ខុមហ្វ្រែល ទំព័រ១១។

[១២៦] សូមមើល Michael M. Cernea "គ្រោះថ្នាក់ និង ការរៀបចំធ្វើឡើងវិញ: គំរូសម្រាប់ការចាកចេញដោយបង្ខំចិត្តរបស់ប្រជាពលរដ្ឋ និង ការតាំងលំនៅដ្ឋានថ្មី" មានក្នុង: Michael M. Cernea and Christopher McDowell (eds.) "គ្រោះថ្នាក់ និង ការរៀបចំធ្វើឡើងវិញ: បទពិសោធន៍នៃការតាំងទីលំនៅថ្មី និងជនភៀសខ្លួន" (The World Bank: Washington, DC, ឆ្នាំ២០០០)

តំបន់តាំងទីលំនៅថ្មី។

## ៥.៩ ការចូលរួមរបស់សហគមន៍ និង សមាហរណកម្មទៅក្នុងសង្គម

ការកសាងសហគមន៍ឡើងវិញ ក៏ដូចជាការចូលរួមរបស់សហគមន៍ និងសមាហរណកម្ម ទៅក្នុងសង្គម នៅកន្លែងតាំងទីលំនៅថ្មី មានសារៈសំខាន់ជាចាំបាច់សម្រាប់ការអភិវឌ្ឍន៍។ ប៉ុន្តែការអនុវត្តបែបនេះ កម្រនឹងត្រូវគេយកមកអនុវត្តណាស់ នៅពេលតាំងទីលំនៅថ្មី។[១២៦]

### *ការចូលរួម និងការរួបរួមគ្នារបស់សហគមន៍*

នៅពេលដែលសហគមន៍ បានតាំងទីលំនៅថ្មី ជាទូទៅសហគមន៍នៅតែទន់ខ្សោយ និងគ្មានការចងក្រងគ្នាទេ ដែលតែងតែជាលទ្ធផលនៃភាពបែកបាក់គ្នា ក្នុងកំឡុងពេលចរចារមុនពេលបណ្តេញចេញ ។ ទោះបីជាសមាជិកសហគមន៍ចេះជួយគ្នាចែករំលែក ឬខ្ចីស្បៀងអាហារ ពីគ្នាទៅវិញទៅមក និងទទួលស្គាល់ថា ពួកគាត់ទាំងអស់គ្នាកំពុងជួបប្រទះការលំបាកដូចគ្នាក៏ដោយ ក៏ការគាំទ្រគ្នាក្នុងសហគមន៍គ្មានភាពរឹងមាំទេ និងមានបណ្តាញជួយគ្នាទៅវិញទៅមកតិចតួចណាស់ លុះត្រាតែមានអង្គការមិនមែនរដ្ឋាភិបាល ជួយរៀបចំសកម្មភាពសហគមន៍។ ទាំងបុគ្គលម្នាក់ៗ និងសហគមន៍ទាំងមូលមិនមានបំណងចូលរួមធ្វើការទាមទារ ឬធ្វើផែនការលើកកម្ពស់លក្ខខ័ណ្ឌរស់នៅរបស់ពួកគេ នៅតាមកន្លែងតាំងទីលំនៅថ្មីទេ។

ចំពោះភាពទន់ខ្សោយ និងភាពបែកបាក់បែបនេះ អាជ្ញាធរមិនបានទំនុកបំរុងដល់សហគមន៍ទេ ហើយបានបង្ហាញពីគំនិតផ្តួចផ្តើមតិចតួចក្នុងការពិគ្រោះយោបល់ជាមួយសហគមន៍ និងបញ្ចូលសហគមន៍ក្នុងផែនការគម្រោងលំនៅដ្ឋាន ឬការកែលំអរហេដ្ឋារចនាសម្ព័ន្ធនៅនឹង កន្លែងតាំងទីលំនៅថ្មី។ អណ្តូង និង គំរោងប្រាក់កម្ចីសំរាប់សាងសង់លំនៅដ្ឋាន គឺជាករណីដែលត្រូវពិភាក្សា (សូមមើលប្រអប់លេខ៩)។ ករណីសហគមន៍ អភិវឌ្ឍន៍មានជ័យ គឺជាករណីលើកលែង ពីព្រោះកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ ក្នុងការរៀបចំ និងចូលរួមក្នុងដំណើរការនៃការតាំងទីលំនៅថ្មីរបស់ពួកគាត់ ត្រូវបានជំរុញនិងលើកទឹកចិត្តដោយភាគីពាក់ព័ន្ធទាំងអស់ (សូមមើលប្រអប់លេខ៧)។

ជាគោលការណ៍ សហគមន៍មានការរៀបចំបានល្អ តាមរយៈតំណាងរបស់ខ្លួន ក៏ប៉ុន្តែការអនុវត្តជាក់ស្តែងតំណាងទាំងនោះ ជាទូទៅមិនបម្រើគោលបំណងរបស់សហគមន៍ទាំងមូលទេ។ តំណាងសហគមន៍ត្រូវបានគេមើល ឃើញថាមានជាប់ពាក់ព័ន្ធជាមួយអាជ្ញាធរ ឬក្រុមហ៊ុន និងធ្វើកិច្ចការនៅកន្លែងតាំងទីលំនៅថ្មី ដោយមិនមានភាពស្មោះត្រង់ជាមួយសមាជិកសហគមន៍ទេ។ ប្រជាពលរដ្ឋដែលបានផ្តល់បទសម្ភាសន៍នៅកន្លែងតាំងទីលំនៅថ្មី លើកលែងតែសហគមន៍អភិវឌ្ឍន៍មានជ័យ ស្ពានឆេះ អូរកម្ពុជា បាននិយាយថា តំណាងសហគមន៍ ជាអ្នកបង្កបញ្ហានិងការលំបាកផ្សេងៗ ជាជាងជួយសហគមន៍។ តំណាងសហគមន៍មិនដែលរៀបចំកិច្ចប្រជុំជាមួយសមាជិកសហគមន៍ ដើម្បីពិភាក្សាអំពីបញ្ហាកង្វល់នានាដែលប៉ះពាល់ សហគមន៍ទេ ។ លើសពីនេះទៀត គេបានចោទប្រកាន់ថា តំណាងសហគមន៍ ទទួលប្រាក់សំណូក និង មានការគាំទ្រពីអាជ្ញាធរ ។ ជាក់ស្តែងនៅអណ្តូង តំណាងសហគមន៍ ដែលធ្វើសេចក្តីសម្រេចលើកិច្ចការភាគច្រើននៅលើទីតាំងនេះ ត្រូវបានគេនិយាយថាបានផ្តល់ដីឡូតិ៍ ឱ្យទៅអ្នកដែលមិនមានការទទួលស្គាល់ជាផ្លូវការ ឬ ឱ្យទៅអ្នកខាងក្រៅជាថ្នូរនឹងប្រាក់សំណូក។

### *សមាហរណកម្មទៅក្នុងសហគមន៍មូលដ្ឋាន*

ក្នុងករណីខ្លះ ភ្លាមៗក្រោយពីការផ្លាស់ប្តូរទីតាំងថ្មី របស់ក្រុមប្រជាពលរដ្ឋចូលទៅក្នុងតំបន់ណាមួយ ប្រជាពលរដ្ឋមូលដ្ឋានដែលកំពុងរស់នៅតំបន់ជុំវិញទីតាំងនោះ មានអារម្មណ៍មិនល្អទេហើយបារម្ភអំពីសុវត្ថិភាព និងសន្តិសុខ នៅក្នុងភូមិរបស់គាត់ និងគិតឃើញដោយលំអៀងចោទប្រកាន់ចំពោះគ្រួសារប្រជាពលរដ្ឋដែលបានផ្លាស់មករស់នៅទីតាំងថ្មី។

ជាក់ស្តែងនៅភូមិអណ្តូង យោងតាមប្រធានភូមិអណ្តូងបានអោយដឹងថា សហគមន៍មូលដ្ឋានពីដំបូង បានចាត់ទុកគ្រួសារប្រជាពលរដ្ឋដែលផ្លាស់មករស់នៅទីតាំងថ្មីថាសុទ្ធតែជាចោរ។ ប៉ុន្តែប៉ុន្មានឆ្នាំកន្លងមកនេះ ឥរិយាបថប្រកាន់ និងអារម្មណ៍ភ័យខ្លាចបានរលាយអស់ហើយ ហើយគ្រួសារសហគមន៍អណ្តូង និងសហគមន៍មូលដ្ឋានរាប់រកគ្នាសំរាប់សកម្មភាពសង្គមផ្សេងៗ និងមានការរៀបអាពាហ៍ពិពាហ៍រវាងកូនៗរបស់សហគមន៍ទាំងពីរផង។

មានឥរិយាបថប្រកាន់នឹងក្រុមគ្រួសារអ្នកជំងឺអេដស៍ ដែលបានផ្លាស់មករស់នៅទួលសំបូរផងដែរ។ ភ្លាមៗបន្ទាប់ពីការតាំងទីលំនៅថ្មី គ្រួសារអ្នកជំងឺអេដ៍ បានត្អូញត្អែរអំពី អារម្មណ៍ ដែលត្រូវគេគិតថាជាមនុស្សអសោចកេរ្តិ៍ និង មានការរើសអើងចំពោះ ស្ថានភាពជំងឺអេដស៍ របស់ពួកគាត់។ ប្រជាពលរដ្ឋ និងមន្ត្រីមូលដ្ឋានមួយចំនួនបានហៅកន្លែងតាំងទីលំនៅថ្មីនោះ ថា "ភូមិអេដស៍" ហើយមានករណីរាយការណ៍ពីការប្រមាថ និងការដេញចេញ។[១២៧] ក៏ប៉ុន្តែរយៈពេលច្រើនខែកន្លងមកនេះ គ្រួសារអ្នកជំងឺអេដស៍បានធ្វើសមាហរណកម្មទៅក្នុង សហគមន៍កាន់តែទូលំទូលាយ ដោយសារតែកិច្ចខិតខំគួរឱ្យកត់សម្គាល់របស់អង្គការCenter of Hope និង អង្គការ Caritas។ បទពិសោធន៍បានបង្ហាញថា ជាភាពឆ្លាតវៃមួយដែល អាចធ្វើបានទោះជានៅពេលណាក៏ដោយ ត្រូវអនុញ្ញាតអោយមានការចែករំលែកឱកាសនានា ដែលបានផ្តល់ទៅអោយគ្រួសារផ្លាស់ទីលំនៅថ្មី ជាមួយសហគមន៍ដែលរស់នៅផ្ទាល់ជាមួយ គ្រួសារទាំងនេះ ឬសហគមន៍ជិតខាង ហើយវាក៏ជាបំណងនៃការធ្វើសមា

[១២៧] ប្រជាពលរដ្ឋដែលផ្តល់សម្ភាសន៍បានិយាយថា នៅពេលដែលពួកគេទៅផ្សារ ឬដើរតាមផ្លូវ នៅទួលសំបូរ ពួកគាត់ឃើញអ្នកភូមិទួលសំបូរ ក្រលេកមើលមកពួកគាត់ក្នុងភាពជាសត្រូវ និយាយខ្សឹបខ្សៀវគ្នា ធ្វើកាយវិការ ។ល។ ដើម្បីមាក់ងាយពួកគាត់ ពីព្រោះពួកគាត់ជាអ្នកជំងឺអេដស៍ ។ គ្រួសារពីរ ដែលមានកូនស្រីរបស់ពួកគាត់ទៅផ្សារទិញបង្អែម ។ អ្នកភូមិទួលសំបូរមួយចំនួន បាននិយាយប្រាប់គ្នា នៅពេលពួកគេដើរឆ្លងកាត់ទីនោះ ថា ពួកគេមិនគួរទៅក្បែរ (ឬទាក់ទងជាមួយ) ក្មេងស្រីទាំងនេះទេ ពីព្រោះ ពួកគេអាចនឹងឆ្លងជំងឺ ។ ក្មេងស្រីទាំងនេះរន្ធត់ជាខ្លាំង ហើយជាលទ្ធផល ក្មេងស្រីទាំងពីរនាក់បានសម្រេចចិត្តមកនាំភ្នំពេញវិញ ។

**ប្រអប់លេខ ១៤: កិច្ចឧបត្ថម្ភគាំទ្រ របស់អង្គការCaritas ចំពោះសហគមន៍ទួលសំបូរ--ឆ្ពោះទៅរកសមាហរណកម្មសហគមន៍ និងការពឹងផ្អែកលើខ្លួនឯង[១២៨]**

បច្ចុប្បន្ន ភូមិទួលសំបូរ មានបីសហគមន៍: សហគមន៍មូលដ្ឋាន(បានតាំងទីលំនៅថ្មី នៅទីនោះក្នុងឆ្នាំ១៩៩៩-២០០០) គ្រួសារអ្នកជំងឺអេដស៍មកពីបូរីកីឡា និង ៣៩គ្រួសារដែល លំនៅដ្ឋានរបស់គាត់ត្រូវបានបំផ្លាញដោយការបាក់ច្រាំងទន្លេ ក្នុងខែមេសា ឆ្នាំ២០០៨។ កាលពីដំបូងអង្គការ Caritas បានចាប់ផ្ដើមការងារនៅទួលសំបូរ ដើម្បីផ្លាស់ប្ដូរទីលំនៅ ប្រជាពលរដ្ឋ៣៩គ្រួសារនេះ(ដែលទីបំផុតបានផ្លាស់ ទៅរស់នៅ ឯទួលសំបូរនៅ ដើមឆ្នាំ២០១០)។ អង្គការ Caritas បានធ្វើការជាមួយសហគមន៍ក្នុងការវាយ តម្លៃពីសេចក្ដីត្រូវការរបស់ពួកគាត់ ហើយក្រុមគ្រួសារទាំងនេះបានចាត់ទុកថា លំនៅដ្ឋានមានសុវត្ថិភាព គឺជាអាទិភាពរបស់ខ្លួន។ បន្ទាប់មកអង្គការ Caritas បានចុះហត្ថលេខាលើ“ កិច្ចព្រមព្រៀងភាពជាដៃគូ” មួយ ជាមួយសាលារាជធានីភ្នំពេញ ក្នុងការសាងសង់លំនៅដ្ឋាន នៅទួលសំបូរ ដែលសាលារាជធានីជាអ្នកផ្ដល់ដី រួមចំណែកក្នុងការចាក់បំពេញដី និង ធានាថា គ្រួសារប្រជាពលរដ្ឋទទួលបានប័ណ្ណកម្មសិទ្ធស្លាពរ ក្រោយរយៈពេលប្រាំឆ្នាំនៃការកាន់កាប់។ គ្រួសារប្រជាពលរដ្ឋបានឃើញទីតាំងនេះជាមុន និងបានឯកភាពយកទីតាំងនេះ។ ពួកគាត់បានធ្វើការជាមួយ អង្គការ Caritas ក្នុងការជ្រើសរើស និងរចនាប្លង់លំនៅដ្ឋានរបស់ពួកគាត់។ ពួកគាត់ក៏បានពិភាក្សា និងឯកភាពលើការផ្ដល់វិភាគទានក្នុងការចំណាយ លើការសង់លំនៅដ្ឋានរបស់ពួកគាត់ ប្រហែលជា១ដុល្លារក្នុងមួយថ្ងៃសំរាប់រយៈពេល ១៨ខែ។



ទីធ្លាសម្រាប់ក្មេងលេង,នៅទួលសំបូរ, ថ្លែងអំណរគុណចំពោះការថតរូបដោយ: karona / OHCHR



[១២៨] ព័តមានក្នុងប្រអប់នេះផ្អែកលើបទសម្ភាសន៍ជាមួយ លោក គឹម រតនា នាយកប្រតបត្តិអង្គការ Caritas ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១០ ។

# ជំពូទី៥ ៖ ការចាប់ផ្តើមជីវិតជាថ្មីឡើងវិញនៅកន្លែងតាំងទីលំនៅថ្មី

ខណៈពេលលំនៅដ្ឋានធ្វើអំពីឥដ្ឋកំពុងត្រូវបានកសាង សម្រាប់គ្រួសារប្រជាពលរដ្ឋទាំងនោះ អង្គការ Caritas បានឃើញ ប្រជាពលរដ្ឋប្រហែលជា៩៥ គ្រួសារជាអ្នកជំងឺអេដស៍ មកពីបូរីកីឡា ត្រូវផ្លាស់មករស់នៅជាប់នឹងទីតាំងលំនៅដ្ឋានថ្មីនេះដែរ នៅក្នុងសំណង់ដែលគ្មានគុណភាព និងមានទំហំតូចជាងលំនៅដ្ឋានតាមបទដ្ឋានរបស់អង្គការ Caritas។ អង្គការ Caritas និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀត និង អង្គកាសហប្រជាជាតិ បានសំដែងនូវក្តីកង្វល់អំពីហានិភ័យដែលប្រជាពលរដ្ឋអ្នកជំងឺអេដស៍នឹងប្រឈមមុខ ដូចជា ការរើសអើង និងស្ថានភាពតានតឹងជាមួយនឹងគ្រួសារមកពីច្រាំងទន្លេ និងសហគមន៍ មូលដ្ឋាន។ ពេលដែលអាជ្ញាធរ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាល បានឯកភាពគ្នា ដោះស្រាយស្ថានភាពរស់នៅរបស់គ្រួសារអ្នកជំងឺអេដ៍ ដូច្នេះ អង្គការ Caritas បានសម្រេចដាក់ទួលសំបូរជាទីតាំងអាទិភាព"ករណីបន្ទាន់" ដោយដាក់រួមគ្នាទាំងសំរាប់ ក្រុមគ្រួសារមកពីច្រាំងទន្លេ និងបូរីកីឡា។ តាមសំណើពីអង្គការ Caritas និងទីភ្នាក់ងារអង្គការសហប្រជាជាតិ សាលារាជធានីភ្នំពេញបានឯកភាពផ្តល់ដីបន្ថែមទៀត ដើម្បីសាងសង់លំនៅដ្ឋាន ហើយពង្រីកដីសហគមន៍ (ដូចជាធ្វើជាទីធ្លាកំសាន្តសំរាប់កុមារ)។ អង្គការ Caritas ក៏បានចាប់ផ្តើមគម្រោងមុខរបរចិញ្ចឹមជីវិត សម្រាប់សហគមន៍ទាំងពីរបន្ថែមទៀត ដោយផ្អែកតាមការវាយតម្លៃអំពីតម្រូវការនិងជំនាញរបស់ក្រុមគ្រួសារផ្ទាល់។ សកម្មភាពរួមរបស់សហគមន៍ទាំងពីរក៏បានរៀបចំឡើង ដែលនឹងផ្តល់ឱកាសក្នុងការផ្សព្វផ្សាយអំពីបញ្ហា មេរោគអេដ៍ និងជំងឺអេដស៍ផងដែរ។[១២៩]

ក្រោយមក នៅក្នុងឆ្នាំ២០១០ អង្គការ Caritas នឹងចាប់ផ្តើមអនុវត្តគម្រោងរយៈពេលបីឆ្នាំ ដែលមានឈ្មោះថា "គម្រោងអភិវឌ្ឍន៍រួមសហគមន៍ទួលសំបូរ" សម្រាប់ផលប្រយោជន៍របស់ ប្រជាពលរដ្ឋគ្រប់រូបនៅទួលសំបូរទាំងមូល។ អង្គការ Caritas ក៏នឹងគាំទ្រអោយមានការបោះឆ្នោតជ្រើសរើសតំណាងសហគមន៍ម្នាក់ ដែលតំណាងអោយបីសហគមន៍ សម្រាប់ភូមិទាំងមូល។ ជាការពង្រឹងសមត្ថភាពបន្ថែមតាមរយៈបទពិសោធន៍របស់ខ្លួនដែលធ្វើការមួយសហគមន៍នានានៅជនបទក្នុងខេត្តចំនួនប្រាំបួន អង្គការ Caritas ក៏មានផែនការជួយ "សមាគមន៍អភិវឌ្ឍន៍ភូមិ" ដែលជាប្រភេទសមាគម មានការស្ម័គ្រចិត្ត ស្វ័យ័ត និងភាពម្ចាស់ការរបស់អ្នកភូមិ ដែលសហគមន៍នេះនឹងបម្រើជាវេទិកា និងជាយន្តការសម្រាប់អ្នកភូមិ ដើម្បីលើកឡើងនូវកង្វល់ និងដោះស្រាយបញ្ហានានា ដែលទាក់ទងនឹងសហគមន៍ទាំងមូល។

តំណាងអង្គការ Caritas បានកត់សម្គាល់អំពីភាពសំខាន់ ដែលត្រូវមានផែនការរយៈពេលវែង សម្រាប់ ការតាំងទីលំនៅថ្មី ដែលត្រូវបានរៀបចំ និងអនុវត្តដោយតម្លាភាពយ៉ាងពេញលេញ និងដោយមានការចូលរួមយ៉ាងពេញលេញពីសហគមន៍ដែលទទួលរងផលប៉ះពាល់ ដូចជាករណីក្រុមគ្រួសារមកពីច្រាំងទន្លេដែរ ដែលសំដែងនូវសេចក្តីពេញចិត្តចំពោះការផ្លាស់ប្តូរមករស់នៅឯទួលសំបូរ។

[១២៩] សម្រាប់ថ្ងៃបុណ្យចូលឆ្នាំខ្មែរ ក្នុងខែមេសា កន្លងទៅ Caritas បានរៀបចំពិធីមួយដែលមានប្រជាពលរដ្ឋចូលរួម៥០០នាក់ ដែលពួកគាត់មកពីភូមិទួលសំបូរទាំងមូល។ Caritas បាន ពន្យល់ អំពីសារសំខាន់សម្រាប់សមាជិកសហគមន៍ឲ្យចេះធ្វើការរួមគ្នា។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អភិបាលរង ឯកឧត្តម ម៉ាន់ ឈឿន និងអាជ្ញាធរមូលដ្ឋានក៏បានសម្តែងការគាំទ្រចំពោះសហគមន៍ទាំងមូលដែរ។

### ប្រអប់លេខ១៥: ដំណើររឿងរបស់ មករា រស់នៅបុរីសន្តិភាព២ នៅដំណាក់ត្រយឹង

នៅឆ្នាំ១៩៩២ មករា បានទិញដីមួយឡូត៍ដែលមានទំហំ ៨ម គុណ ២២ម (១៧៦ម²) នៅឯដីក្រហមពីយោធាម្នាក់។ ប្រធានភូមិនិងមេឃុំបានដឹងលឺ ធ្វើជាសាក្សី និងបញ្ជាក់លើ កិច្ចសន្យាទិញលក់ដី។ ប្តីរបស់គាត់ ដែលជានគរបាល A3 បានទទួលមរណភាពនៅឆ្នាំ១៩៩២ នៅក្នុងឧប្បត្តិហេតុផ្ទុះគ្រាប់មីន។ មករា បានថែរក្សាកូនពីរនាក់ តែម្នាក់ឯង ដោយប្រកបមុខរបរជាគ្រូទាយ និងលក់ថ្នាំបុរាណខ្មែរនៅផ្ទះរបស់គាត់ផ្ទាល់។ គាត់រកចំណូលបានប្រហែលជា ១០០.០០០ រៀល(២៥ដុល្លារ) ក្នុងមួយថ្ងៃ។ ជាមួយនឹងប្រាក់ចំណូលនេះ គាត់មានអាហារគ្រប់គ្រាន់សម្រាប់កូនៗរបស់គាត់ និងអាចបញ្ជូនកូនទៅរៀនបាន។ "ខ្ញុំមិនមានទេ ប៉ុន្តែខ្ញុំក៏មិនដែលជំពាក់បំណុលគេដែរ ហើយខ្ញុំមិនដែលខ្វល់ពីរឿងថាគ្មានអ្វីអោយ កូនៗរបស់ខ្ញុំហូបនៅថ្ងៃស្អែកនោះទេ"។

កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៩ សហគមន៍ដីក្រហម មានទាំងខ្លួនគាត់ផ្ទាល់ ត្រូវបានគេបណ្តេញចេញ។" សន្តិសុខក្រុមហ៊ុននិងកងម្លាំងប្រដាប់អាវុធ បង្ខំឱ្យពួកយើងចេញពីផ្ទះរបស់ពួកយើងដោយប្រើឧស្ម័នបង្ហូរទឹកភ្នែក ធ្វើឱ្យពួកយើងទន់ដៃជើង ហើយបានប្រើ គ្រឿងចក្រឈូសបំផ្លិចបំផ្លាញផ្ទះរបស់ពួកយើង និងទ្រព្យសម្បត្តិទាំងអស់នៅខាងក្នុងផ្ទះ។ ខ្ញុំភ័យខ្លាំងពេក រហូតមិនអាចយកទ្រព្យសម្បត្តិរបស់ខ្ញុំចេញមកបានទេ។ ទ្រព្យសម្បត្តិ និងប្រាក់សន្សំ ដែលបានមកពីការខិតខំប្រឹងប្រែងរយៈពេលជាច្រើនឆ្នាំមកនោះ ត្រូវបានបំផ្លិចបំផ្លាញអស់រលីង។ ខ្ញុំគ្មានសល់អ្វីទេ" ។

នៅតំណាក់ត្រយឹង មករាទទួលបានផ្ទះមួយល្វែងទំហំ ៤០ម² ដែលមានបង្គន់នៅពី ខាងក្រៅផ្ទះ។ គាត់បាន និយាយថា "ខ្ញុំត្រូវតែបង្ខំចិត្តខ្លួនឯងទទួលយកផ្ទះនោះ ពីព្រោះខ្ញុំដឹងថា ប្រសិនបើមិនយកទេ ខ្ញុំនឹងមិនបានអ្វីទេ។ ផ្ទះល្វែងនោះមិនគួរឱ្យពេញចិត្តទេ វាហាក់ដូចជាបានសង់ដោយគ្មានគុណភាព។ ទឹកលិចតាមដំបូល នៅពេលមានភ្លៀងធ្លាក់ ហើយទ្វារងាយនឹងទម្លុះចូលណាស់។ គាត់និយាយថា "ខ្ញុំបានខ្ចីប្រាក់គេ យកមកជួសជុលកែលំអរផ្ទះ ដោយភ្ជាប់បង្គន់មកនៅក្នុងផ្ទះវិញ និងធ្វើដំបូលខាងមុខផ្ទះដើម្បីកុំឱ្យក្តៅពេក"។ គាត់ក៏បានត្អូញត្អែរអំពីតម្លៃទឹកដែលថ្លៃជាងតម្លៃកំណត់ដោយរដ្ឋាករទឹកស្វយ័ត។

ការបណ្តេញចេញប្រព្រឹត្តឡើងចំពាក់កណ្តាលបវេសនកាល និងចំឆ្នាំប្រឡងរបស់សិស្សរៀន ថ្នាក់ទីប្រាំបួន ដែលការប្រឡងប្រព្រឹត្តទៅនៅក្នុងខែកក្កដា។ ដូច្នេះ មករា ត្រូវទុកកូនឱ្យរៀន នៅសាលាដដែល ទំរាំដល់ពួកគេបញ្ចប់ការប្រឡងដោយឱ្យពួកគេរស់នៅជាមួយ បងប្អូនធម៌ របស់គាត់នៅទីក្រុង។ គ្រាន់តែកូនរបស់គាត់ប្រឡងចប់ភ្លាម គាត់បានរៀបចំផ្ទេរកូនរបស់គាត់អោយទៅរៀននៅវិទ្យាល័យជម្ពូវន្ត ដែលមានចម្ងាយ ៧គ.ម ពីដំណាក់ត្រយឹង។

មករាបានបន្តការងារដូចមុនដដែល គឺធ្វើគ្រូទាយ និងលក់ថ្នាំបុរាណខ្មែរនៅផ្ទះរបស់គាត់ នៅដំណាក់ត្រយឹង។ ឥឡូវនេះ មានអតិថិជនមករកគាត់តិចជាងមុនឆ្ងាយណាស់។ ថ្ងៃខ្លះ គាត់រកប្រាក់បានតែ ២,០០០រៀលប៉ុណ្ណោះ ហើយថ្ងៃខ្លះទៀត គាត់រកមិនបានសោះតែម្តង។ "ថ្ងៃខ្លះម៉ូយប្រចាំរបស់ខ្ញុំទូរស័ព្ទហៅខ្ញុំឱ្យទៅភ្នំពេញ ពីព្រោះពួកគេមិនចង់ធ្វើដំណើរមកដំណាក់ត្រយឹងទេ ដែលពួកគេគិតថា

ឆ្ងាយពេក។ ពេលខ្ញុំមានសុខភាពល្អ ខ្ញុំជិះម៉ូតូឌុបទៅជួបអតិថិជនរបស់ខ្ញុំ ប៉ុន្តែខ្ញុំឧស្សាហ៍ឈឺណាស់ តាំងពីការបណ្តេញចេញមក ដូច្នេះខ្ញុំមិនអាចធ្វើដំណើរទៅជាញឹកញាប់បានទេ។ ជីវិតជួបការលំបាក ខ្លាំងណាស់ ពីព្រោះចំណូលដែលខ្ញុំរកបាន វាតិចតួចពេកមិនអាចផ្គត់ផ្គង់ម្ហូបអាហារគ្រប់គ្រាន់ និង ការរៀនសូត្រដល់កូនទាំងពីរនាក់បានទេ។ ម្ហូបអាហារទិញពីផ្សារនៅទីនេះថ្លៃជាងនៅទីប្រជុំជនក្នុង ទីក្រុងទៀត។ "ខ្ញុំរកបានតិចតែ ចំណាយច្រើន"។

"ពួកយើងហូបតិចជាងមុនឆ្ងាយណាស់ បើប្រៀបធៀបនឹងពេលដែលពួកយើងនៅដីក្រហម។ ពួកយើងហូបតែបាយជាមួយទឹកស៊ីអ៊ីវជាញឹកញាប់។ ខ្ញុំព្រួយបារម្ភជានិច្ច ពីព្រោះខ្ញុំត្រូវគិត អំពី ម្ហូបអាហារសម្រាប់កូនៗរបស់ខ្ញុំ។ ខ្ញុំមិនដែលជំពាក់បំណុលគេទេ ពេលរស់នៅឯដីក្រហម ប៉ុន្តែ ខ្ញុំជំពាក់បំណុលគេនៅទីនេះ ខ្ញុំព្រួយអំពីអនាគតរបស់កូនៗខ្ញុំណាស់ ពីព្រោះខ្ញុំគ្មានប្រាក់ចំណូល ជាប់លាប់ទេ"។

មករា មានអារម្មណ៍អស់សង្ឃឹម ក្រុមគ្រួសារដែលត្រូវគេបណ្តេញចេញជាច្រើនទៀតក៏មាន អារម្មណ៍ដូចមករា ដែរ " ខ្ញុំឈឺចាប់ និងមានអារម្មណ៍តានតឹងរហូត តាំងពីពេលបណ្តេញចេញមក។ ខ្ញុំត្រូវចាប់ផ្តើមជីវិតរបស់ខ្ញុំពីបាតដៃទទេម្តងទៀត។ បទពិសោធន៍ពីដីក្រហមធ្វើឱ្យ ខ្ញុំឈឺចុកចាប់ខ្លាំង ណាស់ ហើយខ្ញុំធ្លាក់ខ្លួនឈឺជាញឹកញាប់ដោយសារនឹកឃើញរឿងរ៉ាវទាំងនេះ"។



មករា កំពុងទាយអោយអតិថិជន, ថ្លែងអំណរគុណចំពោះការថតរូបដោយ: R. McCormack/ OHCHR



តំបន់អណ្តូង

ថ្លែងអំណរគុណចំពោះការថតរូបដោយៈ karona / OHCHR

# ៦

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

ជំពូកចុងក្រោយនេះធ្វើការសន្និដ្ឋានលើការសិក្សានេះ ដោយគូសបញ្ជាក់អំពីបទពិសោធន៍ផ្សេងៗគ្នាដែលគ្រួសារតាំងទីលំនៅថ្មីជួបប្រទះ ទៅតាមគុណភាព និងភាពគ្រប់គ្រាន់នៃការធ្វើផែនការ ការចូលរួមរបស់សហគមន៍ និងការគោរពកិច្ចការពារផ្នែកនីតិវិធី ។ សារៈសំខាន់នៃការចំណាយធនធានចាំបាច់មួយចំនួនទាំងដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមាននៃការតាំងទីលំនៅថ្មី និងទាំងសំរាប់ដំណើរការនៃការតាំងទីលំនៅថ្មី ដែលប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវលក្ខខ័ណ្ឌដែលមានចែងក្នុងរបៀបវារៈនៃយុទ្ធសាស្រ្តសំរាប់ការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា។ ជំរុញឲ្យមានការបង្កើតគំរូប្រកបដោយសមធម៌ និងមានប្រសិទ្ធភាពនៃការតាំងទីលំនៅថ្មី ការកសាងបន្ថែមលើបទដ្ឋាន និងទម្លាប់អនុវត្តល្អក្នុងស្រុក និងជាអន្តរជាតិ ។

បន្ទាប់មកជំពូកនេះ បន្តផ្តល់អនុសាសន៍មួយចំនួន ដើម្បីដោះស្រាយបញ្ហាទាំងឡាយដែលបានធ្វើការវាយតំលៃក្នុងការសិក្សានេះ និងដើម្បីធ្វើឲ្យប្រសើរឡើងដល់ដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅកម្ពុជា ។ អនុសាសន៍ទាំងនេះ មានគោលដៅផ្តល់ជូនជាចម្បងទៅរាជរដ្ឋាភិបាលកម្ពុជា ប៉ុន្តែអនុសាសន៍ជាច្រើនក៏ទាក់ទងផងដែរចំពោះដៃគូអភិវឌ្ឍន៍នានា ។

អនុសាសន៍ទាំងនេះផ្តល់ឲ្យទាក់ទងនឹងដំណើរការនៅមុនការបណ្តេញចេញ/ការតាំងទីលំនៅថ្មី សកម្មភាពនៅក្នុងអំឡុងពេលនៃការបណ្តេញចេញ និងការទទួលបាននូវការដោះស្រាយ លក្ខខ័ណ្ឌនិងបទដ្ឋាននៅកន្លែងតាំងទីលំនៅថ្មី សុវត្ថិភាពខាងការកាន់កាប់និងការចុះបញ្ជីដីធ្លី ក្របខ័ណ្ឌច្បាប់ និងគោលយោបាយការស្រាវជ្រាវ ការឆ្លើយតបទៅនឹងលក្ខខ័ណ្ឌផ្សេងៗនៅកន្លែងតាំងទីលំនៅថ្មីដែលមានស្រាប់ និងការបង្កើតជាគំរូមួយសំរាប់ការតាំងទីលំនៅថ្មី។






# ជំពូកទី៦ ៖ សេចក្តីសន្និដ្ឋាន និង អនុសាសន៍

## សេចក្តីសន្និដ្ឋាន

ដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅគ្រប់ទិសទីលើពិភពលោក មានទៅដោយហានិភ័យនៃភាពក្រីក្រ និងសេចក្តីលំបាកវេទនា។ បទពិសោធន៍នៅកម្ពុជា ក៏មិនមានអ្វីខុសប្លែកគ្នាដែរ។ កាលបើមានការត្រៀមរៀបចំតិចតួចសម្រាប់ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី កាលបើគ្មានការពិគ្រោះយោបល់ជាមួយសហគមន៍ ហើយសហគមន៍មិនមានឱកាសចូលរួមធ្វើសេចក្តីសំរេចចិត្ត កាលបើកិច្ចធានាការពារផ្នែកនីតិវិធីច្បាប់មិនត្រូវបានគេគោរពអនុវត្តតាម ហើយការបណ្តេញចេញត្រូវគេប្រើប្រាស់កំលាំង និងអំពើហឹង្សា និងកាលបើសេវាហេត្ថារចនាសម្ព័ន្ធ និង ជំរើសសម្រាប់ការចិញ្ចឹមជីវិតនៅកន្លែងតាំងទីលំនៅថ្មីមិនមានគ្រប់គ្រាន់នោះ វាកាន់តែធ្វើឲ្យគ្រួសារទាំងនោះជួបការលំបាកឡើងថែមទៀត ក្នុងការដោះស្រាយស្ថានការណ៍របស់ខ្លួន និងការដកខ្លួនចេញពីភាពក្រីក្រ ។ ដូច្នេះ ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី បាននាំឲ្យសហគមន៍ដែលក្រីក្រស្រាប់ និងដែលគេមិនសូវគិតគូរដល់នោះ កាន់តែក្រីក្រទៅៗ។

ច្រើនឆ្នាំបន្ទាប់ពីការតាំងទីលំនៅថ្មី គ្រួសារប្រជាពលរដ្ឋនៅអណ្តូង ត្រពាំងអញ្ចាញ និង ស្ពានឆេះ នៅតែបន្តរស់នៅក្នុងស្ថានភាពដ៏លំបាកជាខ្លាំងដែលមានភាពអាក្រក់ជាងមុនពេលនៃការបណ្តេញចេញទៅទៀត។ សហគមន៍ទាំងនេះបង្ហាញពីការដែលពួកគាត់ខំត្រដរស់ច្រើនជាងការខិតខំដើម្បីការអភិវឌ្ឍន៍ គ្មានការរីកចំរើន និង មានការពឹងផ្អែកលើអ្នកដទៃច្រើនជាងភាពស្វ័យភាព និងសមត្ថភាពផ្ទាល់ខ្លួន។ មានគំនិតផ្តួចផ្តើមតិចតួច ដើម្បីធ្វើឲ្យប្រសើរឡើងដល់ហេត្ថារចនាសម្ព័ន្ធ និង ស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ ហើយអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានសំដែងកង្វល់ និងភាពអស់កំលាំង ចំពោះគំនិតនៃការបន្តធ្វើជាអ្នកផ្តល់ជំនួយឧបត្ថម្ភ[១៣០]ដ៏សំខាន់ (ឬតែមួយគត់)។ ផលប៉ះពាល់នៃការបណ្តេញចេញបានធ្វើឲ្យខូចខាតធ្ងន់ធ្ងរដែលសហគមន៍ទាំងនេះ

[១៣០] ជាឧទាហរណ៍ ទោះបីជាមានការអំពាវនាវឲ្យមានការសម្របសម្រួលជាមួយក្រុមហ៊ុន និងអាជ្ញាធរក្តី ក៏អង្គការមិនមែនរដ្ឋាភិបាល(NGOs) នៅតែជាអ្នកផ្តល់ជំនួយមនុស្សធម៌តែមួយគត់ ដល់ប្រជាពលរដ្ឋ ៣០០ គ្រួសារ ដែលជាអ្នកជួលផ្ទះ និងជាអាជីវករ ដែលត្រូវបានគេទុកឲ្យនៅតាម ចិញ្ចើមថ្នល់ក្នុងភូមិដំណាក់ត្រយឹង។ គិតចាប់ពីខែកុម្ភៈ ដល់ ខែធ្នូ ឆ្នាំ២០០៩ អង្គការ BABSEA, Caritas, Centre of Hope, Jesuit Refugee Service, Licadho, Samaritan's Purse, Village Earth and World Vision រួមគ្នាចំណាយប្រាក់យ៉ាងតិច ៧០,០០០ ដុល្លារ អាមេរិក លើការគាំទ្រជាមូលដ្ឋាន (ដូចជា ស្បៀងអាហារ ផ្ទះសម្បែង និងគ្រឿងសម្ភារៈសំរាប់ចំអិនអាហារ ការអប់រំកុមារ ទឹក អនាម័យ និង កិច្ចគាំពារសុខភាព)។

ដែលត្រូវប្រើពេលវេលាច្រើនឆ្នាំ ដើម្បីស្តារជីវភាពរស់នៅរបស់ខ្លួនឡើងវិញ ហើយជាក់ស្តែងវាគឺអ្វីដែលត្រូវចោទសួរថាតើស្ថានភាពខាងសេដ្ឋកិច្ច និងជាមនុស្សរបស់សហគមន៍ទាំងនេះមាននិរន្តភាព ឬក៏គ្មានទាល់តែសោះ?

ផ្ទុយទៅវិញ បើសិន ជាអាជ្ញាធរ សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ធ្វើការរួមគ្នា ដើម្បីរៀបចំផែនការសម្រាប់ការតាំងទីលំនៅថ្មីដែលមានការចូលរួមពីសហគមន៍ និងមានការគិតគូយ៉ាងពេញលេញអំពីសេចក្តីត្រូវការរបស់គ្រួសារប្រជាពលរដ្ឋដែលរងផលប៉ះពាល់ នោះវាមិនត្រឹមតែកាត់បន្ថយបាននូវផលប៉ះពាល់អវិជ្ជមាននៃការតាំងទីលំនៅថ្មីនោះប៉ុណ្ណោះទេ ប៉ុន្តែដំណើរការនេះថែមទាំងអាចជួយធ្វើឲ្យស្ថានភាពរស់នៅរបស់គ្រួសារប្រជាពលរដ្ឋបានល្អប្រសើរ និងមាននិរន្តរភាព ដូចករណីដែលសហគមន៍អភិវឌ្ឍន៍មានជ័យជាដើម ។ ស្ថានភាពគ្រួសារអ្នកជំងឺអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍នៅទួលសំបូរ គឺជាឧទាហរណ៍វិជ្ជមានមួយទៀត ដែលករណីនេះគឺកិច្ចសហការគ្នាក្នុងចំណោមអាជ្ញាធរជាតិ និងអាជ្ញាធរក្រុង អង្គការមិនមែនរដ្ឋាភិបាល ទីភ្នាក់ងារអង្គការសហប្រជាជាតិ បាននាំឲ្យមានការឆ្លើយតបយ៉ាងទូលំទូលាយចំពោះ ផលប៉ះពាល់អវិជ្ជមានដែលមានពីដំបូងមកចំពោះគ្រួសារទាំងនោះ ។

ក្នុងការអនុម័តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣ សម្តេចនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់អំពីសេចក្តីត្រូវការដើម្បីធានានូវ "សមធម៌សង្គម" ដែលជាការរួមចំណែកដ៏សំខាន់ចំពោះ "ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ"។[១៣១] ចក្ខុវិស័យនេះ មានសារៈសំខាន់ណាស់ចំពោះដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មី ហើយគេសង្ឃឹមថាអាជ្ញាធរគ្រប់ជាន់ថ្នាក់នឹងចងចាំប្រសាសន៍អំពាវនាវរបស់សម្តេចនាយករដ្ឋមន្ត្រី ហើយនឹងយកទៅអនុវត្តប្រកបដោយប្រសិទ្ធភាព ។

អាជ្ញាធរជាតិ និង អាជ្ញាធរក្រុងបានប្រឈមមុខនឹង ការទាមទារផ្សេងៗគ្នាពីភាគីជាច្រើន និងការងារដ៏លំបាកក្នុងការធ្វើឲ្យមានតុល្យភាពរវាងរបៀបវារៈខាងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងរបៀបវារៈខាងការអភិវឌ្ឍន៍សង្គមកិច្ច ។ ដោយគិតអំពីភាពតានតឹងទាំងនេះ សាលារាជធានីភ្នំពេញ ជាពិសេសបានខិតខំប្រឹងប្រែងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដើម្បីកាត់បន្ថយតម្លៃនៃផលប៉ះពាល់អវិជ្ជមានក្នុងការបណ្តេញចេញមួយចំនួន ។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះ ធនធាន និងការដោះស្រាយតាមផ្លូវច្បាប់មានតិចតួចបំផុត និងមានពេលវេលាតិចតួចបំផុតក្នុងការត្រៀមរៀបចំសំរាប់ដំណើរការការបណ្តេញចេញ និងការតាំងទីលំនៅថ្មី ។ ខណៈដែរ គំរោងតាំងទីលំនៅថ្មី ទំនងជាមានគោលដៅធ្វើឲ្យប្រសើរឡើងដល់បរិស្ថានទីក្រុង និងកាត់បន្ថយភាពក្រីក្រ ប៉ុន្តែតាមពិតទៅមានករណីជាច្រើនក្នុងការសិក្សានេះ បង្ហាញឲ្យឃើញពីការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ ។

ដើម្បីឲ្យការតាំងទីលំនៅថ្មីមាននិរន្តរភាព គេចាំបាច់ត្រូវលៃបំរុងធនធានគ្រប់គ្រាន់ ដើម្បីធានាបទដ្ឋានអប្បបរមា។ គេត្រូវតែយល់ច្បាស់ថា ការតាំងទីលំនៅថ្មី មិនមែនអាចដំណើរការទៅដោយតំលៃថោក ដោយគ្មានការចំណាយនានា នៅពេលបន្ទាប់នោះឡើយ ។ ធនធានសន្ទឹកសន្ធាប់ត្រូវបានចំណាយ ដើម្បីគាំទ្រដល់សហគមន៍អភិវឌ្ឍន៍មានជ័យ និងសហគមន៍ទួលសំបូរ (ហើយសហគមន៍



[១៣១] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៩-២០១៣) អារម្ភកថារបស់សម្តេចនាយករដ្ឋមន្ត្រី ។

# ជំពូកទី៦ ៖ សេចក្តីសន្និដ្ឋាន និង អនុសាសន៍

ទាំងនេះតូចណាស់ បើប្រៀបធៀបទៅនឹងសហគមន៍ដទៃទៀត) ។ ប៉ុន្តែ តម្លៃនៃផលប៉ះពាល់អវិជ្ជមានរយៈពេលវែងទៅលើមនុស្ស និងសេដ្ឋកិច្ចសង្គមនៃការតាំងទីលំនៅថ្មី របស់សហគមន៍ដទៃទៀតដែលបានចំណាយថវិកាតិចតួចពីដំបូងនោះ មិនអាចលុបបំបាត់ផលប៉ះពាល់ទាំងនោះបានភ្លាមៗឡើយ ។ បច្ចុប្បន្ននេះ គ្រួសារភាគច្រើននៅ អណ្តូង រស់នៅក្នុងសភាពក្រីក្របំផុត និងត្រូវការការជួយឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុ ពីអង្គការមិនមែនរដ្ឋាភិបាល ឬ ពីរដ្ឋាភិបាល សំរាប់រយៈពេលច្រើនឆ្នាំទៅមុខទៀត។ បញ្ហាសង្គមនៅទីតាំងនោះក៏ជាបញ្ហាមួយដែរ នៅពេលដែលគ្រួសារជាច្រើននៅអណ្តូង បានវិលត្រឡប់មករស់នៅទីក្រុងវិញ ដែលភាគច្រើនជាអ្នកជួលផ្ទះគេស្នាក់នៅ ហើយបានរស់នៅក្នុងតំបន់មិនរៀបរយក្នុងស្ថានភាពខាងសេដ្ឋកិច្ច សង្គម លំបាក និងងាយរងគ្រោះជាងនៅមុនពេលនៃការតាំងទីលំនៅថ្មីទៅទៀត ។ ទាំងអស់នេះ គឺជាផលប៉ះពាល់អវិជ្ជមានរយៈពេលវែង ហើយវាមានភាពធ្ងន់ធ្ងរច្រើនជាងការដោះស្រាយបញ្ហានៃភាពក្រីក្រនៅទីប្រជុំជនទៅទៀត ។

ពេលខ្លះ ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី ត្រូវបានគេសំអាងលើហេតុផលតំរូវការខាងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក៏ប៉ុន្តែហេតុផលនេះមិនពិតប្រាកដដូចជាការអះអាងក្នុងករណីទាំងអស់នោះទេ។ ប៉ុន្តែមានមតិផ្ទុយថា ការអនុវត្តន៍បែបនេះ មិនត្រឹមតែរំលោភច្បាប់ជាតិ ការប្តេជ្ញាចិត្តក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងអាចធ្វើឲ្យខូចដល់ការរីកចំរើនផ្នែកសេដ្ឋកិច្ចរយៈពេលវែង និង ទិសដៅកាត់បន្ថយភាពក្រក្រីរបស់កម្ពុជាផងដែរ។ ទន្ទឹមនឹងនេះ ក៏មានការកើនឡើងនៃភស្តុតាងជាបទពិសោធន៍ ដែលបង្ហាញឲ្យឃើញពីផលប្រយោជន៍ខាងសង្គម និងសេដ្ឋកិច្ចដែលកើតមកពីការធានាបាននូវ សុវត្ថិភាពខាងការកាន់កាប់ដីធ្លី និងសិទ្ធិមនុស្សទាក់ទងនឹង ទឹក អនាម័យ សុខភាព ។ល។[១៣២]

ចំពោះមុខនៃស្ថានភាពបែបនេះ គឺជាការសំខាន់ដែលគេត្រូវចំណាយធនធានចាំបាច់នានាដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមាននៃការតាំងទីលំនៅថ្មី ហើយដាក់បញ្ចូលដំណើរការនៃការតាំងទីលំនៅថ្មីជាចំនុចសំខាន់ទៅក្នុងរបៀបវារៈនៃការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា ។ ទន្ទឹមនឹងនគរូបនីយកម្មមានសន្ទុះខ្លាំង សេចក្តីត្រូវការឲ្យមានគំរូ សំរាប់ការតាំងទីលំនៅថ្មីប្រកបដោយសមធម៌ និងមានប្រសិទ្ធភាព ក៏ក្លាយជាបញ្ហាបន្ទាន់ផងដែរ ។ គេសង្ឃឹមថា រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយដៃគូនានា នឹងកសាងបន្ថែមពីលើការអនុវត្តន៍ល្អក្នុងស្រុក និងជាអន្តរជាតិ ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងថែមទៀតនូវគំរូសំរាប់ការតាំងទីលំនៅថ្មី ដែលត្រូវសំអាងមិនត្រឹមតែ លើការគណនាសំណងបែបចង្អៀត និង សំរាប់រយៈពេលខ្លី និង ការកាត់បន្ថយលើចំណាយប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមានចក្ខុវិស័យទូលំទូលាយគិតគូដល់ការស្តារឡើងវិញ និង ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដែលនេះគឺជាគោលការណ៍ឈ្នះ ឈ្នះ សំរាប់ទាំងអាជ្ញាធរ និងសហគមន៍យ៉ាងពិតប្រាកដ ។[១៣៣]

[១៣២] របាយការណ៍អភិវឌ្ឍន៍ជាសាកលឆ្នាំ២០០៣, និរន្តរភាពនៃការអភិវឌ្ឍន៍ក្នុងពិភពលោកដ៏ ស្វាហាប់: កំនែទំរង់ស្ថាប័ន, ការរីកចំរើនលូតលាស់ និង គុណភាពនៃការរស់នៅ *(World Development Report 2003, Sustainable Development in a Dynamic World: Transforming Institutions, Growth, and Quality of Life)*", ជំពូកទី៦ ការទទួលបាន ភាពប្រសើរបំផុតពីទីក្រុង" ដែលសហការបោះពុម្ពផ្សាយដោយ ធនាគារពិភពលោក និង រោងពុម្ព Oxford University Press ។

[១៣៣] សូមមើល មីឆែល អេម ស៊ីនី (អ៊ីដ) សេដ្ឋកិច្ចនៃការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត ៖ សំណួរ និងបញ្ហាប្រឈម (វ៉ាស៊ិនតោន ឌីស៊ី ៖ ធនាគារពិភពលោក ឆ្នាំ១៩៩៩) ។

# អនុសាសន៍

របាយការណ៍នេះ ផ្តល់នូវអនុសាសន៍មួយចំនួនសំរាប់ការដោះស្រាយ។ អនុសាសន៍នេះ ដាក់ស្នើជាបឋមជូនទៅរាជរដ្ឋាភិបាល ជាពិសេស ទៅក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងសុខាភិបាល (ជាពិសេស អាជ្ញាធរប្រយុទ្ធនឹងមេរោគអេដស៍/ជម្ងឺអេដស៍) ក៏ដូចជា អាជ្ញាធររាជធានី និងអាជ្ញាធរមូលដ្ឋាន ។ ការិយាល័យ OHCHR សង្ឃឹមថា អនុសាសន៍ទាំងនេះ អាចជួយ និងជំរុញលើកទឹកចិត្ត ឲ្យមានការពិភាក្សាចាំបាច់នានា ដើម្បីបង្កើតគោលនយោបាយមួយស្តីពីការតាំងទីលំនៅថ្មី ដែលជាចក្ខុវិស័យនៅក្នុងឯកសារបណ្តោះអាសន្ន ឆ្នាំ២០០២ ស្តីពីយុទ្ធសាស្ត្រក្របខ័ណ្ឌគោលនយោបាយដីធ្លី។ មានការសង្ឃឹមថា អនុសាសន៍ទាំងនេះភាគច្រើន មានប្រយោជន៍ និងពាក់ព័ន្ធចំពោះអ្នកផ្តល់ជំនួយ តួអង្គអភិវឌ្ឍន៍ និង អ្នកពាក់ព័ន្ធឯទៀតៗ ក្នុងការគាំទ្រដល់ដំណើរការ និងកម្មវិធីមួយចំនួន ដូចបានគូសបញ្ជាក់ខាងក្រោមនេះ។

## ១. ដំណើរការមុនការបណ្តេញចេញ និង ក្នុងកំឡុងពេលនៃការតាំងទីលំនៅថ្មី ៖

- ការបណ្តេញចេញ គួរតែអនុវត្តសំរាប់ជាមធ្យោបាយចុងក្រោយបំផុតតែប៉ុណ្ណោះ។ ជំរើសគ្រប់យ៉ាងផ្សេងទៀត មានដូចជា ការអភិវឌ្ឍន៍នៅនឹងកន្លែង និងការធ្វើឲ្យបានល្អប្រសើរឡើងនៅនឹងកន្លែង (រួមមាន តាមសារាចរ លេខ០៣ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់) គួរតែបានជ្រើសរើសយកមកអនុវត្តជាមុនសិន ។

- ដោយការសហការជាមួយសហគមន៍ដែលរងផលប៉ះពាល់ **អនុម័តផែនការសំរាប់ការតាំងទីលំនៅថ្មីដែលមានលក្ខណៈទូលំទូលាយ និងមានតម្លាភាព នៅមុនការបណ្តេញចេញ ឬការតាំងទីលំនៅថ្មីណាមួយ ។**

- **ធានាឲ្យមានការចូលរួមពីគ្រួសារដែលរងផលប៉ះពាល់ នៅក្នុងដំណើរការធ្វើផែនការ** ទាំងនៅមុនពេល ទាំងនៅក្រោយពេលនៃការតាំងទីលំនៅថ្មី ។ ការពិគ្រោះយោបល់ជាមួយសហគមន៍ដែលរងផលប៉ះពាល់ គួរតែមានតម្លាភាព និងមិនត្រូវធ្វើឡើងក្រោមការគាបសង្កត់ ឬការបំភិតបំភ័យទេ ។ ការចូលរួមរបស់សហគមន៍ គួរត្រូវបានធានាគ្រប់ដំណាក់កាលទាំងអស់នៃការធ្វើផែនការ ទាំងមុនពេល និងក្រោយពេលការតាំងទីលំនៅថ្មី រាប់ទាំង ៖
    - ជំរើសផ្សេងៗជំនួសឲ្យការបណ្តេញចេញ
    - ទីតាំងនៃកន្លែងតាំងទីលំនៅថ្មី
    - លំនៅដ្ឋាន និង ហេដ្ឋារចនាសម្ព័ន្ធនៅទីតាំងថ្មី
    - ពេលវេលានៃការបណ្តេញចេញ ឬការតាំងទីលំនៅថ្មី

- **ទទួលស្គាល់សិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ និងបង្កើតយន្តការផ្សព្វផ្សាយព័ត៌មានឲ្យបានគ្រប់ គ្រាន់ដល់គ្រួសារដែលរងផលប៉ះពាល់ ។**

- នៅពេលរៀបចំផែនការតាំងទីលំនៅថ្មី គួរតែ

ជំពូក ៦

# អនុសាសន៍ (បន្ត)

យកចិត្តទុកដាក់គិតគូអំពីសេចក្តីត្រូវការជាក់ស្តែង និងភាពងាយរងគ្រោះនៃបុគ្គល ឬក្រុមមនុស្សមួយចំនួន ដូចជា ជនពិការ អ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ស្ត្រី និងកុមារ ជាដើម។ គួរស្វែងរកដំណោះស្រាយសមស្របនិងចំគោលដៅ។ ទោះជាក្នុងកាលៈទេសៈណាក៏ដោយមិនត្រូវមានការរើសអើង និងការប្រកាន់បែងចែកចំពោះអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍នៅក្នុងដំណើរការនៃការតាំងទីលំនៅថ្មីឡើយ ។

## ២. សកម្មភាពនៅក្នុងអំឡុងពេលនៃការបណ្តេញចេញ និងការទទួលបានដំណោះស្រាយ ៖

- សកម្មភាពនៃការបណ្តេញចេញ ត្រូវគោរពទាំងស្រុងចំពោះសេចក្តីតម្រូវខាងនីតិវិធីត្រឹមត្រូវ ដូចមានចែងក្នុងបទដ្ឋាន សិទ្ធិមនុស្សអន្តរជាតិ ស្របតាមគោលការណ៍ទូទៅស្តីពីភាពចាំបាច់ និងភាពសមាមាត្រ ។ ជាពិសេស អាជ្ញាធរនានាត្រូវផ្តល់ឲ្យគ្រួសារដែលរងផលប៉ះពាល់នូវឱកាសពិគ្រោះយោបល់យ៉ាងពិតប្រាកដ ជៀសវាងការប្រើប្រាស់កំលាំងមិនសមាមាត្រ ត្រូវជូនដំណឹងដោយទុកពេលវេលាគ្រប់គ្រាន់ និងសមហេតុផល មិនត្រូវធ្វើការបណ្តេញចេញ ជាពិសេសនៅពេលមានអាកាសធាតុអាប់អួរ ឬនៅពេលយប់ឡើយ ត្រូវធានាឲ្យមាន និងអនុវត្តការដោះស្រាយតាមផ្លូវច្បាប់ ហើយប្រសិនជាអាចធ្វើបាន ត្រូវផ្តល់ជំនួយផ្នែកច្បាប់ដល់អ្នកដែលត្រូវការជំនួយនេះ ដើម្បីស្វែងរកការដោះស្រាយតាមផ្លូវតុលាការ។[១៣៤]
- ធានាឲ្យមានការគោរពយ៉ាងមឹងម៉ាត់តាមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ពាក់ព័ន្ធ ក្នុងករណី មានអំពើហិង្សាកើតឡើងរវាងអាជ្ញាធរ និងសហគមន៍ ឬមានការចោទប្រកាន់លើសមាជិក ឬតំណាងសហគមន៍ ។
- ផ្តល់សំណង ដែលមិនមែនត្រឹមតែសំរាប់ការបាត់បង់ដីធ្លី និងអាគារប៉ុណ្ណោះទេ ប៉ុន្តែត្រូវផ្តល់សំណងផងដែរ ចំពោះការបាត់បង់មុខរបរចិញ្ចឹមជីវិត ព្រមទាំង តំលៃនៃការខាតបង់មិនមែនសេដ្ឋកិច្ច ឬ ការរំខានផ្សេងៗផងដែរ (ឧទាហរណ៍ ការរុះរើអាគារ ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ការចំណាយលើមុខរបរ ការបាត់បង់ ឬការថយចុះនៃប្រាក់ឈ្នួល ឬប្រាក់ចំណូល ជាដើម) ។

## ៣. លក្ខខ័ណ្ឌ និង បទដ្ឋាន នៅកន្លែងតាំងទីលំនៅថ្មី ៖

- ធានាថា សហគមន៍ទាំងឡាយបានទទួលព័ត៌មានគ្រប់គ្រាន់ និងបានពិគ្រោះយោបល់ អំពីការអភិវឌ្ឍន៍គំរោងផ្សេងៗ ដែលមានគោលដៅធ្វើឲ្យប្រសើរឡើងដល់លក្ខខ័ណ្ឌនៃកន្លែងតាំងទីលំនៅថ្មី ដូចជា ការប្រើ និងការទទួលអត្ថប្រយោជន៍ពីប្រាក់កម្ចីសំរាប់សង់លំនៅដ្ឋាន ឬ ប្រភេទផ្ទះដែលត្រូវសង់ ។ល។
- ធានាថា បន្ទាប់ពីការបណ្តេញចេញ សហគមន៍ដែលត្រូវបានតាំងទីលំនៅថ្មីទាំងអស់ ទទួលបានយ៉ាងហោចណាស់នូវកំរិតជីវភាពរស់នៅប្រហាក់ប្រហែលគ្នានឹងជីវភាពនៅមុនការបណ្តេញចេញ ហើយត្រូវធានាបទដ្ឋានអប្បបរមានៅគ្រប់កន្លែងតាំងទីលំនៅថ្មីទាំងអស់ ដោយមិនគិតពីបទដ្ឋាននៃការរស់នៅដែលពួកគាត់មាន នៅមុនការបណ្តេញ



[១៣៤] *សេចក្តីពន្យល់ទូទៅលេខ ៧* នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (CESCR)។

ចេញឡើយ ។

- **មុននឹងឲ្យមានការតាំងទីលំនៅថ្មី ត្រូវវាយតំលៃអំពីឱកាសមានមុខរបរចិញ្ចឹមជីវិតនៅកន្លែងតាំងទីលំនៅថ្មី** ។ នៅពេលវាយតំលៃរួចហើយ បើឃើញថាឱកាសមានមុខរបរនេះ មានមិនគ្រប់គ្រាន់ ឬបង្ហាញថា មានហានិភ័យ គេត្រូវពិចារណាឡើងវិញអំពីពេលវេលា ឬទីតាំងនៃកន្លែងតាំងទីលំនៅថ្មីនោះ ឬចាត់វិធានការជាបន្ទាន់ **ដើម្បីផ្ដល់ដំណោះស្រាយចំពោះការថយចុះប្រាក់ចំណូល ឬការបាត់បង់ការងារ និងមុខរបរក្នុងរយៈពេលខ្លី និងបង្កើតកម្មវិធីដើម្បីគាំទ្រដល់ការចិញ្ចឹមជីវិតរបស់គ្រួសារដែលរងផលប៉ះពាល់ក្នុងរយៈពេលមួយសមស្រប** ។

- **ធានាថា ដីឡូត៍ និងផ្ទះសម្បែងដែលផ្ដល់មានទំហំ និងគុណភាពសមស្រប** ។ ធានាបទដ្ឋានអប្បបរមានៃភាពគ្រប់គ្រាន់ និងទំហំសមល្មមសំរាប់គ្រួសារទាំងអស់ដោយមិនគិតពី ប្រភេទផ្ទះសម្បែង ដែលពួកគាត់មានកន្លងមកឡើយ ។ ទំហំផ្ទះសម្បែងគួរតែមានទំហំគ្រប់គ្រាន់ និង ផ្ដល់នូវភាពជាឯកជនដល់សមាជិកគ្រួសារនីមួយៗ និងអាចផ្ដល់អោយអាចរស់នៅបាននៅពេលកើនសមាជិកគ្រួសារ។ ក្នុងករណីនៃគ្រួសារដែលមានលក្ខខ័ណ្ឌប្រសើរជាងបទដ្ឋានអប្បបរមាដែលបានកំណត់ខាងលើ នៅមុនពេលនៃការឲ្យតាំងទីលំនៅថ្មីនោះ ត្រូវរក្សាបទដ្ឋានដដែលសំរាប់គ្រួសារទាំងនោះ។

- **ធានាថា សេវា និង ហេដ្ឋារចនាសម្ព័ន្ធអប្បបរមា** ត្រូវបានរៀបចំឲ្យមានរួចជាស្រេច *មុននឹង*មានការតាំងទីលំនៅថ្មី រាប់ទាំង សេវាទឹកស្អាត អនាម័យគ្រប់គ្រាន់ និងប្រព័ន្ធបង្ហូរសំអុយ ផ្ទះសម្បែង និងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងការទទួលបានសេវាគាំពារសុខភាព និងសេវាអប់រំ ។ កិច្ចខិតខំប្រឹងប្រែងនានាគួរត្រូវបានធ្វើឡើងដើម្បីធានាថា ការសិក្សារបស់កុមារមិនរងនូវការរំខានដោយសារតែការតាំងទីលំនៅថ្មី។

- **អាជ្ញាធរឃុំ/សង្កាត់នៅកន្លែងតាំងទីលំនៅថ្មីត្រូវជួយសំរួលផ្ដល់ឯកសារចាំបាច់នានា ដល់អ្នកបោះឆ្នោតនៅកន្លែងតាំងទីលំនៅថ្មី** ដើម្បីប្រើប្រាស់សំរាប់ការចុះឈ្មោះរបស់ខ្លួន ក្នុងបញ្ជីចុះឈ្មោះអ្នកបោះឆ្នោត ។

- **ពង្រឹងកិច្ចសម្របសម្រួលរវាង និងក្នុងចំណោម ស្ថាប័នរដ្ឋ និង ក្រសួង/មន្ទីរនានា រាប់ទាំង រវាងអាជ្ញាធរជាតិ និង អាជ្ញាធរមូលដ្ឋាន។** ការនេះសំខាន់ជាពិសេស ចំពោះការទទួលបានសេវាសាធារណៈ ដូចជា សេវាអប់រំ និងកិច្ចគាំពារសុខភាព (រាប់ទាំង ការបន្តកិច្ចគាំពារដល់បុគ្គលទាំងឡាយដែលផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍) ការផ្ទេរ ឬ ការចេញឯកសាររដ្ឋបាល ដូចជា សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ និង ឯកសារសំរាប់បោះឆ្នោត និង ការចុះបញ្ជីដីធ្លី បានទាន់ពេលវេលា ។

## ៤. សុវត្ថិភាពខាងការកាន់កាប់ និង ការចុះបញ្ជីដី៖

- **មុននឹងមានការបណ្ដេញចេញណាមួយ ត្រូវវាស់វែងដីធ្លី និង ចុះបញ្ជីដីសហគមន៍ដែលរងការ**

# អនុសាសន៍ (បន្ត)

គំរាមគំហែងពីការបណ្តេញចេញនោះ និងកំណត់អំពីស្ថានភាពគតិយុត្តរបស់គ្រួសារទាំងនោះឲ្យស្របតាមច្បាប់ ។

- ការពារពីការបណ្តេញចេញចំពោះគ្រួសារទាំងឡាយដែលអះអាងថា ពួកគាត់មានសិទ្ធិភោគៈស្របច្បាប់លើដីរបស់គាត់ តាមច្បាប់ភូមិបាលឆ្នាំ ២០០១ ខណៈរង់ចាំការសំរេចជាស្ថាពរអំពីបណ្តឹងទាមទាររបស់ពួកគាត់ ។

- ប្រសិនជាការដកហូតដីធ្លីមិនអាចជៀសវាងបាន និងមានបញ្ជាក់ហេតុផលត្រឹមត្រូវតាមផ្លូវច្បាប់សំរាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈ ត្រូវផ្តល់សំណងសមរម្យ និងយុត្តិធម៌ជាមុន ដល់ភោគី ឬ កម្មសិទ្ធិករ ដូចមានចែងក្នុងច្បាប់ស្តីពីអស្សាមិករណ៍ ។ អ្នកដែលជ្រើសរើសទៅតាំងទីលំនៅថ្មី គួរតែផ្តល់ជូនគាត់នូវប័ណ្ណកម្មសិទ្ធិដីធ្លីភ្លាមៗ បន្ទាប់ពីការតាំងទីលំនៅថ្មី និងទទួលបានដីដែលបានបំពេញតាមបទដ្ឋានអប្បបរមា នៃភាពគ្រប់គ្រាន់ ឬ ប្រសិនជាដីរបស់ពួកគាត់មុនពេលធ្វើការដកហូតនោះមានកំរិតស្តង់ដាខ្ពស់ជាង ត្រូវផ្តល់ជូនគាត់នូវដីដែលមានទំហំគុណភាពនិងតំលៃស្មើគ្នា ។

- **សំរួលដំណើរការនៃការធានាសុវត្ថិភាពខាងការកាន់កាប់ដីធ្លីរបស់គ្រួសារប្រជាពលរដ្ឋនៅកន្លែងតាំងទីលំនៅថ្មី** ហើយជាពិសេសត្រូវ៖

  – ធានាសុវត្ថិភាពខាងការកាន់កាប់ជាផ្លូវការសំរាប់កន្លែងតាំងទីលំនៅថ្មីទាំងមូល និងសំរាប់សហគមន៍ដែលបានតាំងទីលំនៅថ្មី ឧទាហរណ៍ តាមរយៈ**ការចុះបញ្ជីទីកន្លែងតាំងទីលំនៅថ្មីនោះជាដីសម្បទានសង្គមកិច្ច** ស្របតាមអនុក្រឹត្យលេខ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ។

  – ភ្លាមៗបន្ទាប់ពីការតាំងទីលំនៅថ្មី ត្រូវចេញឲ្យគ្រួសារនីមួយៗនូវ **ឯកសារមួយដែលធានាសុវត្ថិភាពខាងការកាន់កាប់។** ឯកសារនេះ អាចយកលំនាំតាមឯកសារដែលបានចេញឲ្យកន្លងមកសំរាប់គ្រួសារដែលបានតាំងទីលំនៅថ្មី (សូមមើលឧបសម្ព័ន្ធទី២) ឬយកលំនាំតាមកិច្ចសន្យាដែលបានប្រគល់ឲ្យអ្នកទទួលដីឡូតិ៍ ស្របតាមគំរោងបែងចែកដីសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ច (LASED)។

- អាជ្ញាធរពាក់ព័ន្ធ គួរបង្កើត**នីតិវិធីចុះបញ្ជីដីជាប្រព័ន្ធ និង ផ្តល់ប័ណ្ណកម្មសិទ្ធិឲ្យដល់គ្រួសារប្រជាពលរដ្ឋ ដែលបានតាំងទីលំនៅថ្មី៖**

  – ការចុះបញ្ជី និង ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី គួរធ្វើភ្លាមៗ បន្ទាប់ពីការតាំងទីលំនៅថ្មីក្នុងករណីនៃភោគី និងម្ចាស់អចលនទ្រព្យ ឬចំពោះករណីនៃគ្រួសារដទៃទៀត បន្ទាប់ពីក្របខ័ណ្ឌពេលវេលាមួយជាក់លាក់ និងសមស្របនិងស៊ីសង្វាក់គ្នា ឧទាហរណ៍ រយៈពេលប្រាំឆ្នាំ (តាមអនុក្រឹត្យលេខ១៩) ឬដប់ឆ្នាំ (តាមសារាចរ លេខ០៣ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្ន ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់) ចាប់ពីថ្ងៃតាំងទីលំនៅថ្មី ។

– ក្របខ័ណ្ឌពេលវេលាសំរាប់ការផ្ដល់ប័ណ្ណកម្មសិទ្ធិដីធ្លីគួរតែបានយកទៅពិភាក្សាបន្ថែមទៀត ក្នុងចំណោមអាជ្ញាធរពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីធានាភាពស៊ីសង្វាក់គ្នាជាមួយនឹងក្របខ័ណ្ឌច្បាប់ និងសុវត្ថិភាពខាងការកាន់កាប់ពេញលេញសំរាប់គ្រួសារដែលតាំងទីលំនៅថ្មី ។

## ៥. ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ៖

- **អភិវឌ្ឍបន្ថែមនូវគោលការណ៍ណែនាំទូលំទូលាយមួយ ដើម្បីណែនាំអំពីដំណើរការនៃការបណ្ដេញចេញ និងការតាំងទីលំនៅថ្មី ដូចជាគោលនយោបាយស្ដីពីការតាំងទីលំនៅថ្មី ឬបទបញ្ញាសំរាប់គោលដៅនេះ ។**

- **គោលនយោបាយនេះ គួរតែបញ្ចូលនូវបទដ្ឋានអន្តរជាតិ និងការអនុវត្តន៍ល្អប្រសើរបំផុត ហើយក្នុងនោះរាប់បញ្ចូលទាំង ធាតុផ្សំមួយចំនួនដូចខាងក្រោមនេះ ៖**

– គោលការណ៍ណែនាំផ្សេងៗ ដូចជា ការបណ្ដេញចេញ គួរតែជាមធ្យោបាយចុងក្រោយបំផុតហើយត្រូវស្វែងរកជំរើសផ្សេងៗជំនួសឲ្យការបណ្ដេញចេញ ហើយគ្រួសារដែលតាំងទីលំនៅថ្មី មិនត្រូវបានគេធ្វើឲ្យធ្លាក់ទៅក្នុងស្ថានភាពអាក្រក់ជាងមុនពេលបណ្ដេញចេញឡើយ និងការចូលរួមរបស់សហគមន៍ គឺជាការសំខាន់ចាំបាច់ ។

– ការការពារផ្នែកនីតិវិធីសំរាប់ដំណើរការធ្វើផែនការនៅមុនការបណ្ដេញចេញ រាប់ទាំងការខិតខំរិះរកជំរើសផ្សេងៗឲ្យអស់ពីលទ្ធភាពដើម្បីជំនួសឲ្យការបណ្ដេញចេញ ការពិគ្រោះយោបល់ និង ការទទួលបានព័ត៌មានគ្រប់គ្រាន់ ។

– ការការពារផ្នែកនីតិវិធី នៅអំឡុងពេលនៃការបណ្ដេញចេញ ។

– ការការពារភោគី និងកម្មសិទ្ធិករ ពីការដកហូតដីធ្លី (អស្សាមិករណ៍) ដោយខុសច្បាប់ ឬការបណ្ដេញចេញដោយខុសច្បាប់ ។

– និយមន័យនៃបទដ្ឋានអប្បបរមាសំរាប់កន្លែងតាំងទីលំនៅថ្មី ។

– យន្តការនានាសំរាប់សម្របសម្រួលរវាងអាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋាន ។

## ៦. ភាពចន្លោះប្រហោងក្នុងការស្រាវជ្រាវ និងភស្តុតាង ៖

- **ធ្វើការស្រាវជ្រាវជាបន្ថែមអំពីផលប៉ះពាល់នៃការបណ្ដេញចេញ ឬការតាំងទីលំនៅថ្មីទៅលើសុខភាពផ្លូវចិត្តនៃគ្រួសារប្រជាពលរដ្ឋ និងអំពីឧប្បត្តិហេតុ និងការកើតមានអំពើហឹង្សាក្នុងគ្រួសារនៅក្នុងចំណោមគ្រួសារប្រជាពលរដ្ឋដែលតាំងទីលំនៅថ្មី ។**

- **ធ្វើការវាយតំលៃអំពីស្ថានភាពសេដ្ឋកិច្ចសង្គមនៃគ្រួសារទាំងឡាយ ដែលបានសំរេចចិត្តទទួលយកសំណងជាលុយកាក់ជំនួសឲ្យការតាំងទីលំនៅថ្មី ដើម្បីសំគាល់អំពីហានិភ័យនៃភាពងាយ**

# អនុសាសន៍ (បន្ត)

រងគ្រោះ និងភាពក្រីក្រ ។

- វាយតម្លៃអំពីកម្រិតនៃប្រាក់បំណុល និងការសងបំណុល ក្នុងចំណោមសហគមន៍ដែលបានតាំងទីលំនៅថ្មី។

## ៧. ដោះស្រាយចំពោះសេចក្តីត្រូវការនៅកន្លែងតាំងទីលំនៅថ្មីដែលមានស្រាប់៖

- ធានា ឬ ធ្វើឲ្យបានល្អប្រសើរឡើងដល់ ផ្ទះសម្បែង ដល់ការទទួលបានទឹកស្អាត និង អនាម័យ សំរាប់គ្រួសារទាំងអស់ដែលរស់នៅ អណ្តូង ត្រពាំងអញ្ចាញ ភូមិស្រះពោធិ (ខេត្តកណ្តាល) អូរកម្ពុជា (ខេត្តព្រះសីហនុ) និងនៅកន្លែងតាំងទីលំនៅថ្មីផ្សេងៗទៀតដែលគ្រួសារប្រជាពលរដ្ឋត្រូវការជាចាំបាច់បំផុត ដោយធ្វើការសហការជាមួយសហគមន៍ដែលរងផលប៉ះពាល់ ។

- ធ្វើជំរឿនប្រពលរដ្ឋនៅអណ្តូង ដើម្បីអាចឲ្យដឹងអំពីចំនួនពិតប្រាកដនៃអ្នករស់នៅទីនោះ មុននឹងបន្តអនុវត្តគំរោងលំនៅដ្ឋាន ហើយសេចក្តីជូនដំណឹងត្រូវមានរយៈពេលគ្រប់គ្រាន់ ដើម្បីឲ្យគ្រប់គ្រួសារទាំងនោះមានវត្តមាននៅទីតាំងនោះ នៅពេលចុះធ្វើជំរឿន ។

- អាជ្ញាធរថ្នាក់ជាតិ និងអជ្ញាធរខេត្តព្រះសីហនុ គួរផ្តល់ដីធ្លីគ្រប់គ្រាន់ (ដីកសិកម្ម និងដីលំនៅដ្ឋាន) និងផ្ទះសម្បែងដល់គ្រួសារប្រជាពលរដ្ឋនៅសហគមន៍ស្ពានឆេះ ដែលពួកគាត់ត្រូវបានបាត់បង់ដីធ្លីតាំងពីឆ្នាំ ២០០៧ មក។

- ធ្វើការវាយតំលៃអំពីកំរិតនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់គ្រួសារប្រជាពលរដ្ឋនៅកន្លែងតាំងទីលំនៅថ្មីទាំងអស់។ ពិនិត្យមើលអំពីកំរិតនៃសេចក្តីត្រូវការរបស់គ្រួសារទាំងនោះ ខាងស្បៀងអាហារ និងខាងការឧបត្ថម្ភការចិញ្ចឹមជីវិត ។

- អាជ្ញាធរពាក់ព័ន្ធ ដោយមានកិច្ចសហការជាមួយអ្នកផ្តល់សេវាសំខាន់ៗ និងអាជ្ញាធរក្រុង គួរធ្វើការវាយតំលៃអំពីសេចក្តីត្រូវការ និង ភាពងាយរងគ្រោះនៃគ្រួសារដែលផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ដែលបច្ចុប្បន្នកំពុងរស់នៅតាមកន្លែងតាំងទីលំនៅថ្មីនានានៅរាជធានីភ្នំពេញ ដើម្បីធានាឲ្យមានការពិនិត្យព្យាបាល កិច្ចគាំពារសុខភាព និង វិធានការកាត់បន្ថយផលប៉ះពាល់ឲ្យបានសមស្រប។

## ៨. ការសាកល្បងបង្កើតជាគំរូមួយនៃការតាំងទីលំនៅថ្មីនៅកម្ពុជា ៖

- គំរោងសាកល្បងមួយគួរអាចត្រូវបានបង្កើតឡើង និងអនុវត្តរួមគ្នាដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា ដោយប្រើប្រាស់អនុសាសន៍ទាំងឡាយដែលបានផ្តល់ក្នុងការសិក្សានេះ គោលការណ៍ណែនាំជាអន្តរជាតិ និងការអនុវត្តន៍ដែលល្អប្រសើរបំផុត និងបទពិសោធន៍ពីសហគមន៍អភិវឌ្ឍន៍មានជ័យ និង សហគមន៍ទូលសំបូរ ។ គំរោងសាកល្បងនេះអាចផ្តោតលើការតាំងទីលំនៅថ្មីនៃសហគមន៍មួយ ដោយផ្អែកលើមូលហេតុនៃផលប្រយោជន៍សាធារណៈ ។

A

# ឧបសម្ព័ន្ធ

ផ្នែកនេះមានឧបសម្ព័ន្ធចំនួន៣ ទាក់ទងនឹងការសិក្សានេះ ៖

- ឧបសម្ព័នទី១៖ សេចក្តីសង្ខេបនៃករណីទាំងឡាយដែលបានសិក្សា ទៅតាមទីកន្លែងតាំងទីលំនៅថ្មី
- ឧបសម្ព័ន្ធទី២៖ ឯកសារចេញផ្តល់ឲ្យអ្នកតាំងទីលំនៅថ្មីដើម្បីទទួលស្គាល់កម្មសិទ្ធិ
- ឧបសម្ព័ន្ធទី៣៖ ឯកសារយោង

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ សេចក្តីសង្ខេបនៃករណីទាំងឡាយដែលបានសិក្សា *

| កន្លែងតាំងទីលំនៅថ្មី/ ទីកន្លែង | ចំនួនគ្រួសារ នៅទីតាំងថ្មី | ទីកន្លែងមុនការ តាំងទីលំនៅថ្មី និងចំនួនគ្រួសារ | កាលបរិច្ឆេទនៃ ការបណ្តេញចេញ ឬការតាំងទីលំនៅថ្មី | ដំណើរការនៃការបណ្តេញចេញ/ការតាំងទីលំនៅថ្មី និង ស្ថានភាពទីតាំង |
|---|---|---|---|---|
| **រាជធានីភ្នំពេញ** | | | | |
| **អភិវឌ្ឍន៍មានជ័យ (ហៅថា "វេង ស្រេង ")**<br><br>នៅជិតផ្លូវវេងស្រេង ក្នុងសង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ | ១២៩ គ្រួសារ | ១២៩ គ្រួសារ **នៅលើផ្លូវជិតស្ពានទូតចិន** ក្នុងសង្កាត់ទួលស្វាយព្រៃ ខ័ណ្ឌចំការមន | ការតាំងទីលំនៅថ្មីជាផ្លូវការ នៅថ្ងៃទី ២០ ខែមករា ឆ្នាំ ១៩៩៩<br><br>ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៃទីតាំងថ្មីនេះ ក្នុង ខែមេសា ឆ្នាំ ២០០០ | <u>សវតា</u> ៖ បន្ទាប់ពីការព្យាយាមបណ្តេញចេញដោយមិនបានប្រកាសឲ្យដឹងជាមុន ក្នុង ឆ្នាំ ១៩៩៦ ការចរចាបានធ្វើឡើងរវាងអាជ្ញាធរក្រុង និងអាជ្ញាធរមូលដ្ឋាន និងសហគមន៍ ដើម្បី ស្វែងរក ជំរើសផ្សេងពីការបណ្តេញចេញ ។ គំរោងតាំងទីលំនៅថ្មីមួយ ត្រូវបានព្រមព្រៀង ។<br><br><u>ការតាំងទីលំនៅថ្មី</u> ៖ កន្លែងតាំងទីលំនៅថ្មី ត្រូវបានសហគមន៍ជ្រើសរើសយក ស្ថិតនៅជិតទី តាំងចាស់របស់ពួកគាត់ ។ ការតាំងទីលំនៅថ្មីនេះមានការចូលរួមពីសហគមន៍ ដោយមានកិច្ចសហការជាមួយ អង្គការក្រៅរដ្ឋាភិបាល និងមជ្ឈមណ្ឌលសហប្រជាជាតិ ដើម្បីលំនៅដ្ឋាន និង ក្នុងក្របខ័ណ្ឌពេលវេលាមួយសមស្រប ។ កិច្ចព្រមព្រៀងនេះបានធ្វើដោយ ភាគីពាក់ពន្ធ័ផ្សេងៗ: សាលារាជធានីភ្នំពេញប្តេជ្ញាទិញដី មជ្ឈមណ្ឌលសហប្រជាជាតិដើម្បីលំនៅដ្ឋាន ចំណាយលើការចាក់ដីបំពេញ និងហេដ្ឋារចនាសម្ព័ន្ធ។ សហព័ន្ធសាមគ្គីភាព សហគមន៍ អ្នកក្រីក្រក្នុងទីក្រុង (SUPF) ជួយខាងការសម្របសម្រួលសហគមន៍។ មូលនិធិអភិវឌ្ឍន៍ កាត់បន្ថយភាពក្រីក្រក្នុងទីក្រុង (UPDF) ផ្តល់ឥណទានផ្ទះ និង អង្គការដទៃទៀត ផ្តល់ជំនួយ ផ្នែកបច្ចេកទេសសម្រាប់រចនាប្លង់ និងសាងសង់លំនៅដ្ឋាន។<br><br><u>ទីតាំង</u> ៖ គ្រួសារទាំងនោះបានទៅតាំងទីលំនៅថ្មី នៅតំបន់អភិវឌ្ឍន៍មានជ័យ នៅពេលដែល ការងារលើហេត្ថារចនាសម្ព័ន្ធចាំបាច់មួយចំនួន (ផ្លូវថ្នល់ ប្រព័ន្ធលូបង្ហូរទឹក ប្រព័ន្ធទឹក អានាម័យ) ត្រូវ បានសាងសង់ចប់សព្វគ្រប់ ។ គ្រួសារទាំងនេះ ត្រូវបានផ្តល់អាយនូវ ដីនិងលំនៅដ្ឋានសមរម្យ។ សហគមន៍នេះត្រូវបានតភ្ជាប់ទៅនឹងបណ្តាញផ្គត់ផ្គង់ទឹករដ្ឋ ក្នុងឆ្នាំ២០០៥ ហើយនិងបណ្តាញអគ្គិសនីរដ្ឋក្នុងឆ្នាំ ២០០៧ ។ ឱកាសប្រកបរបរចិញ្ចឹមជីវិត របស់ពួកគេមានមាន ភាពល្អប្រសើរ និងមាន លទ្ធភាពប្រើប្រាស់បានហេត្ថារចនាសម្ព័ន្ធ និងសេវាសាធារណៈផ្សេងៗ។<br><br>**[សូមមើលផងដែរ ប្រអប់លេខ៧ ស្តីពីសហគមន៍អភិវឌ្ឍន៍មានជ័យ]** |
| | | | | |

*តារាងបន្តទំព័របន្ទាប់*

** តាមខេត្ត និងតាមលំដាប់អក្សរ*

| កន្លែងតាំងទីលំនៅថ្មី/ ទីកន្លែង | ចំនួន គ្រួសារ នៅទីតាំងថ្មី | ទីកន្លែងមុនការតាំងទីលំនៅថ្មី និងចំនួនគ្រួសារ | កាលបរិច្ឆេទនៃ ការបណ្តេញចេញ ឬ ការតាំងទីលំនៅថ្មី | ដំណើរការនៃការបណ្តេញចេញ/ការតាំងទីលំនៅថ្មី និង ស្ថានភាពទីតាំង |
|---|---|---|---|---|
| **អណ្តូង**<br><br>ភូមិអណ្តូង<br><br>សង្កាត់គោករកា ខ័ណ្ឌដង្កោរ | តាមការប៉ាន់ស្មាន គ្រួសារប្រជាពលរដ្ឋដែលបច្ចុប្បន្នកំពុងរស់នៅ ភូមិអណ្តូង មានចំនួន ប្រែប្រួលពី ៨០០ - ១៨០០ គ្រួសារ | ប្រជាពលរដ្ឋប្រមាណជា ៦០០ គ្រួសារ ដែលភាគ**ច្រើនជាអ្នកជួលផ្ទះ នៅតំបន់សំបុកចាប ក្នុងភូមិ** ១៤ នៅតាមដងទន្លេបាសាក់ ក្នុងសង្កាត់ ទន្លេបាសាក់ ខ័ណ្ឌចំការមន | ៦ មិថុនា ២០០៦ | <u>សរតា</u> ៖ ក្នុងឆ្នាំ២០០០ និង ២០០១ ដោយសារមានអគ្គីភ័យបានដុតបំផ្លាញផ្ទះសម្បែងរបស់ គ្រួសារប្រជាពលរដ្ឋ នៅផ្នែកខ្លះនៃទីតាំងក្នុងសង្កាត់ទន្លេបាសាក់ ដែលគេហៅថា សំបុកចាប ក្នុងភូមិ ១៤  ទើបប្រជាពលរដ្ឋប្រមាណជា ៣៥០០ - ៤០០០ គ្រួសារ ត្រូវបានគេឲ្យទៅតាំងទី លំនៅថ្មីនៅខ័ណ្ឌដង្កោរ និងខ័ណ្ឌឫស្សីកែវ ។ ប៉ុន្តែគ្រួសារជាច្រើនបានវិលត្រឡប់មកសំបុក ចាបវិញ ហើយស្នាក់នៅក្នុងតំបន់មិនរៀបរយនេះ។ ក្នុងខែឧសភា ឆ្នាំ២០០៦ ប្រជាពលរដ្ឋ ប្រមាណជា ១៥០០ គ្រួសារ (ម្ចាស់ផ្ទះ និង អ្នកជួលផ្ទះ) រស់នៅតំបន់សំបុកចាប ។<br><br>បន្ទាប់ពីមានការបណ្តេញចេញ ប្រជាពលរដ្ឋជាម្ចាស់ផ្ទះនៅសំបុកចាប នៅដើមខែឧសភា ឆ្នាំ២០០៦ និងការបំផ្លិចបំផ្លាញផ្ទះសម្បែងទាំងអស់ហើយនោះ អ្នកជួលផ្ទះបានបន្តរស់នៅ តំបន់សំបុកចាប ដោយគ្មានទីជម្រក។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួន ត្រូវបានគេរាំង មិនឲ្យចូលចែកជំនួយមនុស្សធម៌។<br><br><u>ការបណ្តេញចេញ</u> ៖ នៅព្រលឹម ថ្ងៃទី៦ ខែមិថុនា កម្មករក្រុមហ៊ុន សួរ ស្រ៊ុន ដោយមាន វត្តមាន នៃកំលាំងនគរបាលក្រុង និងកងរាជអាវុធហត្ថ ប្រមាណជា១០០០នាក់ ប្រដាប់ ដោយអាវុធវែង ខ្លី ដំបងឆក់ របាំងមុខ ការពារឧស្ម័ន និងគ្រឿងឧបករណ៍ការពារកុប្បកម្ម បានធ្វើការបណ្តេញអ្នកភូមិចេញ ។ គេមិន បានទុកពេលវេលាគ្រប់គ្រាន់ឲ្យ ប្រជាពលរដ្ឋទាំងនេះ រៀបចំវិចខ្ចប់របស់របរផ្ទាល់ខ្លួនឡើយ ។<br><br>ប្រជាពលរដ្ឋប្រមាណជា ៦០០ គ្រួសារ ត្រូវបានគេយកទៅដាក់នៅលើទីវាលមួយកន្លែង នៅអណ្តូង (ដីរបស់សាលារាជធានីភ្នំពេញ)  នៅពេលជាមួយគ្នានោះដែរ មានគ្រួសារប្រជាពលរដ្ឋខ្លះ បាននៅលើដីកម្មសិទ្ធិឯកជនស្ថិតនៅជាប់ទីនោះ ។<br><br><u>ចំនួន</u> ៖ នៅក្នុងអំឡុងពេលប៉ុន្មានថ្ងៃមុនការបណ្តេញចេញនេះ មានមនុស្សបន្ថែមទៀតមកពី កន្លែងផ្សេងៗក្នុងរាជធានីភ្នំពេញ ឬមកពីទីឆ្ងាយបានមកតាំងទីលំនៅ នៅសំបុកចាប ដោយសង្ឃឹម ថានឹងបានទទួលដីឡូតិ៍ ។ ក្រោយពីការទៅតាំងទីលំនៅថ្មីនៅអណ្តូង មានប្រជាពលរដ្ឋជាច្រើនបានបន្តចូលទៅតាំងទីលំនៅទីនោះ ។<br><br><u>ទីតាំង</u> ៖ នៅពេលតាំងទីលំនៅថ្មី ទីតាំងនេះខ្វះលក្ខណៈជាជម្រក ហេត្ថារចនាសម្ព័ន្ធ ជាមូលដ្ឋាន សេវាផ្គត់ផ្គង់ទឹក ឬ អនាម័យ និងសេវាចាំបាច់ផ្សេងទៀត ។ អានាម័យសមស្រប ប្រព័ន្ធលូបង្ហូរទឹក និងទឹកសំរាប់ប្រើប្រាស់គ្រប់គ្រាន់ នៅតែខ្វះខាតរហូតបច្ចុប្បន្ន ។<br><br>គ្រួសារទាំងនោះ ជួបប្រទះការលំបាកក្នុងជីវភាពរស់នៅ និងមានឱកាសតិចតួចសំរាប់ប្រកបរបរចិញ្ចឹមជីវិត ។ លំនៅដ្ឋាននៅមិនទាន់មានគ្រប់គ្រាន់សំរាប់គ្រួសារភាគច្រើន។ **[សូមមើលប្រអប់ លេខ៩ ៖ បញ្ហាគំរោងលំនៅដ្ឋាននៅអណ្តូង]**<br><br>មានការពឹងផ្អែកខ្លាំងលើអង្គការមិនមែនរដ្ឋាភិបាល(NGOs) ចំពោះជីវភាពរស់នៅ ការថែទាំសុខភាព ស្បៀងអាហារ និងការអប់រំក្នុងកំរិតខ្លះ ។ |



ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១ ៖ សេចក្តីសង្ខេបនៃករណីទាំងឡាយដែលបានសិក្សា *

| កន្លែងតាំងទីលំនៅថ្មី/ ទីកន្លែង | ចំនួន គ្រួសារ នៅទីតាំងថ្មី | ទីកន្លែងមុនការតាំងទីលំនៅថ្មី និងចំនួនគ្រួសារ | កាលបរិច្ឆេទនៃ ការបណ្តេញចេញ ឬ ការតាំងទីលំនៅថ្មី | ដំណើរការនៃការបណ្តេញចេញ/ការតាំងទីលំនៅថ្មី និងស្ថានភាពទីតាំង |
|---|---|---|---|---|
| **រាជធានីភ្នំពេញ (បន្ត)** | | | | |
| **ដំណាក់ត្រយឹង (ហៅ "បូរីសន្តិភាព ២")**<br><br>ក្នុងភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខ័ណ្ឌដង្កោរ | ម្ចាស់ផ្ទះចំនួន ៩១ គ្រួសារ បានទទួលផ្ទះម្នាក់មួយល្វែងពី ក្រុមហ៊ុន 7NG ចំណែកអ្នក ឯទៀត (ច្រើន ជាង ៣៣០ នាក់) ត្រូវគេ ទុកឲ្យនៅលើ ចិញ្ចើមថ្នល់ | នៅថ្ងៃ បណ្តេញចេញមានប្រជាពល រដ្ឋ ច្រើនជាង ៤០០ គ្រួសារ **(ម្ចាស់ ផ្ទះ ១៥០ និង ប្រមាណ ២០០ នាក់ ជា ម្ចាស់ស្តង់ ឬ អាជីវករ និង អ្នក ជួលផ្ទះ ដែល គេ មិនដឹងចំនួន ពិត ប្រាកដ) នៅ តំបន់ដីក្រហម** ស្ថិតក្នុងសង្កាត់ទន្លេបាសាក់<br><br>ខ័ណ្ឌចំការមន<br><br>ចំនួនគ្រួសារ សរុបពីដំបូង មាន ១.៤៦៥ (ម្ចាស់ផ្ទះ) យោងតាមស្ថិតិផ្លូវការ | | <u>សវតា</u> ៖ អ្នកភូមិដីក្រហមបានរស់នៅក្នុងសង្កាត់ទន្លេបាសាក់ តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០។ គ្រួសារជាច្រើនបានដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីធ្លី តាមរយៈប្រព័ន្ធចុះបញ្ជីដាច់ដោយដុំ ប៉ុន្តែ ពាក្យសុំរបស់ពួកគាត់មិនត្រូវបានពិនិត្យសំរេចគ្រប់គ្រាន់ទេ ។ ក្នុងឆ្នាំ២០០៣ គណៈរដ្ឋមន្ត្រី បានប្រកាសថា ទីតាំងដីក្រហម គឺជាសម្បទានដីសង្គមកិច្ច ។ ក្នុងការដោះដូរសំរាប់ការ អភិវឌ្ឍន៍នៅនឹងកន្លែង អាជ្ញាធរបានចាត់ចែងអោយមានការរៀបចំ ការចែករំលែកដីជាមួយ ក្រុមហ៊ុនឯកជន 7NG ។ ក្នុងឆ្នាំ ២០០៥ ក្រុមហ៊ុននេះបានចុះកិច្ចសន្យាមួយ ជាមួយតំណាង សហគមន៍ និង ប្រធានភូមិ ដោយយល់ព្រមឲ្យក្រុមហ៊ុន 7NG សង់ផ្ទះល្វែង ឲ្យសហគមន៍នៅ ដំណាក់ត្រយឹងជាថ្នូរនឹងដីនៅតំបន់ដីក្រហម។ កិច្ចសន្យានេះ ត្រូវបានគ្រួសារភាគច្រើននៅ ដីក្រហមច្រានចោល ដោយពួកគេជ្រើសរើសអ្នកតំណាងថ្មី និងទាមទារអោយ មោឃភាពកិច្ចសន្យានេះ។<br><br>ចាប់តាំងពី ខែសីហា ឆ្នាំ២០០៦មក អ្នកភូមិ ទទួលរងការគាបសង្កត់អោយចាកចេញ ពីតំបន់ ដីក្រហម ។ យោងស្ថិតិផ្លូវការរបស់សាលាក្រុងភ្នំពេញ គិតត្រឹមខែកុម្ភ ឆ្នាំ២០០៨ មាន ប្រជាពលរដ្ឋចំនួន ១.៣៧៤ គ្រួសារ (ត្រូវជា ៩៣ភាគរយ) នៃចំនួនសរុប បានយល់ព្រម និងផ្ទេរលំនៅដ្ឋានចេញពីដីក្រហម ។ គ្រួសារដែលនៅសល់ បានបន្តរស់នៅ លើដីក្រហម រហូតដល់ថ្ងៃបណ្តេញចេញ ។<br><br><u>ការបណ្តេញចេញ</u> ៖ ក្នុងឆ្នាំ២០០៨ សាលារាជធានីភ្នំពេញ បានបង្កើនការចរចាលើប្រាក់ សំណងរវាងក្រុមហ៊ុន 7NG និងអ្នកភូមិ ។ នៅដើមខែមករា ឆ្នាំ២០០៩ ការចរចានេះត្រូវបាន បញ្ឈប់ភ្លាមៗដោយមិនមានការពន្យល់អំពីមូលហេតុឡើយ។<br><br>ការការពារខាងនីតិវិធីមិនត្រូវបានគេគោរព ។ នៅយប់ និងនៅព្រឹកព្រលឹម ថ្ងៃទី២៣ – ២៤ ខែ មករា ឆ្នាំ២០០៩ នគរបាល កងរាជអាវុធហត្ថ និងកម្មករក្រុមហ៊ុន បានធ្វើការបណ្តេញអ្នកភូមិ ចេញ ។ ពួកគេបានប្រើប្រាស់កំលាំង ដើម្បីបណ្តេញប្រជាពលរដ្ឋ និង ប្រើប្រាស់គ្រឿងយន្ត ធុនធ្ងន់ដើម្បី ឈូសកំទេចផ្ទះសម្បែង ។ នគរបាល និងសមាជិកសហគមន៍បានប៉ះទង្គិចគ្នា ដែលបណ្តាលឲ្យមនុស្សយ៉ាងតិច ១៨ នាក់ ត្រូវរងរបួស ។<br><br><u>ទីតាំង</u> ៖ នៅដំណាក់ត្រយឹង មានតែម្ចាស់ផ្ទះ ៩១ គ្រួសារប៉ុណ្ណោះ ដែលក្រុមហ៊ុន 7NG និងសាលា រាជធានីភ្នំពេញទទួលស្គាល់ ហើយបានទទួលផ្ទះល្វែង ។ គ្រួសារជាច្រើន បានត្អូញត្អែរអំពីភាពមិនសម្បូរមនៃផ្ទះល្វែង ដែលគេកំពុងតែរស់នៅ និងការខ្វះប្រាក់ចំណូល និងឱកាសប្រកបរបរចិញ្ចឹមជីវិត ។<br><br>ម្ចាស់ផ្ទះដទៃទៀត ក៏ដូចជា អាជីវករ និងអ្នកជួលផ្ទះ ត្រូវបានគេទុកឲ្យនៅតាមចិញ្ចើមថ្នល់ ។ ពួកគាត់បានរស់នៅក្នុងជម្រកបណ្តោះអាសន្ន ដោយមិនមានទឹកប្រើប្រាស់ និងអានាម័យ ឬសេវាមូលដ្ឋាន រហូតដល់ ពេលពួកគេផ្លាស់ទៅទីតាំងថ្មីនៅខេត្តកណ្តាល។<br><br>[សូមមើលខាងក្រោម ភូមិស្រះពោធិ ខេត្តកណ្តាល] |
| | | | | |

*តារាងបន្តទំព័របន្ទាប់*

| កន្លែងតាំងទីលំនៅថ្មី/ ទីកន្លែង | ចំនួនគ្រួសារ នៅទីតាំងថ្មី | ទីកន្លែងមុនការ តាំងទីលំនៅថ្មី និងចំនួនគ្រួសារ | កាលបរិច្ឆេទនៃ ការបណ្តេញចេញ ឬការតាំងទីលំនៅថ្មី | ដំណើរការនៃការបណ្តេញចេញ/ការតាំងទីលំនៅថ្មី និង ស្ថានភាពទីតាំង |
|---|---|---|---|---|
| **ទួលសំបូរ**<br>ភូមិទួលសំបូរ សង្កាត់ព្រៃវែង<br>ខ័ណ្ឌដង្កោរ | គ្រួសារសរុប ២៨០ - ២៩០ | ៩៥ គ្រួសារ ក្នុង**នោះមាន ៩២ គ្រួសារ ដែលមានសមាជិក គ្រួសារផ្ទុក មេរោគអេដស៍/ជម្ងឺអេដស៍ នៅបូរីកីឡា** ក្នុងសង្កាត់វាល វង់ ខ័ណ្ឌ ៧ មករា<br>២០០ គ្រួសារ បានតាំងទីលំនៅថ្មីក្នុងឆ្នាំ ១៩៩៩/២០០០ (មិនមែនជា កម្មវត្ថុនៃការ សិក្សានេះទេ)<br>៣៩ គ្រួសារ បានតាំងទីលំនៅថ្មីក្នុងឆ្នាំ ២០១០ (មិនមែនជាកម្មវត្ថុនៃការសិក្សានេះទេ*) | ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៩ (២១ គ្រួសារ)<br>ខែកក្កដា ឆ្នាំ២០០៩ (២៥ គ្រួសារ) | <u>សវតា</u> ៖ ទីតាំងបូរីកីឡា គឺជាកម្មវត្ថុនៃការរៀបចំបែងចែកដីរវាងសាលារាជធានីភ្នំពេញ ក្រុមហ៊ុនផានីមិច និងសហគមន៍ ដោយហេតុនេះ ម្ចាស់ផ្ទះល្វែង និងអ្នកជួលផ្ទះរយៈពេលវែង ទាំងអស់ ត្រូវទទួលបានផ្ទះមួយល្វែង ក្នុងអាគារថ្មី ដែលក្រុមហ៊ុនបានសន្យាសាងសង់ ។ ក្នុង ឆ្នាំ២០០៧ ប្រជាពលរដ្ឋ ២១ គ្រួសារដែលផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ត្រូវបានគេបណ្តេញចេញពីផ្ទះល្វែងរបស់ខ្លួន ហើយបាន ផ្លាស់ទៅ រស់នៅក្នុងជម្រកបណ្តោះអាសន្នមួយ ហៅថា "ផ្ទះខៀវ" ដោយគេមិនបានផ្តល់លទ្ធភាពឲ្យពួកគាត់បានធ្វើសម្ភាសន៍និងពិនិត្យវាយតំលៃ ដើម្បីសំរេចអំពីសិទ្ធិ ទទួលផ្ទះល្វែងឡើយ ។ ក្នុងឆ្នាំ ២០០៨ មានប្រជាពលរដ្ឋច្រើនជាង ៥០ គ្រួសារ ដែលផ្ទុកមេ រោគអេដស៍/ជម្ងឺអេដស៍ នៅបូរីកីឡា រាប់ទាំងប្រជាពលរដ្ឋ២១គ្រួសារទៀត ដែលស្នាក់នៅ "ផ្ទះខៀវ" មានការសន្យាពីសាលា រាជធានីភ្នំពេញ និង សម្តេចនាយករដ្ឋមន្ត្រី ថានឹងផ្តល់ដីឲ្យពួកគាត់ ដោយសន្មត់ថា ក្នុងចំណោមពួកគាត់ មិនមាននរណាម្នាក់ ត្រូវទទួល បានផ្ទះល្វែងនៅបូរីកីឡាឡើយ។ សាលារាជធានីភ្នំពេញបានប្រគល់ដីឡូត៍ឲ្យពួកគាត់ នៅ ទួលសំបូរ ហើយក្រោយមក បានយល់ព្រមសាងសង់ ទីជម្រកនៅទីតាំងនោះ ។<br><u>ការតាំងទីលំនៅថ្មី</u> ៖ នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៩ គ្រួសារប្រជាពលរដ្ឋដែលរស់នៅក្នុង "ផ្ទះខៀវ" ត្រូវបានគេឲ្យរុះរើទៅនៅតំបន់ទួលសំបូរ ដោយមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន។ ក្នុងខែកក្កដា ប្រជាពលរដ្ឋនៅសល់ប្រហែលជា ២០ គ្រួសារ ដែលបានស្នើសុំដីទៅនាយករដ្ឋ មន្ត្រី ក៏ត្រូវបានគេឲ្យទៅតាំងទីលំនៅថ្មីនៅទួលសំបូរផងដែរ ។<br><u>ទីតាំង</u> ៖ គ្រួសារនីមួយៗត្រូវបានគេបែងចែកផ្ទះល្វែងតូចមួយ ក្នុងអាគារប្រក់ស័ង្កសី ដែល សាលារាជធានីភ្នំពេញបានសាងសង់។ វាបង្ហាញឲ្យឃើញច្បាស់ភ្លាមៗថា អាគារទាំងនេះមិន គ្រប់លក្ខណៈទេ និងបានគំរាមកំហែងដល់សុខភាព និងសន្តិសុខ ។ មានបញ្ហាខាងសន្តិសុខស្បៀង និងការទទួលបានកិច្ចគាំពារសុខភាព ក៏ដូចជាធ្វើអោយអាសោចកេរ្តិ៍ឈ្មោះ (ស្ទីកម៉ា) ។<br>កិច្ចសហការគ្នាក្នុងចំណោមអាជ្ញាធរជាតិ និងអាជ្ញាធរក្រុង ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាលបាននាំឲ្យស្ថានភាពខាងលំនៅដ្ឋាន និងជីវភាពរស់នៅរបស់គ្រួសារទាំងនោះមានលក្ខណៈល្អប្រសើរឡើង ។ |

** ប្រហែល២០០ គ្រួសារដែលបានតាំងទីលំនៅថ្មីដោយសន្តិវិធីក្នុងឆ្នាំ១៩៩៩-២០០០។ ពួកគេភាគច្រើនមកពីសង្កាត់បឹងសឡាង ទួលគោក និងតំបន់ពួកឬស្សី ក្នុងខ័ណ្ឌមានជ័យនៅដើមឆ្នាំ២០១០ និងមាន ៣៩គ្រួសារបានស្ម័គ្រចិត្តផ្លាស់ទីលំនៅពីច្រាំងទន្លេនៅខ័ណ្ឌឫស្សីកែវមករស់នៅទួលសំបូរ (សូមមើលប្រអប់លេខ១៥)*

# ឧបសម្ព័ន្ធ

## ឧបសម្ព័នទី១ ៖ សេចក្តីសង្ខេបនៃករណីទាំងឡាយដែលបានសិក្សា

| កន្លែងតាំងទីលំនៅថ្មី/ ទីកន្លែង | ចំនួនគ្រួសារ នៅទីតាំងថ្មី | ទីកន្លែងមុនការ តាំងទីលំនៅថ្មី និងចំនួនគ្រួសារ | កាលបរិច្ឆេទនៃ ការបណ្តេញចេញ ឬការតាំងទីលំនៅថ្មី | ដំណើរការនៃការបណ្តេញចេញ/ការតាំងទីលំនៅថ្មី និងស្ថានភាពទីតាំង |
| --- | --- | --- | --- | --- |
| **រាជធានីភ្នំពេញ (បន្ត)** | | | | |
| **ត្រពាំងអញ្ចាញ** ក្នុងភូមិត្រពាំងអញ្ចាញ សង្កាត់ត្រពាំងក្រសាំង ខ័ណ្ឌដង្កោរ | តាមកំណត់ហេតុផ្លូវការមាន ១៩៣៧ គ្រួសារ<br><br>តាមការប៉ាន់ស្មានបច្ចុប្បន្ននេះ មាន ប្រជាពលរដ្ឋ ៧០០ - ៨០០ គ្រួសារ រស់នៅជា អចិន្រ្តៃយ៍នៅទីតាំងនេះ | ប្រជាពលរដ្ឋ ជាង ១០០០ គ្រួសារ ដែល ជា**ម្ចាស់ផ្ទះនៅសំបុកចាប** ក្នុងភូមិ ១៤ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន<br><br>ប្រជាពលរដ្ឋ តិចជាង២០០ គ្រួសារ មកពី កន្លែងផ្សេងៗ (មិនមែនជាកម្មវត្ថុនៃការសិក្សានេះទេ)* | ១-៥ ឧសភា ២០០៦ | <u>សវតា</u> ៖ មានប្រជាពលរដ្ឋច្រើនជាង១០០០ គ្រួសារ ដែលជាម្ចាស់ផ្ទះនៅសំបុកចាប **[សូមមើល សេចក្តីអធិប្បាយខាងលើអំពីអណ្តូង សំរាប់សវតាបន្ថែមអំពីសហគមន៍សំបុកចាប]**<br><u>ការបណ្តេញចេញ</u> ៖ នៅព្រឹកព្រលឹម ថ្ងៃទី៣ ខែឧសភា នគរបាល អាជ្ញាធរក្រុង និងអាជ្ញាធរ ខ័ណ្ឌ ដែលមានទាំងកំលាំងសន្តិសុខប្រដាប់ដោយអាវុធ និងដំបងឆក់ បានធ្វើការ បណ្តេញគ្រួសារប្រជាពលរដ្ឋ ដែលមានបង្កាន់ដៃទទួលដីឡូតិ៍នៅកន្លែងតាំងទីលំនៅថ្មី ក្នុងភូមិត្រពាំងអញ្ចាញ។<br><u>ទីតាំង</u> ៖ ពេលមកដល់ទីតាំងថ្មី គ្រួសារនីមួយៗបានទទួលដីមួយឡូតិ៍ទំហំ (៥ ម x ១២ ម) ។ មិន មានផ្ទះទេ ។ នៅថ្ងៃតាំងទីលំនៅថ្មីនោះ ការសាងសង់ផ្សារមួយ និងសាលាបឋមសិក្សាមួយ កំពុងស្ថិតក្នុងដំណាក់កាលដំបូង ហើយមណ្ឌលសុខភាព នៅមិនទាន់បានសាងសង់នៅឡើយទេ គេត្រូវប្រើពេលពីរបីខែទៀត ដើម្បីសង់អាគារទាំងនេះឲ្យចប់សព្វគ្រប់ ។<br><br>ទីតាំងនោះងាយនឹងលិចទឹក ហើយមិនមានប្រព័ន្ធលូបង្ហូរទឹកគ្រប់គ្រាន់ ។ មិនមាន ជម្រក ឬ ហេត្ថារចនាសម្ព័ន្ធជាមូលដ្ឋាន ត្រូវបានសាងសង់មុនការតាំងទីលំនៅថ្មីនេះទេ ។ អនាម័យមិនគ្រប់គ្រាន់ ហើយទឹកមានតំលៃខ្ពស់ ។ |
| | | | | |

*តារាងបន្តទំព័របន្ទាប់*

** យោងតាមតំណាងសហគមន៍គិតមកដល់ខែវិច្ឆកា ឆ្នាំ២០០៩មានប្រជាពលរដ្ឋ១២១៦គ្រួសារមកពីសំបុកចាប មាន៤២គ្រួសារមកពីបុរីកីឡា មាន៣៦គ្រួសារមកពីច្បារអំពៅ ក្នុងខណ្ឌមានជ័យ មាន១៣២គ្រួសារមកពីជ្រោយចង្វា ក្នុងខណ្ឌឫស្សីកែវ និងមាន១១គ្រួសារមកពីក្រុម៧៨ក្នុងខណ្ឌចំការមន*

| កន្លែងតាំងទីលំនៅថ្មី/ ទីកន្លែង | ចំនួនគ្រួសារ នៅទីតាំងថ្មី | ទីកន្លែងមុនការ តាំងទីលំនៅថ្មី និងចំនួនគ្រួសារ | កាលបរិច្ឆេទនៃ ការបណ្តេញចេញ ឬការតាំងទីលំនៅថ្មី | ដំណើរការនៃការបណ្តេញចេញ/ការតាំងទីលំនៅថ្មី និងស្ថានភាពទីតាំង |
|---|---|---|---|---|

## ខេត្តកណ្តាល

| | | | | |
|---|---|---|---|---|
| **ភូមិស្រះពោធិ** ឃុំភ្នំបាត ស្រុកពញាឮ | ៥១០ គ្រួសារ | **ដំណាក់ ត្រយឹង** ភូមិដំណាក់ ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោរ រាជធានីភ្នំពេញ<br><br>មានប្រជាពលរដ្ឋ ៥៦៥ គ្រួសារ ក្នុង ខែវិច្ឆិកា ឆ្នាំ ២០០៩។ | ខែធ្នូ ឆ្នាំ ២០០៩ | សវតា ៖ អាជីវករ និងអ្នកជួលផ្ទះ ដែលត្រូវបានគេបណ្តេញចេញពីដីក្រហម ក្នុងខែមករា ឆ្នាំ២០០៩ បានរស់នៅលើចិញ្ចើមថ្នល់នៅដំណាក់ត្រយឹងក្នុងស្ថានភាពលំបាកបំផុត រហូត ដល់ខែធ្នូ ឆ្នាំ២០០៩ ។<br><br>តួលេខ ៖ អង្គការក្រៅរដ្ឋាភិបាល បានធ្វើការប៉ាន់ស្មានថា មានប្រជាពលរដ្ឋ ៣៣៥ គ្រួសារ ភ្លាមៗបន្ទាប់ពីថ្ងៃបណ្តេញចេញ ហើយតាមឯកសារផ្លូវការពីតំណាងសហគមន៍ បញ្ជាក់ថា មានប្រជាពលរដ្ឋ ៥៦៥ គ្រួសារ ក្នុងខែវិច្ឆិកា ឆ្នាំ២០០៩។ តាមតំណាងសហគមន៍ថ្មីនៅភូមិ ស្រះពោធិ បច្ចុប្បន្ននេះ មានប្រជាពលរដ្ឋនៅទីនោះ ៥១០ គ្រួសារ ។<br><br>ការបណ្តេញចេញ និងទីតាំង ៖ ក្រុមហ៊ុន 7NG បានផ្តល់ដីឡូតិ៍ឲ្យគ្រួសារទាំងនោះ ក្នុងមួយ គ្រួសារទំហំ (៤ ម x ៦ ម) ក្នុងភូមិស្រះពោធិ ។ ដោយសារគ្មានជំរើសផ្សេងពីនេះ គ្រួសារទាំង នោះបានយល់ព្រមប្តូរទីតាំងទៅនៅទីនោះ ។ ពួកគាត់បានចាប់ផ្តើមកសាងជីវិតឡើងវិញជាថ្មីម្តងទៀត នៅលើដីទទេ ដែលទីតាំងថ្មីនេះប្រឈមនឹងទឹកជំនន់ ដោយគ្មានហេដ្ឋារចនាសម្ព័ន្ធ និងសេវាដែលអាចប្រើប្រាស់បានទេ ។ |

# ឧបសម្ព័ន្ធ

## ឧបសម្ព័នទី១ ៖ សេចក្តីសង្ខេបនៃករណីទាំងឡាយដែលបានសិក្សា

| កន្លែងតាំងទីលំនៅថ្មី/ ទីកន្លែង | ចំនួនគ្រួសារនៅទីតាំងថ្មី | ទីកន្លែងមុនការ តាំងទីលំនៅថ្មី និងចំនួនគ្រួសារ | កាលបរិច្ឆេទនៃការបណ្តេញចេញ ឬការតាំងទីលំនៅថ្មី | ដំណើរការនៃការបណ្តេញចេញ/ការតាំងទីលំនៅថ្មី និងស្ថានភាពទីតាំង |
|---|---|---|---|---|
| **ខេត្តព្រះសីហនុ** | | | | |
| **អូរកម្ពុជា**<br>ក្នុងសង្កាត់រាម ខ័ណ្ឌព្រៃនប់ | ៤៦ គ្រួសារ | ៤៦ គ្រួសារ នៅ **តំបន់ក្បាលហុង** ក្នុងភូមិអុង សង្កាត់រាម ខ័ណ្ឌព្រៃនុប | ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ | <u>សវតា</u> ៖ គ្រួសារនៅតំបន់ក្បាលហុង ក្នុងនោះ គ្រួសារខ្លះបាន និងកំពុងប្រកបរបរកសិកម្ម និងរស់នៅលើដីនោះតាំងពីឆ្នាំ១៩៩៧ បានរងការគំរាមបណ្តេញចេញពីសំណាក់កងទ័ពជើងទឹកតាំងពីឆ្នាំ២០០៤ ។ ក្នុងឆ្នាំ២០០៦ កងទ័ពជើងទឹកបានរឹបអូសយកដីស្រែចំការរបស់គ្រួសារប្រជាពលរដ្ឋ ។ ចាប់ពីឆ្នាំ២០០៧ កងទ័ពជើងទឹក បានរារាំងប្រជាពលរដ្ឋមិនឲ្យជួសជុលនិងសាងសង់ផ្ទះសម្បែងរបស់ខ្លួន ហើយពេលខ្លះបានប្រើប្រាស់កំលាំងទៀតផង។ ដោយខ្លាចបាត់បង់ដីលំនៅដ្ឋានរបស់ខ្លួន គ្រួសារទាំងនោះបានងាកមករកអាជ្ញាធរឃុំ ដើម្បីសុំជួយអន្តរាគមន៍ ហើយអាជ្ញាធរឃុំបានបញ្ចុះបញ្ចូលកងទ័ពជើងទឹកឲ្យយល់ព្រមផ្តល់ដីឲ្យប្រជាពលរដ្ឋនៅតំបន់ផ្សេង ។<br><br><u>ការបណ្តេញចេញ</u> ៖ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ ក្នុងកិច្ចប្រជុំមួយដែលបានរៀបចំឡើង ដោយមេបញ្ជាកងទ័ពជើងទឹក ស្ថិតក្នុងវត្តមាននៃមន្ត្រីភូមិ និងមន្ត្រីឃុំ គេបានប្រកាសប្រាប់ អំពីការតាំងទីលំនៅថ្មីនៃគ្រួសារទាំងនោះទៅកាន់តំបន់អូរកម្ពុជា ដែលគេបានរៀបចំដីឡូត៍ ក្នុងមួយឡូត៏ៗទំហំ (២០ ម x ៣០ ម) ដើម្បីបែងចែកឲ្យប្រជាពលរដ្ឋសរុប ៤៦ គ្រួសារ តាមរយៈការចាប់ឆ្នោត ។ គ្រួសារទាំងអស់បានចាប់ផ្តើមចាកចេញនៅថ្ងៃប្រកាសនោះ ហើយត្រូវដឹកជញ្ជូនរបស់របរផ្ទាល់ខ្លួន និងសាងសង់ផ្ទះសម្បែងនៅទីតាំងថ្មីដោយខ្លួនឯង ។<br><br><u>ទីតាំងថ្មី</u> ៖ ខ្វះខាតហេត្ថរចនាសម្ព័ន្ធ និងសេវាជាមូលដ្ឋាន ហើយផ្លូវទៅកាន់កន្លែងតាំងទីលំនៅថ្មីក៏នៅមិនទាន់បានឈូសឆាយនៅឡើយ ។ ទីតាំងថ្មីនេះ ស្ថិតនៅឆ្ងាយពីសាលារៀន និងឱកាសប្រកបរបរចិញ្ចឹមជីវិត ។ |
| | | | | |

*តារាងបន្តទំព័របន្ទាប់*

| កន្លែងតាំងទីលំនៅថ្មី/ ទីកន្លែង | ចំនួនគ្រួសារ នៅទីតាំងថ្មី | ទីកន្លែងមុនការ តាំងទីលំនៅថ្មី និងចំនួនគ្រួសារ | កាលបរិច្ឆេទនៃ ការបណ្តេញចេញ ឬការតាំងទីលំនៅថ្មី | ដំណើរការនៃការបណ្តេញចេញ/ការតាំងទីលំនៅថ្មី និងស្ថានភាពទីតាំង |
|---|---|---|---|---|
| **ស្ពានឆេះ**<br><br>នៅតាមចិញ្ចើមផ្លូវ ជិតផ្ទេរ អូត្រេះ ក្នុងសង្កាត់លេខ៤ ខ័ណ្ឌមិត្តភាព | ៧១ គ្រួសារ (គ្រួសារឯទៀតបានទៅរស់នៅជាមួយបងប្អូនសាច់ញាតិ នៅកន្លែងផ្សេងៗ) | ១០៧ គ្រួសារ **ស្ពានឆេះ** ក្នុងសង្កាត់លេខ៤ ខ័ណ្ឌមិត្តភាព | មានការព្យាយាមបណ្តេញ ចេញ នៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៦<br><br>ការបណ្តេញចេញ នៅថ្ងៃទី ២០ ខែមេសា ឆ្នាំ២០០៧ | <u>សវតា</u> ៖ នគរបាល និង កងរាជអាវុធហត្ថច្រើនជាង ៨០ នាក់ បានព្យាយាមបណ្តេញគ្រួសារ ប្រជាពលរដ្ឋចេញពីដី ក្នុងឆ្នាំ២០០៦ ដោយគ្មានការជូនដំណឹងជាមុន ។ កំលាំងនគរបាល បានអះអាងថា ដីនោះជាកម្មសិទ្ធិរបស់បុគ្គលឯកជន ។ សមាជិកសហគមន៍បានជំទាស់នឹងការបណ្តេញចេញនេះ ។ បន្ទាប់មក សាលាខេត្តព្រះសីហនុបានចេញសេចក្តីជូនដំណឹង អំពីការបណ្តេញចេញលើកទីមួយ ក្នុងខែតុលា ឆ្នាំ២០០៦ ហើយសេចក្តីជូនដំណឹងលើកទីពីរ ក្នុងខែមករា ឆ្នាំ២០០៧ ។ គ្រួសារប្រជាពលរដ្ឋមិនព្រមអនុវត្តតាម ។<br><br><u>ការបណ្តេញចេញ</u> ៖ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៧ មានកងកំលាំងប្រដាប់អាវុធ ប្រមាណជា ១៥០ នាក់ រួមមាន កងរាជអាវុធហត្ថ នគរបាល កងយោធពលខេមរភូមិន្ទ ប្រដាប់ដោយអាវុធ ដំបងឆក់ និងឧស្ម័នបង្ហូរទឹកភ្នែក បានធ្វើការបណ្តេញប្រជាពលរដ្ឋចេញ ពីផ្ទះសម្បែង ។ ការបណ្តេញចេញនេះប្រើហឹង្សា ដែលបណ្តាលឲ្យបុរស ១៣ នាក់ និងស្ត្រីប្រាំនាក់បានរងរបួស ។ ផ្ទះប្រជាពលរដ្ឋ ត្រូវបានដុះបំផ្លាញ ឬវាយកំទេច ក្នុងពេលបណ្តេញចេញនេះ ហើយសមាជិកសហគមន៍ដប់បីនាក់ ត្រូវបានចាប់ខ្លួន និងឃុំខ្លួន នៅពេលបន្ទាប់មក ។<br><br><u>ទីតាំងថ្មី</u> ៖ គ្រួសារទាំងនោះ មិនបានទទួលដីធ្លី ឬសំណងណាមួយឡើយ ដូច្នេះពួកគាត់ត្រូវ ស្នាក់នៅជាបណ្តោះអាសន្ននៅតាមចិញ្ចើមថ្នល់ជិតទីតាំងដើមរបស់ពួកគាត់ ហើយបានរស់ទីនោះរហូតមកទល់សព្វថ្ងៃនេះ ។ |

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី២៖ ឯកសារចេញផ្តល់ឲ្យអ្នកតាំងទីលំនៅថ្មី ដើម្បីទទួលស្គាល់កម្មសិទ្ធិ*

### រាជធានីភ្នំពេញ

**សហគមន៍អភិវឌ្ឍន៍មានជ័យ** គឺជាសហគមន៍តែមួយគត់ដែលបានទទួលឯកសារពីការិយាល័យ/មន្ទីររៀបចំដែនដី ។ ក្នុងឆ្នាំ ២០០២ គ្រួសារប្រជាពលរដ្ឋមួយចំនួនបានទទួល "ប័ណ្ណសំគាល់សិទ្ធិ កាន់កាប់អចលនវត្ថុ" [ឯកសារ ១] ដែលចេញដោយការិយាល័យ/មន្ទីររៀបចំដែនដីក្រុង/ស្រុក ។ ក្នុងខែមីនា ឆ្នាំ២០០៩ គ្រួសារខ្លះបានទទួលប័ណ្ណកម្មសិទ្ធិដីធ្លី[ឯកសារ ២] តាមរយៈការ ចុះបញ្ជីដី ជាប្រព័ន្ធ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ជាការគួរកត់សំគាល់ថា គ្រួសារនៃសហគមន៍នេះបានទទួលប័ណ្ណកម្មសិទ្ធិដីរយៈពេលដប់ឆ្នាំ បន្ទាប់ពី ពួកគេបានតាំងលំនៅថ្មីក្នុងឆ្នាំ១៩៩៩ មិនមែនរយៈពេលប្រាំឆ្នាំនោះទេ ហើយវាទំនងជាកើតឡើងស្របពេលគ្នា ដែលមន្ទីររៀបចំដែនដី ធ្វើការកំនត់តំបន់វិនិច្ឆ័យរបស់ខ្លួន សំរាប់ការចេញប័ណ្ណកម្មសិទ្ធិ ។



*ឯកសារ ១ និង ២ បានពីអភិវឌ្ឍន៍មានជ័យ, រាជធានីភ្នំពេញ*

**នៅអណ្តូង** ប្រជាពលរដ្ឋដែលបានទទួល "ដីឡូត៍ផ្លូវការ" ក្នុងឆ្នាំ២០០៦ បានទទួល "ប័ណ្ណលឿង" [ឯកសារ៣ ] និង "កិច្ចសន្យាទទួលគោលនយោបាយសម្បទានដីសង្គមកិច្ច" [ឯកសារ ៤] ។ ប័ណ្ណលឿងមានចុះលេខដីឡូត៍ និងមានចុះហត្ថលេខា និងត្រាដោយអភិបាលរងស្រុក និងឈ្មោះអ្នកទទួលដីឡូត៍ ។ បើតាមកិច្ចសន្យា ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦ អ្នកទទួលដីឡូត៍ ត្រូវសន្យា ៖

១) សាងសង់ជម្រកស្នាក់នៅ ក្នុងរយៈពេលយ៉ាងយូរ ៣០ ថ្ងៃ ក្រោយពីទទួលបានដីឡូត៍។

២) ស្នាក់នៅក្នុងជម្រកនេះជាអចិន្ត្រៃយ៍ រហូតដល់អាចទទួលបានសិទ្ធិគ្រប់គ្រាន់ ។

៣) មិនធ្វើការលក់ដូរដី ដោយមិនមានការអនុញ្ញាតពីសាលាក្រុងភ្នំពេញ ។ ករណីមានលួចលក់ ដូរ ឬផ្ទេរឲ្យអ្នកដទៃ ឬជូលឲ្យអ្នកដទៃ ខ្ញុំបាទ/នាងខ្ញុំសុខចិត្តអោយអាជ្ញាធរដកហូតវិញ ដោយឥតលក្ខខ័ណ្ឌ ។

៤) ចូលរួមចំណែក និងសហការការពារសន្តិសុខ សណ្តាប់ធ្នាប់ អភិវឌ្ឍន៍ ថែរក្សា ការពារទ្រព្យសម្បត្តិ សាធារណៈ ដែលមាននៅតំបន់ រួមទាំងការពារបរិស្ថានជុំវិញតំបន់។

៥) សុខចិត្តចូលរួមគ្រប់គ្រង និង កាន់កាប់ដីធ្លីក្នុងនាមទ្រព្យសម្បត្តិសម្ងហភាព ដោយសុខចិត្តចងក្រងជាសហគមន៍ឡើង ដើម្បីដឹកនាំ ។

គ្រួសារទាំងឡាយដែលបានទទួលផ្ទះល្វែងដែលសាងសង់ដោយមូលនិធិ UPDF/MPP នៅអណ្តូងត្រូវបានគេ ប្រាប់នៅពេលដែលពួកគេបានបង់ថ្លៃឈ្នួលផ្ទះចប់សព្វគ្រប់ គេនឹងចេញឲ្យពួកគាត់នូវប័ណ្ណកម្មសិទ្ធិដីធ្លីដូចគ្នា នឹងប្រជាពលរដ្ឋនៅត្រពាំងអញ្ចាញដែរ ។

*ឯកសារ គឺរៀបតាមខេត្ត និងតាមលំដាប់អក្សរ។ ឯកសារទាំងនេះគឺបានទទួលពីគ្រួសារដែលបានតាំងទីលំនៅថ្មី*

## ឧបសម្ព័ន្ធទី២៖ ឯកសារចេញផ្តល់ឲ្យអ្នកតាំងទីលំនៅថ្មី ដើម្បីទទួលស្គាល់កម្មសិទ្ធិ(បន្ត)



*ឯកសារ ៣ និង ៤ បានពីអណ្តូង, រាជធានីភ្នំពេញ*

**អតីតប្រជាពលរដ្ឋរស់នៅដីក្រហមដែលបានតាំងទីលំនៅថ្មីនៅដំណាក់ត្រយឹង** បានទទួលឯកសារបីប្រភេទផ្សេងៗគ្នា ។ ឯកសារទីមួយគឺជា "តារាង ស្ថិតិចំនួនគ្រួសារ" [ឯកសារ៥] ដែលចេញដោយក្រុមហ៊ុន 7NG និងទទួលស្គាល់យល់ព្រមដោយអាជ្ញាធរ (ប្រធានភូមិ ចៅសង្កាត់ និងអភិបាលខ័ណ្ឌ) នៅទីតាំងដើម ខ័ណ្ឌចំការមន ។ តារាងនោះបានបញ្ជាក់ថា "គ្រួសារបានស្ម័គ្រចិត្តទៅរស់នៅតំបន់អភិវឌ្ឍន៍ថ្មីរបស់ក្រុមហ៊ុន 7NG ស្ថិតនៅភូមិដំណាក់ត្រយឹង ដែលក្រុមហ៊ុនបានប្រគល់ផ្ទះ ល្វែងមួយដែលមានទំហំ (៤ ម x ១២ ម) ហើយគ្រួសារមិនទាមទារអ្វីបន្ថែមទៀតទេ"។ ឯកសារទីពីរ គឺ "ប័ណ្ណទទួលយកផ្ទះល្វែងថ្មី" [ឯកសារ៦] ចេញដោយក្រុមហ៊ុន 7NG ។ ឯកសារចុងក្រោយគឺ "លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី/ផ្ទះសម្បែង" [ឯកសារ៧] ចុះហត្ថលេខា រវាងក្រុមហ៊ុន 7NG និងអ្នកទទួលផ្ទះល្វែងដោយមាន ចៅសង្កាត់ និងអភិបាលខ័ណ្ឌធ្វើជាសាក្សី ។

គ្រួសារប្រជាពលរដ្ឋនៅ **ទួលសំបូរ** មិនបានទទួលឯកសារណាមួយរៀងៗខ្លួនទេ ប៉ុន្តែឈ្មោះរបស់ពួកគាត់ និងការផ្ទេរដីឡូត៍ទៅឲ្យពួកគាត់មាននៅលើបញ្ជីឈ្មោះផ្លូវការរួម ។ [គ្មានឯកសារសំរាប់បង្ហាញ ]



ប័ណ្ណទទួលយកផ្ទះល្វែងថ្មីលេខ:

7NG Group Co., Ltd.

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ ម្ចាស់ផ្ទះឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៦៩ ជនជាតិខ្មែរ មានទីលំនៅផ្ទះលេខ: ក្រុមទី១១៣ ភូមិ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ក្នុងសហគមន៍ ដីក្រហម៥ បានទទួលយកផ្ទះល្វែងថ្មីលេខ: ពីក្រុមហ៊ុន 7NG (បុរីសន្តិភាព២) នៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

បញ្ជាក់: ម្ចាស់ផ្ទះខាងលើត្រូវទទួលខុសត្រូវដោះស្រាយអ្នកជួលចេញ និងម្ចាស់ការរុះរើផ្ទះចាស់ដោយខ្លួនឯងអោយបានមុនថ្ងៃទី.......ខែ..........ឆ្នាំ២០០៨ ដើម្បីទទួលយកផ្ទះថ្មីពីក្រុមហ៊ុន 7NG ។

តំណាងក្រុមហ៊ុន 7NG ស្នាមមេដៃម្ចាស់ផ្ទះ

*ឯកសារ ៥ , ៦ និង ៧ បានពីដំណាក់ត្រយឹង, រាជធានីភ្នំពេញ*

ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី២៖ ឯកសារចេញផ្តល់ឲ្យអ្នកតាំងទីលំនៅថ្មី ដើម្បីទទួលស្គាល់កម្មសិទ្ធិ(បន្ត)

នៅត្រពាំងអញ្ចាញ ប្រជាពលរដ្ឋបានទទួលឯកសារផ្សេងៗគ្នា ផ្អែកតាមកាលបរិច្ឆេទនៃការបណ្តេញចេញ និងទីតាំងដើមរបស់ពួកគាត់ ។ អតីតប្រជាពលរដ្ឋនៅបូរីកីឡា និងនៅជ្រោយចង្វារបានទទួល "ប័ណ្ណទទួលស្គាល់ ម្ចាស់ដីឡូតិ៍" [ឯកសារ៨ ] ដែលបានចុះហត្ថលេខា និងបោះត្រាដោយប្រធានភូមិ ចៅសង្កាត់ អភិបាលខ័ណ្ឌ និងនាយខុទ្ទកាល័យ សាលារាជធានីភ្នំពេញ ។ ប័ណ្ណទទួលស្គាល់ម្ចាស់ដីឡូតិ៍នេះមានសេចក្តីដូចតទៅ ៖

១) យោងអនុក្រឹត្យលេខ១៩ អ.ន.ក្រ.បក ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៣ ស្តីពីដីសម្បទានសង្គមកិច្ច ប័ណ្ណនេះ ហាមលក់ដូរដាក់បញ្ចាំ ផ្ទេរសិទ្ធិ ឬធ្វើអំណោយឲ្យអ្នកដទៃក្នុងរយៈពេល ០៥ ឆ្នាំ គិតចាប់ពី ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៨(ថ្ងៃចេញបណ្ណ័)។

២) ក្នុងករណីល្មើសនឹងចំណុចទី១ ខាងលើ សាលាក្រុងភ្នំពេញនឹងដកហូតដីនោះវិញ ដោយគ្មានល័ក្ខខ័ណ្ឌ ។

៣) ផុតរយៈពេល ០៥ ឆ្នាំ រដ្ឋនឹងចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់កម្មសិទ្ធិលើអចលនវត្ថុ ជូនម្ចាស់កាន់កាប់ដើម្បីប្រើប្រាស់តទៅ។

៤). ជនណាដែលប្រើប្រាស់ប័ណ្ណនេះខុសគោលដៅ នឹងត្រូវទទួលទោសតាមច្បាប់កំណត់ ។

អតីតប្រជាពលរដ្ឋដែលត្រូវបានបណ្តេញចេញពីភូមិសំបុកចាប ក្នុងខែមិថុនា ឆ្នាំ ២០០៦ បានទទួល "តារាងស្ថិតិ សមាជិកគ្រួសារ" [ឯកសារ៩] មួយច្បាប់ ដែលចេញដោយក្រុមហ៊ុន សួរ ស្រ៊ុន ដែលមិនមានចុះហត្ថលេខាដោយអាជ្ញាធរណាមួយ"* ។ នៅដើមឆ្នាំ២០១០ អ្នកភូមិមួយចំនួនត្រូវបានអាជ្ញាធរប្រាប់ថា នៅពេលឆាប់ៗនេះ គេនឹងចេញប័ណ្ណកាន់កាប់ដីធ្លីមួយដែលមានលក្ខណៈស្រដៀងគ្នា និងអ្នកដែរជាអតីតប្រជាពលរដ្ឋនៅបូរីកីឡា និងជ្រោយចង្វារ ។

## នៅខេត្តកណ្តាល




*ឯកសារ ៨ និង ៩ បានពីដំណាក់ត្រយឹង, រាជធានីភ្នំពេញ*

** តារាងស្ថិតិសមាជិកគ្រួសារ/គំរូដូចគ្នានេះដែរបានចេញដោយក្រុមហ៊ុន 7NG អោយដល់ប្រជាពលរដ្ឋដែលបានបណ្តេញចេញ ពីដីក្របាមអោយទៅរស់នៅដំណាក់ត្រយឹងលើកលែងតែតារាងស្ថិតិសមាជិកគ្រួសារដែលចេញដោយក្រុមហ៊ុន 7NG មានចុះហត្ថលេខាដោយអាជ្ញាធរមូលដ្ឋាន*

## ឧបសម្ព័ន្ធទី២៖ ឯកសារចេញផ្តល់ឲ្យអ្នកតាំងទីលំនៅថ្មី ដើម្បីទទួលស្គាល់កម្មសិទ្ធិ(បន្ត)

**អាជីវករ និងអ្នកជួលផ្ទះនៅដីក្រហម** ត្រូវបានគេឲ្យរុះរើចេញពីភូមិដំណាក់ត្រយឹងក្នុងខែធ្នូ ឆ្នាំ២០១០ ទៅទីតាំងថ្មីដែលក្រុមហ៊ុន 7NG ផ្តល់ឲ្យ ក្នុងភូមិស្រះពោធិ៍ ឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្តាល ដោយបានទទួល "ប័ណ្ណអ្នកទទួលដីឡូតិ៍" [ឯកសារ ១០ ] ដែលចេញដោយក្រុមហ៊ុន 7NG ។


បណ្ណទទួលដីឡូតិ៍
នាមឈ្មោះ [redacted] ភេទ ស្រី អាយុ [redacted] ឆ្នាំ
សមាជិកគ្រួសារចំនួន [redacted] នាក់ ប្រុស [redacted] នាក់ ស្រី [redacted] នាក់
ដីឡូតិ៍លេខ [redacted] ទំហំ (4x6 ម)
ថ្ងៃទី ០៨ ខែ ... ឆ្នាំ ២០១០
អ្នកទទួលដីឡូតិ៍ អ្នកប្រគល់
[redacted]

*ឯកសារ ១០ , បានពីភូមិស្រះពោធិ៍, ខេត្តកណ្តាល*

### នៅខេត្តព្រះសីហានុ

**នៅអូរកម្ពុជា** កងទ័ពជើងទឹកបានចេញបង្កាន់ដៃរៀងៗខ្លួន[ឯកសារ១១] (ដែលបង្កាន់ដៃនោះមានឈ្មោះអ្នកទទួល លេខដីឡូតិ៍ និងត្រារបស់កងទ័ព ជើងទឹក) ឲ្យគ្រួសារប្រជាពលរដ្ឋ និងបានសន្យាផ្ទាល់មាត់ថាពួកគាត់នឹងទទួលប័ណ្ណកម្មសិទ្ធិដីធ្លីក្រោយរយៈពេលប្រាំឆ្នាំ ដោយមានល័ក្ខខ័ណ្ឌថា ពួកគេត្រូវរស់នៅជាប់ៗគ្នាក្នុងរយៈនេះលើដី និងមិនត្រូវលក់ដីនេះឡើយ ។


[redacted] C [redacted]

*ឯកសារ ១១, បានពីភូមិស្រះពោធិ៍, ខេត្តព្រះសីហានុ*

សហគមន៍**ស្ពានដេះ** មិនបានទទួលឯកសារណាមួយទេ។

# ឧបសម្ព័ន្ធទី៣៖ ឯកសារយោង

### លិខិតុបករណ៍អន្តរជាតិ

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (១៩៤៨)
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (១៩៦៦)
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (១៩៦៦)

### គោលការណ៍ណែនាំជាអន្តរជាតិ

- គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ "សេចក្តីពន្យល់ទូទៅលេខ ៤ ស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ" (E/1992/23)
- គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ "សេចក្តីពន្យល់ទូទៅលេខ ៧ ស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យៈ ការបណ្តេញចេញដោយបង្ខំ" (E/1998/22 ឧបសម្ព័ន្ធ IV )
- OHCHR ប្រចាំកម្ពុជា "សេចក្តីអត្ថាធិប្បាយរបស់អង្គការសហប្រជាជាតិ គោលការណ៍ ណែនាំស្តីពី ការបណ្តេញចេញ និង ការតាំងទីលំនៅថ្មី" កូនសៀវភៅសរសេរជាភាសាខ្មែរ - អង់គ្លេស (ខែ ធ្នូ ២០០៩)
- អ្នករាយការណ៍ពិសេស ស្តីសិទ្ធិមានលំនៅដ្ឋានសមរម្យ ជាផ្នែកមួយនៃសិទ្ធិទទួលបានកំរិតជីវភាព រស់នៅគ្រប់គ្រាន់ "គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និង ការចាកចេញដោយបង្ខំចិត្តដោយផ្អែកលើការអភិវឌ្ឍន៍" (A/HRC/4/18 ឧបសម្ព័ន្ធI)
- Sphere Project "ធម្មនុញ្ញមនុស្សធម៌ និងបទដ្ឋានអប្បបរមាក្នុងការឆ្លើយតបទៅនឹងគ្រោះ មហន្តរាយ" តាមរយៈគេហទំព័រ ៖ http://www.sphereproject.org/
- អង្គការ UNHCR "សៀវភៅណែនាំសំរាប់សង្គ្រោះបន្ទាន់" អត្ថបទបោះពុម្ពផ្សាយលើកទី2
- អង្គការសុខភាពពិភពលោក (WHO) និងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) "សិទ្ធិខាងសុខភាព" Factsheet លេខ ៣១ (២០០៩)

### ច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយនានារបស់កម្ពុជា

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ (ដែលបានធ្វើវិសោធនកម្មក្នុង ១៩៩៩)
- ច្បាប់ភូមិបាល ឆ្នាំ២០០១
- ច្បាប់អស្សាមិករណ៍ ឆ្នាំ ២០១០
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នៃរាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៦ - ២០១០
- អនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ឆ្នាំ២០០៣
- សារាចរលេខ០៣ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រាន កាន់កាប់ ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជន, ខែឧសភា ឆ្នាំ២០១០
- ប្រកាសលេខ៥៦៧ របស់ក្រសួងមហាផ្ទៃ ស្តីពី សៀវភៅស្នាក់នៅ ខែវិច្ឆិកា ឆ្នាំ១៩៩៧

## ឧបសម្ព័ន្ធទី៣៖ ឯកសារយោង (បន្ត)

- ប្រកាសលេខ ២៤៧៣ របស់ក្រសួងមហាផ្ទៃ ស្តីពី នីតិវិធី ល័ក្ខខ័ណ្ឌនៃការសុំ ការផ្តល់ ការប្រើប្រាស់ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ខែកក្កដា ឆ្នាំ ២០០៧
- ឯកសារគោលនយោបាយ របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ស្តីពីសម្បទានសង្គមកិច្ច នៅព្រះរាជាណាចក្រកម្ពុជា ខែមីនា ឆ្នាំ ២០០២ ។
- សេចក្តីណែនាំបន្ថែម លេខ០១៥ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពី ការចុះបញ្ជី និងគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ ខែធ្នូ ឆ្នាំ២០០៤

### របាយការណ៍ សៀវភៅ និង មាត្រាច្បាប់

- អង្គការលើកលែងទោសអន្តរជាតិ "សិទ្ធិត្រូវបានគេដកហូត: ការបណ្តេញចេញដោយបង្ខំនៅ កម្ពុជា *(Rights Razed – Forced evictions in Cambodia)"* (ខែកុម្ភៈ ឆ្នាំ២០០៨)
- អង្គការស្ពានទៅកាន់សន្តិភាពអាស៊ីអាគ្នេយ៍ (BABSEA), មជ្ឈមណ្ឌលស្តីពីសិទ្ធិលំនៅដ្ឋាន និង ការបណ្តេញចេញ (COHRE), អង្គការ Jesuit Refugee Service (JRS), " មិនទទួលបានកម្មសិទ្ធ: អសុវត្ថិភាពខាងការកាន់កាប់ដីធ្លី និងអសមភាពក្នុងវិស័យដីធ្លីនៅកម្ពុជា (*Untitled: Tenure Insecurity and Inequality in the Cambodian Land Sector)*" (ឆ្នាំ ២០០៩)
- គណៈកម្មាធិកាប្រព្រឹត្តិកម្មនៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា "កំពុងបាត់បង់ ដីធ្លី: ការបណ្តេញចេញដោយបង្ខំ និងការគំរាមគំហែងនៅកម្ពុជា *(Losing Ground: Forced Eviction and Intimidation in Cambodia)*" (ខែកញ្ញា ឆ្នាំ២០០៩)
- អង្គការ Caritas, Centre of Hope, Centre for Child and Adolescent Mental Health, Jesuit Refugee Service, Licadho, Samaritan's Purse, Village Earth និងអង្គការ World Vision, "ការវាយតំលៃអំពី តំរូវការផ្នែកមនុស្សធម៌ លើប្រជាពលរដ្ឋដែលត្រូវគេបណ្តេញចេញពីតំបន់ដីក្រហម: សុខភាព ម្ហូបអាហារ អនាម័យ ការអប់រំ តំរូវការខាងថ្នាំសង្កូវ និងសុខភាពផ្លូវចិត្ត (*Humanitarian Needs Assessment for Dey Krahorm Evictees: Health, Food, Sanitation, Education, Medical Needs and Mental Health)*" (ឆ្នាំ ២០០៩)
- Cernea, Michael M and McDowell, C (ed.), "គ្រោះថ្នាក់ និង ការរៀបចំធ្វើឡើងវិញ: បទពិសោធន៍នៃការតាំងទីលំនៅថ្មី និងជនភៀសខ្លួន (*Risks and Reconstruction: Experiences of Resettlers and Refugees*)" Washington, DC: The World Bank, (ឆ្នាំ២០០០)
- Cernea, Michael M. (ed.) "ស្ថានភាពសេដ្ឋកិច្ចនៃការតាំទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្ត: បញ្ហា និង កត្តាប្រឈម *(The Economics of Involuntary Resettlement: Questions and Challenges)*" Washington, DC: The World Bank (ឆ្នាំ១៩៩៩)
- មជ្ឈមណ្ឌលស្តីពីសិទ្ធិលំនៅដ្ឋាន និងការបណ្តេញចេញ (COHRE) មជ្ឈមណ្ឌលស្តីពីសិទ្ធិលំនៅដ្ឋាន និងការបណ្តេញចេញ (COHRE) "ភាពជោគជ័យ និង យុទ្ធសាស្ត្រ: ការឆ្លើយតបទៅនឹង ការបណ្តេញចេញដោយបង្ខំ (*Successes and strategies: responses to forced evictions)*" (ឆ្នាំ២០០៨)
- របាយការណ៍ស្រាវជ្រាវ អង្គការ COMFREL "ការអង្កេតទៅលើអ្នកមានសិទ្ធិបោះឆ្នោតដែលផ្លាស់ ទីលំនៅដោយបង្ខំ អ្នកផ្ទុកមេរោគអេដ៍ និងអ្នកជំងឺអេដ៍ ក្នុងការចុះឈ្មោះបោះឆ្នោត *(Evictee voter registration in 2009, including those with HIV/AIDS, and a re-audit of voters not registered on the 2008 voter list)"* (ខែឧសភា ឆ្នាំ២០១០)
- Din S, "បរិបទនៃការផ្លាស់ប្តូរថ្មីៗ និងគោលនយោបាយ ដែលប៉ះពាល់ទៅលើសហគមន៍រស់នៅ ក្នុងសំណង់មិនរៀបរយក្នុងទីក្រុងភ្នំពេញ ប្រទេសកម្ពុជា និង បញ្ហាពាក់ព័ន្ធការផ្តល់អោយមាន ការចូលរួមក្នុងកម្មវិធីនៃការតាំងទីលំនៅថ្មីនាពេលបច្ចុប្បន្ន និងអនាគត *(A recent changes in context and basic policy affecting urban slum dwellers communities in Phnom Penh, Cambodia, and implication on participatory approach in ongoing and future relocation programs)*" Master of Sciences, Bangkok, Asian Institute of Technology (AIT), (ខែសីហា ឆ្នាំ២០០២)

# ឧបសម្ព័ន្ធទី៣៖ ឯកសារយោង(បន្ត)


- Fallavier P, "ការវិភាគដោយប្រៀបធៀបលើគំរោងតាំងទីលំនៅថ្មីៗនាបច្ចុប្បន្ននៅទីក្រុងភ្នំពេញ *(A comparative analysis of recent resettlement projects in Phnom Penh)*" អង្គការសហប្រជាជាតិលំនៅដ្ឋាន មនុស្សជាតិនិងទីក្រុង (UN Habitat), អង្គការអ្នកស្ម័គ្រចិត្តកម្ពុជាដើម្បី អភិវឌ្ឍន៍សហគមន៍ (CVCD), មជ្ឈមណ្ឌលធនធានសំរាប់ទីក្រុង (URC), (ខែធ្នូ ឆ្នាំ២០០១)
- Fallavier P, "ការវិភាគ លើការអង្កេតពីផលប៉ះពាល់ចំពោះជីវភាពរស់នៅ ដោយសារ គំរោងតាំង ទីលំនៅថ្មីៗ ពីខែមករា ដល់ខែមិនា ឆ្នាំ២០០២ នៅទីកន្លែងតាំងទីលំនៅ ប្រាំកន្លែង ក្នុងទីក្រុង ភ្នំពេញ (*Analysis of the survey on impacts of relocation projects upon livelihoods conducted from January to March 2002 in five resettlements sites in Phnom Penh)*", ការត្រួតពិនិត្យ និង វាយតំលៃដោយមាន ការចូលរួម លើផលប៉ះពាល់ចំពោះគំរោង CMB/00/003: គំរោងកាត់បន្ថយភាពក្រីក្រក្នុងទីក្រុង ភ្នំពេញ (Phnom Penh Urban Poverty Reduction Project), UN Habitat, CVCD, URC, (ខែធ្នូ ឆ្នាំ២០០២)
- Fallavier P, " ប្រវត្តិសហគមន៍, អគ្គីភ័យនៅតំបន់ទន្លេបាសាក់ នាថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ *(Community Profile, Fire in the Tonle Bassac, 26 November 2001)*", UN Habitat, CVCD, URC, (ខែវិច្ឆិកា ឆ្នាំ២០០២)
- Fallavier P, " មេរៀនជាបទពិសោធន៍ និងទិសដៅគោលនយោបាយសំរាប់កម្មវិធីតាំងទីលំនៅថ្មី នៅទីក្រុងភ្នំពេញ ។ ការរកឃើញជាបណ្តោះអាសន្ន ដែលផ្អែកលើការពិនិត្យតាមដានដល់ទីកន្លែង រយៈពេល១៧ខែ (*Lessons from experience and policy directions for resettlement programs in Phnom Penh. Interim findings, based on seventeen months of field observation)*", UN Habitat, CVCD, URC, (ខែមករា ឆ្នាំ២០០៣)
- អង្គការស្បៀងអាហារ និងកសិកម្ម នៃអង្គការសហប្រជាជាតិ (FAO), "ការតំរូវអោយដកហូតដីធ្លី និងសំណង *(Compulsory acquisition of land and compensation)*" ការសិក្សាលេខ១០ ស្តីពីការកាន់កាប់ដី (ឆ្នាំ២០០៨)
- Habitat International, Beng Hong S.K and Payne G, "បង្កើនសុវត្ថិភាពខាងការកាន់កាប់ដីធ្លី សំរាប់អ្នករស់នៅតាមតំបន់ក្រីក្រ ក្នុងទីក្រុងភ្នំពេញ ប្រទេសកម្ពុជា: ករណីសិក្សាដោយការវិភាគ *(Improving Tenure Security for the Urban Poor in Phnom Penh, Cambodia: an Analytical Case Study)*" (ឆ្នាំ២០០៨)
- ក្រុមការងារសិទ្ធិដីធ្លី និងលំនៅដ្ឋាន "សិទ្ធិដីធ្លី និងលំនៅដ្ឋាន នៅកម្ពុជា - របាយការណ៍ស្រប ដាក់ជូន គណកម្មការសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ របស់អង្គការសហប្រជាជាតិ *(Land and Housing Rights in Cambodia – Parallel Report to UN Committee on Economic, Social and Cultural Rights)*" (ខែមេសា ឆ្នាំ២០០៩)
- អង្គការ Licadho "ការរំលោភយកដីធ្លី និងភាពក្រីក្រនៅកម្ពុជា: ការអភិវឌ្ឍន៍ក្លែងក្លាយ" (ខែឧសភា ឆ្នាំ២០០៩)
- អង្គការ Licadho "សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម" (ខែមករា ឆ្នាំ២០០៨)
- អង្គការ Licadho "របាយករណ៍ស្តីពីការវាយតំលៃបន្ទាន់: លក្ខខ័ណ្ឌមនុស្សធម៌នៅជំរុំតាំង ទីលំនៅថ្មីក្នុងភូមិអណ្តូង *(Rapid Assessment Report: Humanitarian Conditions in Andong Village Relocation Camp)*" (ខែសីហា ឆ្នាំ២០០៦)
- ការិយាល័យ OHCHR ប្រចាំកម្ពុជា "របាយការណ៍ប្រចាំឆ្នាំ២០០៨ - ២០០៩ ដោយមាន ការអត្ថាធិប្បាយរបស់រាជរដ្ឋាភិបាលកម្ពុជា" (ឆ្នាំ២០០៩)
- Payne G. *et al*, "បង្កើន សុវត្ថិភាពខាងការកាន់កាប់ដីធ្លី និងជំរើសសំរាប់លំនៅដ្ឋានថ្មីក្នុង ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា *Increasing tenure security and options for new housing in Phnom Penh, Cambodia)*" របាយការណ៍វឌ្ឍនភាពកម្ពុជា ដាក់ជូនក្រសួងដែនដី នគររូបនីយកម្ម និងសំណង់, សាលាក្រុងភ្នំពេញ, Cities Alliance, UN Habitat, and Gtz, 2003; *Final Report*, *ibid*, (ខែវិច្ឆិកា ឆ្នាំ២០០៤)
- សមាគមធាងត្នោត (STT) "ការអង្កេតលើខ័ណ្ឌទាំង៨: ការតាំងទីលំនៅនៃអ្នកក្រីក្រក្នុងទីក្រុង ភ្នំពេញ *(The 8 Khan Survey: Urban poor settlements in Phnom Penh)*" (ខែធ្នូ ឆ្នាំ២០០៩)

# ឧបសម្ព័ន្ធទី៣៖ ឯកសារយោង (បន្ត)


- សមាគមធាងត្នោត (STT) "ព្រឹត្តិន័យ និងតួលេខ, គ្រួសារដែលគេអោយផ្លាស់ទីលំនៅ: ភ្នំពេញ *(Facts and Figures, Displaced families: Phnom Penh)*" (ខែមេសា ឆ្នាំ២០០៩)
- សមាគមធាងត្នោត (STT) "ទីតាំងនៃការផ្លាស់ប្តូទីលំនៅ ក្នុងទីក្រុងភ្នំពេញ: ឯកសារដែលបានធ្វើ បច្ចុប្បន្នភាពលើទីតាំងនៃការផ្លាស់ប្តូទីលំនៅ នៅក្នុង និងជិតទីក្រុងភ្នំពេញ *(Relocation Sites in Phnom Penh: an updated documentation of relocation sites in and around Phnom Penh)*" (ខែសីហា ឆ្នាំ២០០៧)
- មូលនិធិអភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្រក្នុងទីក្រុង (UPDF), "ពត៌មានស្តីពីសកម្មភាពថ្មីៗរបស់ មូលនិធិ អភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្រក្នុងទីក្រុង ប្រទេសកម្ពុជា" (ខែឧសភា ឆ្នាំ២០០៣ និង ខែឧសភា ឆ្នាំ២០០៨)
- UPDF និង បណ្តាញ សហគមន៍សន្សំ–ឥណទានទីក្រុងភ្នំពេញ "ពត៌មានសហគមន៍" លេខទី២ (ខែមិថុនា ឆ្នាំ២០០៣), លេខទី៤ (ខែតុលា ឆ្នាំ២០០៦)
- មជ្ឈមណ្ឌលធនធានសំរាប់ទីក្រុង "ការសិក្សាពីដំណើរការផ្លាស់ប្តូរទីលំនៅរបស់សហគមន៍អ្នក ក្រីក្រ ក្នុងរាជធានីភ្នំពេញ", សម្ព័ន្ធភាពទីក្រុង (អង្គការសហប្រជាជាតិទទួលបន្ទុកលំនៅដ្ឋាន / ធនាគារ ពិភពលោក) បង្កើតយុទ្ធសាស្រ្តអភិវឌ្ឍន៍ទីក្រុងសំរាប់សាលាក្រុងភ្នំពេញ, កម្ពុជា (ខែមេសា ឆ្នាំ២០០២)
- ធនគារពិភពលោក, កម្មវិធីទឹកស្អាត និងអនាម័យ – តំបន់អាស៊ីអាគ្នេយ៍ និងប៉ាអាស៊ីហ្វិក, "ផលប៉ះពាល់សេដ្ឋកិច្ចដោយកត្តាអនាម័យនៅប្រទេសកម្ពុជា, ការសិក្សាលើប្រទេសចំនួន៥ មាន កម្ពុជា អិនណ្ឌូនេអាស៊ី ឡាវ ហ្វីលីពីន និងវៀតណាម (*Economic Impacts of Sanitation in Cambodia. A five-country study conducted in Cambodia, Indonesia, Lao PDR, The Philippines and Vietnam, under the Economics of Sanitation Initiative)* (ឆ្នាំ២០០៨)
- ធនគារពិភពលោកប្រចាំកម្ពុជា "ព្រឹត្តិបត្រលេខ៨ (ខែមករា–កុម្ភ ឆ្នាំ២០១០)"
- "របាយការណ៍អភិវឌ្ឍន៍ជាសាកលឆ្នាំ២០០៣, និរន្តរភាពនៃការអភិវឌ្ឍន៍ក្នុងពិភពលោកដ៏ ស្វាហាប់: កំនែទំរង់ស្ថាប័ន, ការរីកចំរើនលូតលាស់ និងគុណភាពនៃការរស់នៅ *(World Development Report 2003, Sustainable Development in a Dynamic World: Transforming Institutions, Growth, and Quality of Life)*", សហការ បោះពុម្ពផ្សាយដោយ ធនាគារពិភពលោក (World Bank) និង Oxford University Press (ឆ្នាំ២០០៣)

### ប្រកាសព័ត៌មាន និង អត្ថបទសារពត៌មាន

- ម៧៨, ប្រកាសព័ត៌មាន, (២៥ មិថុនា ២០០៩)
- 'ទីក្រុង អ្នកអភិវឌ្ឍន៍ ការវាយកំទេចផ្ទះសម្លេងរបស់អ្នកភូមិដីក្រហម', កាសែតភ្នំពេញប៉ុស្តិ៍ (២៤ មករា ២០០៩)
- 'ការអនុម័តគំរោងធ្លាក់ចុះ ៨៣ ភាគរយ' *កាសែតភ្នំពេញប៉ុស្តិ៍* (៣០ មេសា ២០១០)

### សន្ទរកថា

- ឯកឧត្តម អ៊ឹម ឈុន លឹម ទេសរដ្ឋមន្រ្តី និងជារដ្ឋមន្រ្តីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់, សន្ទរកថា ថ្លែងនាសម័យប្រជុំលើកទី១៥ នៃគណ:កម្មាធិការសម្របសម្រួលរវាងរដ្ឋា ភិបាល និងដៃគូអភិវឌ្ឍន៍, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៩ ។

រក្សាសិទ្ធិ ឆ្នាំ ២០១២

ការិយាល័យ ប្រចាំ ប្រទេសកម្ពុជា

ឧត្តមស្នងការ អង្គការសហប្រជាជាតិ

ទទួលបន្ទុកសិទ្ធិមនុស្ស

United Nations
Human Rights

OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS
Cambodia Country Office - Phnom Penh - Cambodia